# អភិធម្មត្ថសង្គហៈ
# បរិច្ឆេទទី ២ និង ទី ៣

## ចេតសិកសង្គហវិភាគវណ្ណនា
## បកិណ្ណកសង្គហវិភាគវណ្ណនា

ចងក្រងដោយ

អ្នកគ្រូ អ៊ុំ សុជា

អ្នកគ្រូ ប៉ោរ សុមាលី

១៥ កើត ខែ អាសាឍ ព.ស ២៥៥៩

# ពាក្យប្រារព្ធ

ចេតសិកបរមត្ថនេះ ជាធម្មជាតកើតរួមជាមួយនឹងចិត្ត ធម្មជាតិនេះពុំមានគ្រូណាមួយសម្តែងបានឡើយ មានតែមហាបុរស (ព្រះលោកនាថ) ទ្រង់បានជ្រាបច្បាស់ដោយសព្វញ្ញុតញ្ញាណ ព្រះអង្គទ្រង់បានប្រកាសសម្តែងនាអតីតកន្លងអស់ ២៥៩៦ វស្សាមកហើយ តែក្នុងសម័យបច្ចុប្បន្ននេះ នៅមានគម្ពីរអភិធម្មត្ថសង្គហៈ ដែលព្រះថេរៈព្រះនាម(**ព្រះអនុរុទ្ធាចារ្យ**) បានចងក្រងទុកនូវព្រះពុទ្ធវចនដ៏មានខ្លឹមសារនេះបិតនៅរហូតដល់សព្វថ្ងៃ ធ្វើឲ្យអ្នកសិក្សាជំនាន់ក្រោយៗនេះ បានទទួលនូវវិធីសាស្ត្រដ៏ងាយស្រួលក្នុងការចូលទៅសិក្សាព្រះត្រៃបិដក មួយអន្លើបានជ្រាបច្បាស់ថា ធម៌ទាំងនេះផ្សេងគ្នាមានចំនួន ៥២ យ៉ាង គាក់តែងនូវចិត្តឲ្យវិចិត្រផ្សេងៗគ្នា គួរឲ្យមោទនភាពនូវស្នាដៃរបស់ព្រះថេរៈ (**ព្រះអនុរុទ្ធាចារ្យ**)។ យើងខ្ញុំទាំងពីរបានសិក្សាហើយក៏មានការយល់ដឹងនូវចេតសិកបរមត្ថនេះ បានមួយចំណែកល្មមសមគួរ កើតសេចក្តីជ្រះថ្លាថានឹងបន្តកម្រងមាតិកាធម៌នេះតទៅទៀត ទើបផ្តើមរៀបរៀងចងក្រងចេតសិកបរមត្ថនេះទុកជាធម្មរតកដែលព្រះបរមសាស្តាបានត្រាស់ទុកមក ដើម្បីជាប្រយោជន៍ដល់បរិស័ទទូទៅបានជ្រាបច្បាស់នូវធម្មជាតិនេះថាមានពិត ទោះបីជាសត្វលោកបានដឹងក្តី ពុំបានដឹងក្តី ក៏ធម្មជាតិរបស់ចេតសិកនេះ រួបរួមគាក់តែងឲ្យចិត្តនេះមានការវិចិត្រទៅ ដូចជាធ្វើឲ្យចិត្តខឹង ចិត្តស្អប់ ចិត្តស្រឡាញ់ ចិត្តបុណ្យ ចិត្តបាប(ជាដើម) ទៅតាមធម្មជាតិដែលចេតសិកចូលមកគាក់តែងចិត្តនោះ។

ហេតុនេះហើយ សូមបរិស័ទគ្រប់រូបរូតរះឡើង កុំព្រងើយកន្តើយ កុំបណ្តោយពេលឲ្យកន្លងទៅ ព្រោះថា ព្រះធម៌កំពុងបិតនៅ អ្នកប្រាជ្ញមាននៅគ្រាន់នឹងបានជាទីពឹង ចូលទៅសិក្សានិងសាកសួរបង្កើននូវចំណេះ ចម្រើននូវការយល់ដឹង អភិវឌ្ឍន៍ជីវិតឲ្យមានខ្លឹមសាររស់នៅក្នុងសង្គម តែងបាននូវសេចក្តីសុខក្នុងបច្ចុប្បន្ន និងបរលោក។

ដោយធម្មទាននេះ ចូរជាប្រយោជន៍ដល់សព្វសត្វ សូមបានជាពន្លឺ (ពោលគឺប្រាជ្ញា) ដឹកនាំជីវិតឲ្យឆ្ពោះទៅរកសន្តិសុខ(ពោលគឺនិព្វាន) កុំបីអាក់ខានឡើយ។

ថ្ងៃទី ១៥ កើត ខែ ចេត្រ ព.ស. ២៥៥៨

អ៊ុំ សុជា
ប៉ោរ សុមាលី

## មាតិកាធម៌ ទំព័រ

ពាក្យប្រារព្ធ ........ [ក]
អភិធម្មត្ថសង្គហបាលី ........ ១
តារាងចេតសិក ........ ៨

# បរិច្ឆេទទី ២

សម្បយោគលក្ខណៈ ........ ៩
អញ្ញសមានាចេតសិក ១៣ ........ ១២
បីតិមាន ៥ ប្រភេទតាមលំដាប់របស់កម្លាំង ........ ២៥
អកុសលចេតសិក ១៤ ដួង ........ ៣០
សោភណសាធារណចេតសិក ១៩ ដួង ........ ៥៤
វិរតិចេតសិក ៣ ដួង ........ ៧៣
អប្បមញ្ញាចេតសិក ២ ដួង ........ ៧៦
បញ្ញិន្ទ្រិយចេតសិក ១ ដួង ........ ៧៩
សម្បយោគន័យ ១៦ ........ ៨១
អញ្ញសមានាចេតសិក សម្បយោគន័យ ........ ៨២
អកុសលចេតសិក សម្បយោគន័យ ........ ៨៦
សោភណចេតសិក សម្បយោគន័យ ........ ៩០
តារាងសម្បយោគន័យ ១៦ ន័យ ........ ៩៦
និយតយោគី អនិយតយោគីចេតសិក ........ ៩៨
សង្គហន័យ ៣៣ ន័យ ........ ៩៩
លោកុត្តរចិត្ត សង្គហន័យ ........ ១០០
មហគ្គតចិត្ត សង្គហន័យ ........ ១០៣
កាមាវចរសោភណចិត្ត សង្គហន័យ ........ ១០៦
ចិត្តដែលមិនប្រកបដោយវិរតិ អប្បមញ្ញា ........ ១១១

វិសេសកចេតសិក ............ ១១២
អកុសលចិត្ត សង្គហន័យ ............ ១១៣
សព្វាកុសលយោគីចេតសិក ............ ១១៨
អហេតុកចិត្ត សង្គហន័យ ............ ១១៨
តារាងសង្គហន័ ៣៣ ន័យ ............ ១២១
តារាងសម្បយោគន័យ សង្គហន័យរួមគ្នា ............ ១២២
ការរាប់ចំនួនចេតសិកស្មើនឹងចំនួនចិត្ត ............ ១២៣

## បរិច្ឆេទទី ៣

ពាក្យប្រារព្ធ ............ ១២៦
អភិធម្មត្ថសង្គហបាលី បរិច្ឆេទទី ៣ ............ ១២៧
បកិណ្ណកសង្គហវិភាគ ............ ១៣៣
វេទនាសង្គហៈ ............ ១៣៦
ហេតុសង្គហៈ ............ ១៤៣
កិច្ចសង្គហៈ ............ ១៤៩
ទ្វារសង្គហៈ ............ ១៦១
អារម្មណសង្គហៈ ............ ១៦៨
វត្ថុសង្គហៈ ............ ១៨៣

ត្រួតពិនិត្យនិងកែសម្រួល

ភាសាបាលី និង សេចក្តីប្រែ

ដោយ

លោកម្ចាស់ សុចិណ្ណ ញ៉ឹប យ័ន្ត

លោកម្ចាស់ ឡុង សាវុឌ្ឍ

# ជំនួយការកុំព្យូទ័រ

ដោយ

យុវជនៈ ម៉េត សុភក្ត្រា

# អភិធម្មត្ថសង្គហបាលី

## បរិច្ឆេទទី ២

## ចេតសិកសង្គហវិភាគ

[១] ឯកុប្បាទនិរោធា ច ឯកាលម្ពណវត្ថុកា
ចេតោយុត្តា ទ្វិបញ្ញាស ធម្មា ចេតសិកា មតា ។

[២] កថំ ? ផស្សោ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយំ មនសិការោ ចេតិ សត្តិមេ ចេតសិកា សព្វចិត្តសាធារណា នាម ។

[៣] វិតក្កោ វិចារោ អធិមោក្ខោ វីរិយំ បីតិ ឆន្ទោ ចាតិ ឆ ឥមេ ចេតសិកា បកិណ្ណកា នាម ។

[៤] ឯវមេតេ តេរស ចេតសិកា អញ្ញសមានាតិ វេទិតព្វា ។

[៥] មោហោ អហិរិកំ អនោត្តប្បំ ឧទ្ធច្ចំ លោភោ ទិដ្ឋិ មានោ ទោសោ ឥស្សា មច្ឆរិយំ កុក្កុច្ចំ ថិនំ មិទ្ធំ វិចិកិច្ឆា ចេតិ ចុទ្ទសិមេ ចេតសិកា អកុសលា នាម ។

[៦] សទ្ធា សតិ ហិរិ ឱត្តប្បំ អលោភោ អទោសោ តត្រមជ្ឈត្តតា កាយបស្សទ្ធិ ចិត្តបស្សទ្ធិ កាយលហុតា ចិត្តលហុតា កាយមុទុតា ចិត្តមុទុតា កាយកម្មញ្ញតា ចិត្តកម្មញ្ញតា កាយបាគុញ្ញតា ចិត្តបាគុញ្ញតា កាយុជុកតា ចិត្តុជុកតា ចេតិ ឯកូនវីសតិមេ ចេតសិកា សោភណសាធារណា នាម ។

[៧] សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ ចេតិ តិស្សោ វិរតិយោ នាម ។

[៨] ករុណា មុទិតា អប្បមញ្ញាយោ នាមាតិ សព្វថាបិ បញ្ញិន្ទ្រិយេន សទ្ធឹ បញ្ចវីសតិមេ ចេតសិកា សោភណាតិ វេទិតព្វា ។

[៩] ឯត្តាវតា ច-
តេរសញ្ញសមានា ច ចុទ្ទសាកុសលា តថា

សោភណា បញ្ចវីសាតិ ទ្វិបញ្ញាស បវុច្ចរេ ។

[១០] តេសំ ចិត្តាវិយុត្តានំ យថាយោគមិតោ បរំ
ចិត្តុប្បាទេសុ បច្ចេកំ សម្បយោគោ បវុច្ចតិ ។

[១១] សត្ត សព្វត្ថ យុជ្ជន្តិ យថាយោគំ បកិណ្ណកា
ចុទ្ទសាកុសលេស្វេវ សោភណេស្វេវ សោភណា ។

[១២] កថំ ? សព្វចិត្តសាធារណា តាវ សត្តិមេ ចេតសិកា សព្វេសុបិ ឯកូនននវុតិ-ចិត្តុប្បាទេសុ លព្ភន្តិ ។

[១៣] បកិណ្ណកេសុ បន វិតក្កោ តាវ ទ្វិបញ្ចវិញ្ញាណ វជ្ជិត កាមាវចរ ចិត្តេសុ ចេវ, ឯកាទសសុ បឋមជ្ឈានចិត្តេសុ ចាតិ បញ្ចបញ្ញាសចិត្តេសុ ឧប្បជ្ជតិ ។

[១៤] វិចារោ បន តេសុ ចេវ, ឯកាទសសុ ទុតិយជ្ឈានចិត្តេសុ ចាតិ ឆសដ្ឋិចិត្តេសុ ។

[១៥] អធិមោក្ខោ ទ្វិបញ្ចវិញ្ញាណវិចិកិច្ឆាសហគតវជ្ជិតចិត្តេសុ ។

[១៦] វីរិយំ បញ្ចទ្វារាវជ្ជនទ្វិបញ្ចវិញ្ញាណសម្បដិច្ឆនសន្តីរណវជ្ជិតចិត្តេសុ ។

[១៧] បីតិ ទោមនស្សុបេក្ខាសហគតកាយវិញ្ញាណចតុត្ថជ្ឈានវជ្ជិតចិត្តេសុ ។

[១៨] ឆន្ទោ អហេតុកមោមូហវជ្ជិតចិត្តេសូតិ ។

[១៩] តេ បន ចិត្តុប្បាទា យថាក្កមំ-

ឆសដ្ឋិ បញ្ចបញ្ញាស ឯកាទស ច សោឡស
សត្តតិ វីសតិ ចេវ បកិណ្ណកវិវជ្ជិតា ។
បញ្ចបញ្ញាស ឆសដ្ឋិ - ដ្ឋសត្តតិ តិសត្តតិ
ឯកបញ្ញាស ចេកូន- សត្តតិ សបកិណ្ណកា ។

[២០] អកុសលេសុ បន មោហោ អហិរិកំ អនោត្តប្បំ ឧទ្ធច្ចញ្ចាតិ ចត្តារោមេ ចេតសិកា សព្វាកុសលសាធារណា នាម , សព្វេសុបិ ទ្វាទសាកុសលេសុ លព្ភន្តិ ។

[២១] លោភោ អដ្ឋសុ លោភសហគតចិត្តេស្វេវ លព្ភតិ ។

[២២] ទិដ្ឋិ ចតូសុ ទិដ្ឋិគតសម្បយុត្តេសុ ។

[២៣] មានោ ចតូសុ ទិដ្ឋិគតវិប្បយុត្តេសុ ។

[២៤] ទោសោ ឥស្សា មច្ឆរិយំ កុក្កុច្ចញ្ចាតិ ទ្វីសុ បដិឃសម្បយុត្តចិត្តេសុ ។

[២៥] ថិនមិទ្ធំ បញ្ចសុ សសង្ខារិកចិត្តេសុ ។

[២៦] វិចិកិច្ឆា វិចិកិច្ឆាសហគតចិត្តេយេវាតិ ។

[២៧] សព្វាបុញ្ញេសុ ចត្តារោ លោភមូលេ តយោ គតា
ទោសមូលេសុ ចត្តារោ សសង្ខារេ ទ្វយំ តថា ។
វិចិកិច្ឆា វិចិកិច្ឆា- ចិត្តេ ចាតិ ចតុទ្ទស
ទ្វាទសាកុសលេស្វេវ សម្បយុជ្ជន្តិ បញ្ចធា ។

[២៨] សោភណេសុ បន សោភណសាធារណា តាវ ឯកូនវីសតិមេ ចេតសិកា សព្វេសុបិ ឯកូនសដ្ឋិសោភណចិត្តេសុ សំវិជ្ជន្តិ ។

[២៩] វិរតិយោ បន តិស្សោបិ លោកុត្តរចិត្តេសុ សព្វថាបិ និយតា ឯកតោវ លព្ភន្តិ, លោកិយេសុ បន កាមាវចរកុសលេស្វេវ កទាចិ សន្ទិស្សន្តិ វិសុំ វិសុំ ។

[៣០] អប្បមញ្ញាយោ បន ទ្វាទសសុ បញ្ចមជ្ឈានវជ្ជិតមហគ្គតចិត្តេសុ ចេវ កាមាវចរកុសលេសុ ច សហេតុកកាមាវចរកិរិយចិត្តេសុ ចាតិ អដ្ឋវីសតិចិត្តេស្វេវ កទាចិ នានា ហុត្វា ជាយន្តិ ឧបេក្ខាសហគតេសុ បនេត្ថ ករុណាមុទិតា ន សន្តីតិ កេចិ វទន្តិ ។

[៣១] បញ្ញា បន ទ្វាទសសុ ញាណសម្បយុត្តកាមាវចរចិត្តេសុ ចេវ សព្វេសុបិ បញ្ចតឹស មហគ្គតលោកុត្តរចិត្តេសុ ចាតិ សត្តចត្តាលីសចិត្តេសុ សម្បយោគំ គច្ឆតីតិ ។

[៣២] ឯកូនវីសតិ ធម្មា ជាយន្តេកូនសដ្ឋិសុ
តយោ សោឡសចិត្តេសុ អដ្ឋវីសតិយំ ទ្វយំ ។
បញ្ញា បកាសិតា សត្ត- ចត្តាលីសវិធេសុបិ

សម្បយុត្តា ចតុធេវំ　　សោភណេស្វេវ សោភណា ។

[៣៣] ឥស្សាមច្ឆេរកុក្កុច្ច-　　វិរតីករុណាទយោ
នានា កទាចិ មានោ ច　　ថិនមិទ្ធំ តថា សហ ។

[៣៤] យថាវុត្តានុសារេន　　សេសា និយតយោគិនោ
សង្គហញ្ច បវក្ខាមិ　　តេសំ ទានិ យថារហំ ។

[៣៥] ឆត្តឹសានុត្តរេ ធម្មា　　បញ្ចតឹស មហគ្គតេ
អដ្ឋតឹសាបិ លព្ភន្តិ　　កាមាវចរសោភណេ ។
សត្តវីសតិបុញ្ញម្ហិ　　ទ្វាទសាហេតុកេតិ ច
យថាសម្ភវយោគេន　　បញ្ចធា តត្ថ សង្គហោ ។

[៣៦] កថំ ? លោកុត្តរេសុ តាវអដ្ឋសុ បឋមជ្ឈានិកចិត្តេសុ អញ្ញសមានា តេរស ចេតសិកា, អប្បមញ្ញាវជ្ជិតា តេវីសតិ សោភណចេតសិកា ចេតិ ឆត្តឹស ធម្មា សង្គហំ គច្ឆន្តិ ។

តថា ទុតិយជ្ឈានិកចិត្តេសុ វិតក្កវជ្ជា ។ តតិយជ្ឈានិកចិត្តេសុ វិតក្កវិចារវជ្ជា ។ ចតុត្ថ-ជ្ឈានិកចិត្តេសុ វិតក្កវិចារបីតិវជ្ជា ។ បញ្ចមជ្ឈានិកចិត្តេសុបិ ឧបេក្ខាសហគតា តេ ឯវំ សង្គ-យ្ហន្តីតិ ។ សព្វថាបិ អដ្ឋសុ លោកុត្តរចិត្តេសុ បញ្ចកជ្ឈានវសេន បញ្ចធាវ សង្គហោ ហោតីតិ ។

[៣៧] ឆត្តឹស បញ្ចតឹស ច　　ចតុត្តឹស យថាក្កមំ
តេត្តឹសទ្វយមិច្ចេវំ　　បញ្ចធានុត្តរេ ឋិតា ។

[៣៨] មហគ្គតេសុ បន តីសុ បឋមជ្ឈានិកចិត្តេសុ តាវ អញ្ញសមានា តេរស ចេតសិកា វិរតិត្តយវជ្ជិតា ទ្វាវីសតិ សោភណចេតសិកា ចេតិ បញ្ចតឹស ធម្មា សង្គហំ គច្ឆន្តិ ។ ករុណាមុទិតា បនេត្ថ បច្ចេកមេវ យោជេតព្វា ។

តថា ទុតិយជ្ឈានិកចិត្តេសុ វិតក្កវជ្ជា ។ តតិយជ្ឈានិកចិត្តេសុ វិតក្កវិចារវជ្ជា ។ ចតុត្ថ-ជ្ឈានិកចិត្តេសុ វិតក្កវិចារបីតិវជ្ជា ។ បញ្ចមជ្ឈានិកចិត្តេសុ បន បន្នរសសុ អប្បមញ្ញាយោ

ន លព្ភន្តីតិ ។ សព្វថាបិ សត្តវីសតិមហគ្គតចិត្តេសុ បញ្ចកជ្ឈានវសេន បញ្ចធាវ សង្គហោ ហោតីតិ ។

[៣៩] បញ្ចត្តឹស ចតុត្តឹស តេត្តឹស ច យថាក្កមំ
ពាត្តឹស ចេវ តឹសេតិ បញ្ចធាវ មហគ្គតេ ។

[៤០] កាមាវចរសោភណេសុ បន កុសលេសុ តាវ បឋមទ្វយេ អញ្ញសមានា តេរស ចេតសិកា , បញ្ចវីសតិ សោភណចេតសិកា ចេតិ អដ្ឋតឹស ធម្មា សង្គហំ គច្ឆន្តិ ។ អប្បមញ្ញា វិរតិយោ បនេត្ថ បញ្ចបិ បច្ចេកមេវ យោជេតព្វា ។

តថា ទុតិយទ្វយេ ញាណវជ្ជិតា ។ តតិយទ្វយេ ញាណសម្បយុត្តា បីតិវជ្ជិតា ។ ចតុត្ថទ្វយេ ញាណបីតិវជ្ជិតា តេ ឯវ សង្គយ្ហន្តិ ។ កិរិយចិត្តេសុបិ វិរតិវជ្ជិតា តថេវ ចតូសុបិ ទុកេសុ ចតុធាវ សង្គយ្ហន្តិ ។

តថា វិបាកេសុ ច អប្បមញ្ញាវិរតិវជ្ជិតា តេ ឯវ សង្គយ្ហន្តីតិ ។ សព្វថាបិ ចតុវីសតិ កាមាវចរសោភណចិត្តេសុ ទុកវសេន ទ្វាទសធាវ សង្គហោ ហោតីតិ ។

[៤១] អដ្ឋតឹស សត្តតឹស ទ្វយំ ឆត្តឹសកំ សុភេ
បញ្ចតឹស ចតុត្តឹស ទ្វយំ តេត្តឹសកំ ក្រិយេ ។
តេត្តឹស បាកេ ពាត្តឹស ទ្វយេកតឹសកំ ភវេ
សហេតុកាមាវចរ- បុញ្ញបាកក្រិយាមនេ ។

[៤២] ន វិជ្ជន្តេត្ថ វិរតី ក្រិយេសុ ច មហគ្គតេ
អនុត្តរេ អប្បមញ្ញា កាមបាកេ ទ្វយំ តថា ។
អនុត្តរេ ឈានធម្មា អប្បមញ្ញា ច មជ្ឈិមេ
វិរតី ញាណបីតិ ច បរិត្តេសុ វិសេសកា ។

[៤៣] អកុសលេសុ បន លោភមូលេសុ តាវ បឋមេ អសង្ខារិកេ អញ្ញសមានា តេរស ចេតសិកា, អកុសលសាធារណា ចត្តារោ ចាតិ សត្តរស លោភទិដ្ឋីហិ សទ្ធឹ ឯកូនវីសតិ ធម្មា សង្គហំ គច្ឆន្តិ ។

[៤៤] តថេវ ទុតិយេ អសង្ខារិកេ លោភមានេន ។

[៤៥] តតិយេ តថេវ បីតិវជ្ជិតា លោភទិដ្ឋីហិ សហ អដ្ឋារស ។

[៤៦] ចតុត្ថេ តថេវ លោភមានេន ។

[៤៧] បញ្ចមេ បន បដិឃសម្បយុត្តេ អសង្ខារិកេ ទោសោ ឥស្សា មច្ឆរិយំ កុក្កុច្ចញ្ចាតិ ចតូហិ សទ្ធឹ បីតិវជ្ជិតា តេ ឯវ វីសតិ ធម្មា សង្គយ្ហន្តិ ។ ឥស្សាមច្ឆរិយកុក្កុច្ចានិ បនេត្ថ បច្ចេកមេវ យោជេតព្វានិ ។

[៤៨] សសង្ខារិកបញ្ចកេបិ តថេវ ថិនមិទ្ធេន វិសេសេត្វា យោជេតព្វា

[៤៩] ឆន្ទបីតិវជ្ជិតា បន អញ្ញសមានា ឯកាទស, អកុសលសាធារណា ចត្តារោ ចាតិ បន្នរស ធម្មា ឧទ្ធច្ចសហគតេ សម្បយុជ្ជន្តិ ។

[៥០] វិចិកិច្ឆាសហគតចិត្តេ ច អធិមោក្ខវិរហិតា វិចិកិច្ឆាសហគតា តថេវ បន្នរស ធម្មា សមុបលព្ភន្តីតិ ។ សព្វថាបិ ទ្វាទសាកុសលចិត្តុប្បាទេសុ បច្ចេកំ យោជិយមានាបិ គណនវសេន សត្តធាវ សង្គហិតា ភវន្តីតិ ។

[៥១] ឯកូនវីសាដ្ឋារស វីសេកវីស វីសតិ
ទ្វាវីស បន្នរសេតិ សត្តធា កុសលេ ឋិតា ។

[៥២] សាធារណា ច ចត្តារោ សមានា ច ទសាបរេ
ចុទ្ទសេតេ បវុច្ចន្តិ សព្វាកុសលយោគិនោ ។

[៥៣] អហេតុកេសុ បន ហសនចិត្តេ តាវ ឆន្ទវជ្ជិតា អញ្ញសមានា ទ្វាទស ធម្មា សង្គហំ គច្ឆន្តិ ។

[៥៤] តថា វោដ្ឋព្វនេ ឆន្ទបីតិវជ្ជិតា ។

[៥៥] សុខសន្តីរណេ ឆន្ទវីរិយវជ្ជិតា ។

[៥៦] មនោធាតុត្តិកាហេតុក បដិសន្ធិយុគឡេ ឆន្ទបីតិវីរិយវជ្ជិតា ។

[៥៧] ទ្វិបញ្ចវិញ្ញាណេ បកិណ្ណកវជ្ជិតា តេយេវ សង្គយ្ហន្តីតិ ។

សព្វថាបិ អដ្ឋារសសុ អហេតុកេសុ គណនវសេន ចតុធាវ សង្គហោ ហោតីតិ ។

[៥៨] ទ្វាទសេកាទស ទស　　សត្ត ចាតិ ចតុព្វិធោ
　　អដ្ឋារសាហេតុកេសុ　　ចិត្តុប្បាទេសុ សង្គហោ ។
[៥៩] អហេតុកេសុ សព្វត្ថ　　សត្ត សេសា យថារហំ
　　ឥតិ វិត្ថារតោ វុត្តោ　　តេត្តឹសវិធសង្គហោ ។
[៦០] ឥត្ថំ ចិត្តាវិយុត្តានំ　　សម្បយោគញ្ច សង្គហំ
　　ញត្វា ភេទំ យថាយោគំ　　ចិត្តេន សមមុទ្ទិសេ ។

ឥតិ អភិធម្មត្ថសង្គហេ ចេតសិកសង្គហវិភាគោ នាម ទុតិយោ បរិច្ឆេទោ ។

# ចេតសិក ៥២ ដួង

| | | |
|---|---|---|
| សព្វ.សាធារណចេ.៧ ដួង | ផស្ស, វេទនា, សញ្ញា, ចេតនា, ឯកគ្គ., ជីវិតិ., មនសិ. | អញ្ញសមានាចេ.១៣ ដួង |
| បកិណ្ណកចេតសិក ៦ ដួង | វិតក្ក, វិចារ, អធិ., វីរិយ, បីតិ, ឆន្ទ | |
| មោចតុកចេតសិក ៤ ដួង | មោហ, អហិរិ, អនោ., ឧទ្ធច្ច | អកុសលចេតសិក ១៤ ដួង |
| លោតិកចេតសិក ៣ ដួង | លោភ, ទិដ្ឋិ, មានះ | |
| ទោចតុកចេតសិក ៤ ដួង | ទោស, ឥស្សា, មច្ឆរិ., កុក្កុច្ច | |
| ថីទុកចេតសិក ២ ដួង | ថីន, មិទ្ធ | |
| វិចិកិច្ឆាចេតសិក ១ ដួង | វិចិកិ. | |
| សោ.សាធារណចេ.១៩ ដួង | សទ្ធា, សតិ, ហិរិ, ឱត្តប្ប, អលោ, អទោ, តត្រ; កាយបស្ស, ចិត្តបស្ស, កាយលហុ, ចិត្តលហុ, កាយមុទុ, ចិត្តមុទុ, កាយកម្ម, ចិត្តកម្ម, កាយបាគុ., ចិត្តបាគុ., កាយឧជុ., ចិត្តឧជុកតា | សោភណចេតសិក ២៥ ដួង |
| វិរតិចេតសិក ៣ ដួង | វាចា, កម្មន្ត, អាជីវ | |
| អប្បមញ្ញាចេតសិក ២ ដួង | ករុណា, មុទិតា | |
| បញ្ញិន្ទ្រិយចេតសិក ១ ដួង | បញ្ញា | |

**ចេតសិកទាំងអស់ ៥២ ដួង**

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ២

## ចេតសិកសង្គហវិភាគ

( ការចែកចេតសិកជាពួក )

## សម្បយោគលក្ខណៈ៤

( លក្ខណៈ៤ យ៉ាងរបស់ចេតសិក )

**[១] ឯកុប្បាទនិរោធា ច ឯកាលម្ពណវត្ថុកា**

**ចេតោយុត្តា ទ្វិបញ្ញាស ធម្មា ចេតសិកា មតា ។**

ប្រែថា: សភាវធម៌ ៥២ យ៉ាង ប្រកបជាមួយចិត្ត កើតនិងរលត់ខណៈតែមួយជាមួយចិត្ត មានអារម្មណ៍និងទីតាំងតែមួយជាមួយចិត្ត ឈ្មោះថា **ចេតសិក** ។

## អធិប្បាយ

ព្រះអនុរុទ្ធាចារ្យកាលបើបានសម្តែងការប្រមូលចិត្តហើយ ឥឡូវនេះនឹងសម្តែងការប្រមូលចេតសិកជាលំដាប់តទៅ ទើបផ្តើមពោលគាថាដំបូង ដើម្បីសម្តែងសេចក្តីរបស់ស័ព្ទ និង អត្ថដែលជាអង្គធម៌ព្រមទាំងលក្ខណៈដែលចេតសិកប្រកបរួមជាមួយចិត្ត ៤ ប្រការ ។

ក្នុងគាថាដំបូងនោះ កន្លះគាថាថា **ឯកុប្បាទនិរោធា ច ឯកាលម្ពណវត្ថុកា** ( មានការកើត និង រលត់ខណៈតែមួយជាមួយនឹងចិត្ត មានអារម្មណ៍ និង ទីតាំងតែមួយជាមួយនឹងចិត្ត ) នោះ ជាពាក្យសម្តែងលក្ខណៈចំពោះ ៤ ប្រការរបស់ចេតសិកក្នុងការប្រកបរួមជាមួយចិត្ត ។

ពាក្យថា **ចេតោយុត្តា** ( ប្រកបជាមួយចិត្ត ) សម្ដែងសេចក្ដីរបស់ចេតសិក គឺ សភាវៈប្រកបក្នុងចិត្ត ។

ន័យម្យ៉ាងទៀត **ចេតសិក** គឺ សភាវៈប្រកបជាមួយនឹងចិត្ត ។

[ ពាក្យថា **ចេតសិក** មានសេចក្ដី ២ ប្រការគឺ ៖

-សភាវៈប្រកបក្នុងចិត្ត ដោយមានវិគ្គហសម្ដែងថា **ចេតសិ យុត្តា = ចេតសិកា** សភាវៈប្រកបក្នុងចិត្ត ។

-សភាវៈប្រកបជាមួយចិត្ត ដោយមានវិគ្គហសម្ដែងថា **ចេតសា យុត្តា = ចេតសិកា** សភាវៈប្រកបជាមួយនឹងចិត្ត ] ។

ពាក្យថា **ទ្វិបញ្ញាស ធម្មា** ( សភាវធម៌ ៥២ យ៉ាង ) ជាការសម្ដែងចំនួនចេត-សិក។

ចំណែកពាក្យថា **ចេតសិកា** ( ឈ្មោះថា **ចេតសិក** ) សម្ដែងបទសម្រេច ។ ក្នុងគាថានោះ ពាក្យថា **ឧប្បាទ** គឺការកើតឡើងដោយសភាវៈតទៅខាងមុខ ពោលគឺភាវៈជាអនាគតរបស់ធម៌ទាំងឡាយ បានដល់ **ការឧប្បត្តិ** ដោយអធិប្បាយសេចក្ដីថា សង្ខតធម៌ទាំងពួង មានភាវៈជាអនាគតតនៅខាងមុខ កាលបើបានទទួលការព្រមព្រៀងនៃបច្ច័យ ទើបចូលដល់ភាវៈជាបច្ចុប្បន្នបាន កាលបើរលត់ពីបច្ចុប្បន្ននេះទៅក៏ចូលដល់ភាពជាអតីត ។

ពាក្យថា **និរោធ** គឺការរលត់ បានដល់ ការវិនាសទៅនៃសភាវៈ ការប្រាសទៅ ការមិនទៀង ការស្លាប់។

ពាក្យថា **ឯកុប្បាទ** គឺមានការកើតក្នុងខណៈជាមួយគ្នា ។

ពាក្យថា **ឯកនិរោធ** គឺ មានការរលត់ក្នុងខណៈជាមួយគ្នា តាមន័យដែលបានពោលទុកហើយ ( ក្នុងខាងដើមបរិច្ឆេទ ) ថា៖

[ ការកើតរបស់ចិត្ត ការកើតនោះឯង ជាការកើតរបស់ចេតសិកមានផស្សៈជាដើម ការជរារបស់ចិត្ត ជាការជរារបស់ចេតសិកមានផស្សៈជាដើម ការរលត់របស់ចិត្ត ជាការរលត់របស់ចេតសិកមានផស្សៈជាដើម អារម្មណ៍

របស់ចិត្ត ជាអារម្មណ៍របស់ចេតសិកមានផស្សៈជាដើម ទីតាំងរបស់ចិត្ត ជាទីតាំងរបស់ចេតសិកមានផស្សៈជាដើម ] ។

ពាក្យថា **ឯកុប្បាទនិរោធ** គឺមានការកើតនិងការរលត់ក្នុងខណៈជាមួយគ្នា គប្បីជ្រាបការលុប **ឯក** ស័ព្ទ ក្នុងបទខាងក្រោយ ។

សូម្បីពាក្យក្រោយ [ **ឯកាលម្ពណវត្ថុកា** ] ក៏ដូចគ្នាដែរ ។

ពាក្យថា **ឯកាលម្ពណ គឺ** មានអារម្មណ៍ជាមួយគ្នា ។

ពាក្យថា **ឯកវត្ថុក** គឺ មានទីតាំងជាមួយគ្នា។

ពាក្យថា **ឯកាលម្ពណវត្ថុក** គឺមានអារម្មណ៍ និង ទីតាំងជាមួយនឹងចិត្ត។ សូម្បីចិត្តមួយដួង អាចទទួលដឹងអារម្មណ៍បានច្រើនយ៉ាង តែខ្ញុំព្រះករុណា [ ព្រះដីកាចារ្យ ] ពោល [ រូបជាឯកវចនៈ ] ថា **ឯកំ អាលម្ពណំ** ( មានអារម្មណ៍ជាមួយគ្នា ) ដោយសម្តែងសភាពតែមួយ។

[ សូម្បីអារម្មណ៍មានច្រើន ក៏ព្រះដីកាចារ្យមិនបានពោលជាពហុវចនៈថា **អាលម្ពណានិ** ( អារម្មណ៍ទាំងឡាយ ) ដែរ តែពោលជាឯកវចនៈថា **ឯកំ អាលម្ពណំ** ( មានអារម្មណ៍តែមួយជាមួយគ្នា ) ព្រោះត្រូវការពោលដល់ប្រភេទជាមួយគ្នា ការប្រើពាក្យក្នុងលក្ខណៈបែបនេះ ហៅថា **ជាត្យាបេក្ខន័យ** ( ន័យសម្លឹងរកប្រភេទ ] ។

កាលបើពោលថា សភាវធម៌ដែលប្រកបជាមួយចិត្ត ឈ្មោះថាចេតសិក សូម្បីរូបកើតពីបច្ច័យដែលកើតរួមជាមួយចិត្ត មានការសម្ព័ន្ធជាមួយចិត្តពិតប្រាកដ ដោយប្រព្រឹត្តទៅទាក់ទិនជាមួយចិត្ត ក៏គប្បីបានឈ្មោះថា ចេតសិកប្រកបជាមួយចិត្តផង ដូច្នោះ ព្រះអនុរុទ្ធាចារ្យទើបពោលថា **ឯកុប្បាទនិរោធា ច ឯកាលម្ពណវត្ថុកា** ( កើត និងរលត់ខណៈតែមួយជាមួយចិត្ត មានអារម្មណ៍ និង ទីតាំងតែមួយជាមួយចិត្ត ) ដើម្បីបដិសេធរូប [ ដែលកើតរួមជាមួយចិត្ត ] ទាំងនោះ ។

សេចក្តីពិត រូបដូចដែលបានពោល សូម្បីកើតរួមជាមួយចិត្តក្នុងខណៈមួយ តែក៏មិនមានលក្ខណៈថា ការកើតរបស់ចិត្ត ជាខណៈកើតរបស់រូប ព្រោះមានក្រសែផ្សេងគ្នា ដោយសារក្រសែរបស់រូបធម៌ ផ្សេងពីក្រសែរបស់នាម [ រូបរលត់យឺតជាងនាម ១៧ ដួង ] ។

ព្រះអនុរុទ្ធាចារ្យពោលថា **ឯកនិរោធ** ( រលត់ខណៈតែមួយជាមួយចិត្ត ) ជាដើម ដើម្បីសម្តែងថា ការកើតឡើងរបស់ចេតសិក មានផស្សៈជាដើម មិនត្រឹមតែកើតឡើងខណៈតែមួយជាមួយចិត្តប៉ុណ្ណោះទេ ការរលត់ អារម្មណ៍ និង វត្ថុ ( ទីតាំង ) ទាំងអស់ ក៏ប្រព្រឹត្តទៅក្នុងខណៈតែមួយជាមួយចិត្ត ព្រោះបើមិនពោលដូច្នេះ បុគ្គលក៏មិនអាចដឹងសេចក្តីនេះបាន ។

**[២] កថំ** ? ចេតសិក ៥២ ដួងគឺអ្វីខ្លះ ?

ព្រះអនុរុទ្ធាចារ្យ កាលបើពោលពាក្យសួរថា ចេតសិក ៥២ ដួងគឺអ្វីខ្លះ ? ហើយក៏ផ្តើមសម្តែងចែកអង្គធម៌ ៥២ ប្រការដោយពួក ៣ [ អញ្ញសមានារាសី អកុសលរាសី និង សោភណរាសី ] ។

## អញ្ញសមានាចេតសិក ១៣

**ផស្សោ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយំ មនសិការោ ចេតិ សត្តិមេ ចេតសិកា សព្វចិត្តសាធារណា នាម ។**

ប្រែថា: ចេតសិកទាំង ៧ ដួងពួកនេះគឺ **ផស្សៈ** ( ការប៉ះខ្ទប់អារម្មណ៍ ) **វេទនា** ( ការសោយអារម្មណ៍ ) **សញ្ញា** ( ការចងចាំអារម្មណ៍ ) **ចេតនា** ( ការតាំងចិត្ត ) **ឯកគ្គតា** ( ការមានអារម្មណ៍តែមួយ ) **ជីវិតិន្ទ្រិយ** ( ការរក្សាសម្បយុត្តធម៌ ) **មនសិការ** ( ការធ្វើទុកក្នុងចិត្ត ) ឈ្មោះថា **សព្វចិត្តសាធារណចេតសិក ៗ**

## អធិប្បាយ

ក្នុងប្រយោគនោះ **ផស្សៈ** ( ការប៉ះខ្ទប់ ) គឺសភាវៈប៉ះខ្ទប់ ( អារម្មណ៍ ) ។

ន័យម្យ៉ាងទៀត **ផស្សៈ**គឺ សភាវៈធ្វើឲ្យសម្បយុត្តធម៌ប៉ះខ្ទប់ ( អារម្មណ៍ )។

ន័យម្យ៉ាងទៀត **ផស្សៈ** គឺ ការប៉ះខ្ទប់ ( អារម្មណ៍ ) ។

[ ពាក្យថា **ផស្សៈ** មានសេចក្តី ៣ ប្រការ គឺ៖

-សភាវៈប៉ះខ្ទប់អារម្មណ៍ **ផុសតីតិ** = **ផស្សោ** ។

-សភាវៈធ្វើឲ្យសម្បយុត្តធម៌ប៉ះខ្ទប់អារម្មណ៍ **ផុសន្តិ សម្បយុត្តកា ធម្មា ឯតេនាតិ** = **ផស្សោ** ។

-ការប៉ះខ្ទប់អារម្មណ៍ **ផុស្សនំ** = **ផស្សោ** ] ។

ការប៉ះខ្ទប់ ( អារម្មណ៍ ) ក្នុងរឿងនេះ គឺការចូលទៅពាល់ត្រូវរសដែលគួរប្រាថ្នា ឬ មិនគួរប្រាថ្នារបស់អារម្មណ៍ ជាហេតុឲ្យវេទនាប្រាកដឡើង សោយរសរបស់អារម្មណ៍ ដូចព្រះពុទ្ធតម្រាស់ថា **ផស្សប្បច្ចយោ វេទនា** “ វេទនារមែងមានព្រោះផស្សៈជាបច្ច័យ ” ។

**ផស្សៈ** នេះ មានការប៉ះខ្ទប់ ( អារម្មណ៍ ) ជាលក្ខណៈ ។

- សួរថាៈ ផស្សៈជាហេតុឲ្យកើតអ្វីខ្លះ ?

-ឆ្លើយថា ផស្សៈរមែងជាហេតុឲ្យកើតការប្រែប្រួលនៃចិត្តតាមសមគួរដល់រសរបស់អារម្មណ៍។

ន័យម្យ៉ាងទៀត ផស្សៈជាហេតុឲ្យកើតវេទនាដែលផ្សេងគ្នា ។ ដូចជាបានឃើញបុគ្គលដទៃកំពុងទំពារម្ជូរជាដើម ហើយចេញទឹកមាត់ច្រោក ដោយវត្ថុជូរនោះពុំបានមកប៉ះនឹងចុងអណ្តាតរបស់ខ្លួនឡើយ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា **ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុ-វិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ** ប្រែថាៈ អាស្រ័យចក្ខុ និង រូប ចក្ខុវិញ្ញាណទើបកើតឡើង ឈ្មោះថា មានផស្សៈ ព្រោះមានការព្រមព្រៀងនៃធម៌ ៣ យ៉ាង ។

អធិប្បាយថាការព្រមព្រៀងគ្នា គឺការប្រជុំគ្នានៃធម៌ ៣ យ៉ាង គឺ ចក្ខុ រូប ចក្ខុវិញ្ញាណ ទើបមានផស្សៈ ឈ្មោះថា ចក្ខុសម្ផស្ស ។

**វេទនា** សភាវៈសោយ [ អារម្មណ៍ ] បានដល់ សោយរសរបស់អារម្មណ៍ ឬ ធ្វើរសរបស់អារម្មណ៍ដែលមិនប្រាកដច្បាស់ ឲ្យជាក់ច្បាស់ដល់សម្បយុត្តធម៌ ឬ ដល់បុគ្គលអ្នកមានវេទនា ។

ន័យម្យ៉ាងទៀត **វេទនា** គឺ សភាវៈធ្វើឲ្យពពួកសត្វកើតសេចក្តីពេញចិត្ត ឬ មិនពេញចិត្ត ។

ន័យម្យ៉ាងទៀត **វេទនា** គឺការសោយ [ អារម្មណ៍ ] ដូចមានព្រះពុទ្ធវចនៈថា:

**វេទយតិ វេទយតីតិ ខោ ភិក្ខវេ តស្មា វេទនាតិ វុច្ចតិ។ កិញ្ច វេទយតិ សុខម្បិ វេទយតិ, ទុក្ខម្បិ វេទយតិ, អទុក្ខមសុខម្បិ វេទយតិ។**

ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតហៅថាវេទនា ព្រោះដឹង ដឹងអ្វី ? ដឹងសុខខ្លះ ដឹងទុក្ខខ្លះ ដឹងសភាពមិនទុក្ខមិនសុខខ្លះ ។

[ ពាក្យថា **វេទនា** មាន ៣ យ៉ាង គឺ ៖

-សភាវៈសោយអារម្មណ៍ = **វេទយតីតិ** > **វេទនា** ។

-សភាវៈធ្វើឲ្យពពួកសត្វកើតសេចក្តីពេញចិត្ត ឬ មិនពេញចិត្ត = **វិន្ទន្តិ ឯតាយ សត្តា សាតំ វា អសាតំ វា លភន្តីតិ** > **វេទនា។**

-ការសោយអារម្មណ៍ = **វេទយិតំ** > **វេទនា** ] ។

-សួរថា: សភាវធម៌ គឺ៖ ចិត្ត និង ចេតសិកទាំងអស់ដឹងរសរបស់អារម្មណ៍ជាប្រក្រតី ទើបឈ្មោះថា វេទនា មែន ឬ?

-ឆ្លើយថា: សភាវធម៌ទាំងនោះ មិនឈ្មោះថា វេទនា ព្រោះខ្វល់ខ្វាយក្នុងនាទីដទៃ ទើបដឹងរសរបស់អារម្មណ៍ដោយត្រង់មិនបាន កាលបើធ្វើនាទីរបស់ខ្លួនៗ រមែងដឹងរសរបស់អារម្មណ៍ត្រឹមតែចំណែកខ្លះ តែវេទនារមែងដឹងដោយភាពជាធំ ព្រោះមិនមាននាទីដទៃ ហើយមានភាពជាធំក្នុងនាទីដឹងវេទនាទើបគួរបានឈ្មោះថា វេទនាប៉ុណ្ណោះ ដោយហេតុនេះ ព្រះអដ្ឋកថាចារ្យ

ទើបពោលចិត្ត និង ចេតសិក ដូចចុងភៅភ្លក្សរសអាហារដ៏ប្រសើររបស់ព្រះរាជា ហើយពោលថា វេទនា ដូចព្រះរាជា [ អ្នកសោយ ] ។

**សញ្ញា** ( ការចងចាំអារម្មណ៍ ) បានដល់ ការធ្វើចំណាំដើម្បីឲ្យបានដឹងទៀត [ នៅក្នុងឱកាសខាងមុខ ] ។ ពិតហើយ សភាវធម៌នេះ ជាការធ្វើចំណាំដើម្បីឲ្យដឹងបាន តាមការចំណាំពីមុនមក អធិប្បាយបានថា សញ្ញា កាលបើកើតឡើងមានការបន្ថែមនូវការចងចាំ រមែងដល់នូវភាពជាសញ្ញាដែលកប់ណែនទៅរហូតមួយជីវិតខ្លះ ជាប់ទៅតាមភពដទៃខ្លះ រមែងឲ្យផលជាសភាវៈមិនវង្វេងដល់ពពួកសត្វ ។ កាលបើបុគ្គលដល់នូវភាពជាអ្នកមានសញ្ញាប្រកាន់ខុសយ៉ាងមាំហើយ រមែងមានផលធ្វើឲ្យបុគ្គលនោះ ក្លាយទៅជាបុគ្គលដែលព្រះសព្វញ្ញុពុទ្ធមិនអាចប្រោសបាន ។ សញ្ញានោះលោកប្រៀបបានថា:

**សញ្ញានន្តំ និមិត្តករណេ ទារុតច្ឆកសទិសាតិ ច ។ យថាគហិតនិមិត្តវសេន អភិនិវេសករណេ ហត្ថិទសកអន្ធសទិសាតិ ច ។ ឧបដ្ឋិតវិសយគ្គហណេ តិណបុរិសកេសុ មិគ្គបោតកសទិសាតិ ច វុត្តាតិ ។**

ប្រែថា: ដូចជាងឈើធ្វើគ្រឿងចំណាំដើម្បីឲ្យបានចាំទៀត ។ ដូចមនុស្សខ្វាក់ស្ទាបដំរីក្នុងខណៈធ្វើការជឿដោយភាពជាអារម្មណ៍ ដូចដែលបានទទួលយកហើយ ។ ដូចម្រឹកឃើញទីងមោងដេញចាប ក្នុងខណទទួលយកអារម្មណ៍ដែលប្រាកដ ។

[ ជាងឈើរមែងធ្វើគ្រឿងចំណាំទុកនៅលើកំណាត់ឈើដែលបានកាត់ហើយជាកង់ៗ ឬ ជ្រៀកជាបន្ទះមកហើយ ដើម្បីងាយស្រួលនៅពេលយកមកប្រើធ្វើតាមតម្រូវការដែលកំណត់ទុក ។ បុគ្គលខ្វាក់ភ្នែកបានស្ទាបដំរី កាលបើចាប់ត្រង់កន្ទុយហើយប្រាប់ថា ដំរីដូចអំបោស ចំណែកអ្នកដែលចាប់ត្រង់ជើងហើយក៏ប្រាប់ថា ដំរីដូចសសរជាដើម តាមដែលខ្លួនបានស្ទាប ។ ពួកម្រឹកកាលបើឃើញរូបទីងមោងដែលគេដាក់ដេញក្អែកជាដើម ដែលមានរូបសណ្ឋានដូចមនុស្ស ក៏រមែងគិតថាជាមនុស្សដោយអំណាចរបស់សញ្ញា ] ។

**ក្នុងព្រះបាលីព្រះអង្គបានត្រាស់សម្តែងថា:**

**សញ្ជានាតិ ។ សញ្ជានាតីតិ ខោ ភិក្ខវេ តស្មា សញ្ញាតិ វុច្ចតិ ។ កិញ្ច សញ្ជានាតិ ។ នីលម្បិ សញ្ជានាតិ ។ បីតកម្បិ សញ្ជានាតីតិ អាទិ ។**

ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតហៅថាសញ្ញា ព្រោះចំណាំ ។ ចំណាំអ្វី ? ចំណាំពណ៌ខៀវខ្លះ ចំណាំពណ៌លឿងខ្លះ ជាដើម ។

**ចេតនា** ( ការតាំងចិត្ត ) គឺសភាវៈបន្ត បានដល់ ការបន្តសម្បយុត្តធម៌ឲ្យស្មើក្នុងអារម្មណ៍ ឬ កិច្ចនោះៗ ពោលគឺ ធ្វើសម្បយុត្តធម៌ឲ្យប្រព្រឹត្តទៅយ៉ាងតជាប់គ្នា ដោយសភាពជាប់តគ្នាក្នុងអារម្មណ៍ ឬ កិច្ចទាំងនោះ ។

ន័យម្យ៉ាងទៀត **ចេតនា** សភាវៈគាក់តែងសម្បយុត្តធម៌ បានដល់ ការចាត់ចែង ដើម្បីឲ្យបានទទួលអារម្មណ៍ ឬ សេចក្តីសម្រេចនៃកម្ម ។

ន័យម្យ៉ាងទៀត **ចេតនា** គឺសភាវៈរួមសម្បយុត្តធម៌ បានដល់ ការរួមសម្បយុត្តធម៌ចូលទុកក្នុងអារម្មណ៍ ធ្វើឲ្យប្រជុំរួមគ្នា ។ ដោយពិតហើយចេតនានោះអាចពោលបានថា **អាយូហនរសាហិ ច សំវិធានបច្ចុប្បដ្ឋានា** ប្រែថា “មាននាទីខ្វល់ខ្វាយ មានការចាត់ចែង ជាគ្រឿងប្រាកដ ឬ ជាផល ” ។

កាលបើចេតនាប្រព្រឹត្តទៅដោយការខ្វល់ខ្វាយ ចាត់ការជានិច្ចក្នុងអារម្មណ៍ សូម្បីសភាវធម៌ដែលប្រកបជាមួយនឹងចេតនា ក៏ធ្វើកិច្ចរបស់ខ្លួនៗឲ្យប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយជាមួយគ្នា ដូចមានសាធកៈ ( ក្នុងគម្ពីរអដ្ឋកថា ) ថា:

**តេនេវ សា សកិច្ចបរកិច្ចសាធកជេដ្ឋសិស្សមហាវឌ្ឍកិអាទិសទិសា**

ប្រែថា “ ប្រៀបដូចសិស្សឯក និង មេជាងឈើជាដើម អ្នកឲ្យសម្រេចកិច្ចរបស់ខ្លួន និង កិច្ចរបស់អ្នកដទៃ ” ។

[ កាលបើសិស្សឯកជាប្រធាននាំស្វាធ្យាយធម៌ សិស្សដទៃក៏ស្វាធ្យាយតាម ដូចមេជាងឈើធ្វើការងារ កូនជាងក៏ធ្វើតាម ] ។

[ ពាក្យថា **ចេតនា** មានសេចក្តី ៣ ប្រការ គឺ ៖

-សភាវៈបន្ត =**ចេតយតិ អភិសន្ទហតីតិ** > **ចេតនា** ( **ចិត** ធាតុ មានអត្ថថា **បន្ត** )។

-សភាវៈតាក់តែងសម្បយុត្តធម៌ = **ចេតយតិ បកប្បេតីតិ** > **ចេតនា** ( **ចិត** ធាតុ មានអត្ថថា **តាក់តែង** ) ។

-សភាវៈរួមសម្បយុត្តធម៌ = **ចេតយតិ អាយូហតីតិ** > **ចេតនា** ( **ចិត** ធាតុ មានអត្ថថា **រួម** ) ] ។

ចេតនា រាប់ចូលក្នុងសង្ខារក្ខន្ធ ក៏ព្រោះមានលក្ខណៈតាក់តែងសង្ខតធម៌ ២ ប្រការ គឺ ៖

**១- តាក់តែងសង្ខតធម៌** គឺ ចាត់ចែងឲ្យធម៌ដែលកើតរួមជាមួយខ្លួន បាន ប្រព្រឹត្តទៅក្នុងអារម្មណ៍ដោយអាការៈរបស់ខ្លួនៗ ដូចបានពោលហើយនោះ បានដល់ ចេតនាដែលកើតក្នុងចិត្តគ្រប់ដួង ។

**២- តាក់តែងសង្ខតធម៌** គឺ ចាត់ចែងវិបាក និង កម្មជរូប ( រូបដែលកើតពីកម្ម ) ឲ្យកើតឡើងក្នុងកាលតទៅ ព្រោះហេតុដូច្នោះ ទើបបានដល់ ចេតនាក្នុង កុសល និង អកុសលចិត្ត ដែលដល់នូវភាពជាកម្មដែលនឹងញ៉ាំងវិបាក និង កម្មជរូបឲ្យកើតឡើងប៉ុណ្ណោះ ដូចមានសាធកក្នុង ( ឆក្កនិបាត មហាវគ្គ ) ព្រះអង្គបានត្រាស់ថា **ចេតនាហំ ភិក្ខវេ កម្មំ វទាមិ** ប្រែថា “ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ចេតនាជាតួកម្មយ៉ាងនេះ ” ។

**ឯកគ្គៈ** បានដល់ ចិត្តដែលមានចំណែកមួយ គឺ អារម្មណ៍មួយ ។

ន័យម្យ៉ាងទៀត **ឯកគ្គៈ** បានដល់ ចិត្តដែលមានទីបំផុត គឺ អារម្មណ៍មួយ។

[ តាមន័យដំបូង ក្នុងពាក្យថា **ឯកគ្គ** (**ឯក** + **អគ្គ** ) **អគ្គ** ស័ព្ទមានអត្ថថា **កោដ្ឋាស** ( ចំណែក ) ន័យក្រោយ មានអត្ថថា **កោដិ** ( ទីបំផុត ) ] ។

**ឯកគ្គតា** ( ការមានអារម្មណ៍មួយ ) គឺ ភាវៈនៃចិត្តដែលមានអារម្មណ៍មួយ តាមប្រក្រតី សូម្បីជាអារម្មណ៍ប្រភេទដូចគ្នា ក៏មានសភាពផ្សេងគ្នា អាការៈ តាំងមាំនៃចិត្តដែលមិនងាករេទៅរកភាវៈផ្សេងៗរបស់អារម្មណ៍ណាមួយ ហើយ នៅប្រព្រឹត្តទៅយ៉ាងតាំងមាំក្នុងភាវមួយ សូម្បីត្រឹមមួយខណៈនេះ ទើបកាន់

យកថាជាអារម្មណ៍មួយ ហើយជាហេតុជាទីមករបស់ឈ្មោះថា **ឯកគ្គ** ( ចិត្ត ដែលមានអារម្មណ៍មួយ ) ដូចមានសាធក [ ក្នុងគម្ពីរធម្មសង្គណីអដ្ឋកថា ] ថាៈ

**និវាតេ ទីបច្ចីនំ ឋិតិ វិយ ចេតសោ ឋិតីតិ ទដ្ឋព្វា ។**

ប្រែថា សូមជ្រាបថា ឯកគ្គតា គឺការតាំងនៅនៃចិត្ត ដូចការតាំងនៅនៃ អណ្តាតរបស់ដួងប្រទីបដែលនៅក្នុងទីស្ងប់ខ្យល់ ។

**ជីវិត** គឺសភាវៈធ្វើឲ្យសម្បយុត្តធម៌ប្រព្រឹត្តទៅបាន ។

ពាក្យថា **ឥន្ទ** មានសេចក្តីថា អ្នកជាធំ ចំណែកភាវៈជាធំក្នុងទីនេះ ឈ្មោះ ថា **ឥន្ទ ។**

ឈ្មោះថា **ជីវិតិន្ទ្រិយ៍** គឺ ( សភាវៈបន្តជីវិត ) ព្រោះធ្វើឲ្យសម្បយុត្តធម៌ ប្រព្រឹត្តទៅបាន និង មានភាពជាធំ ។ សេចក្តីពិត ជីវិតិន្ទ្រិយ៍គ្រប់គ្រងសហ- ជាតធម៌ឲ្យគង់នៅ ( តាំងនៅ ) និង ប្រព្រឹត្តទៅ ដូចពាក្យថា បើប្រាសចាក យើងហើយ ពួកអ្នកនឹងមានជីវិតដូចម្តេចបាន ពួកអ្នកចូរឲ្យយើងធ្វើភាពជាធំ ក្នុងការតាំងនៅរក្សាជីវិតអ្នកទាំងឡាយ ដូចសាធកៈ ( ក្នុងគម្ពីរអដ្ឋកថា ) ថាៈ

**តំ បវត្តសន្តតាធិ-បតេយ្យន្តិ ច បទុមុប្ប លានុបាលកមុទកំ វិយាតិ ច ។**

ប្រែថា “ ជីវិតិន្ទ្រិយ៍មានសភាពជាធំក្នុងក្រសែចិត្តដែលប្រព្រឹត្តទៅជាប់ តគ្នា ប្រៀបដូចទឹករក្សានូវផ្កាបទុម និង ផ្កាឧប្បល ” ។

ក្នុងពាក្យនោះ គប្បីធ្វើវិគ្រោះហ៍សមាសថា “ ពាក្យថា **បវត្តសន្តតិ** ( ក្រសែចិត្តដែលប្រព្រឹត្តទៅជាប់តគ្នា ) គឺក្រសែចិត្តដែលប្រព្រឹត្តទៅជាប់តគ្នា រហូតដល់ខន្ធបរិនិព្វាន ។

ពាក្យថា **អាធិបតេយ្យ** ( ភាពជាធំ ) គឺភាវៈនៃភាពជាធំក្រៃលែង ។

ពាក្យថា **បវត្តសន្តតាធិបតេយ្យ** គឺមានភាពជាធំក្នុងក្រសែចិត្តដែលប្រព្រឹត្ត ទៅជាប់តគ្នា”។ សូម្បីក្រសែចិត្តកើតរលត់ ហើយរលត់ទៀត ក៏នៅតែញុំាង ជីវិតឲ្យរស់នៅបានដោយអានុភាពរបស់ជីវិតិន្ទ្រិយ៍នោះ រមែងកើតឡើងប្រព្រឹត្ត ទៅរឿយៗរហូតដល់ខន្ធបរិនិព្វាន ( ការរលត់ខន្ធ ) ព្រោះក្រសែចិត្តដែល

ប្រព្រឹត្តទៅជាប់តគ្នាជាពិសេសដូច្នេះ រមែងមិនមានក្នុងសភាវៈដែលប្រាសចាក ចិត្តគ្រប់គ្រង ដែលមិនមានជីវិតិន្ទ្រីយ៍ ។

[ ជីវិតិន្ទ្រីយ៍ ប្រៀបដូចការតាមគ្រប់គ្រងថែរក្សានាមធម៌ទាំងអស់ជាប្រក្រតី ( ជានិច្ចជាកាល ) សូម្បីនាមធម៌ទាំងឡាយកើតឡើង ហើយរលត់ទៅតាមលក្ខណសង្ខតធម៌ ក៏រមែងនឹងកើតឡើងបានទៀតក្នុងឱកាសតទៅ ដោយអំណាចរបស់ជីវិតិន្ទ្រីយ៍នេះ ចំណែករូបធម៌ទាំងឡាយ ក៏មានការតាមគ្រប់គ្រងថែរក្សាឲ្យមានការកើតឡើងតទៅទៀត បានដូចគ្នា ។ ការតាមគ្រប់គ្រងថែរក្សារូបធម៌ទាំងអស់ ជារូបល្អិតមួយប្រភេទហៅថាជីវិតរូប ] ។

កាលបើសភាវៈគ្រប់គ្រងរបស់ធម៌ទាំងនោះប្រាកដនៅ ជីវិតិន្ទ្រីយ៍រមែងគ្រប់គ្រងធម៌ទាំងនោះបានក្នុងខណៈដែលនៅមាន ( ប្រាកដនៅនៃជីវិតិន្ទ្រីយ៍ និង ធម៌ដែលត្រូវគ្រប់គ្រង ) ដូចទឹករក្សាផ្កាឧបលជាដើម ។ ហើយជីវិតិន្ទ្រីយ៍រមែងគ្រប់គ្រងធម៌ដែលកើតឡើងតាមបច្ច័យរបស់ខ្លួនៗ ដូចមេដោះតាមថែរក្សាទារកដែលកើតពីស្ត្រីដទៃ ។ រមែងប្រព្រឹត្តទៅជាមួយធម៌ដែលខ្លួនឲ្យប្រព្រឹត្តទៅ ដូចនាយសំពៅជាអ្នកនាំសំពៅ ដែលខ្លួនគ្រប់គ្រងនោះឲ្យប្រព្រឹត្តទៅ និង មិនប្រព្រឹត្តទៅក្រោយពីភង្គខណៈ ព្រោះខ្លួនឯង និង ធម៌ដែលប្រព្រឹត្តទៅជាមួយមិនមានក្នុងភង្គខណៈ ទាំងមិនតាំងនៅក្នុងភង្គខណៈ ព្រោះវិនាសទៅឯង ដូចប្រឆេះ និង ប្រេងដែលអស់ទៅ មិនអាចញ៉ាំងអណ្តាតភ្លើងឲ្យកើតឡើងបាន តែមិនបានវៀរចាកពីអានុភាពនៃការរក្សា ការឲ្យប្រព្រឹត្តទៅ និង ការតាំងទុក ព្រោះជីវិតិន្ទ្រីយ៍ញ៉ាំងនាទីនោះឲ្យសម្រេចក្នុងខណៈនោះៗ តាមដែលពោលទុកហើយ ។

**មនសិការ** ( ការធ្វើទុកក្នុងចិត្ត ) គឺ សភាវៈធ្វើអារម្មណ៍មិនឲ្យទំនេរក្នុងចិត្ត

ន័យម្យ៉ាងទៀត **មនសិការ** គឺ សភាវៈធ្វើចិត្តឲ្យបង្អោនទៅក្នុងអារម្មណ៍ជានិច្ច ។

[ ពាក្យថា មនសិការៈ មានសេចក្តី ២ ប្រការ គឺ៖

-សភាវៈធ្វើអារម្មណ៍មិនឲ្យទំនេរក្នុងចិត្ត = **មនស្មិំ អារម្មណំ អសុញ្ញំ ករោតីតិ** > **មនសិការោ** ( **មន** បុព្វបទ + **ករ** ធាតុ + **ណ** បច្ច័យ ) ។

-សភាវៈធ្វើចិត្តឲ្យបង្អោនទៅក្នុងអារម្មណ៍ជានិច្ច = **មនំ អារម្មណេ និច្ចនិន្នំ ករោតីតិ** > **មនសិការោ** ( **មន** បុព្វបទ +**ករ** ធាតុ + **ណ** បច្ច័យ ) ] ។

មនសិការមាន ៣ យ៉ាង គឺ វីថិបដិបាទកមនសិការៈ ជវនបដិបាទកមនសិការៈ និង អារម្មណបដិបាទកមនសិការៈ ។

**វីថិបដិបាទកមនសិការ** ( មនសិការដែលញ៉ាំងវិថីចិត្តឲ្យប្រព្រឹត្តទៅ ) បានដល់ បញ្ចទ្វារាវជ្ជនចិត្ត ព្រោះធ្វើក្រសែចិត្តដែលកើតក្នុងបញ្ចទ្វារឲ្យសម្រេច គឺ ឲ្យប្រកបក្នុងអារម្មណ៍ ( តាមបញ្ចទ្វារ ) ។

**ជវនបដិបាទកមនសិការ** ( មនសិការដែលញ៉ាំងជវនឲ្យប្រព្រឹត្តទៅ ) បានដល់ មនោទ្វារាវជ្ជនចិត្តដែលធ្វើឲ្យក្រសែជវនចិត្តកើត ហើយប្រព្រឹត្តទៅបានសម្រេច គឺឲ្យប្រកបក្នុងអារម្មណ៍ ( តាមមនោទ្វារ ) ។

ចិត្តទាំងពីរប្រភេទនេះបានឈ្មោះថា យោនិសោមនសិការៈ ឬ អយោនិសោមនសិការៈ ក្នុងទីនោះៗ ដោយសារចិត្តបានទទួលការឧបត្ថម្ភពីបច្ច័យគឺការសន្សំ ការបង្អោនទៅ និង ការកំណត់ជាដើមមករហូត រមែងធ្វើក្រសែចិត្តឲ្យបង្អោនទៅក្នុងអារម្មណ៍ដោយត្រូវទំនង ឬ មិនត្រូវទំនង។

**អារម្មណបដិបាទកមនសិការ** ( មនសិការដែលញ៉ាំងអារម្មណ៍ឲ្យប្រព្រឹត្តទៅ ) គឺ សភាវធម៌ ( មនសិការចេតសិក ) ដែលធ្វើឲ្យកើតក្រសែចិត្តប្រព្រឹត្តទៅជាប់តគ្នាតាំងពីបដិសន្ធិចិត្ត សូម្បីលះអារម្មណ៍ហើយរលត់ទៅ ក៏កើតឡើងថ្មីក្នុងអារម្មណ៍ចាស់បានទៀត កាលបើមិនមានហេតុពិសេស ( គឺកាលបើមិនមានអារម្មណ៍ដទៃដែលច្បាស់ជាងមកប្រាកដ ក៏ធ្វើឲ្យកើតក្រសែចិត្តក្នុងអារម្មណ៍ចាស់បាន ) ។

អារម្មណបដិបាទកមនសិការៈនេះ ត្រូវសំដៅយកទុកក្នុងទីនេះព្រោះមនសិការចេតសិកនេះ ប្រកបអារម្មណ៍ទុកក្នុងចិត្តឬប្រកបចិត្តទុកក្នុងអារម្មណ៍ដូច ( ក្នុងគម្ពីរអដ្ឋកថា ) ថាៈ

**អយំ សារណលក្ខណោតិ ច សម្បយុត្តានំ អារម្មណេន សម្បយោជនរសោតិ ច អារម្មណបដិបាទកដ្ឋេន សម្បយុត្តានំ សារថី វិយ ទដ្ឋព្វោ ។**

ប្រែថាៈ មនសិការចេតសិកនេះ មានលក្ខណៈញុាំងសម្បយុត្តធម៌ឲ្យប្រព្រឹត្តទៅ មាននាទីញុាំងសម្បយុត្តធម៌ឲ្យប្រកបទុកក្នុងអារម្មណ៍ ដូចនាយសារថីបង្គាប់សេះឲ្យបោលទៅ ។

ពាក្យថា **សាធារណ** គឺ សភាវធម៌ដែលទ្រទ្រង់ទុកស្មើគ្នា ( គឺទូទៅ ) ។

ពាក្យថា **សព្វចិត្តសាធារណ** គឺ សភាវធម៌ដែលទូទៅដល់ចិត្តទាំងអស់ ។

**[៣] វិតក្កោ វិចារោ អធិមោក្ខោ វីរិយំ បីតិ ឆន្ទោ ចាតិ ឆ ឥមេ ចេតសិកា បកិណ្ណកា នាម**

ប្រែថា ចេតសិក ៦ ដួងទាំងនេះគឺៈ **វិតក្ក** ( ការត្រិះរិះ ) **វិចារ** ( ការពិចារណា ) **អធិមោក្ខ** ( ការជឿសប់ ) **វីរិយ** ( ការព្យាយាម ) **បីតិ** ( ការឆ្អែតចិត្ត ) **ឆន្ទ** ( ការប៉ងប្រាថ្នា ) ឈ្មោះថា **បកិណ្ណកចេតសិក។**

**វិតក្ក** គឺ ( ការត្រិះរិះ ) គឺសភាវៈត្រិះរិះ ( អារម្មណ៍ ) ។

**វិតក្ក** រមែងញុាំងសម្បយុត្តធម៌ឲ្យចូលទៅកាន់អារម្មណ៍ ដូចមានអដ្ឋកថាចារ្យពោលថាៈ **អារម្មណាភិនិរោបនលក្ខណោ វិតក្កោ** វិតក្កៈ មានលក្ខណៈលើកសម្បយុត្តធម៌ឲ្យចូលទៅកាន់អារម្មណ៍ **អារម្មណេ ចិត្តស្ស អភិនិរោបនលក្ខណោ** វិតក្កៈមានសភាពលើកចិត្តទុកក្នុងអារម្មណ៍ ។ ដូចមនុស្សពួកខ្លះអាស្រ័យញាតិឬ មិត្តជា **រាជវល្លភៈ** ( អ្នកស្និទស្នាលព្រះរាជា ) ទើបចូលទៅកាន់ព្រះរាជនិវេសន៍បាន យ៉ាងណាមិញ ចិត្តក៏អាស្រ័យវិតក្កៈចូលទៅកាន់អារម្មណ៍បាន ក៏យ៉ាងនោះដែរ ។

សូម្បីបញ្ចវិញ្ញាណចិត្តមិនមានវិតក្កៈ ក៏ចូលកាន់អារម្មណ៍ដោយអំណាចការប៉ះខ្ទប់រវាងវត្ថុ និងអារម្មណ៍ ចំណែកទុតិយជ្ឈានចិត្ត ក៏រមែងចូលកាន់អារម្មណ៍ដោយអំណាចរបស់ឧបចារភាវនា ជាដើម ។

ចំណែកក្នុងអដ្ឋកថាមជ្ឈិមនិកាយ ពោលថា ការលើកមកនោះមិនត្រឹមត្រូវទេ ហើយសម្តែងសេចក្តីថា **ចិត្តម្បិ ហិ អារម្មណំ អារុហតិយេវ ។ តស្ស បន និច្ចំ សហាយោ មនសិការោ។ តស្ស មិញ្ហិ អសតិ តំ និយាមករហិតា នាវា វិយ យំ វា តំ វា អារម្មណំ តហេត្វា បវត្តេយ្យ ។** ចិត្តរមែងចូលកាន់អារម្មណ៍បាន ព្រោះមិត្ត

ប្រចាំរបស់ចិត្តគឺមនសិការៈ បើមិនមានមនសិការៈ ចិត្តក៏កើតឡើងទទួលអារម្មណ៍ផ្សេងៗដោយមិនមានទិសតំបន់ ដូចនាវាប្រាសចាកអ្នកកាច់ចង្កូត ។

ដោយហេតុនោះ បញ្ចវិញ្ញាណដែលមានមនសិការៈជាមិត្ត រមែងចូលកាន់អារម្មណ៍ដោយសភាពទទួលអារម្មណ៍របស់ខ្លួន តែក្នុងខណៈកើតអកុសលចិត្ត និង លោភចិត្ត ជាដើម ក៏មានកម្លាំងក្នុងការចូលទៅកាន់អារម្មណ៍ ដូចព្រះពុទ្ធវចនៈថា **បាបស្មឹ រមតេ មនោ** ( ចិត្តរមែងរីករាយក្នុងបាប ) ទុតិយជ្ឈានចិត្តជាដើម រមែងចូលកាន់អារម្មណ៍ដោយអំណាចមនសិការៈ វីរិយៈ និង សតិ។ ចំណែកវិតក្កៈបានត្រិះរិះដោយអាការៈនោះៗហើយ ធ្វើសភាវធម៌ដែលកើតរួមជាមួយខ្លួន ឲ្យមានកម្លាំងក្រៃលែង ក្នុងការចូលទៅកាន់អារម្មណ៍ ។

ដោយប្រការដូច្នេះ សភាវធម៌នេះ ទើបបានឈ្មោះថា **វិតក្ក** ព្រោះមានការខ្វល់ខ្វាយច្រើនជាងសភាវធម៌ដទៃក្នុងកិច្ចនោះ ។

-សួរថា: សូម្បីនាមធម៌ដទៃក៏ចូលទៅកាន់អារម្មណ៍ ព្រោះមានសភាពទទួលដឹងអារម្មណ៍ ហេតុដូចម្តេច ទើបហៅសភាវៈធម៌នេះថាជា វិតក្កៈ ?

-ឆ្លើយថា: ការចូលទៅកាន់អារម្មណ៍របស់នាមធម៌ពួកដទៃ រមែងសម្រេចដោយសារប្រកបដោយកិច្ចដទៃ តែវិតក្កៈនេះមិនមានកិច្ចដទៃក្រៅអំពីកិច្ចនេះ ( គឺ ការចូលទៅកាន់អារម្មណ៍ ) លោកទើបហៅសភាវធម៌នេះដូចយ៉ាងនោះ ថាជា **វិតក្ក** ។

**វិចារ** គឺ សភាវៈពិចារណា ។

ន័យម្យ៉ាងទៀត **វិចារ** គឺ សភាវៈធ្វើឲ្យសម្បយុត្តធម៌ពិចារណា ។

ន័យម្យ៉ាងទៀត **វិចារ** គឺ សភាវៈជាហេតុឲ្យសម្បយុត្តធម៌ពិចារណា ។

[ ពាក្យថា**វិចារ** មានសេចក្តី ៣ ប្រការ គឺ ៖

-សភាវៈពិចារណា = **វិចរតីតិ** > **វិចារោ** ។

-សភាវៈធ្វើឲ្យសម្បយុត្តធម៌ពិចារណា = **វិចារេតិ សម្បយុត្តធម្មេតិ** > **វិចារោ ។**

-សភាវៈជាហេតុឲ្យសម្បយុត្តធម៌ពិចារណា = **តេ ធម្មា វិចរន្តិ ឯតេនាតិ** > **វិចារោ ។**

ការពិចារណា ក្នុងទីនេះគឺ សភាវៈដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ដោយអំណាចការរំពឹងពិចារណាអារម្មណ៍ ក្នុងខណៈដែលវិតក្កៈនាំចិត្តចូលកាន់អារម្មណ៍ហើយ ] ។

បណ្ដាវិតក្កៈ និង វិចារៈទាំងពីរនេះ វិតក្កៈមានសភាពគ្រោតគ្រាត កើតឡើងមុន ហើយជាសភាវៈញ៉ាំងចិត្តឲ្យបានចូលកាន់អារម្មណ៍មុន វិតក្កៈទើបប្រៀបដូចសម្លេងរគាំងគោះដំបូង ចំណែកវិចារៈមានភាពល្អិត កើតតាមក្រោយ ជាសភាវៈញ៉ាំងចិត្តឲ្យជាប់ទៅតាមអារម្មណ៍ វិចារៈទើបប្រៀបដូចសម្លេងរំពងរបស់រគាំង ។

**អធិមោក្ខ** ( ការជឿស៊ប់ ) គឺការចុះស៊ប់ ពោលគឺភាវៈនៃចិត្តចុះស៊ប់ មិនស្ទាក់ស្ទើរ ក្នុងអារម្មណ៍ដែលប្រព្រឹត្តទៅ ថាជាយ៉ាងនេះ ឬ ក៏ជាយ៉ាងនោះឡើយ ដូចសាធកៈ ( ក្នុងគម្ពីរអដ្ឋកថា ) ថាៈ

**សោ អារម្មណេ សន្និដ្ឋានលក្ខណោតិ ច អារម្មណេ និច្ចលភាវេនឥន្ទខីលសទិសោតិ ច ។**

ប្រែថា “ អធិមោក្ខមានលក្ខណៈចុះស៊ប់ក្នុងអារម្មណ៍ ដូចសសរខឿនព្រោះរឹងមាំក្នុងអារម្មណ៍ ” ។

**វិរិយ** ( ការព្យាយាម ) គឺ ភាពអង្គអាចក្នុងការងារ ឬ កិរិយារបស់អ្នកអង្គអាចក្នុងការងារ ។ ការពិតបុគ្គលដែលប្រកបដោយវិរិយៈ ជាអ្នកអាចហ៊ានក្នុងការងារ រមែងសម្គាល់ការងារសូម្បីធំក៏ថាតូច សូម្បីលំបាកក៏ថាងាយ សូម្បីធ្ងន់ក៏ថាស្រាល មិនគិតដល់សេចក្ដីលំបាករបស់ខ្លួន ផ្គត់ផ្គង់កាយ និង ចិត្តឲ្យស្មើ ដើម្បីឲ្យការងារសម្រេចចប់ចុះទៅបាន វិរិយៈទើបធ្វើឲ្យបុគ្គលប្រព្រឹត្តទៅយ៉ាងនោះ និងជាកិរិយាតាមផ្លូវកាយ និង ចិត្តរបស់បុគ្គលអ្នកមានលក្ខណៈដូចនេះ ។

ន័យម្យ៉ាងទៀត **វិរិយ** គឺសភាវៈគប្បីឲ្យកើតឡើងដោយវិធី គឺន័យពោលគឺ ឧបាយ បានដល់ ការក្រវើនក្រតើនជាខាងដើមថា **វិរិយវតោ កឹ នាម កម្មំ ម សិជ្ឈតីតិ អាទិកេន** “ អ្នកមានវិរិយៈធ្វើកម្មមិនសម្រេចឬ ? ” ជាដើម ។

ន័យម្យ៉ាងទៀត **វីរិយ** គឺ សភាវៈធ្វើឲ្យបុគ្គលអ្នកដល់ព្រមដោយវីរិយនោះ ខ្ពស់ខ្ពាយជាពិសេស ដោយមានប្រយោជន៍ខ្លួនឯង និង អ្នកដទៃជាហេតុ ។

[ ពាក្យថា **វីរិយ** មានសេចក្តី ៤ ប្រការគឺ ៖

- ភាពអង់អាចក្នុងការងារ = **វីរស្ស ភាវោ** > **វីរិយំ** ( **វីរ** ស័ព្ទ + **ណ្យ** បច្ច័យ ក្នុងភាវតទ្ធិត )

-កិរិយារបស់អ្នកអង់អាចក្នុងការងារ = **វីរស្ស កម្មំ** > **វីរិយំ** ( **វីរ** ស័ព្ទ + **ណ្យ** បច្ច័យក្នុងកម្មតទ្ធិត )

-សភាវៈគប្បីឲ្យកើតឡើងដោយវិធី = **វិធិនា ឦរយិតព្វំ បវត្តយិតព្វន្តិ** > **វីរិយំ** (**វិធិ** បុព្វបទ + **ឦរ** ធាតុ + **ណ្យ** បច្ច័យ ទីឃៈ **ឥ** ក្នុង **វិ** ជា **ឦ** )។

-សភាវៈធ្វើឲ្យខ្ពស់ខ្ពាយជាពិសេស = **វិសេសេន ឦរន្តិ កម្បន្តិ តំសមង្គិនោ ឯតេនាតិ** > **វីរិយំ** ( **វិ** បុព្វបទ + **ឦរ** ធាតុ + **ណ្យ** បច្ច័យ ក្នុងករណសាធណ ) ] ។

ម្យ៉ាងទៀត សម្បយុត្តធម៌ដែលវីរិយឧបត្ថម្ភ រមែងមិនបោះបង់នូវកិច្ចការដែលខ្លួនគប្បីធ្វើ ( ក្នុងអារម្មណ៍ ) តែងកើតឡើងនូវភាពឧស្សាហ៍ជានិច្ចដើម្បីសេចក្តីសម្រេចកិច្ចរបស់ខ្លួន និង ដើម្បីសម្រេចកិច្ចក្នុងសម្បយុត្តធម៌ដូចដែលបានពោលមកហើយនោះ ។ បុគ្គលដែលដល់ព្រមដោយសម្បយុត្តធម៌ក៏មានកាយ និង ចិត្តដែលខ្ពស់ខ្ពាយជានិច្ច ព្រោះមានប្រយោជន៍ទំនុកបម្រុងខ្លួន ឬ អ្នកដទៃជាហេតុ ខ្ញុំព្រះករុណា ( ព្រះដីកាចារ្យ ) ទើបពោល “ ឈ្មោះថា **វីរិយ**ព្រោះធ្វើឲ្យអ្នកដល់ព្រមដោយវីរិយៈនោះ ខ្ពស់ខ្ពាយ ( ជាពិសេស ) ” ដូចសាធកៈ ( ក្នុងគម្ពីរអដ្ឋកថា ) ថាៈ

**តំ ឧបត្ថម្ភនលក្ខណន្តិ ច បគ្គហលក្ខណន្តិ ច ឧស្សាហលក្ខណន្តិ ច គេហស្ស ថូណូបត្ថម្ភនសទិសន្តិ ច សម្មា អារទ្ធំ សព្វសម្បត្តីនំ មូលំ**

ប្រែថា “វីរិយៈ មានលក្ខណៈឧបត្ថម្ភ, មានលក្ខណៈលើកតម្កើង, មានលក្ខណពុះពារ, ប្រៀបដូចគេយកសសរមកបន្ថែម ដើម្បីជួយទល់ផ្ទះចាស់មិនឲ្យរលំ ឬ បាក់បែក យ៉ាងណាមិញ សម្បយុត្តធម៌ទាំងឡាយ មិនរាថយ

មិនលើកលែងក្នុងកិច្ចការរបស់ខ្លួន ដែលគប្បីធ្វើក្នុងអារម្មណ៍ ក៏ព្រោះមានវីរិ-យៈឧបត្ថម្ភគាំទ្រ ក៏យ៉ាងនោះដែរ, ការប្រារព្ធដោយល្អ រមែងជាមូលហេតុនៃសម្បត្តិទាំងអស់ ”។

**បីតិ** គឺសភាវៈធ្វើកាយ និង ចិត្តឲ្យឆ្អែត គឺឲ្យកើតការរីករាយចិត្ត ។

ន័យម្យ៉ាងទៀត **បីតិ** គឺសភាវៈធ្វើការរីករាយឲ្យចម្រើន ដូចផ្កាបទុមដែលរីកល្អហើយ ។

ន័យម្យ៉ាងទៀត **បីតិ** គឺ សភាវៈធ្វើឲ្យបុគ្គលអ្នកដល់ព្រមដោយបីតិរុងរឿង គឺមានកាយ និង ចិត្តរុងរឿង ដូចព្រះច័ន្ទពេញវង់ ។

[ ពាក្យថា **បីតិ** មានសេចក្ដី ៣ ប្រការ គឺ ៖

-សភាវៈធ្វើកាយ និងចិត្តឲ្យឆ្អែត = **បិណយតិ កាយចិត្តំ តប្បេតីតិ** > **បីតិ** ( **បី** ធាតុ = ឆ្អែត + **ណេ** ការិតបច្ច័យ + **តិ** បច្ច័យក្នុងហេតុកត្តុសាធនៈ ) ។

-សភាវៈធ្វើការរីករាយឲ្យចម្រើន = **បិណយតិ វឌ្ឍេតីតិ** > **បីតិ** ( **បី** ធាតុ = ចម្រើន + **ណេ** ការិតបច្ច័យ + **តិ** បច្ច័យក្នុងហេតុកត្តុសាធនៈ ) ។

-សភាវៈធ្វើឲ្យបុគ្គលរុងរឿង = **បិណន្តិ ឯតាយាតិ** > **បីតិ** ( **បី** ធាតុ = រុងរឿង + **តិ** បច្ច័យ ក្នុងករណសាធនៈ ) ] ។

## បីតិមាន ៥ ប្រភេទតាមលំដាប់របស់កម្លាំង គឺ ៖

**ក) ខុទ្ទកាបីតិ** បីតិតូចតាច កើតឡើងម្ដងម្កាលហើយរលត់ទៅ ធ្វើឲ្យកើតអាការព្រឺរោម ។

**ខ) ខណិកាបីតិ** បីតិមួយរយៈតូច កើតឡើងច្រើនដង តាំងពី ២ ខណៈឡើងទៅ តែកើតមិនយូរ ដូចការកើតឡើងនៃផ្លេកបន្ទោរ ។

**គ) ឱក្កន្តិកាបីតិ** បីតិជ្រួតជ្រាប កើតឡើងតជាប់គ្នា ធ្វើឲ្យដឹងខ្លួនថា នៅក្នុងក្រសែរលកទឹកឬមានចរន្តអគ្គិសនីរត់ទៅក្នុងរាងកាយ ។

**ឃ) ឧព្វេង្គាបីតិ** បីតិលោតហោះ កាលបើកើតឡើងធ្វើឲ្យរាងកាយអណ្តែត ឬ ដឹងខ្លួនថា ហោះឡើងទៅឰដ៏អាកាស ។

**ង) ផរណាបីតិ** បីតិផ្សាយទៅ កាលបើកើតឡើងហើយ មានសភាពត្រជាក់ ផ្សាយចេញទៅសព្វសព៌ាង្គកាយ ។

ដូចដែលបានដឹងថា ព្រះមហាតិស្សត្ថេរ អ្នកគង់នៅក្នុងបុណ្ណវល្លិកវិហារ បានទៅកាន់លានព្រះចេតិយវេលាល្ងាច លុះពេលព្រលប់បានឃើញពន្លឺព្រះចន្ទក្នុងថ្ងៃពេញបូរមី ទើបបែរមុខទៅមហាចេតិយ៍ហើយរំពឹងគិតថា ក្នុងវេលាស្មើនេះ ពួកបរិស័ទទាំង ៤ កំពុងក្រាបថ្វាយបង្គំព្រមគ្នាហើយហ្ន៎! ឧព្វេង្គាបីតិ ដែលមានព្រះពុទ្ធរូបជាអារម្មណ៍ឲ្យកើតឡើង ដោយសារអារម្មណ៍ដែលបានឃើញតាមប្រក្រតី ហើយបានអណ្តែតខ្លួនឡើងទៅឰដ៏អាកាស បានឈរនៅទីព្រះលានមហាចេតិយនោះឯង ។

រឿងមួយទៀត សូម្បីកុលធីតាម្នាក់ នៅក្នុងភូមិវត្តកាលកៈ ដែលជាទីគោចររបស់អ្នកទៅកាន់គិរិកណ្ឌកវិហារ បានអណ្តែតខ្លួនទៅឰដ៏អាកាស ដោយឧព្វេង្គាបីតិ ដោយមានគុណព្រះពុទ្ធដ៏មានកម្លាំងជាអារម្មណ៍ ដូចបានឮមកថា មាតាបិតារបស់កុលធីតានោះ ត្រូវធ្វើដំណើរទៅព្រះវិហារ ដើម្បីនឹងបានស្តាប់ធម៌ក្នុងពេលព្រលប់ បានប្រាប់ថា ម្នាលកូនស្រី កូនមានគភ៌ចាស់ហើយ មិនអាចនឹងដើរទៅក្នុងពេលដែលមិនសមគួរនោះទេ ម៉ែ និង ពុកឯងទៅស្តាប់ធម៌ណាំ! ពេលត្រឡប់មកវិញនឹងចែកបុណ្យដល់កូន ។

នាងកុលធីតាសូម្បីចង់ទៅយ៉ាងណាក៏ដោយ ក៏ពុំអាចជំទាស់នឹងពាក្យរបស់មាតាបិតាបាន ទើបរង់ចាំនៅឯផ្ទះ បានទៅឈរនៅមាត់ទ្វារផ្ទះ បានក្រលេកមើលព្រះចេតិយ ដែលនៅលើភ្នំគិរិកណ្ឌកវិហារដោយពន្លឺព្រះចន្ទ បានឃើញការបូជាដួងប្រទីបនៅព្រះចេតិយ និងបានឃើញបរិស័ទទាំង ៤ ធ្វើការបូជាព្រះចេតិយដោយវត្ថុទាំងឡាយ មានផ្កានិងគ្រឿងក្រអូបជាដើម ហើយធ្វើការប្រទក្សិណ ថែមទាំងបានស្តាប់សម្លេងស្វាធ្យាយព្រះធម៌ជាគណៈរបស់ព្រះសង្ឃ ។

លំដាប់នោះនាងបានគិតយ៉ាងនេះថា “ ឱ! អ្នកទាំងនោះមានបុណ្យ បាននាំគ្នាទៅកាន់គិរិកណ្ឌកវិហារ បានប្រទក្សិណទីលានព្រះចេតិយ និង បានស្ដាប់ធម្មកថាដ៏ពិរោះយ៉ាងនេះ ” ខណៈកំពុងសម្លឹងមើលព្រះចេតិយដូច កែវមុក្ដានោះឯង ឧព្វេង្គាបីតិក៏កើតឡើង នាងបានអណ្ដែតទៅឰដ៏អាកាស ហើយចុះមកទីលានព្រះចេតិយ មុនមាតាបិតារបស់នាងដែលបានទៅដល់ ហើយបានថ្វាយបង្គំព្រះចេតិយ៍ ឈរស្ដាប់ព្រះធម៌ទីនោះ ។

ពេលនោះមាតាបិតារបស់នាងក៏បានមកដល់ ហើយសួរនាងថា “ នែ កូនស្រី កូនមកតាមផ្លូវណា ? ” នាងក៏បានឆ្លើយតបវិញថា “ បពិត្រមាតា កូនបានមកតាមផ្លូវអាកាស មិនបានមកតាមផ្លូវថ្មើរជើងទេ ” មាតាបិតារបស់ នាងបានពោលថា “ នែកូនធម្មតាព្រះខីណាស្រពទាំងឡាយ ទើបធ្វើដំណើរ តាមផ្លូវអាកាសបាន ម្ដេចក៏កូនពោលយ៉ាងនេះ ” នាងតបថា “ កាលបើខ្ញុំ ឈរសម្លឹងព្រះចេតិយ៍ព្រមដោយពន្លឺព្រះចន្ទ បីតិមានកម្លាំងដោយប្រារព្ធព្រះ ពុទ្ធគុណជាអារម្មណ៍ក៏កើតឡើងក្នុងខណៈនោះ ខ្ញុំពុំបានជ្រាបថា ខ្លួនខ្ញុំឈរ ឬ អង្គុយ ហើយអណ្ដែតទៅឰដ៏អាកាសដោយកាន់យកនូវនិមិត្តនោះឯង ហើយបានមកឈរនៅទីលានព្រះចេតិយនេះឯង ” ឧព្វេង្គាបីតិធ្វើឲ្យអណ្ដែត ទៅឰដ៏អាកាសយ៉ាងនេះឯង ។

ម្យ៉ាងទៀត បីតិទាំង ៥ យ៉ាងនេះកាលបើតាំងគភ៌ចាស់ក្លាហើយ រមែង ញ៉ាំងបស្សទ្ធិ ២ យ៉ាងគឺៈ កាយបស្សទ្ធិ និង ចិត្តបស្សទ្ធិឲ្យបរិបូរ ។

បស្សទ្ធិ កាលបើតាំងគភ៌ចាស់ក្លាហើយ រមែងញ៉ាំងសុខពីរយ៉ាង គឺៈ កាយិកសុខ និង ចេតសិកសុខឲ្យបរិបូរ ។

សេចក្ដីសុខ កាលបើតាំងគភ៌ចាស់ក្លាហើយ រមែងញ៉ាំងសមាធិ ៣ យ៉ាងគឺៈ ខណិកសមាធិ ឧបចារសមាធិ និង អប្បនាសមាធិឲ្យបរិបូរ ។

បណ្ដា **បីតិ** ទាំងនោះ បីតិពីរយ៉ាងដទៃ វៀរបីតិដែលញ៉ាំងអប្បនាសមាធិ ឲ្យបរិបូណ៌ រមែងគួរក្នុងរឿងកាមាវចរកុសលនេះ ។

**ឆន្ទ** គឺ សេចក្ដីប្រាថ្នា ពោលគឺ សេចក្ដីត្រូវការ បំណង សេចក្ដីប្រាថ្នា ។

**ឆន្ទៈ** មាន ២ ប្រភេទ គឺៈ **តណ្ហាឆន្ទ** ( សេចក្តីប្រាថ្នា គឺ ចំណង់ ) និង **កត្តុកម្យតាឆន្ទ** សេចក្តីប្រាថ្នា ( គឺសេចក្តីត្រូវការដើម្បីធ្វើ ) ក្នុងទីនេះសំដៅយក **កត្តុកម្យតាឆន្ទ** ។

ពាក្យថា **កត្តុកាម** គឺ អ្នកប្រាថ្នា សំដៅដល់ អ្នកដល់ព្រមដោយសេចក្តីប្រាថ្នា ។

ពាក្យថា **កត្តុកម្យ** គឺ ភាវនៃអ្នកប្រាថ្នា ។

ពាក្យថា **កត្តុកម្យតា** គឺ ភាវនៃអ្នកប្រាថ្នានោះឯង ដូចពាក្យថា **ទេវតា** គឺ ទេពនោះឯង ( ដោយចុះ**តា**បច្ច័យ ក្នុងអត្ថសកត្ថដែលមិនមានសេចក្តីណាៗ )។

ពាក្យថា **កត្តុ** ក្នុងបទនេះថា **កត្តុកម្យតា** ប្រមូលអត្ថរបស់ស័ព្ទធាតុទុកទាំងអស់ ពាក្យថា **កត្តុកម្យតា** នេះ ទើបរួបរួមបទកិរិយាទាំងអស់ ដោយន័យថាៈ

**កថេតុកម្យតា** ( សេចក្តីប្រាថ្នាដើម្បីនិយាយ ) ។

**ចិន្តេតុកម្យតា** ( សេចក្តីប្រាថ្នាដើម្បីគិត ) ។

**ទដ្ឋុកម្យតា** ( សេចក្តីប្រាថ្នាដើម្បីឃើញ ) ។

**សោតុកម្យតា** ( សេចក្តីប្រាថ្នាដើម្បីស្តាប់ ) ជាដើម ។

**ឆន្ទៈ** សូម្បីជាសេចក្តីប្រាថ្នាអារម្មណ៍ ក៏មិនបានប្រាថ្នាដោយសេចក្តីភ្លើតភ្លើន ត្រេកត្រអាល សេចក្តីប្រតិព័ទ្ធ តែប្រាថ្នាដោយត្រូវការនឹងឲ្យសម្រេចប្រយោជន៍ៗដែលខ្លួនប្រាថ្នា ប្រៀបដូចនាយខ្មាន់ធ្នូរបស់ព្រះរាជាអ្នកត្រូវការទ្រព្យ ឬ កិត្តិយស ប្រាថ្នាព្រួញចំនួនច្រើន ដែលគួរបាញ់ទៅរកសត្រូវ យ៉ាងណាមិញ ឆន្ទៈក៏មានឧបមេយ្យយ៉ាងនោះដែរ រមែងប្រាថ្នានឹងបានទទួលវត្ថុដែលជាទាន ដែលគួរលះឲ្យដល់អ្នកដទៃ ឬ អ្នកដែលនៅមិនទាន់បានទទួល ហើយប្រាថ្នានឹងរក្សាវត្ថុដែលខ្លួនបានទទួលហើយ ។

តាមធម្មតាកាលបើឆន្ទៈមានកម្លាំងច្រើន រមែងមានកម្លាំងច្រើនជាងតណ្ហា ការពិតឆន្ទៈជា**អធិបតី** ( ធម៌ដែលជាធំ ) និង **ឥទ្ធិបាទ** ( ទីតាំងនៃការសម្រេច ) តែបើនៅពេលណាឆន្ទៈមានកម្លាំងស្មើនឹងតណ្ហា ពួកសត្វត្រូវធ្លាក់ក្នុងអំណាចតណ្ហា បើត្រូវតណ្ហាគ្របសង្កត់ហើយ ក៏មិនអាចលះបង់ទ្រព្យសម្បត្តិ សេចក្ដីសុខក្នុងរាជសម្បត្តិ ឬ សម្បត្តិក្នុងទេវលោក និងព្រហ្មលោក ដើម្បីចេញចាកទុក្ខក្នុងវដ្ដៈបាន ។

ពាក្យថា **បកិណ្ណ** គឺ ចេតសិកដែលរាត់រាយក្នុងសោភណចិត្ត និង អសោភណចិត្ត

**បកិណ្ណក** គឺ ចេតសិកដែលរាត់រាយន៉ុះៗឯង ( ដោយចុះ **ក** បច្ច័យ ក្នុងអត្ថសកត្ថ ដែលមិនមានសេចក្ដីណាៗ ) ។

**[៤] ឯវមិមេ តេរស ចេតសិកា អញ្ញសមានាតិ វេទិតព្វា ។**

ប្រែថា “គប្បីជ្រាបថា ចេតសិក ១៣ ដូងពួកនេះ ឈ្មោះថា អញ្ញសមានាចេតសិក” ។

**អញ្ញសមាន** គឺចេតសិកដែលជាពួកតែមួយជាមួយនឹងចិត្តដទៃ ។

ន័យម្យ៉ាងទៀត **អញ្ញសមាន** គឺចេតសិកដែលជាពួកតែមួយដល់ចិត្តដ៏ទៃ ។

[ ពាក្យថា **អញ្ញសមានា** មានសេចក្ដី ២ ប្រការគឺ ៖

-ចេតសិកដែលជាពួកតែមួយជាមួយនឹងចិត្តដទៃ = **អញ្ញេហិ សមានា** > **អញ្ញសមានា** ( តតិយាតប្បុរិសសមាស ) ។

-ចេតសិកដែលជាពួកតែមួយដល់ចិត្តដទៃ = **អញ្ញេសំ សមានា** > **អញ្ញសមានា** ( ចតុត្ថីតប្បុរិសសមាស ) ] ។

បានសេចក្ដីថា ចេតសិកទាំងនេះ កាលបើប្រកបជាមួយសោភណចិត្តក្នុងកាលណា ក្នុងកាលនោះ ក៏មែងជាពួកតែមួយជាមួយគ្នានឹងសោភណចិត្ត

វៀរអសោភណចិត្តក្នុងកាលនោះ ។ តែបើប្រកបជាមួយអសោភណចិត្តក្នុងកាលណា ក្នុងកាលនោះ ក៏រមែងជាពួកតែមួយជាមួយគ្នានឹងអសោភណចិត្ត ។

**ចប់ការសម្តែងសេចក្តីបរមត្ថក្នុងអញ្ញសមានារាសី**

# អកុសលចេតសិក ១៤ ដួង

**[៥] មោហោ អហិរិកំ អនោត្តប្បំ ឧទ្ធច្ចំ លោភោ ទិដ្ឋិ មានោ ទោសោ ឥស្សា មច្ឆរិយំ កុក្កុច្ចំ ថិនំ មិទ្ធំ វិចិកិច្ឆា ចេតិ ចុទ្ទសិមេ ចេតសិកា អកុសលា នាម ។**

ប្រែថា “ ចេតសិក ១៤ ដួង ពួកនេះគឺ៖ **មោហៈ** ( ការវង្វេង ) **អហិរិក** ( ការមិនខ្មាស់បាប ) **អនោត្តប្ប** ( ការមិនតក់ស្លុតអំពីផលរបស់បាប ) **ឧទ្ធច្ច** ( ការរវើរវាយ ) **លោភៈ** ( ការជាប់ជំពាក់ ) **ទិដ្ឋិ** ( ការយល់ខុស ) **មានះ** ( ការលើកតម្កើងខ្លួន ) **ទោសៈ** ( ការថ្នាំងថ្នាក់ ) **ឥស្សា** ( ការច្រណែន ) **មច្ឆរិយ** ( ការកំណាញ់ ) **កុក្កុច្ច** ( ការក្តៅក្រហាយ ) **ថីន** ( ការងងុយងោកងក់ ) **មិទ្ធ** ( ការរួញរា ) និង **វិចិកិច្ឆា** ( ការសង្ស័យ ) ឈ្មោះថា **អកុសលចេតសិក** ” ។

[ អកុសលចេតសិក ១៤ ដួងនេះ ចែកចេញជា ៥ ក្រុមគឺ៖

-**មោចតុក្កៈ** ក្រុមចេតសិក ៤ ដួង ដែលមានមោហៈនៅខាងដើមគឺ មោហៈ អហិរិកៈ អនោតប្បៈ ឧទ្ធច្ចៈ។

-**លោតិកៈ** ក្រុមចេតសិក ៣ ដួង ដែលមានលោភនៅខាងដើម គឺ៖ លោភៈ ទិដ្ឋិ មានៈ

-**ទោចតុក្កៈ** ក្រុមចេតសិក ៤ ដួង ដែលមានទោសនៅខាងដើម គឺ៖ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ ។

-**ថីទុកៈ** ក្រុមចេតសិក ២ ដួង ដែលមានថីននៅខាងដើម គឺ៖ ថីនៈ មិទ្ធៈ ។

-**វិចិកិច្ឆា** គឺ វិចិកិច្ឆាចេតសិក ] ។

# អធិប្បាយអកុសលរាសី

ឥឡូវនេះ ព្រះអនុរុទ្ធាចារ្យនឹងសម្តែងអកុសលរាសី ទើបពោល **មោហៈ** ( ការវង្វេង ) ជាដើម ។

ក្នុងប្រយោគនោះ **មោហៈ** ( ការវង្វេង ) គឺ សភាវៈវង្វេង ។

ន័យម្យ៉ាងទៀត **មោហៈ** គឺ សភាវៈធ្វើឲ្យពពួកសត្វវង្វេង ។

ន័យម្យ៉ាងទៀត **មោហៈ** គឺការវង្វេង បានសេចក្តីថា ការធ្វើចិត្តឲ្យងងឹតខ្វាក់ ដោយបិទបាំងនូវសេចក្តីល្អទុកទាំងអស់ ប្រៀបដូចការងងឹតប្រកបដោយអង្គ ៤ គឺ៖

**១**- ថ្ងៃ ១៤ រោច ។

**២**- ពាក់កណ្តាលអធ្រាត្រ ។

**៣**- ព្រៃស្តុក ។

**៤**- ពពកខ្មៅបាំងព្រះច័ន្ទ ។ បានធ្វើសេចក្តីងងឹតដល់ចក្ខុ ។

[ ពាក្យថា **មោហៈ** មានសេចក្តី ៣ ប្រការគឺ ៖

-សភាវៈវង្វេង = **មុយ្ហតីតិ** > **មោហោ** ( ចុះ **ណ** បច្ច័យក្នុងកត្តុសាធនៈ )

-សភាវៈធ្វើឲ្យពពួកសត្វវង្វេង = **មុយ្ហន្តិ សត្តា ឯតេនាតិ** > **មោហោ** ( ចុះ **ណ** បច្ច័យក្នុងករណសាធនៈ ) ។

-សេចក្តីវង្វេង = **មុយ្ហនំ** > **មោហោ** ( ចុះ **ណ** បច្ច័យក្នុងភាវសាធនៈ ) ]

**មោហៈ** នេះព្រះអង្គទ្រង់ត្រាស់ទុកក្នុងព្រះបាលីថា **មិច្ឆាញាណ** ( ការដឹងខុស ) ២៦, **និងក្នុងគម្ពីរអដ្ឋកថាលោកពោលថា:**

**មិច្ឆាញាណន្តិ បាបកិរិយាសុ ឧបាយចិន្តាវសេន បវត្តោ មោហោ**

ប្រែថា " **មិច្ឆាញាណ** គឺ មោហៈដែលប្រព្រឹត្តទៅដោយការរិះគិតរកឧបាយក្នុងការធ្វើបាប " ។

សូម្បីព្រះអដ្ឋកថាចារ្យ ក៏បានពោលថា **អវិជ្ជា** មាន ២ យ៉ាង ដោយចែកជាការមិនបដិបត្តិ និង ការបដិបត្តិខុស ។

**ការមិនបដិបត្តិ** គឺ ការមិនដឹងក្នុងផ្នែកល្អ ។

**ការបដិបត្តិខុស** គឺ មិច្ឆាញាណក្នុងផ្នែកបាប ។

កាលបើពោលដល់ផ្នែកបាប សភាវៈ ៥ គឺ មោហៈ លោភៈ ទិដ្ឋិ វិតក្ក និង វិចារៈ ទាំងនេះ មានសភាពហាក់ដូចជាបញ្ញា និងកាលបើរួមជាមួយចិត្ត ផងក៏មាន ៦ យ៉ាង ធម៌ពួកនោះ កាលបើកើតក្នុងបុគ្គលអ្នកមានបញ្ញា ឬ ដល់ព្រមដោយការស្តាប់សិក្សា រមែងញ៉ាំងគេឲ្យសម្រេចផលជាអ្នកឆ្លាត និង អាចក្នុងការធ្វើបាប ដោយការគិតរកឧបាយនោះៗ ក្នុងការធ្វើបាប ។

**អហិរិ** គឺ សភាវៈមិនខ្មាស់ ពោល គឺ មិនស្អប់ខ្ពើមចំពោះកាយទុច្ចរិតជា ដើម ។

ន័យម្យ៉ាងទៀត **អហិរិ** គឺ សភាវៈដែលជាបដិបក្ខចំពោះហិរិ ។

**អហិរិកៈ** ( ការមិនខ្មាស់បាប ) គឺ សភាវៈមិនខ្មាស់នោះនុ៎ះឯង ( ដោយចុះ **ក** បច្ច័យ ក្នុងអត្ថសកត្ថៈដែលមិនមានសេចក្តីណាៗ ) ។

ការពិត **អហិរិកៈ** នៅពេលប្រឈមមុខនឹងការធ្វើបាប រមែងមិនឲ្យ ឱកាសដល់ហិរិ តែធ្វើឲ្យកើតសេចក្តីពេញចិត្តក្នុងការធ្វើបាប សមដូចសាធកៈ ថាៈ

**កាយទុច្ចរិតាទីហិ អជិគុច្ឆនលក្ខណន្តិ ច អលជ្ជាលក្ខណន្តិ ច ។**

ប្រែថា " **អហិរិក** មានលក្ខណៈមិនស្អប់ខ្ពើម មានលក្ខណៈមិនខ្មាស់ ចំពោះកាយទុច្ចរិតជាដើម " ។

**អនោត្តប្បៈ** ( ការមិនតក់ស្លុតចំពោះផលរបស់បាប ) គឺ សភាវៈមិនតក់ស្លុត សំដៅដល់ មិនតក់ស្លុតចំពោះ ( ផលរបស់ ) កាយទុច្ចរិតជាដើម ។

ន័យម្យ៉ាងទៀត **អនោត្តប្បៈ** គឺ សភាវៈដែលបដិបក្ខចំពោះឱត្តប្បៈ ។

ការពិត **អនោត្តប្បៈ** នៅពេលប្រឈមមុខនឹងការធ្វើបាប រមែងមិនឲ្យ ឱកាសដល់ឱត្តប្បៈ ហើយញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅ ដោយការធ្វើចិត្តមិនឲ្យ តក់ស្លុតចំពោះផលរបស់បាប ដូចសាធកៈ ( ក្នុងគម្ពីរអដ្ឋកថា ) ថាៈ

**កាយទុច្ចរិតាទីហិ អសារជ្ជលក្ខណន្តិ ច អនុត្តាសលក្ខណន្តិ ច ។**

ប្រែថា “ មានលក្ខណ:មិនខ្លាចក្រែងកាយទុច្ចរិតជាដើម មានលក្ខណ: មិនតក់ស្លុត ” ។

ម្យ៉ាងទៀត ខ្ញុំព្រះករុណា ( ព្រះដីកាច្ប ) តែងពោលថា:

**អហិរិក:** រមែងមិនខ្មាស់បាបជាប្រក្រតី ដូចសូករ ( ជ្រូក ) មិនខ្មាស់លាមក ចំណែក **អនោត្តប្ប:** រមែងមិនខ្លាចក្រែង ដូចមមាចមិនខ្លាចភ្លើង ។

ពាក្យថា **ឧទ្ធដ:** គឺ សភាវ:ងាករេ បានដល់ ចិត្តដែលងាករេទៅក្នុងអារម្មណ៍ផ្សេងៗ ដូចកូនរូបោះទៅហើយវិលទៅលើផ្ទៃថ្ម ។

**ឧទ្ធច្ច:** ( ការរវើរវាយ ) គឺ សភាវ:ធ្វើឲ្យចិត្តងាករេ ប្រព្រឹត្តទៅដោយអាការ:ងាករេ គប្បីជ្រាប ដូចទឹក ទង់ជ័យ និង ទង់ផ្ទាំងសំពត់ដែលត្រូវខ្យល់បក់ផាត់ទៅមក ។

**លោភ:** ( សេចក្ដីលោភ: ) គឺសភាវ:ចង់បាន ។

ន័យម្យ៉ាងទៀត **លោភ** គឺសភាវ:ធ្វើឲ្យសម្បយុត្តធមិចង់បាន ។

ន័យម្យ៉ាងទៀត **លោភ** គឺ សេចក្ដីចង់បាន ។

[ ពាក្យថា **លោភ** មានសេចក្ដី ៣ ប្រការគឺ ៖

-សភាវ:ចង់បាន = **លុព្ភតីតិ** > **លោភោ** ( ចុះ **ណ** បច្ច័យក្នុងកត្តុសាធន: ) ។

-សភាវ:ធ្វើឲ្យសម្បយុត្តធមិចង់បាន = **លុព្ភន្តិ សម្បយុត្តា ធម្មា ឯតេនាតិ** > **លោភោ** ( ចុះ **ណ** បច្ច័យក្នុងករណសាធន: ) ។

-សេចក្ដីចង់បាន = **លុព្ភនំ** > **លោភោ** ( ចុះ **ណ** បច្ច័យក្នុងភាវសាធន: ) ] ។

**ឯត្ថ ច លុព្ភនំ នាម អារម្មណាភិសជ្ជនំ ទដ្ឋព្វំ ។ សោ បន អារម្មណេ លគ្គនដ្ឋេ-មក្កដាលេបោ វិយ អភិកង្ខដ្ឋេន តត្តកបាលេ ខិត្តមំសបេសិ វិយ អបរិចាកដ្ឋេន តេលព្ជនរា-គោ វិយ តណ្ហានទិភាវេន វឌ្ឍិត្វា សត្តានំ អបាយាវហដ្ឋេន សព្វានិ សុក្ខកដ្ឋសាខាបលា-សតិណកសដានិ មហាសមុទ្ទំ វហន្តី សីឃសោតា នទី វិយ ទដ្ឋព្វោ ។**

ប្រែថា លោភ:មានការជាប់ជំពាក់ក្នុងអារម្មណ៍ លោភ:ដូចតាំងដែលលាបជ័រ ដែលស្វាបានចាប់ទុក ព្រោះជាសភាវ:ជាប់ជំពាក់ក្នុងអារម្មណ៍ ។

ដូចដុំសាច់ដាក់ទៅក្នុងខ្ទះក្តៅ ព្រោះសភាវៈជាប់នឹងខ្ទះ។ ដូចសំពត់ប្រឡាក់ប្រេង ជាសភាវៈលាងមិនចេញ ។ ដូចស្ទឹងដែលមានក្រសែទឹកហូរគួចយកនូវសម្រាម គឺ កំណាត់ឈើ មែកឈើ ស្លឹកឈើ និង ស្មៅស្ងួតទាំងអស់ទៅកាន់មហាសមុទ្រ ព្រោះជាសភាវៈមិនឆ្អែត ក្លាយទៅជាស្ទឹងតណ្ហា ដែលផាត់នាំទៅកាន់អបាយ ។

**ទិដ្ឋិ** គឺ ការយល់ខុស បានដល់ ការយល់ខុសក្នុងធម៌ទាំងនោះ ក្នុងសភាវៈដែលមិនមានពិត ផ្ទុយពីបញ្ញាដែលដឹងធម៌ក្នុងសភាវៈពិត ។

ទិដ្ឋិកាលបើកើតឡើងដល់បុគ្គលអ្នកសម្គាល់ខ្លួនថាជាបណ្ឌិត មានមិច្ឆាវិតក្កៈច្រើន រមែងមានកម្លាំងខ្លាំង មានលក្ខណៈហាក់ដូចបដិវេធញ្ញាណ ក្នុងផ្នែកមិនពិត ។

**មិច្ឆាភិនិវេសលក្ខណា បរមំ វជ្ជំ** ។ **ទិដ្ឋិ** មានលក្ខណៈយល់ខុស គប្បីជ្រាបថា មានទោសច្រើន ។

**ទិដ្ឋិគតៈ** គឺ ការយល់ដែលប្រព្រឹត្តទៅក្នុងទិដ្ឋិទាំងឡាយ ព្រោះរាប់ចូលក្នុងទិដ្ឋិ ៦២ សេចក្តីនៃទិដ្ឋិនេះបានពោលទុកក្នុងព្រហ្មជាលសូត្រ ។

ពាក្យថា **ទិដ្ឋិគហណៈ** ( ព្រៃស្តុក គឺ ទិដ្ឋិ ) បានដល់ ទិដ្ឋិនោះ ឯង ព្រោះជាវត្ថុដែលកន្លងផុតទៅបានដោយលំបាក ដូចស្មៅស្តុក ព្រៃស្តុក ភ្នំស្តុក ។

ពាក្យថា **ទិដ្ឋិកន្តារៈ** ( កន្តារ គឺ ទិដ្ឋិ ) បានដល់ ទិដ្ឋិនោះឯង ព្រោះជាវត្ថុដែលគួររវាំង និង មានភ័យចំពោះមុខ ដូចចោរកន្តារ ( ផ្លូវលំបាកព្រោះចោរ ) កន្តារសត្វកាច ( ផ្លូវលំបាកព្រោះសត្វកាច ) កន្តារខ្សាច់ ( ផ្លូវលំបាកព្រោះវាលខ្សាច់ ) កន្តារទឹក ( ផ្លូវលំបាកព្រោះទឹក ) កន្តារទុព្ភិក្ខភ័យ ( ភ័យព្រោះអត់អាហារ )។

ឈ្មោះថា **ទិដ្ឋិវិសូកាយិកៈ** ( ការយល់ជាសត្រូវដល់សម្មាទិដ្ឋិ ) ព្រោះជាវត្ថុដែលទម្លាយ និង ជំទាស់ជាមួយសម្មាទិដ្ឋិ ដោយពិតហើយ ការយល់ខុសកើតឡើងរមែងទម្លាយនិង ជំទាស់ជាមួយសម្មាទិដ្ឋិ ។

ពាក្យថា **ទិដ្ឋិវិប្ផន្ទិតៈ** ( ការប្រែប្រួលនៃទិដ្ឋិ ) គឺការប្រែប្រួលខុសនៃទិដ្ឋិ ព្រោះពេលខ្លះក៏កាន់យកនូវសភាពទៀង ពេលខ្លះក៏កាន់យកសភាពសូន្យ ដោយពិតហើយ អ្នកមានការយល់ខុស ច្រើនតាំងនៅក្នុងការយល់តែម្យ៉ាងមិនបាន ពេលខ្លះក៏ស្របតាមសភាពទៀង ពេលខ្លះក៏ស្របតាមសភាពសូន្យ ។

ពាក្យថា **ទិដ្ឋិសំយោជនៈ** បានដល់ ទិដ្ឋិ គឺ សំយោជន ព្រោះជាគ្រឿងចង។

ពាក្យថា **គាហៈ** ( សេចក្តីប្រកាន់ ) គឺ សភាវៈប្រកាន់អារម្មណ៍ទុកយ៉ាងមាំ ដូចក្រពើជាដើម ខាំមនុស្សទុកយ៉ាងមាំ ។

ឈ្មោះថា **បតិដ្ឋាហៈ** ( សភាពតាំងមាំ ) ព្រោះតាំងទុកដោយចំពោះ ដោយពិតហើយ ការតាំងមាំនេះ រមែងប្រកាន់ទុកដោយតាំងមាំ ដោយការប្រព្រឹត្តិទៅយ៉ាងមានកម្លាំង ។

ពាក្យថា **អភិនិវេសៈ** ( ការប្រកាន់មាំ ) គឺ សភាវៈប្រកាន់មាំ ដោយសភាពជារបស់ទៀងជាដើម ។

ពាក្យថា **បរាមាសៈ** ( ការចាប់ប្រកាន់ខុស ) គឺសភាវៈដែលកន្លងផុតពីសភាវធម៌ ហើយកាន់យកដោយប្រការដទៃ ដោយសភាពទៀងជាដើម ។

ពាក្យថា **កុម្មគ្គៈ** ( ផ្លូវអាក្រក់ ) គឺ ផ្លូវដែលគួរស្អប់ខ្ពើម ព្រោះនាំការវិនាសមកឲ្យ ឬ ជាផ្លូវនៃអបាយដែលបណ្ឌិតស្អប់ខ្ពើម ។

ឈ្មោះថា **មិច្ឆាបថៈ** ( ផ្លូវខុស ) ព្រោះជាផ្លូវទៅតាមផ្លូវខុស ( គឺផ្លូវមិនពិត ) ឧបមាដូច អ្នកវង្វេងទិស សូម្បីកាន់យកថាផ្លូវនេះ ជាផ្លូវទីភូមិឯណោះ ក៏មិនញុំាងបុគ្គលនោះឲ្យដល់ភូមិស្រុកនោះបានឡើយ យ៉ាងណាមិញ បុគ្គលអ្នកមានមិច្ឆាទិដ្ឋិ សូម្បីកាន់យកថា នេះជាផ្លូវទៅកាន់សុគតិក៏មិនអាចឲ្យដល់សុគតិភូមិក៏យ៉ាងនោះដែរ ទើបឈ្មោះថា **មិច្ឆាបថៈ** ( ផ្លូវខុស ) ព្រោះតាមផ្លូវមិនពិត ។

**មានះ** ( សភាវៈលើកខ្លួន ) បានសេចក្តីថា លើកតម្កើងខ្លួនយ៉ាងមាំ ។

ពាក្យថា **សេយ្យោហមស្មីតិ មានោ** ( ការប្រកាន់ខ្លួនថាប្រសើរជាងគេ ) គឺមានះដែលកើតឡើងយ៉ាងនេះថា យើងប្រសើរជាងគេ ដោយសេចក្តីខ្ពស់បំផុត ។

ពាក្យថា **សទិសោហមស្មីតិ មានោ** ( ការប្រកាន់ខ្លួនថា យើងស្មើនឹងគេ ) គឺមានះដែលកើតឡើងយ៉ាងនេះថា យើងស្មើនឹងគេ ដោយសេចក្តីថាស្មើគ្នា ។

ពាក្យថា **ហីនោហមស្មីតិ > មានោ** ( ការប្រកាន់ខ្លួនថាយើងអន់ជាងគេ ) គឺមានះដែលកើតឡើងយ៉ាងនេះថាយើងអន់ជាងគេ ដោយសេចក្តីថា ថោកទាបជាងគេ ។

ឈ្មោះថា **មានះ** ( ការប្រកាន់ខ្លួន ) ដោយអំណាចធ្វើសេចក្តីប្រកាន់ខ្លួន ។

ឈ្មោះថា **មញ្ញនា មញ្ញិតត្តំ** ( កិរិយាដែលប្រកាន់ខ្លួន ការប្រកាន់ខ្លួន ) នេះជាការសម្តែងដល់អាការៈ និង សភាវៈ ។

ឈ្មោះថា **ឧណ្ណតិ** ( សភាវៈលើកខ្លួន ) ដោយសេចក្តីថា លើកឡើងទុក

ឈ្មោះថា **ឧណ្ណាមៈ** ( សភាវៈលើកតម្កើងខ្លួន ) ព្រោះជាសភាវៈញុំាងបុគ្គលអ្នកកើតមានះ ឲ្យប៉ោង គឺ លើកឲ្យតែងតាំងឡើង ។

ឈ្មោះថា **ធជៈ** ( សភាវៈដូចទង់ ) ដោយសេចក្តីថា លើកតម្កើងឡើងហើយ ។

ឈ្មោះថា **សម្បគ្គាហៈ** ( សភាវៈលើកចិត្តឡើង ) ព្រោះជាសភាវៈផ្គងចិត្ត ដោយសេចក្តីថា លើកឡើង ។

ទង់ដែលលើកឡើងខ្ពស់ក្នុងចំនួនទង់ច្រើន ហៅថា **កេតុ** ( ទង់ជ័យ ) សូម្បីមានះដែលកើតឡើងរឿយៗ ព្រោះអាស្រ័យមានះដែលកើតតៗមក ក៏ដូចទង់ជ័យ ដោយសេចក្តីថា លើកឡើងទុកឲ្យខ្ពស់ ទើបហៅថា **កេតុ** ។

ពាក្យថា **កេតុកម្យ** គឺចិត្តដែលត្រូវការឡើងខ្ពស់ដូចទង់ ។

ពាក្យថា **កេតុកម្យតា** គឺភាវៈរបស់ចិត្តដែលត្រូវការឡើងខ្ពស់ដូចទង់ ។

ម្យ៉ាងទៀត ភាវៈដែលត្រូវការឡើងខ្ពស់ដូចទង់នោះ ជារបស់ចិត្ត មិនមែនជារបស់អត្តា ដូច្នោះទើបទ្រង់ត្រាស់ថា **កេតុកម្យតា ចិត្តស្ស** ( ភាវៈនៃចិត្តដែលត្រូវការដូចទង់ ) ។ ការពិតហើយ ចិត្តដែលប្រកបជាមួយមានះ រមែងត្រូវការឡើងខ្ពស់ដូចទង់ ហើយភាវៈនៃចិត្តនោះឯងឈ្មោះថា **កេតុកម្យតា** គឺ មានះដែលហៅថាជាទង់ ។

**មានះ** បានទទួលការឧបត្ថម្ភដោយជាតិ ត្រកូល ទ្រព្យសម្បត្តិ កិត្តិយស ភាពជាធំ ជាដើម និង គុណគឺ សីល ការស្តាប់ លាភសក្ការៈជាដើម រមែង ចម្រើនក្រៃលែង រហូតសម្គាល់ខ្លួនក្នុងចំណោមមហាជន ថាខ្ពង់ខ្ពស់ជាងគេ ដូចទង់ ដូចសាធកៈ ( ក្នុងអដ្ឋកថា ) ថា **ឧន្នតិលក្ខណោតិ ច ឧម្មាទោ វិយាតិ ច** ប្រែថា “ មានលក្ខណៈប៉ោង ជាធម្មជាតិដូចសភាពឆ្កួត ” ។

ពាក្យថា **ទោសៈ** ( សេចក្តីក្រោធ ) គឺ សភាវៈប្រទូស្តរ៉ាយ ។

ពាក្យថា **ទុស្សនា** ( កិរិយាដែលប្រទូស្តរ៉ាយ គឺ អាការៈដែលប្រទូស្តរ៉ាយ ) ។

ពាក្យថា **ទុស្សិតត្តៈ** ( ការប្រទូស្តរ៉ាយ ) គឺ ភាវៈនៃការប្រទូស្តរ៉ាយ ។

ការដល់នូវភាពវិបត្តិនៃចិត្ត ព្រោះជាសភាវៈលះនូវភាពប្រក្រតី ឈ្មោះថា **ព្យាបត្តិ** ( ការប៉ង់អាក្រក់ ) ។

ពាក្យថា **ព្យាបជ្ជនា** ( កិរិយាដែលប៉ងអាក្រក់ ) គឺ អាការៈដែលប៉ងអាក្រក់

ពាក្យថា **វិរោធៈ** គឺ សភាវៈទាស់ទែងគ្នា ។

ពាក្យថា **បដិវិរោធៈ** គឺសភាវៈទាស់ទែងគ្នារឿយៗ ។

បុគ្គលមានចិត្តគ្រោតគ្រាត កាចសាហាវ ឈ្មោះថា **ចណ្ឌិកៈ** ។

ទោសៈដូចពស់ពិសដែលត្រូវគេវាយ ព្រោះមានសភាពកាចសាហាវ ដូចរន្ទះបាញ់ ព្រោះជាសភាវៈផ្សាយទៅ ( ទូទាំងសព៌ាង្គកាយ ) ។ ដូចភ្លើងឆេះព្រៃ ព្រោះជាសភាវៈដុតទីតាំងរបស់ខ្លួន ។ ដូចសត្រូវដែលបានឱកាស ព្រោះជាសភាវៈប្រទូសរ៉ាយ ។ ដូចទឹកមូត្រស្អុយ ផ្សំដោយថ្នាំពិស ព្រោះជាគំនរទោសទាំងអស់ ។

**ឥស្សា** ( សេចក្តីច្រណែន ) គឺសភាវៈច្រណែន ដូចសាធកៈ ( ក្នុងអដ្ឋកថា ) ថា **យា បរលាភសក្ការគរុការមាននវន្ទនបូជនាទីសុ ឥស្សា** ប្រែថា “ ការច្រណែនក្នុងលាភសក្ការៈ ក្នុងការគោរព ក្នុងការរាប់អាន ក្នុងការក្រាបថ្វាយបង្គំ និង ការបូជារបស់បុគ្គលដទៃជាដើម យ៉ាងណា ការច្រណែនណា

ដែលមានលក្ខណៈសម្លឹងរំពៃក្នុងសម្បត្តិរបស់អ្នកដទៃ ដែលទាក់ទងដោយលាភជាដើមរបស់ជនដទៃនោះថា លាភជាដើមនេះនឹងមានប្រយោជន៍អ្វីដល់បុគ្គលទាំងនោះ " ។

ពាក្យថា **លាភោ** ( លាភ ) គឺការបានទទួលបច្ច័យ ៤ មានចីវរបច្ច័យជាដើម ។ ដោយពិតហើយ បុគ្គលអ្នកឥស្សា រមែងសម្លឹងលាភរបស់បុគ្គលដទៃនោះ រមែងមិនប្រាថ្នាថា លាភនេះមានប្រយោជន៍អ្វីដល់ជននោះ ។

ពាក្យថា **សក្ការោ** គឺការបូជាដោយប្រពៃ ។

ពាក្យថា**គរុការោ** ( ការគោរព ) គឺកិរិយាដែលលើកតម្កើង ។

ពាក្យថា **មាននំ** ( ការរាប់អាន ) គឺការធ្វើឲ្យជាទីស្រឡាញ់ ។

ពាក្យថា **វន្ទនំ** ( ការថ្វាយបង្គំ ) គឺការថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។

ពាក្យថា **បូជានា** ( ការបូជា ) គឺការបូជាដោយគ្រឿងក្រអូប និង ផ្កាជាដើម

[ពាក្យថា **ឥស្សា** ( ការច្រណែនក្នុងចិត្ត ) ចំណែកពាក្យថា **ឧសូយ** ( ការឈ្នានិស ) ជាការសម្តែងចេញតាមវាចា មកពី **ឧសូយ** ធាតុ = **ទោសាវិករណេ** ( ការធ្វើទោសឲ្យប្រាកដច្បាស់ ) + **អ** បច្ច័យ ] ។

ពាក្យថា **ឥស្សាយនា** ( កិរិយាដែលច្រណែន, ឫស្យា, ឈ្នានីស ) ។

ពាក្យថា**ឥស្សាយិតត្ត** ( ភាវដែលច្រណែន, ឫស្យា, ឈ្នានីស ) ។

**មច្ឆរៈ** គឺសភាវៈមិនព្រមឲ្យសម្បត្តិរបស់ខ្លួនដល់អ្នកដទៃ ដោយត្រិះរិះថា " គុណធម៌ ឬ វត្ថុនេះ ចូរមានដល់យើងតែម្នាក់ឯង កុំបីមានដល់អ្នកដទៃឡើយ " បានដល់ចិត្តដែលប្រព្រឹត្តទៅយ៉ាងនោះ ។

**មច្ឆរិយ** ( សេចក្តីកំណាញ់ ) គឺភាវៈនៃចិត្តកំណាញ់ ។

ក្នុងមច្ឆរិយនិទ្ទេសនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា **បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយាទីនិ** ប្រែថា " សេចក្តីកំណាញ់ មាន ៥ យ៉ាង មាន កំណាញ់អាវាសជាដើម " ។

**អាវាស** គឺ អារាមទាំងអស់ក្តី បរិវេណអារាមក្តី បន្ទប់តូចមួយបន្ទប់ក្តី ដែលស្នាក់នៅពេលយប់ឬ ពេលថ្ងៃជាដើមក្តី ពួកភិក្ខុដែលនៅក្នុងអាវាសនោះ រមែងនៅជាសុខ រមែងបានទទួលបច្ច័យទាំងឡាយ ភិក្ខុមួយរូបជាអ្នកកំណាញ់ រមែងមិនប្រាថ្នាឲ្យភិក្ខុអ្នកដល់ព្រមដោយវត្ត មានសីលជាទីស្រឡាញ់មកនៅទីនោះ កាលបើបានមកហើយ ក៏គិតថា ភិក្ខុនេះ ចូរជៀសចេញទៅឲ្យឆាប់ចុះ នេះឈ្មោះថា **អាវាសមច្ឆរិយ** ( កំណាញ់អាវាស ) ។

**ត្រកូល** គឺត្រកូលឧបដ្ឋាកខ្លះ ត្រកូលញាតិខ្លះ បើភិក្ខុមិនប្រាថ្នាឲ្យភិក្ខុដទៃចូលទៅកាន់ត្រកូលនោះ រមែងជា **កុលមច្ឆរិយ** ( កំណាញ់ត្រកូល ) តែភិក្ខុមិនប្រាថ្នាឲ្យបុគ្គលអាក្រក់ចូលទៅក្នុងត្រកូលនោះ មិនឈ្មោះថាកុលមច្ឆរិយៈ បើភិក្ខុមិនប្រាថ្នាឲ្យភិក្ខុដែលអាចរក្សាសេចក្តីជ្រះថ្លាចូលទៅក្នុងត្រកូលនោះ ទើបឈ្មោះថា **កុលមច្ឆរិយ** ។

**លាភៈ** គឺការបានទទួលបច្ច័យ ៤ បើភិក្ខុអ្នកមានសីលរូបដទៃបានទទួលបច្ច័យ ៤ នោះ ភិក្ខុកំណាញ់គិតថា សូមកុំឲ្យបាន រមែងជា **លាភមច្ឆរិយ** ( កំណាញ់លាភ ) ។ តែបើភិក្ខុណាញុាំងវត្ថុដែលគេឲ្យដោយសទ្ធា ឲ្យធ្លាក់ចុះទៅក្តី រមែងធ្វើបច្ច័យដែលបានមកឲ្យវិនាសទៅផង ការមិនបរិភោគ ឬ បរិភោគមិនល្អជាដើមក្តី សូម្បីវត្ថុដល់នូវការផ្អូមហើយ ក៏ពុំបានឲ្យដល់ភិក្ខុដទៃ កាលបើបានឃើញភិក្ខុកំណាញ់បែបនេះហើយ ក៏គិតថា ភិក្ខុទាំងនេះ មិនសមគួរដល់បច្ច័យ ៤ នេះឡើយ សមគួរចំពោះភិក្ខុអ្នកមានសីលគប្បីបានគប្បីបរិភោគ មិនឈ្មោះថា **លាភមច្ឆរិយ ។**

**វណ្ណៈ** គឺពណ៌សម្បុរនៃសរីរៈក្តី ការសរសើរគុណធម៌ក្តី ក្នុងវណ្ណៈទាំងពីរនេះ បុគ្គលអ្នកកំណាញ់ពណ៌សម្បុរនោះ កាលបើមានអ្នកដទៃពោលសរសើរដល់បុគ្គលណាម្នាក់ថាមានរូបស្អាតគួរពិចពិលរមិលមើល ក៏មានចិត្តមិនប្រាថ្នានឹងពោលដល់បុគ្គលនោះឡើយ ។ ចំណែកបុគ្គលកំណាញ់ ការសរសើរសេចក្តីល្អរបស់បុគ្គលដទៃ រមែងមិនប្រាថ្នានឹងពោលសរសើរនូវសេចក្តីល្អរបស់បុគ្គលដទៃ ដោយសីលធុតង្គ បដិបទា និង ការប្រព្រឹត្តិឡើយ ។

**ធម៌** គឺ បរិយត្តិធម៌ និង បដិវេធធម៌ ក្នុងធម៌ទាំងពីរយ៉ាងនេះ អរិយសាវកទាំងអស់រមែងមិនកំណាញ់ក្នុងបដិវេធធម៌ រមែងប្រាថ្នាការសម្រេចមគ្គផល ដល់មនុស្សលោក ទេវលោក ក្នុងធម៌ដែលខ្លួនបានសម្រេចហើយ សូមឲ្យសត្វទាំងនោះបានសម្រេចនូវធម៌ទាំងនោះ ។

**ធម្មមច្ឆរិយ** ( ការកំណាញ់ធម៌ ) រមែងមានក្នុង **តន្តិធម្ម** ( ធម៌គឺព្រះបាលី ) ប៉ុណ្ណោះ បុគ្គលអ្នកប្រកបដោយតន្តិធម៌នេះ ជាអ្នកដឹងនូវគន្លឹះ ឬ វិធីអធិប្បាយ ( គម្ពីរអដ្ឋកថា ) ណា រមែងមិនបំណាងនឹងឲ្យអ្នកដទៃដឹងរឿងនោះ។

បុគ្គលណារមែងមិនឲ្យដោយគិតថាបើបុគ្គលនេះរៀនធម៌នេះហើយនឹងទម្លាយការយល់របស់យើងបាន បុគ្គលនោះឈ្មោះថា ជាអ្នកកំណាញ់ធម៌ ។

បណ្តាសេចក្តីកំណាញ់ទាំង ៥ យ៉ាងនេះ លំដាប់ដំបូង ដោយការកំណាញ់អាវាស បុគ្គលនោះរមែងកើតជាយក្ខ ឬ ប្រេត ហើយយកក្បាលទូលនូវសម្រាមនៅទីនោះៗហើយប្រព្រឹត្តទៅ ។

ដោយការកំណាញ់ត្រកូល កាលបើក្នុងត្រកូលនោះ បានធ្វើទាន និង រាប់អានបុគ្គលដទៃ ពេលដែលបានឃើញក៏គិតថា ត្រកូលនេះរបស់អាត្មាអញបែកធ្លាយហើយហ្ន៎! លោហិតក៏ខ្ពុរចេញពីមាត់ មានការចុករាកខ្លះ ពោះវៀនធំទាំងឡាយ ក៏ដាច់ជាកំណាត់ៗលៀនចេញមកខ្លះ ។

ដោយការកំណាញ់លាភ បុគ្គលអ្នកកំណាញ់លាភ ដែលជារបស់សង្ឃរបស់ពួកគណៈ យកមកប្រើជារបស់ផ្ទាល់ខ្លួន រមែងកើតជាយក្ខ ជាប្រេតជាពស់ថ្លាន់ធំ ។

ដោយការកំណាញ់ពណ៌សម្បុរ គុណធម៌ និង ការកំណាញ់បរិយត្តិធម៌ បុគ្គលនោះរមែងជាបុគ្គលមានពណ៌សម្បុរមិនល្អ និង ជាអ្នកថ្លង់ គ ។

ន័យម្យ៉ាងទៀត បុគ្គលរមែងត្រូវភ្លើងឆេះក្នុងខ្ទះទង់ដែង ដោយការកំណាញ់អាវាស ។ រមែងជាបុគ្គលមានលាភតិច ដោយការកំណាញ់ត្រកូល ។ រមែងកើតក្នុងគូថនរក ដោយការកំណាញ់លាភ ។ បុគ្គលកាលបើបានកើត

ក្នុងភពណាៗ រមែងមានពណ៌សម្បុរមិនល្អ ដោយការកំណាញ់ពណ៌សម្បុរ ។ រមែងកើតក្នុងនរកផេះក្ដៅ ដោយការកំណាញ់ធម៌ ។

ពាក្យថា **មច្ឆេរ** ( សេចក្ដីកំណាញ់ ) ដោយឃើញតែប្រយោជន៍ខ្លួន ។

ពាក្យថា **មច្ឆរាយនា** ( កិរិយាដែលកំណាញ់ ) គឺអាការៈនៃការកំណាញ់

ពាក្យថា **មច្ឆរាយិតត្ត** គឺ ភាវៈនៃចិត្តដែលត្រូវសេចក្ដីកំណាញ់ឲ្យប្រព្រឹត្តទៅ ពោលគឺ កើតព្រមដោយសេចក្ដីកំណាញ់ ។

ពាក្យថា **វិវិច្ឆ** ( អ្នកហួងហែង ) គឺមិនប្រាថ្នាសម្បត្តិទាំងអស់ជារបស់ខ្លួនឲ្យដល់អ្នកដទៃ ដោយគិតថា សូមឲ្យសម្បត្តិទាំងពួងចូរមានដល់ខ្លួនប៉ុណ្ណោះ ចូរកុំមានដល់អ្នកដទៃឡើយ ។

ពាក្យថា **វេវិច្ឆ** ( ការហួងហែង ) គឺភាវៈនៃបុគ្គលអ្នកហួងហែង ពាក្យនេះជាឈ្មោះនៃសេចក្ដីកំណាញ់យ៉ាងខ្សោយ ។

បុគ្គលអ្នកមិនអើពើ ព្រះអង្គទ្រង់ត្រាស់ថា **កទរិយោ** ( អ្នកឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ) ។

ពាក្យថា **កទរិយ** ( ការឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ) គឺភាវៈនៃបុគ្គលអ្នកឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ឈ្មោះថា សេចក្ដីកំណាញ់រឹងមាំ ព្រោះបុគ្គលអ្នកប្រកបដោយសេចក្ដីកំណាញ់នោះ រមែងហាមប្រាមនូវការឲ្យរបស់អ្នកដទៃដល់អ្នកដទៃ ។

**សមដូចព្រះពុទ្ធតម្រាសថា:**

**កទរិយោ ပាបសង្កប្បោ មិច្ឆាទិដ្ឋិ អនាទរោ**
**ទទមានំ និវារេតិ យាចមានាន ភោជនំ ។**

ប្រែថា “ បុគ្គលអ្នកឃើញតែប្រយោជន៍ផ្ទាល់ខ្លួន មានការត្រិះរិះអាក្រក់ជាមិច្ឆាទិដ្ឋិ មិនមានការជួយសង្គ្រោះរមែងហាមអ្នកដទៃកំពុងឲ្យភោជនាហារដល់ស្មូមយាចក ” ។

ពាក្យថា **កដុកញ្ចុក** ( អ្នកកំណាញ់ស្វិតស្វាញ ) គឺអ្នកឃើញស្មូមយាចក ហើយញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅល្វីងចត់ ពោលគឺបញ្ឈប់ ឬទុចដំណើរក្នុងការឲ្យ

ពាក្យថា **កដុកញ្ចុកតា** ( សេចក្តីកំណាញ់ស្វិតស្វាញ ) គឺភាវៈរបស់អ្នក ដែលឃើញស្មូមយាចកហើយញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅល្វីងចត់នោះ ។

ន័យម្យ៉ាងទៀត ការដួសបាយដោយចុងស្លាបព្រា ហៅថា **កដុកញ្ចុកតា** ពោលគឺ កាលដែលបុគ្គលដួសបាយពីឆ្នាំងដែលពេញដល់មាត់ឆ្នាំង រមែងកាន់យកដោយចុងស្លាបព្រា មិនអាចដួសពេញស្លាព្រាបាន យ៉ាងណាមិញ ចិត្តរបស់អ្នកកំណាញ់រមែងចង្អៀតចង្អល់ ក៏យ៉ាងនោះដែរ ។ កាលបើចិត្តចង្អៀតចង្អល់ហើយ សូម្បីកាយក៏ចង្អៀតចង្អល់ទៅផង មិនអាចនឹងឈរ ដើម្បីឲ្យដល់ជនដទៃបានឡើយ ដូច្នេះ ទើបហៅសេចក្តីកំណាញ់ថា **កដុក-ញ្ចុកតា** ( ភាវៈជាអ្នកមានចិត្តចង្អៀតដូចស្លាបព្រាដួសបាយ ) ។

ពាក្យថា **អគ្គហិតត្តំ ចិត្តស្ស** ( ការមិនអើពើនៃចិត្ត ) បានសេចក្តីថា ការដែលចិត្តកំណាញ់ស្វិត មិនលាត មានការឲ្យទានជាដើម ឬ ក្នុងការធ្វើឧបការៈដល់អ្នកដទៃ ។

ម្យ៉ាងទៀត សេចក្តីកំណាញ់រមែងមិនប្រាថ្នាឲ្យនូវវត្ថុដែលខ្លួនមានដល់ពួកជនដទៃ ចង់បានទទួលរបស់ពីអ្នកដទៃតែម្នាក់ឯង ដូច្នោះគប្បីជ្រាបថា សេចក្តីកំណាញ់ មានលក្ខណៈលាក់សម្បត្តិរបស់ខ្លួនទុក ឬ មានលក្ខណៈស្អិតជាប់នឹងសម្បត្តិរបស់ខ្លួន ដោយការប្រព្រឹត្តទៅថា ភាពអស្ចារ្យនេះ ចូរមានតែយើងម្នាក់ឯង កុំមានដល់អ្នកដទៃឡើយ ។

ក្នុងពាក្យថា **កុក្កុច្ចំ** ( សេចក្តីក្តៅក្រហាយចិត្ត ) នេះ ពាក្យថា **កត** គឺការធ្វើ

ពាក្យថា **កុកត** គឺការធ្វើដែលគួរស្អប់ខ្ពើម បានដល់ អាការៈដែលគួរស្អប់ខ្ពើម ពោលគឺ ការប្រព្រឹត្តិទៅនៃចិត្តពិសេសដែលបណ្ឌិតគប្បីតិះដៀល ។

ដោយអង្គធម៌ កុក្កុច្ចៈ បានដល់ ចិត្តុប្បាទដែលប្រកបដោយកុក្កុច្ច-ចេតសិក ដែលប្រព្រឹត្តទៅដោយសេចក្តីក្តៅក្រហាយជានិច្ចជាកាលថា “ យើង

នៅមិនទាន់បានធ្វើកម្មល្អហ្ន៎! យើងបានធ្វើកម្មអាក្រក់ហើយហ្ន៎! ” បានសេចក្តីថា កុក្កុច្ច សូម្បីប្រព្រឹត្តទៅយ៉ាងនោះ ក៏មិនអាចធ្វើកម្មល្អ ដែលនៅមិនទាន់បានធ្វើ ឲ្យជារឿងដែលខ្លួនបានធ្វើហើយ ឬ មិនអាចប្តូរកម្មអាក្រក់ដែលបានធ្វើមកហើយ ឲ្យជារឿងដែលនៅមិនទាន់បានធ្វើ រមែងប្រព្រឹត្តទៅឲ្យកើតសេចក្តីរាថយក្នុងកុសលធម៌ ទើបហៅថា**កុកត** ព្រោះត្រឹមជាអាការៈដែលគួរស្អប់ខ្ពើម ដូចមានសាធកៈក្នុង ( គម្ពីរអដ្ឋកថា ) ថាៈ

**កតាកតស្ស សាវជ្ជានវជ្ជស្ស អភិមុខគមនំ បដិសារោ នាម ។ យស្មា បនេសោ កតំ វា បាបំ អកតំ ន ករោតិ ។ អកតំ វា កល្យាណំ កតំ ន ករោតិ ។ តស្មា វិរូបោ កុច្ឆិតោ វា បដិសារោតិ វិប្បដិសារោ ។**

“ **បដិសារ** គឺការរលឹកដល់ទោសដែលធ្វើហើយ ឬ គុណដែលនៅមិនទាន់បានធ្វើ ។

**វិប្បដិសារ** គឺការរលឹកមិនល្អ ។

ន័យម្យ៉ាងទៀត **វិប្បដិសារ** គឺការរលឹកដែលគួរស្អប់ខ្ពើម ព្រោះវិប្បដិសារៈធ្វើអំពើអាក្រក់ដែលធ្វើហើយ ឲ្យនៅមិនទាន់ធ្វើមិនបាន ឬធ្វើអំពើល្អដែលនៅមិនទាន់បានធ្វើ ឲ្យធ្វើហើយមិនបាន ” ។

ពាក្យថា **វិប្បដិសារ** ក្នុងទីនេះ គឺកុក្កុច្ចនេះឯង ។

[ ពាក្យថា **វិប្បដិសារ** មានសេចក្តី ២ ប្រការគឺៈ

-ការរលឹកមិនល្អ = **វិរូបោ បដិសារោ** > **វិប្បដិសារោ** ( **វិ** ឧបសគ្គ មានអត្ថថា មិនល្អ ) ។

-ការរលឹកដែលគួរស្អប់ខ្ពើម = **កុច្ឆិតោ បដិសារោ** > **វិប្បដិសារោ** ( **វិ** ឧបសគ្គ មានអត្ថថា គួរស្អប់ខ្ពើម ) ] ។

ពាក្យថា **កុក្កុច្ចាយនា** ( កិរិយាដែលរំខាន ) គឺអាការៈដែលញុំាងសេចក្តីរំខាននោះឲ្យកើតឡើង ។

ពាក្យថា **កុក្កុច្ចាយិតត្ត** ( សេចក្ដីរំខាន ) គឺភាវនៃបុគ្គលអ្នកប្រព្រឹត្តទៅដោយកុក្កុច្ចៈ ។

អាចារ្យទាំងឡាយពោល **កុចៈ** ធាតុ ទុកក្នុងគម្ពីរធាតុថា មានអត្ថគឺ " រាថយ " និង " ឆ្ងូតស្នាមចិត្ត " **កុក្កុច្ចៈ** ទើបសំដៅដល់ សភាវៈរាថយ ដោយអាការៈដែលគួរស្អប់ខ្ពើម មិនមែនដោយសភាពខ្មាស់ដល់បាប ។

ន័យម្យ៉ាងទៀត **កុក្កុច្ចៈ** គឺសភាវៈឆ្ងូតកោសចិត្ត ( ឲ្យកើតដំបៅ ) ដោយអាការៈដែលគួរស្អប់ខ្ពើម មិនមែនដោយអាការៈដែលដុសខាត់កិលេស សំដៅដល់ ពួកសម្បយុត្តធម៌ដែលប្រព្រឹត្តទៅយ៉ាងនោះ ពោលគឺ ពួកសម្បយុត្តធម៌រាថយ ដោយអាការៈរាថយចិត្តជានិច្ច ដែលជាវត្ថុគប្បីស្អប់ខ្ពើម ប្រព្រឹត្តទៅយ៉ាងនេះថា " យើងមិនបានធ្វើសេចក្ដីល្អហ្ន៎! យើងធ្វើបាបហើយហ្ន៎! " គឺមិនឲ្យចិត្តបង្អោនទៅក្នុងការសមាទានកុសលធម៌ ។

ន័យម្យ៉ាងទៀត រមែងឆ្ងូតកោសចិត្ត គឺធ្វើចិត្តឲ្យបាត់បង់កម្លាំងក្នុងការសមាទានកុសលធម៌ ដោយដែលធ្វើធម៌ដែលមានខ្លឹមសារ គឺសទ្ធាជាដើមឲ្យស្រាលស្តើង ដូចនោះ ពួកសម្បយុត្តធម៌នោះ ទើបបានឈ្មោះថា **កុក្កុច្ចៈ** ពួកសម្បយុត្តធម៌ប្រព្រឹត្តទៅយ៉ាងនោះ ព្រោះប្រកបដោយសភាវធម៌ណា សភាវធម៌នោះ ឈ្មោះថា **កុក្កុច្ចៈ** ព្រោះធ្វើឲ្យកើតសម្បយុត្តធម៌ដែលរាថយ ឬ ឆ្ងូតកោសចិត្ត ។

[ ពាក្យថា **កុក្កុច្ចៈ** មានសេចក្ដី ៣ ប្រការ គឺ ៖

-ភាវៈជាចិត្តប្បាទដែលធ្វើមិនល្អ = **កុកតស្ស ភាវោ** > **កុក្កុច្ចំ** ( **កុកត** + **ណ្យ** បច្ច័យក្នុងភាវតទ្ធិត ) ។

-សភាវៈរាថយដោយអាការៈគួរស្អប់ខ្ពើម = **កុច្ឆិតេនអាការេន កោចតិ សង្កោចតីតិ** > **កុក្កុច្ចោ** ( **កុ** បុព្វបទ + **កុច** ធាតុ = រាថយ + **ណ្យ** បច្ច័យក្នុងកត្តុសាធនៈ )

-សភាវៈឆ្លូតកោសចិត្តដោយអាការៈដែលគួរស្អប់ខ្ពើម = **កុច្ឆិតេន អាការេន កោចតិ វិលិខតីតិ** > **កុក្កុច្ចោ** ( **កុ** បុព្វបទ + **កុច** ធាតុ = ឆ្លូតកោសចិត្ត + **ណ្យ** បច្ច័យ ក្នុងកត្តុសាធនៈ ) ] ។

**កុក្កុច្ច** ប្រារព្ធសេចក្ដីល្អដែលនៅមិនទាន់បានធ្វើមកមុន ឬ សេចក្ដីអាក្រក់ដែលបានធ្វើហើយ រមែងប្រព្រឹត្តទៅដោយសភាវៈដែលក្ដៅក្រហាយនិងសោកស្ដាយជាខាងក្រោយ ដូចសាធកៈ ( ក្នុងគម្ពីរអដ្ឋកថា ) ថាៈ **តំ បច្ឆានុតាបលក្ខណំ កតាកតានុ សោចនរសន្តិ ច**

ប្រែថា “ មានលក្ខណក្ដៅក្រហាយក្នុងកាលខាងក្រោយ ។ មាននាទីសោកស្ដាយដល់កម្មដែលបានធ្វើហើយ ឬ នៅមិនទាន់បានធ្វើ ” ។

ក្នុងពាក្យនេះ ពាក្យថា “ មានលក្ខណក្ដៅក្រហាយចិត្តជាខាងក្រោយ ” បានសេចក្ដីថា មានលក្ខណៈក្ដៅក្រហាយចិត្តក្នុងកាលតមក ព្រោះមិនបានធ្វើសេចក្ដីល្អមកពីមុន ឬ បានធ្វើអាក្រក់មកហើយ ការដែលកុក្កុច្ចមានអារម្មណ៍ជាអតីតពិតប្រាកដ មិនមែនមានអារម្មណ៍ជាបច្ចុប្បន្ន ឬ អនាគតឡើយ។

( ចំណែក ) ក្នុងពាក្យថា “ មាននាទីសោកស្ដាយដល់កម្មដែលធ្វើហើយ ឬ នៅមិនទាន់បានធ្វើ ” ។ គប្បីប្រកបបទថា ( កម្មគឺ ) សេចក្ដីអាក្រក់ដែលបានធ្វើហើយ ឬ សេចក្ដីល្អដែលនៅមិនទាន់បានធ្វើ ដូចសាធកៈក្នុងគម្ពីរមហានិទ្ទេសថាៈ

**ទ្វីហាការេហិ កុក្កុច្ចំ ឧប្បជ្ជតិ កតត្តា ច អកតត្តា ច ។ កថញ្ច ទ្វីហា ។ ប ។ អកតត្តា ច ។ អកតំ មេ កាយសុចរិតំ កតំ កាយទុច្ចរិតន្តិ ឧប្បជ្ជតិ កុក្កុច្ចំ ។ អកតំ មេ វចីសុចរិតំ ។ ប ។ កតំ មនោទុច្ចរិតន្តិ ឧប្បជ្ជតិ កុក្កុច្ចំ ។ អកតា មេ បាណាតិបាតា វេរមណី កតោ បាណាតិបាតោតិ ឧប្បជ្ជតិ កុក្កុច្ចំ ។ ប ។ អកតា មេ សមាទិដ្ឋិ ។ កតា មិច្ឆាទិដ្ឋីតិ ឧប្បជ្ជតិ កុក្កុច្ចំ ។**

ប្រែថា កុក្កុច្ចៈ រមែងកើតឡើងដោយអាការៈ ២ យ៉ាង គឺៈ ធ្វើហើយ និង នៅមិនទាន់បានធ្វើ ។

កុក្កុច្ចៈ រមែងកើតឡើងដោយអាការៈ ២ យ៉ាងនោះ តើដូចម្ដេច ?

**កុក្កុច្ចៈ** រមែងកើតឡើងដូចនេះថា យើងមិនបានធ្វើកាយសុចរិត យើងធ្វើកាយទុច្ចរិតហើយ ។

**កុក្កុច្ចៈ** រមែងកើតឡើងដូចនេះថា យើងមិនបានធ្វើវចីសុចរិត យើងធ្វើវចីទុច្ចរិតហើយ ។

**កុក្កុច្ចៈ** រមែងកើតឡើងដូចនេះថា យើងមិនបានធ្វើមនោសុចរិត យើងធ្វើមនោទុច្ចរិតហើយ ។

**កុក្កុច្ចៈ** រមែងកើតឡើងដូចនេះថា យើងមិនបានវៀរចាកការសម្លាប់សត្វ យើងបានសម្លាប់សត្វហើយ ។

**កុក្កុច្ចៈ** រមែងកើតឡើងដូចនេះថា យើងមិនបានធ្វើសម្មាទិដ្ឋិឲ្យកើត យើងធ្វើមិច្ឆាទិដ្ឋិឲ្យកើតហើយ ។

ព្រះបាលីនេះសម្តែងថា **កុក្កុច្ចៈ** មាន ២ យ៉ាង ដោយចែកតាមអារម្មណ៍ គឺ៖ សុចរិតនៅមិនទាន់បានធ្វើ និង ទុច្ចរិតដែលបានធ្វើហើយ ព្រោះពោលទុក ( ក្នុងពាក្យនោះ ) ថា “ ដោយអាការៈ២យ៉ាង ” ។

**មានះ** មាន ២ យ៉ាងគឺ៖ **យាថាវមាន** ( ការលើកតម្កើងខ្លួនក្នុងរឿងពិត ) និង **អយាថាវមាន** ( ការលើកតម្កើងខ្លួនក្នុងរឿងមិនពិត ) យ៉ាងណាមិញ **កុក្កុច្ចៈ** ក៏មាន ២ យ៉ាងគឺ៖ **យាថាវកុក្កុច្ចៈ** ( សេចក្តីក្តៅក្រហាយក្នុងរឿងពិត ) និង **អយាថាវ-កុក្កុច្ចៈ** ( សេចក្តីក្តៅក្រហាយក្នុងរឿងមិនពិត ) ដូច្នេះអយាថាវកុក្កុច្ចៈ រមែងកើតឡើងដោយអាការៈ២ យ៉ាងថា “ យើងនៅមិនទាន់ធ្វើសេចក្តីល្អ យើងធ្វើសេចក្តីអាក្រក់ហើយហ្ន៎! ” ។

-សួរថា **កុក្កុច្ចៈ** គឺអ្វី ?

-ឆ្លើយថា **អយាថាវកុក្កុច្ចៈ** ( សេចក្តីក្តៅក្រហាយក្នុងរឿងមិនពិត ) គឺកុក្កុច្ចដែលសម្គាល់កម្មល្អថាកម្មអាក្រក់ យល់ថាជាកម្មអាក្រក់ ហើយមិនបានធ្វើក្នុងកាលមុនឬសម្គាល់កម្មអាក្រក់ថាជាកម្មល្អ យល់ថាកម្មល្អ ហើយធ្វើ រមែងកើតឡើងតមកដោយសេចក្តីក្តៅក្រហាយជានិច្ចជាកាល ទាំងកុក្កុច្ចៈដែលកើត

ឡើងដល់បុគ្គលអ្នកសម្គាល់កម្មល្អថាជាកម្មល្អក្នុងកាលមុន កាលបើបានធ្វើហើយ ក៏សម្គាល់ថាជាកម្មអាក្រក់ជាខាងក្រោយ និង អ្នកសម្គាល់កម្មអាក្រក់ថាជាកម្មអាក្រក់មិនបានធ្វើ ហើយសម្គាល់ថាជាកម្មល្អជាខាងក្រោយ ។

គប្បីប្រកបសេចក្ដីនោះដោយន័យថា " កុក្កុច្ចៈដែលសម្គាល់ក្នុងវត្ថុមិនមានទោសថាមានទោស សម្គាល់វត្ថុដែលសមគួរថាមិនសមគួរ សម្គាល់អនាបត្តិ ( វត្ថុដែលមិនជាអាបត្តិ ) ថាជាអាបត្តិជាដើម ឈ្មោះថា **អយាថាវកុក្កុច្ច** ជាដើម " ។

កុក្កុច្ចៈ ទាំងអស់នេះរមែងកើតឡើងដោយអាការៈ ២ យ៉ាង ទើបរាប់ចូលក្នុងអាការៈទាំងពីរ ដូចដែលបានពោលមកហើយ ។

ម្យ៉ាងទៀត **អសំយតកុក្កុច្ចៈ** ( កុក្កុច្ចគឺការមិនសង្រួម ) គឺ កុក្កុច្ចដែលសម្ដែងក្នុងគម្ពីរមហានិទ្ទេសនោះថាៈ

**ហត្ថកុក្កុច្ចកម្បិ កុក្កុច្ចំ ។ បាទកុក្កុច្ចកម្បិ កុក្កុច្ចំ ។ ហត្ថបាទកុក្កុច្ចកម្បិ កុក្កុច្ចំ**

ប្រែថា " ការរពិសដៃ ( គឺដាក់ដៃមិនសមរម្យ មិនគួរមើល ) ការរពិសជើង ( គឺដាក់ជើងមិនសមរម្យ មិនគួរមើល ) ការរពិសដៃជើង ( គឺការដាក់ដៃជើងមិនសមរម្យ មិនគួរមើល ) " ។

**វិនយកុក្កុច្ច** គឺ **កុក្កុច្ចៈ**ដែលប្រាកដក្នុងព្រះវិន័យថា **កុក្កុច្ចាយន្តា ន បដិគ្គណ្ហិំសុ** ប្រែថា "ភិក្ខុទាំងឡាយសង្ស័យ ទើបមិនទទួលចីវរនោះ " ។

និង កុក្កុច្ចៈ ដែលពោលថាៈ

**កថំកុក្កុច្ចប្បកតតាយ អាបជ្ជតិ កប្បិយេ អកប្បិយសញ្ញិតា អកប្បិយេ កប្បិយសញ្ញិតា ។**

ប្រែថា ភិក្ខុត្រូវអាបត្តិព្រោះសេចក្ដីសង្ស័យ គឺសង្ស័យដូចម្ដេច ? គឺសម្គាល់នូវវត្ថុដែលគួរថាមិនគួរ សម្គាល់នូវវត្ថុដែលមិនគួរថាគួរ ។

ពាក្យថា សេចក្ដីសម្គាល់នូវវត្ថុដែលគួរថាមិនគួរ ( **កប្បិយេ អកប្បិយសញ្ញិ-តា** ) បានសេចក្ដីថា ភិក្ខុឆាន់នូវសាច់ជ្រូក ដោយសម្គាល់ថាសាច់ខ្លាឃ្មុំ ឆាន់នូវសាច់ក្ដាន់ ដោយសម្គាល់ថាសាច់ខ្លារខិន ឆាន់នូវភោជនដែលជាកប្បិយៈ ( គួរ ) ដោយសម្គាល់ថាអកប្បិយៈ ( មិនគួរ ) ឆាន់នូវភោជនក្នុងកាល ដោយសម្គាល់ថាវិកាល ឆាន់ភេសជ្ជៈដែលគួរ ដោយសម្គាល់ថាមិនគួរ ។

ពាក្យថា សេចក្ដីសម្គាល់នូវវត្ថុដែលមិនគួរថាគួរ ( **អកប្បិយេ កប្បិយសញ្ញិ-តា** ) បានសេចក្ដីថា ភិក្ខុឆាន់នូវសាច់ខ្លាឃ្មុំ ដោយសម្គាល់ថាសាច់ជ្រូក ឆាន់នូវសាច់ខ្លារខិនដោយសម្គាល់ថាឆាន់សាច់ក្ដាន់ ឆាន់នូវភោជនដែលជាអកប្បិយ ដោយសម្គាល់ថាជាកប្បិយៈ ឆាន់នូវភោជនក្នុងពេលវិកាល ដោយសម្គាល់ថាឆាន់ក្នុងកាល ឆាន់ភេសជ្ជៈដែលជាអកប្បិយៈ ដោយសម្គាល់ថាជាកប្បិយៈ

**វិនយកុក្កុច្ច** ជាសេចក្ដីសង្ស័យក្នុងព្រះវិន័យ សេចក្ដីសង្ស័យក្នុងព្រះវិន័យជាកុសល ឬជាកិរិយាចិត្តប្បាទដែលប្រព្រឹត្តទៅដោយអាការៈសង្ស័យក្នុងឋានៈដែលមិនមែនជាវិស័យរបស់ខ្លួនថា វត្ថុនេះគួរធ្វើ ឬ វត្ថុនេះមិនគួរធ្វើ ភិក្ខុអ្នកស្រឡាញ់សិក្ខាដែលកើតសេចក្ដីសង្ស័យ រមែងមិនធ្វើកម្មនោះ ព្រះសង្គីតិកា-ចារ្យសំដៅយកភិក្ខុពួកនោះ ទើបពោលទុក ( ក្នុងព្រះវិន័យបិដក ) ថាៈ **កុក្កុច្ចាយ-ន្តា ន បដិគ្គណ្ហិំសុ** ប្រែថា “ សង្ស័យទើបមិនទទួល ” ។

ចំណែកភិក្ខុអ្នកធ្វើរមែងត្រូវអាបត្តិ សូម្បីក្នុងវត្ថុដែលគួរព្រះសង្គីតិកាចារ្យសំដៅយកភិក្ខុទាំងនោះ ទើបពោលថាៈ **កុក្កុច្ចប្បកតតាយ អាបត្តិំ អាបជ្ជតិ** ប្រែថា “ ត្រូវអាបត្តិព្រោះមានសេចក្ដីសង្ស័យ ” ។

[ **កុក្កុច្ចៈ** មាន ៣ ប្រភេទគឺៈ

(ក) **ចេតសិកកុក្កុច្ច** គឺ កុក្កុច្ចចេតសិក ។

(ខ) **អសំយតកុក្កុច្ច** គឺ ការមិនសង្រួមដៃជើង អង្គធម៌ បានដល់ អកុសល-ចិត្តុប្បាទដែលមានមោហៈជាប្រធាន ។

(គ) **វិនយកុក្កុច្ច** គឺ សេចក្ដីសង្ស័យក្នុងព្រះវិន័យ អង្គធម៌ បានដល់ កុសលចិត្តុប្បាទ ដែលកើតដល់បុថុជ្ជន និង សេក្ខបុគ្គល ឬ កិរិយាចិត្តុប្បាទ ដែលកើតដល់ព្រះអរហន្ត ] ។

ពាក្យថា ថីនៈ គឺសភាវៈគ្របសង្កត់ចិត្ត ធ្វើឲ្យថយកម្លាំង ដូចមានវចនត្ថថា **ថីយនា ថិយិតត្តំ** ប្រែថា សេចក្ដីរាថយ សភាពស្រយុតស្រយង់ចិត្ត ។

ពាក្យថា **ចិត្តស្ស អកល្លតា** ( សេចក្ដីមិនសមប្រកបនៃចិត្ត ) បានសេចក្ដីថា អាការៈនៃសភាពមិនគួរដល់ការងារនៃចិត្ត ។ សេចក្ដីពិត អ្នកជម្ងឺហៅថា **អកល្លកោ** ( អ្នកជម្ងឺ ) សូម្បីក្នុងព្រះត្រៃបិដកក៏បានពោលថា **នាហំ ភន្តេ អកល្លកោ** ( បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនស្រួលខ្លួន ) ។

ពាក្យថា **អកម្មញ្ញតា** ( ភាពមិនគួរដល់ការងារ ) បានសេចក្ដីថា អាការៈនៃភាពមិនគួរដល់ការងារ ដែលហៅថា អាការៈឈឺនៃចិត្ត ។

ពាក្យថា **ឱលីយនា** បានសេចក្ដីថា អាការៈដែលរាថយ ពោលគឺ ចិត្តដែលឧបត្ថម្ភឥរិយាបថ កាលបើមិនអាចទ្រទ្រង់ឥរិយាបថទុករមែងរាថយ ដូចប្រជៀវតោងដើមឈើ និង ដូចឆ្នាំងខ្លាញ់គោដែលព្យួរទុកនឹងដែកគោល ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា **ឱលីយនា** ( ការរាថយ ) ដោយសំដៅដល់ អាការៈរបស់ចិត្តដូចបានពោលមកហើយនោះ ។

ពាក្យថា **លីនំ** ( រួញរា ) បានសេចក្ដីថា កោងចូលហើយ ព្រោះមានសភាពមិនផ្សាយចេញទៅ។

ពាក្យថា **ថីនំ** ( ភាពស្រយុតស្រយង់ ) បានសេចក្ដីថា សភាវៈដែលតាំងនៅដោយភាពជាដុំ ព្រោះមិនផ្សាយទៅដូចដុំខ្លាញ់គោ ។

ពាក្យថា **ថិយនា** ( អាការៈដែលស្រយុតស្រយង់ ) ជាស័ព្ទដែលសម្តែងអាការៈរបស់ចិត្ត ។

ពាក្យថា **ថិយិតត្ត** ( សភាពដែលស្រយុតស្រយង់ ) គឺ ភាវៈនៃអាការៈដែលចិត្តស្រយុតស្រយង់ ។

[ពាក្យថា **ថិន** ប្រកបរូបស័ព្ទមកពី **ថា** ធាតុ ( គតិនិវត្តិម្ហិ = ហាមការទៅ , តាំងនៅ ) + **យុ** បច្ច័យ ផ្លាស់ **អា** ជា **ឥ** មានរូបវិគ្គហៈថា **យនភាវេន ថាតិ តិដ្ឋ-តីតិ** > **ថីនំ** សភាវៈដែលតាំងនៅជាដុំ ។

ពាក្យថា **ថិយិតត្ត**ប្រកបរូបស័ព្ទមកពី **ថិយិត** + **ត្ត** បច្ច័យក្នុងភាវតទ្ធិត ពាក្យ**ថិយិត** មកពី **ថិនយិត**លុប **ន** អក្សរ មានរូបវិគ្គហៈថា **ថិនេន អយិតំ** > **ថិយិតំ** និងមានរូបវិគ្គហៈថា **ថិយិតស្ស ភាវោ** > **ថិយិតត្តំ**] ។

ពាក្យថា **កាយស្ស** ( នៃកាយ ) បានដល់ នាមកាយដែលហៅថាខន្ធ ៣

ពាក្យថា **អកល្លតា អកម្មញ្ញតា** ( ការមិនសមប្រកបនៃនាមកាយ ភាពមិនគួរដល់ការងារនៃនាមកាយ ) មានន័យដូចដែលបានពោលមកហើយ ។

ពាក្យថា **ឱនាហ** គឺសភាវៈគ្របដណ្តប់កាយ ដូចដុំពពកគ្របដណ្តប់អាកាស ។

ពាក្យថា **បរិយោនាហ** គឺហ៊ុមព័ទ្ធ ។

ពាក្យថា **អន្តោសមោរោធ** គឺសភាវៈបិទបាំងខាងក្នុង ប្រៀបដូចទ្វារនគរត្រូវបិទហើយពួកមនុស្សរមែងចេញទៅក្រៅមិនបាន យ៉ាងណាមិញ ធម៌ដែលត្រូវបិទបាំងហើយ រមែងផ្សាយចេញទៅមិនបាន ក៏យ៉ាងនោះដែរ ដូច្នេះទើបទ្រង់ត្រាស់ថា **អន្តោសមោរោធោ** ( សភាវៈបិទបាំងទុកខាងក្នុង ) ។

ពាក្យថា **មិទ្ធ** គឺ សភាវៈបៀតបៀន ( នាមកាយ ) បានសេចក្តីថា រមែងបៀតបៀន ដោយសភាពមិនគួរដល់ការងារ ។

ពាក្យថា **មិទ្ធ** ប្រកបរូបស័ព្ទមកពី **មេធ** ធាតុ ( **ហឹសាយំ** = បៀតបៀន ) + **ត** បច្ច័យ មានរូបវិគ្គហថា **មេធតីតិ** > **មិទ្ធំ** ប្រែថាសភាវៈបៀតបៀន ( នាម-កាយ ) ។

ដូចមានក្នុងសទ្ទនីតិបករណ៍ ពោលថា **មេធ ហឹសាយំ សង្គមេ ច** ( **មេធ** ធាតុ ប្រព្រឹត្តក្នុងសេចក្ដីថា បៀតបៀន និង គប់រក ) ] ។

ពាក្យថា **សោបប** គឺសភាវៈជាហេតុឲ្យដេកលក់ ។

ពាក្យថា **បចលាយិកា** គឺសភាវៈធ្វើឲ្យទន់ត្របកភ្នែកជាដើម ។

ពាក្យថា **សុបនា សុបិតត្តំ** ( កិរិយាដែលស្ងាប ភាវដែលស្ងាប ) ជាស័ព្ទដែលសម្ដែងអាការៈ និង ភាវៈរបស់ចិត្តនោះ ។

សេចក្ដីសង្ស័យ ឈ្មោះថា **កង្ខា** ដោយអំណាចនៃការស្ទាក់ស្ទើរ ។

សភាវៈញុំាងសេចក្ដីស្ទាក់ស្ទើរឲ្យប្រព្រឹត្តទៅ ឈ្មោះថា **កង្ខាយនា ។**

ន័យម្យ៉ាងទៀត ពាក្យនេះទ្រង់ត្រាស់ទុកដោយភាពជាអាការៈ ( គឺការស្ទាក់ស្ទើរ ) ។

[ ពាក្យថា **កង្ខាយនា** មានសេចក្ដី ២ ប្រការគឺៈ

-សភាវៈញុំាងសេចក្ដីស្ទាក់ស្ទើរឲ្យប្រព្រឹត្តទៅដោយមានវិគ្គហៈថា **អាយ-តីតិ** > **អាយនា, កង្ខាយ អាយនា** > **កង្ខាយនា** ( ពាក្យថា **អាយនា** មកពី **ឥ** ធាតុ = ប្រព្រឹត្តទៅ + **ណេ** ការិតបច្ច័យ + **យុ** បច្ច័យ ក្នុងកត្តុសាធនៈ + **អា** ឥត្ថី បច្ច័យ ។

-ការប្រព្រឹត្តិទៅដោយការស្ទាក់ស្ទើរដោយមានវិគ្គហៈថា **អយិតព្វំ** > **អយនា កង្ខាយ អយនា** > **កង្ខាយនា** ( ពាក្យថា **អយនា** មកពី **ឥ** ធាតុ + **យុ** បច្ច័យក្នុងភាវៈសាធន + **អា** ឥត្ថីបច្ច័យ ) ] ។

ចិត្តដែលប្រព្រឹត្តទៅដោយការស្ទាក់ស្ទើរ ឈ្មោះថា **កង្ខាយិត** ព្រោះត្រូវការស្ទាក់ស្ទើរញុំាងឲ្យប្រព្រឹត្តទៅ ។

ភាវៈនៃចិត្តដែលប្រព្រឹត្តទៅព្រមដោយការស្ទាក់ស្ទើរនោះ ឈ្មោះថា **កង្ខាយិតត្ត** ។

ក្នុងពាក្យថា **វិចិកិច្ឆា** នេះ ពាក្យថា **ចិកិច្ឆា** គឺការរក្សា បានសេចក្តីថា ការរក្សាដោយបញ្ញា ។

**វិចិកិច្ឆា** ( ការសង្ស័យ ) គឺសភាវៈរក្សា ( ដោយបញ្ញា ) មិនបាន ព្រោះលំបាកដល់ការរក្សា ។

ន័យម្យ៉ាងទៀត **វិចិកិច្ឆា** គឺសភាវៈធ្វើឲ្យអ្នកពិចារណានូវសភាវធម៌លំបាកចិត្ត ។

ន័យម្យ៉ាងទៀត **វិចិកិច្ឆា** គឺសភាវៈប្រព្រឹត្តទៅដោយការស្ទាក់ស្ទើរ ។

[ ពាក្យថា **វិចិកិច្ឆា** មានសេចក្តី ៣ ប្រការគឺៈ

-សភាវៈរក្សាដោយបញ្ញាមិនបាន = **វិគតា ចិកិច្ឆា ឯតាយាតិ** > **វិចិកិច្ឆា** ( **វិ** ស័ព្ទ + **ចិកិច្ឆា** ស័ព្ទ ជាបញ្ចមីតប្បុរិសសមាស ) ។

-សភាវៈធ្វើឲ្យអ្នកពិចារណានូវសភាវធម៌លំបាកចិត្ត = **វិចិនំ កិច្ឆា** > **វិចិកិច្ឆា** ( **វិចិន** ស័ព្ទ + **កិច្ឆា** សព្ទ ជាទុតិយាតប្បុរិសសមាស ) ។

-សភាវៈប្រព្រឹត្តទៅដោយសេចក្តីសង្ស័យ = **វិចិកិច្ឆតិ ទ្វេឡ្ហកភាវេន បវត្តតីតិ** > **វិចិកិច្ឆា** ( **វិ** បុព្វបទ + **កិត** ធាតុ + **អ** បច្ច័យក្នុងកត្តុសាធន ) ] ។

**វិចិកិច្ឆា** មាន ២ យ៉ាងគឺ **វិចិកិច្ឆានីវរណា** និង **វិចិកិច្ឆាបដិរូប** ។

**វិចិកិច្ឆានីវរណា** គឺ វិចិកិច្ឆាដែលប្រព្រឹត្តទៅដោយការសង្ស័យក្នុងឋាន ៨ យ៉ាង មានព្រះពុទ្ធជាម្ចាស់ជាដើម ជានីវរណៈ ។

សេចក្តីសង្ស័យក្នុងឋានៈ ៨ យ៉ាងគឺៈ

១- សង្ស័យក្នុងព្រះសាស្តា ។

២- សង្ស័យក្នុងព្រះធម៌ ។

៣- សង្ស័យក្នុងព្រះសង្ឃ ។

៤- សង្ស័យក្នុងត្រៃសិក្ខា ។

**៥**- សង្ស័យក្នុងចំណែកដំបូងគឺអតីតជាតិ ។

**៦**- សង្ស័យក្នុងចំណែកក្រោយគឺអនាគតជាតិ ។

**៧**-សង្ស័យក្នុងចំណែកដំបូង និងចំណែកក្រោយ គឺអតីតជាតិ និង អនាគតជាតិ ។

**៨**- សង្ស័យក្នុងធម៌ដែលជាហេតុ កើតអាស្រ័យគ្នា និងផលដែលកើតអំពីហេតុ ។

**វិចិកិច្ឆាបដិរូប** គឺ វិចិកិច្ឆាដទៃក្រៅអំពីវិចិកិច្ឆានោះទាំងអស់ ដែលប្រព្រឹត្តទៅដល់បុគ្គលអ្នកមិនមែនជាព្រះសព្វញ្ញូ ដោយសង្ស័យក្នុងអារម្មណ៍នោះៗថា “ យ៉ាងដូចម្ដេចទៅ ? ជាយ៉ាងនេះឬ ជាវត្ថុនេះឬ ”។

**វិចិកិច្ឆាបដិរូប** ជាកុសលខ្លះ ជាអកុសលខ្លះ ឬជាកិរិយាអព្យាកតខ្លះ ដែលកើតឡើងដល់ព្រះខីណាស្រពខ្លះ ចំណែកក្នុងអកុសលចេតសិកនេះ សំដៅដល់វិចិកិច្ឆាដែលជានីវរណ ដែលជាអកុសល ។

## ចប់ការសម្ដែងសេចក្ដីបរមត្ថក្នុងអកុសលរាសី

# សោភណចេតសិក ២៥ ដួង

## សោភណសាធារណចេតសិក ១៩ ដួង

**[៦] សទ្ធា សតិ ហិរិឱត្តប្បំ អលោភោ អទោសោ តត្រមជ្ឈត្តតា កាយបស្សទ្ធិ ចិត្ត-បស្សទ្ធិ កាយលហុតា ចិត្តលហុតាកាយមុទុតា ចិត្តមុទុតាកាយកម្មញ្ញតា ចិត្តកម្មញ្ញតា កាយបាគុញ្ញតា ចិត្តបាគុញ្ញតា កាយុជុកតា ចិត្តុជុកតា ចេតិ ឯកូនវីសតិមេ ចេតសិកា សោ-ភណសាធារណា នាម ។**

ប្រែថា " ចេតសិកទាំង ១៩ ដួងទាំងនេះគឺៈ **សទ្ធា** ( ការជឿ ) **សតិ** ( ការរលឹក ) **ហិរិ** ( ការខ្មាស់បាប ) **ឱត្តប្ប** ( ការតក់ស្លុតអំពីផលរបស់បាប ) **អលោភ** ( ការមិនជាប់ជំពាក់ ) **អទោស** ( ការមិនក្រោធ ) **តត្រមជ្ឈត្តតា** ( ភាពជាកណ្តាលក្នុងអារម្មណ៍នោះៗ ) **កាយបស្សទ្ធិ** ( ការស្ងប់នៃកាយ ) **ចិត្តបស្សទ្ធិ** ( ការស្ងប់នៃចិត្ត ) **កាយលហុតា** ( ការស្រាលនៃកាយ ) **ចិត្តលហុតា** ( ការស្រាលនៃចិត្ត ) **កាយមុទុតា** ( ការទន់ភ្លន់នៃកាយ ) **ចិត្តមុទុតា** ( ការទន់ភ្លន់នៃចិត្ត ) **កាយកម្មញ្ញតា** ( ការគួរដល់ការងារនៃកាយ ) **ចិត្តកម្មញ្ញតា** ( ការគួរដល់ការងារនៃចិត្ត ) **កាយបា-គុញ្ញតា** ( ការស្ទាត់ជំនាញនៃកាយ ) **ចិត្តបាគុញ្ញតា** ( ការស្ទាត់ជំនាញនៃចិត្ត ) **កាយុជុកតា** ( ការទៀងត្រង់នៃកាយ ) **ចិត្តុជុកតា** ( ការទៀងត្រង់នៃចិត្ត ) ឈ្មោះថា **សោភណសាធារណចេតសិក** " ។

## អធិប្បាយសោភណសាធារណចេតសិក

**[៦] សទ្ធា** ( ការជឿ ) គឺសភាវៈទ្រទ្រង់អារម្មណ៍ទុកដោយល្អ បានសេចក្តីថា ទឹកនឹងថ្លាស្អាត រមែងទ្រទ្រង់រូបនិមិត្ត គឺ ព្រះចន្ទ ព្រះអាទិត្យជាដើមបានយ៉ាងណាមិញ សទ្ធានេះរមែងទ្រទ្រង់ទុក ឬ តម្រង់អារម្មណ៍ មានគុណព្រះពុទ្ធជាដើមទុកក្នុងខ្លួនដោយល្អ ក៏យ៉ាងនោះដែរ ។

ន័យម្យ៉ាងទៀត **សទ្ធា** គឺ សភាវៈធ្វើឲ្យសម្បយុត្តធម៌ទ្រទ្រង់អារម្មណ៍ទុកដោយល្អ ។

ន័យម្យ៉ាងទៀត**សទ្ធា** គឺ ការទ្រទ្រង់ទុកល្អ ។

[ ពាក្យថា **សទ្ធា** មានសេចក្តី ៣ ប្រការ គឺៈ

-សភាវៈទ្រទ្រង់អារម្មណ៍ទុកដោយល្អ = **សទ្ទហតីតិ** > **សទ្ធា** ។

-សភាវៈធ្វើឲ្យសម្បយុត្តធម៌ទ្រទ្រង់អារម្មណ៍ទុកដោយល្អ = **សទ្ទហន្តិ ឯតាយាតិ** > **សទ្ធា** ។

-ការទ្រទ្រង់ទុកល្អ = **សទ្ទហនំ** > **សទ្ធា** ] ។

សទ្ធិន្ទ្រិយក្នុងអដ្ឋសាលិនីអដ្ឋកថាសម្តែងថាៈ

**សទ្ធា** គឺ សភាវៈធ្វើឲ្យជឿ ។

ន័យម្យ៉ាងទៀត **សទ្ធា** គឺ សភាវៈជឿ ។

ន័យម្យ៉ាងទៀត **សទ្ធា**គឺ សភាវៈជឿនុ៎ះឯង ។

[ ពាក្យថា**សទ្ធា**មានសេចក្តី ៣ ប្រការគឺៈ

-សភាវៈធ្វើឲ្យជឿ = **សទ្ទហន្តិ ឯតាយាតិ** > **សទ្ធា** ។

-សភាវៈជឿ = **សទ្ទហតីតិ** > **សទ្ធា** ។

-ការជឿ = **សទ្ទហនំ** > **សទ្ធា** ] ។

ម្យ៉ាងទៀត **សទ្ធា** នោះមានសភាពញ៉ាំងចិត្តឲ្យថ្លៃផង់ ( **សម្បសាទន-លក្ខណា** ) ឬមានសភាពស្ទុះទៅ ( **សម្បក្ខន្ទនលក្ខណា** ) សទ្ធាកើតឡើងរមែងគ្រប សង្កត់នីវរណធម៌ឲ្យស្ងប់ ធ្វើឲ្យចិត្តថ្លៃផង់ មិនឲ្យកករល្អក់ ដូចកែវមណីរបស់ស្តេចចក្រពត្តិ ធ្វើទឹកឲ្យថ្លាស្អាត កាលបើដាក់ចុះទៅក្នុងទឹកហើយ រមែងធ្វើឲ្យកករ សារាយ ចក និង កម្ទេចស្លឹកឈើស្ងប់លិចចុះ រមែងធ្វើឲ្យទឹកថ្លាស្អាត មិនកករល្អក់ ក៏យ៉ាងនោះដែរ ។

កុលបុត្រអ្នកព្យាយាមបដិបត្តធម៌ មានចិត្តថ្លៃផង់ហើយ ទើបឲ្យទានសមាទានសីល រក្សាឧបោសថកម្ម និងប្រារព្ធភាវនា ដោយប្រការដូច្នេះ គប្បីជ្រាបថា សទ្ធានោះមានសភាពញ៉ាំងចិត្តឲ្យថ្លៃផង់ ។

ឧបមាដូចមហាជនអ្នកភ័យខ្លាច ពេលបានមកដល់មហានទីដែលមានទឹកពេញច្រាំង ច្របូកច្របល់ទៅដោយក្រពើ នាគ និង អារក្សទឹកចាប់មនុស្សស៊ីជាដើម ក៏ឈរនៅច្រាំងទាំងសងខាង ចំណែកមេទ័ពអ្នកក្លាហានក្នុងសង្គ្រាម ពេលគាត់មកដល់ ក៏បានសួរថា ហេតុដូចម្ដេចទើបពួកអ្នកនៅឈរយ៉ាងនេះ ពួកជនទាំងនោះបានឆ្លើយថា ពួកយើងមិនហ៊ានឆ្លង ព្រោះមានភ័យ ទើបមេទ័ពនោះចាប់ដាវដ៏មុត ហើយពោលថា ពួកអ្នកចូរដើរតាមពីក្រោយយើងមក កុំខ្លាចឡើយ ហើយឈានចុះទន្លេ ការពារពួកសត្វកាចមានក្រពើជាដើមដែលបានមកដល់ហើយ ធ្វើសុវត្ថិភាពដល់មនុស្សទាំងឡាយនោះ នាំពីច្រាំងខាងនេះទៅច្រាំងខាងណោះ នាំពីច្រាំងខាងណោះមកច្រាំងខាងនេះ យ៉ាងណាមិញ បើបុគ្គលឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ផ្ដើមភាវនា សទ្ធារមែងជាប្រធាន ជាអ្នកនាំទៅ ក៏យ៉ាងនោះដែរ ដូច្នេះទើបពោលថា សទ្ធាមានសភាពស្ទុះទៅ ។

ន័យម្យ៉ាងទៀត សទ្ធាៈ

-មានសភាពជឿមាំ ឬ មានសភាពចុះស៊ប់ក្នុងវត្ថុដែលគួរជឿ ។

-មាននាទីធ្វើឲ្យថ្លាផង ដូចកែវមណីធ្វើឲ្យទឹកថ្លា ឬ មាននាទីស្ទុះទៅក្នុងវត្ថុដែលគួរជឿ ដូចមេទ័ពឆ្លងអន្លង់ទឹក ។

-មានសភាពមិនកករល្អក់ជាគ្រឿងប្រាកដ ឬ មានការចុះស៊ប់ជាផល ។

-មានវត្ថុដែលគួរជឿ ( សរណៈ ៣, កម្ម និង ផលរបស់កម្ម ) ជាហេតុជិត ឬ មានហេតុកើតរបស់សោតាបត្តិមគ្គជាហេតុជិត ។

[ ហេតុកើតរបស់សោតាបត្តិមគ្គមាន ៤ ប្រការគឺ ៖

១- ការគប់រកសប្បុរស ( **សប្បុរិសូបសេវន** ) ។

២- ការស្ដាប់ព្រះសទ្ធម្ម ( **សទ្ធម្មស្សវន** ) ។

៣- ការធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនង ( **យោនិសោមនសិការ** ) ។

៤- ការបដិបត្តធម៌ដ៏សមគួរដល់លោកុត្តរធម៌ ( **ធម្មានុធម្មបដិបត្តិ** ) ។

សទ្ធាគប្បីជ្រាបដូចដៃ ទ្រព្យ និង គ្រាប់ពូជ ។

**សទ្ធាដូចដៃ** គឺអ្នកមានដៃបានជួបប្រទះឃើញភ្នំដែលដេរដាសដោយរតនៈ ដែលមានតម្លៃច្រើន រមែងយកដៃទៅកើបយក ឬ ក្បង់យកនូវរតនៈនោះ អ្នកមិនមានដៃ មិនអាចកើប ឬ ក្បង់យកបានឡើយ យ៉ាងណាមិញ សប្បុរសលោកបានជួបប្រទះភ្នំរតនៈគឺព្រះពុទ្ធសាសនាដែលដេរដាសដោយរតនៈ គឺ មគ្គ ផល និព្វានហើយ រមែងប្រើដៃគឺ សទ្ធាកើប ឬ ក្បង់យកបាន ចំណែកអ្នកមិនមានដៃគឺសទ្ធា មិនអាចក្បង់ ឬ កើបយកបានឡើយ ក៏យ៉ាងនោះដែរ ។

**សទ្ធាដូចទ្រព្យ** គឺ អ្នកចូលទៅកាន់ហាងលក់រតនៈផ្សេងៗដែលមានតម្លៃ ត្រូវមានទ្រព្យ ទើបទិញទុកបាន ចំណែកអ្នកមិនមានទ្រព្យមិនអាចទិញបានឡើយ យ៉ាងណាមិញ អ្នកចូលទៅកាន់ហាងរតនៈ គឺ ព្រះពុទ្ធសាសនា ត្រូវមានទ្រព្យគឺសទ្ធា ទើបទិញទុកបាន ចំណែកអ្នកមិនមានទ្រព្យគឺសទ្ធា មិនអាចទិញបានឡើយ ក៏យ៉ាងនោះដែរ ដូចមានព្រះពុទ្ធតម្រាស់ត្រាស់ថា **សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ** ( សទ្ធាជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោកនេះ ) ។

**សទ្ធាដូចគ្រាប់ពូជ** គឺ អ្នកមានគ្រាប់ពូជ ទើបព្រោះទុកនៅលើដីដែលមានខ្យល់ ភ្លៀងល្អ ចំណែកអ្នកមិនមានគ្រាប់ពូជ មិនអាចព្រោះបាន យ៉ាងណាមិញ អ្នកមានគ្រាប់ពូជ គឺ សទ្ធារមែងព្រោះទុកនៅលើផែនដី គឺ ព្រះធម៌បាន ចំណែកអ្នកមិនមានគ្រាប់ពូជគឺសទ្ធា មិនអាចព្រោះបានឡើយ ក៏យ៉ាងនោះដែរ ដូចមានព្រះពុទ្ធតម្រាស់ថា **សទ្ធា ពិជំ តបោ វុដ្ឋិ** ( **សទ្ធា** ដូចគ្រាប់ពូជ **តប** ដូចទឹកភ្លៀង ) ។

**សតិ** គឺសភាវៈឲ្យរលឹកបាន ។

ន័យម្យ៉ាងទៀត **សតិ** គឺ សភាវៈរលឹកបាន ។

ន័យម្យ៉ាងទៀត**សតិ** គឺ ការរលឹកបានន៉ុះឯង ។

[ ពាក្យថា **សតិ** មានសេចក្តី ៣ ប្រការគឺៈ

-សភាវៈធ្វើឲ្យរលឹកបាន = **សរន្តិ ឯតាយាតិ** > **សតិ**

-សភាវៈរលឹកបាន = **សរតីតិ > សតិ ។**

-ការរលឹកបាន = **សរណំ > សតិ** ] ។

ន័យម្យ៉ាងទៀត សតិនោះឯងមានសភាពមិនអណ្តែតអណ្តូង ( ដូចយុថ្កាដាក់ចុះទៅលើដី ) និងមានសភាពផ្គត់ផ្គង់ ( សម្បយុត្តធម៌ ) សតិរមែងឲ្យកំណត់ ឲ្យរលឹកកុសលធម៌ដោយប្រពៃ ដូចមន្ត្រីអ្នករក្សាព្រះរាជឃ្លាំងរតនៈ ១០ យ៉ាង រមែងញ៉ាំងព្រះរាជាឲ្យកំណត់ ឲ្យរលឹកដល់ឥស្សរិយសម្បត្តិ ក្នុងពេលល្ងាច និង ពេលព្រឹក ។

**សមដូចព្រះនាគសេនត្ថេរពោលថា:**

**យថា មហារាជ រញ្ញោ ចក្កវត្តិស្ស ភណ្ឌាគារកោ រាជានំ ចក្កវត្តឹ សាយំ បាតំ យសំ សរាបេតិ ឯត្តកា ទេវ ហត្ថី, ឯត្តកា អស្សា, ឯត្តកា រថា, ឯត្តកា បត្តី, ឯត្តកំ ហិរញ្ញំ, ឯត្តកំ សុវណ្ណំ, ឯត្តកំ សព្វំ សាបតេយ្យំ, តំ ទេវោ សរតូតិ, ឯវមេវ ខោ មហារាជ សតិ កុសលេ ធម្មេ អបិលាបេតិ ឥមេ ចត្តារោ សតិបដ្ឋានា, ឥមេ ចត្តារោសម្មប្បធានា, ឥមេ ចត្តារោ ឥទ្ធិបាទា, ឥមានិ បញ្ចិន្ទ្រិយានិ, ឥមានិ បញ្ច ពលានិ, ឥមេ សត្ត ពោជ្ឈង្គា អយំ អរិយោ អដ្ឋង្គិកោ មគ្គោ, អយំ សមថោ , អយំ វិបស្សនា, អយំ វិជ្ជា, អយំ វិមុត្តិ , ឥមេ លោកុត្តរា ធម្មាតិ, ឯវំ ខោ មហារាជ អបិលាបនលក្ខណា សតិ ។**

ប្រែថា “ មហាបពិត្រ មន្ត្រីឃ្លាំងរបស់ស្តេចចក្រពត្តិ រមែងធ្វើឲ្យស្តេចចក្រពត្តិរលឹកដល់ឥស្សរិយសម្បត្តិ ទាំងពេលល្ងាច និង ពេលព្រឹកថា បពិត្រព្រះសម្មតិទេព ដំរីមានប្រមាណប៉ុណ្ណេះ សេះមានប្រមាណប៉ុណ្ណេះ រថមានប្រមាណប៉ុណ្ណេះ ពលថ្មើរជើងមានប្រមាណប៉ុណ្ណេះ ប្រាក់មានប្រមាណប៉ុណ្ណេះ មាសមានប្រមាណប៉ុណ្ណេះ សម្បត្តិទាំងពួងមានប្រមាណប៉ុណ្ណេះ សូមព្រះសម្មតិទេពរលឹកដល់ឥស្សរិយសម្បត្តិនោះ យ៉ាងណាមិញ សូមថ្វាយព្រះពរមហាបពិត្រ សតិក៏ដូច្នោះដែរ រមែងឲ្យរលឹកដល់កុសលធម៌ទាំងឡាយថា:

-ធម៌ ៤ យ៉ាងនេះគឺ សតិប្បដ្ឋាន

-ធម៌ ៤ យ៉ាងនេះគឺ សម្មប្បធាន

-ធម៌ ៤ យ៉ាងនេះគឺ ឥទ្ធិបាទ

-ធម៌ ៥ យ៉ាងនេះគឺ ឥន្ទ្រិយ៍

-ធម៌ ៥ យ៉ាងនេះគឺ ពលៈ

-ធម៌ ៧ យ៉ាងនេះគឺ ពោជ្ឈង្គ

-ធម៌នេះ គឺ អរិយមគ្គមានអង្គ ៨

-សមាធិនេះ គឺ សមថ

-បញ្ញានេះ គឺ វិបស្សនា

-បញ្ញានេះ គឺ វិជ្ជា

-អរហត្តផលនេះ គឺ វិមុត្តិ

-ធម៌ទាំងនេះ គឺ លោកុត្តរធម៌

មហាបពិត្រ សតិមានសភាពមិនអណ្តែតអណ្តូងយ៉ាងនេះ ” ។

ម្យ៉ាងទៀត សតិពិចារណាការសម្រេចនៃធម៌ដែលជាប្រយោជន៍ និង មិនជាប្រយោជន៍ ។

-ដឹងថាធម៌មានកាយទុច្ចរិតជាដើមទាំងនេះ មិនជាប្រយោជន៍ រមែងបន្ថយនូវធម៌ដែលមិនជាប្រយោជន៍ ។

-ដឹងថាធម៌មានកាយសុចរិតជាដើមទាំងនេះ ជាប្រយោជន៍ រមែងផ្គត់ផ្គង់នូវធម៌ដែលជាប្រយោជន៍ ។

ដូចបរិនាយកកែវរបស់ស្តេចចក្រពត្តិ ដឹងវត្ថុដែលមិនជាប្រយោជន៍ និងវត្ថុដែលជាប្រយោន៍របស់ព្រះរាជា រមែងនាំវត្ថុដែលមិនជាប្រយោជន៍ចេញទៅ និង បង្អោនវត្ថុដែលជាប្រយោជន៍ចូលមក ។

ន័យម្យ៉ាងទៀត សតិៈ

-មានសភាពមិនអណ្តែតអណ្តូង

-មាននាទីមិនវង្វេង

-មានការរក្សាអារម្មណ៍ទុកមិនឲ្យចេញពីចិត្តជាគ្រឿងប្រាកដ ឬ មានការសំដៅដល់អារម្មណ៍ជាគ្រឿងប្រាកដ ។

-មានសញ្ញាដែលមាំជាហេតុជិត ឬ មានអារម្មណ៍ដែលជាទីតាំងរបស់សតិ គឺ កង្វរូបជាដើម ជាហេតុជិត ។

គប្បីជ្រាប សតិដូចសរសរខឿន ព្រោះតាំងនៅមាំក្នុងអារម្មណ៍ និង ដូចនាយទ្វារបាល ( អ្នករក្សាទ្វារ ) ព្រោះរក្សាចក្ខុទ្វារជាដើម ។

សតិរមែងរក្សាចិត្តចេញពីអកុសលធម៌ទាំងអស់បាន និង ញុំាងចិត្តឲ្យប្រកបជាមួយកុសលធម៌ ទើបដូចមហាអាមាត្យអ្នកធ្វើកិច្ចទាំងអស់របស់ព្រះរាជាឲ្យសម្រេច ដូចមានព្រះពុទ្ធវចនសម្តែងថាៈ

**សតឹ ខ្វាហំ ភិក្ខវេ សព្វត្ថិកំ វទាមិ ។**

ប្រែថា “ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវសតិថា មានឧបការក្នុងទីទាំងពួង ”

**ហិរិ** គឺសភាវៈខ្មាស់កាយទុច្ចរិតជាដើម ។

**ឱត្តប្ប** គឺ សភាពតក់ស្លុតអំពីផលរបស់បាប ។

**ហិរិ** មានហេតុខាងក្នុង ( គឺខ្លួនឯង ) ជាសមុដ្ឋាន ។

**ឱត្តប្ប** មានហេតុខាងក្រៅ ( គឺបុគ្គលដទៃ ) ជាសមុដ្ឋាន ។

**ហិរិ** មានខ្លួនឯងជាធំ ។

**ឱត្តប្ប** មានលោកជាធំ ។

**ហិរិ** តាំងនៅដោយសភាពខ្មាស់ ។

**ឱត្តប្ប** តាំងនៅដោយសភាពតក់ស្លុត ។

**ហិរិ** មានលក្ខណៈគោរពជឿស្តាប់ ។

**ឱត្តប្ប** មានលក្ខណៈខ្លាចទោស និង ឃើញភ័យ ។

ក្នុងរឿងនេះ បុគ្គលរមែងកើតហិរិ ដែលជាហេតុខាងក្នុងជាសមុដ្ឋាន ដោយហេតុ ៤ ប្រការគឺៈ

**១-** ពិចារណាដល់ជាតិ គឺ បុគ្គលពិចារណាដល់ជាតិយ៉ាងនេះថា ឈ្មោះថា ការធ្វើអំពើអាក្រក់នេះ មិនមែនការងាររបស់បុគ្គលអ្នកបរិបូណ៌ដោយជាតិដូចយើងនេះ ហើយមិនធ្វើបាបមានបាណាតិបាតជាដើម រមែងញុំាងហិរិឲ្យកើតឡើង ។

**២-** ពិចារណាដល់វ័យ គឺ បុគ្គលពិចារណាដល់វ័យយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបនេះ ជាការធ្វើដែលពួកមនុស្សក្មេង ( កំលោះ ) គប្បីធ្វើ ការធ្វើនេះ មិនសមគួរដល់អ្នកតាំងនៅក្នុងវ័យដូចយើងនេះ ហើយមិនធ្វើបាបមានបាណាតិបាតជាដើម រមែងញុំាងហិរិឲ្យកើតឡើង ។

**៣-** ពិចាណាដល់ភាពក្លាហាន គឺ បុគ្គលពិចាណាដល់ភាពក្លាហានយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបនេះជាការធ្វើរបស់បុគ្គលអ្នកមានភាពទន់ខ្សោយ ការធ្វើបាបនេះ មិនសមគួរដល់បុគ្គលអ្នកមានភាពក្លាហានដូចយើងនេះហើយមិនធ្វើបាបមានបាណាតិបាតជាដើម រមែងញុំាងហិរិឲ្យកើតឡើង ។

**៤-** ពិចារណាដល់ភាពជាអ្នករៀនបានច្រើន គឺ បុគ្គលពិចារណាដល់ភាពជាអ្នករៀនបានច្រើនយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបនេះ ជាការធ្វើរបស់អ្នកល្ងង់ខ្លៅ ការធ្វើនេះមិនសមគួរដល់បណ្ឌិត មិនសមគួរដល់បុគ្គលជាពហុស្សូត្រទ្រទ្រង់បញ្ញាដូចយើងនេះ ហើយមិនធ្វើបាបមានបាណាតិបាតជាដើម រមែងញុំាងហិរិឲ្យកើតឡើង ។

-សួរថាៈ ឱត្តប្បមានហេតុខាងក្រៅជាសមុដ្ឋានយ៉ាងដូចម្តេច ?

-ឆ្លើយថាៈ ប្រសិនបើអ្នកធ្វើបាប អ្នកនឹងត្រូវបរិស័ទ ៤ តិះដៀល ។ ជាការពិតហើយ បើបុគ្គលពិចារណាយ៉ាងនេះថាៈ

**គរហិស្សន្តិ តំ វិញ្ញូ អសុចឹ នាគរិកោ យថា**
**វជ្ជិតោ សីលវន្តេហិ កថំ ភិក្ខុ ករិស្សសិ ។**

ប្រែថា “វិញ្ញូជនទាំងឡាយនឹងតិះដៀលអ្នក អ្នកនឹងត្រូវលោកអ្នកមានសីលទាំងឡាយវៀរចាក ប្រៀបដូចអ្នកក្រុងវៀរចាករបស់មិនស្អាត ម្នាលភិក្ខុអ្នកនឹងត្រូវធ្វើដូចម្តេច ?”

គេរមែងមិនធ្វើបាបកម្ម ព្រោះឱត្តប្បមានហេតុខាងក្រៅជាសមុដ្ឋាន ។

-សួរថាៈ ហិរិមានខ្លួនឯងជាធំតើដូចម្តេច ?

-ឆ្លើយថាៈ កុលបុត្រពួកខ្លះនៅក្នុងលោក ធ្វើខ្លួនឲ្យជាធំ ឲ្យជាប្រធាន ហើយគិតថា “ ការធ្វើអំពើអាក្រក់ មិនសមគួរដល់អ្នកបួសដោយសទ្ធាដូចយើងឡើយ ” ជាអ្នករៀនច្រើន បដិបត្តធុតង្គ ហើយមិនធ្វើបាបកម្ម ហិរិរមែងមានខ្លួនឯងជាធំយ៉ាងនេះឯង ដូចមានព្រះពុទ្ធតម្រាស់ថាៈ **សោ អត្តានំ-យេវ អធិបតឹ ជេដ្ឋកំ ករិត្វា អកុសលំ បជហតិ កុសលំ ភាវេតិ សាវជ្ជំ បជហតិ អនវជ្ជំ ភាវេតិ សុទ្ធមត្តានំ បរិហរតិ ។**

ប្រែថាៈ “បុគ្គលនោះរមែងធ្វើខ្លួនប៉ុណ្ណោះឲ្យជាធំ ឲ្យជាប្រធាន ហើយរមែងលះអកុសល ចម្រើនកុសល រមែងលះធម៌ដែលមានទោស ចម្រើនធម៌ដែលមិនមានទោស រមែងរក្សាខ្លួនឲ្យបរិសុទ្ធហ្មត់ចត់ ” ។

-សួរថាៈ ឱត្តប្បៈមានលោកជាធំតើដូចម្តេច ?

-ឆ្លើយថាៈ កុលបុត្រពួកខ្លះក្នុងលោកនេះ ធ្វើលោកឲ្យជាធំ ជាប្រធាន ហើយមិនបានធ្វើបាបកម្ម ដូចមានព្រះពុទ្ធតម្រាស់ថាៈ **មហា ខោ បនាយំ លោក-សន្និវាសោ ។ មហន្តស្មឹ ខោ បន លោកសន្និវាសេ សន្តិ សមណព្រាហ្មណា ឥទ្ធិមន្តោ ទិព្វចក្ខុកា បរចិត្តវិទុនោ ។ តេ ទូរតោបិ បស្សន្តិ អាសន្នាបិ ន ទិស្សន្តិ ។ ចេតសាបិ ចិត្តំ បជានន្តិ ។ តេបិមំ ឯវំ ជានិស្សន្តិ បស្សថ ភោ ឥមំ កុលបុត្តំ ។ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ សមានោ វោកិណ្ណោ វិហរតិ បាបកេហិ អកុសលេហិ ធម្មេហីតិ ។ សន្តិ ទេវតា ឥទ្ធិមន្តិនិយោ ទិព្វចក្ខុកា បរចិត្តវិទុនិយោ ។ តា ទូរតោបិ បស្សន្តិ ។ អាសន្នាបិ ន ទិស្សន្តិ ។ ចេតសាបិ ចិត្តំ បជានន្តិ តាបិ មំ ជានិស្សន្តិ បស្សថ ភោ ឥមំ កុលបុត្តំ ។ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ សមានោ វោកិណ្ណោ វិហរតិ បាបកេហិ អកុសលេហិ ធម្មេហីតិ ។ សោ លោកំយេវ អធិបតឹ ជេដ្ឋកំ កត្វា អកុសលំ បជហតិ ។ កុសលំ ភាវេតិ ។ សាវជ្ជំ បជហតិ។ អនវជ្ជំ ភាវេតិ ។ សុទ្ធមត្តានំ បរិហរតិ ។**

ប្រែថាៈ លោកសន្និវាសនេះធំណាស់ហ្ន៎! ម្យ៉ាងទៀត ក្នុងលោកសន្និវាសដ៏ធំនេះ រមែងមានសមណព្រាហ្មណ៍អ្នកមានរិទ្ធិ សមណព្រាហ្មណ៍ទាំងនោះ មានទិព្វចក្ខុ ដឹងចិត្តអ្នកដ៏ទៃបាន រមែងសម្លឹងឃើញបាន សូម្បីតែក្នុងទីឆ្ងាយ ប្រសិនបើលោកទាំងនោះនៅជិតយើងក៏ពិតមែន ក៏យើងពុំបានឃើញ រមែងដឹងច្បាស់នូវចិត្តរបស់យើងដោយចិត្តរបស់លោក ពួកលោកទាំងនោះនឹងដឹងយើងយ៉ាងនេះថាៈ “ អ្នកដ៏ចម្រើនទាំងឡាយ ចូរមើលកុលបុត្រនេះចុះ គេចេញចាកផ្ទះបួសដោយសទ្ធា នៅតែច្រឡូកច្រឡំដោយអកុសលធម៌ទាំងឡាយដ៏លាមក ” សូម្បីពួកទេព្តាទាំងឡាយដែលមានឫទ្ធិ៍ មានទិព្វចក្ខុ ដឹងចិត្តអ្នកដទៃក៏មាន ទេព្តាទាំងអស់នោះរមែងសម្លឹងមើលបានឆ្ងាយ ពួកលោកទាំងនោះ ទោះបីនៅជិតយើងក៏ពុំឃើញលោក រមែងដឹងច្បាស់នូវចិត្តដោយចិត្តរបស់ខ្លួន ទេពទាំងនោះនឹងដឹងយើងយ៉ាងនេះថាៈ “ អ្នកដ៏ចម្រើនទាំងឡាយ ចូរមើលកុលបុត្រនេះចុះ គេចេញចាកផ្ទះបួសដោយសទ្ធាហើយនៅតែច្រឡូកច្រឡំដោយអកុសលធម៌ទាំងឡាយដ៏លាមក, បុគ្គលនោះធ្វើលោកឲ្យជាធំ ជាប្រធាន ហើយលះអកុសលធម៌ ចម្រើនកុសលធម៌ រមែងលះធម៌ដែលមានទោស ចម្រើនធម៌ដែលមិនមានទោស រមែងរក្សាខ្លួនឲ្យបរិសុទ្ធហ្មត់ចត់ ” ។

ហិរិ និង ឱត្តប្បទាំងពីរនេះ ទ្រង់ត្រាស់ទុកដោយភាពជាធម៌គ្រប់គ្រងលោក ដូចមានព្រះតម្រាស់ថាៈ **ទ្វេមេ ភិក្ខវេ សុក្កា ធម្មា លោកំ បាលេន្តិ។ កតមេ ទ្វេ? ហិរី ច ឱត្តប្បញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ សុក្កា ធម្មា លោកំ បាលេន្តិ។ សចេ ភិក្ខវេ ទ្វេ សុក្កា ធម្មា លោកំ ន បាលេយ្យុំ, នយិធ បញ្ញាយេថ មាតាតិ វា, មាតុច្ឆាតិ វា, មាតុលានីតិ វា, អាចរិយភរិយាតិ វា, គរូនំ ទារាតិ វា។ សម្ភេទំ លោកោ អគមិស្ស យថា អជេឡកា កុក្កុដសូករា សោណសិង្គាលា។ យស្មា ច ខោ ភិក្ខវេ ឥមេ ទ្វេ សុក្កា ធម្មា លោកំ បាលេន្តិ, តស្មា បញ្ញាយតិ មាតាតិ វា មាតុច្ឆាតិ វា មាតុលានីតិ វា អាចរិយភរិយាតិ វា គរូនំ ទារាតិ វា។**

ប្រែថាៈ “ ម្នាលភិក្ខុទាំងឡាយ ធម៌សទាំងពីរប្រការនេះ រមែងគ្រប់គ្រងលោក ។ ធម៌ទាំងពីរប្រការតើដូចម្តេច ? គឺៈ ហិរិ និងឱត្តប្បៈ ។

ម្នាលភិក្ខុទាំងឡាយធម៌សទាំងពីរប្រការនេះឯងគ្រប់គ្រងលោក ។ ប្រសិនបើធម៌សទាំងពីរនេះ មិនបានគ្រប់គ្រងលោកទេ ក្នុងលោកនេះ ក៏មិនគប្បីប្រាកដថាជាម៉ែ មីង អ៊ំ ភរិយារបស់អាចារ្យឬ ភរិយារបស់ព្រាហ្មណ៍ដែលជាគ្រូ មនុស្សលោកនឹងដល់នូវការច្របូកច្របល់គ្នា ដូចពួកចៀម ពពែ មាន់ជ្រូក ឆ្កែស្រុក ឆ្កែព្រៃ ។ ម្នាលភិក្ខុទាំងឡាយ ធម៌សទាំងពីរប្រការនេះ រមែងគ្រប់គ្រងរក្សាលោក ព្រោះហេតុនោះ ទើបប្រាកដជាម៉ែ មីង អ៊ំ ភរិយារបស់អាចារ្យ ឬ ភរិយារបស់ព្រាហ្មណ៍ដែលជាគ្រូ ” ។

**អលោភៈ** ( ការមិនលោភ ) គឺសភាវៈដែលបដិបក្ខដល់សេចក្តីលោភ ។

**អលោភៈ** រមែងប្រព្រឹត្តទៅដើម្បីកំចាត់សភាពលោភក្នុងអារម្មណ៍ដែលខ្លួនសំគាល់ថាល្អ ដែលមានលោភៈនោះប្រព្រឹត្តទៅដោយការចង ។

**អលោភៈ** មានការស្អប់ខ្ពើម តិះដៀលភាពបរិបូណ៌ដោយភព និង សម្បត្តិដែលជាទីតាំងនៃសេចក្តីលោភ ប្រៀបដូចការស្អប់នូវដុំលាមក ជាសភាវៈចេញចាកកាម ( នេក្ខម្មធាតុ ) ។

**អទោសៈ** ( ការមិនក្រោធ ) គឺសភាវៈដែលបដិបក្ខដល់សេចក្តីក្រោធ ។

**អទោសៈ**រមែងប្រព្រឹត្តទៅដើម្បីកំចាត់សេចក្តីក្រោធក្នុងអារម្មណ៍ដែលខ្លួនសំគាល់ថាមិនល្អ ដែលមានទោសនោះ ប្រព្រឹត្តទៅដោយការប្រទូសរ៉ាយ

**អទោសៈ** ជាហេតុឲ្យកើតចិត្តថ្លាស្អាត ( ដូចព្រះចន្ទពេញវង់ ) ក្នុងពពួកសត្វ ជាសភាវៈមិនចងគំនុំ គំកួន ( អព្យាបាទ ) ។

**អទោសៈ** នេះហៅថា “ មេត្តា ” ក្នុងព្រហ្មវិហារ ។

**អមោហៈ** ( ការមិនវង្វេង ) គឺ សភាវៈដែលបដិបក្ខដល់មោហៈ ។

**អមោហៈ** កំចាត់សេចក្តីវង្វេងក្នុងហេតុ ផល ឬ អរិយសច្ច ៤ ដែលមោហៈធ្វើភាពងងឹតឲ្យប្រព្រឹត្តទៅ ។

**អមោហ:** ប្រៀបដូច ការធ្វើឲ្យកើតនូវព្រះចន្ទ និង ព្រះអាទិត្យរាប់ពាន់ដួង ភ្លឺចញ្ចែងចញ្ចាច បានឈ្មោះថា ការដឹង (វិជ្ជា) ។

**អលោភ:** ជាសត្រូវដល់មន្ទិលគឺ សេចក្តីកំណាញ់ ។

**អទោស:** ជាសត្រូវដល់មន្ទិលគឺ ភាពជាអ្នកទ្រុស្តសីល ។

**អមោហ:** ជាសត្រូវដល់នីវរណដែលមិនបំពេញកុសលធម៌ ។

**អលោភ:** ជាហេតុនៃទាន ។

**អទោស:** ជាហេតុនៃសីល ។

**អមោហ:** ជាហេតុនៃភាវនា ។

**អលោភ:** មិនកាន់យកច្រើន ព្រោះថា អ្នកលោភទើបកាន់យកច្រើន ។

**អទោស:** មិនចាប់យកនូវកំហុស ព្រោះថា អ្នកមានទោសប្រទូសរ៉ាយទើបចាប់យកនូវកំហុស ។

**អមោហ:** ធ្វើមិនឲ្យកាន់យកវិបរិត ព្រោះថា អ្នកវង្វេងទើបកាន់យកវិបរិត ។

បុគ្គលមិនបិទបាំងនូវកំហុសដោយអលោភ: ។

បុគ្គលមិនលុបគុណ ឬ រមិលគុណអ្នកដទៃ ដោយអទោស: ។

បុគ្គលរមែងដឹងសភាវ:តាមសេចក្តីពិត ដោយអមោហ: ។

ម្យ៉ាងទៀត ទុក្ខព្រោះព្រាត់ចាកសត្វ និង សង្ខារជាទីស្រឡាញ់ រមែងមិនមានព្រោះអលោភ: ។

ទុក្ខដែលប្រសព្វនូវសត្វ និងសង្ខារដែលមិនជាទីស្រឡាញ់ រមែងមិនមានព្រោះអទោស: ។

ទុក្ខព្រោះមិនបាននូវសត្វ និង សង្ខារដែលជាទីស្រឡាញ់ រមែងមិនមានព្រោះអមោហ: ។

ជាតិទុក្ខ រមែងមិនមានព្រោះអលោភៈ អលោភៈបដិបក្ខដល់តណ្ហា ហើយជាតិទុក្ខក៏មានតណ្ហាជាមូល ។

ជរាទុក្ខ រមែងមិនមានព្រោះអទោសៈ បើបុគ្គលច្រើនដោយសេចក្ដីក្រោធ ជរានឹងប្រាកដលឿន ។

មរណៈទុក្ខ រមែងមិនមានព្រោះអមោហៈ បើបុគ្គលនោះស្លាប់ព្រោះវង្វេងជាទុក្ខ តែទុក្ខរមែងមិនមានដល់ការមិនវង្វេង ។

ម្យ៉ាងទៀត ការនៅរួមគ្នាជាសុខរបស់គ្រហស្ថ រមែងមានព្រោះអលោភៈ ការនៅរួមគ្នាជាសុខរបស់បព្វជិត រមែងមានបានព្រោះអមោហៈ ។ ការនៅរួមគ្នាជាសុខរបស់គ្រហស្ថ និង បព្វជិតទាំងអស់ រមែងមានព្រោះអទោសៈ ។

ការកើតក្នុងកំណើតប្រេត រមែងមិនមានព្រោះអលោភៈ ។

ការកើតក្នុងកំណើតនរក រមែងមិនមានព្រោះ អទោសៈ ។

ការកើតក្នុងកំណើតតិរច្ឆាន រមែងមិនមានព្រោះ អមោហៈ ។

**អលោភៈ** ធ្វើឲ្យគេចចេញពីការបដិបត្តិអម គឺ កាមសុខល្លិកានុយោគ ។

**អទោសៈ** ធ្វើឲ្យគេចចេញពីការបដិបត្តិអម គឺ អត្តកិលមថានុយោគ ។

**អមោហៈ** ធ្វើឲ្យប្រព្រឹត្តទៅក្នុងការបដិបត្តិជាកណ្ដាល ។

**អលោភៈ** ធ្វើឲ្យទម្លាយអភិជ្ឈាកាយគន្ថៈ ។

**អទោសៈ** ធ្វើឲ្យទម្លាយព្យាបាទកាយគន្ថៈ ។

**អមោហៈ** ធ្វើឲ្យទម្លាយគន្ថៈដែលនៅសល់ទាំងពីរ គឺ សីលព្វតបរាមាស-កាយគន្ថ និង ឥទំសច្ចាភិនិវេសកាយគន្ថ ។

សតិប្បដ្ឋានទាំងពីរ គឺៈ **កាយានុបស្សនា** ( ការតាមដឹងកងរូប ) និង **វេទនា-នុបស្សនា** ( ការតាមដឹងវេទនា ) រមែងសម្រេចដោយអានុភាពនៃអលោភៈ និង អទោសៈ ។

សតិប្បដ្ឋានទាំងពីរ គឺៈ **ចិត្តានុបស្សនា** ( ការតាមដឹងចិត្ត ) និង **ធម្មានុបស្សនា** ( ការតាមដឹងធម៌ ) រមែងសម្រេចដោយអានុភាពនៃអមោហៈ ។

**អលោភៈ** រមែងជាបច្ច័យដល់ការមិនមានរោគ ព្រោះបុគ្គលមិនលោភ រមែងមិនសេពនូវវត្ថុដែលមិនសមគួរ ( គឺអាហារ ឧណ្ហភូមិ និង កន្លែងស្នាក់នៅជាដើម ) ដែលជាអារម្មណ៍របស់លោភៈ ព្រោះហេតុដូច្នោះ ទើបមិនមានរោគ ។

**អទោសៈ** រមែងជាបច្ច័យដល់ភាពក្រមុំ កម្លោះ ព្រោះមិនមានទោសប្រទូស្ត និង មិនត្រូវដុតដោយភ្លើង គឺទោសៈដែលនាំឲ្យមានស្បែកជ្រីវជ្រួញ និង សក់ស្កូវ ទើបឋិតនៅក្នុងភាពកម្លោះ ក្រមុំបានយូរ ។

**អមោហៈ** រមែងជាបច្ច័យឲ្យមានអាយុយឺនយូរ ព្រោះបុគ្គលអ្នកមិនវង្វេង ជ្រាបនូវវត្ថុដែលជាប្រយោជន៍ និង មិនជាប្រយោជន៍ រមែងវៀរវត្ថុដែលមិនជាប្រយោជន៍ ហើយសេពនូវវត្ថុដែលជាប្រយោជន៍ ទើបជាអ្នកមានអាយុវែង។

**អលោភៈ** ជាបច្ច័យដល់ការបានភោគសម្បត្តិ ព្រោះអ្នកមិនលោភ រមែងបានភោគសម្បត្តិ ដោយការបរិច្ចាគ ។

**អទោសៈ** ជាបច្ច័យដល់ការបានមិត្តសម្បត្តិ ព្រោះការបានមិត្ត និង មិនសាបសូន្យមិត្តដោយមេត្តា ។

**អមោហៈ** ជាបច្ច័យដល់ការបានទទួលអត្តសម្បត្តិ ព្រោះបុគ្គលមិនវង្វេង តែងធ្វើនូវអំពើជាប្រយោជន៍ដល់ខ្លួន ឈ្មោះថា ញុំាងខ្លួនឲ្យដល់ព្រម ។

**អលោភៈ** ជាបច្ច័យដល់ទិព្វវិហារ ( ឈាន៤ ) ។

**អទោសៈ** ជាបច្ច័យដល់ព្រហ្មវិហារ ( មេត្តាជាដើម ) ។

**អមោហៈ** ជាបច្ច័យដល់អរិយវិហារ ( ផលសមាបត្តិ ) ។

**អលោភ:** ធ្វើឲ្យបុគ្គលស្ងប់រម្ងាប់ក្នុងសត្វ និង សង្ខាររបស់ខ្លួន ព្រោះមិនមានសេចក្តីទុក្ខដែលជាចំណងចង កាលបើសត្វ និង សង្ខារទាំងនោះវិនាសទៅ ។

**អទោស:** ធ្វើឲ្យបុគ្គលស្ងប់រម្ងាប់ក្នុងសត្វ និង សង្ខារខាងក្រៅ ព្រោះមិនមានទោសប្រទូសរ៉ាយ រមែងប្រាសចាកសេចក្តីសម្គាល់ថា មានពៀរក្នុងបុគ្គលដែលចងពៀរនឹងគ្នា

**អមោហ:** ធ្វើឲ្យបុគ្គលស្ងប់ក្នុងសត្វ និងសង្ខារដែលជាកណ្តាល ព្រោះអ្នកមិនវង្វេង រមែងប្រាសចាកចំណងទាំងអស់ ។

**អលោភ:** ធ្វើឲ្យដឹងសភាពមិនទៀង ព្រោះបុគ្គលលោភ រមែងមិនឃើញសង្ខារដែលមិនទៀង ដោយភាពមិនទៀងឡើយ ព្រោះចំណងចងក្នុងគ្រឿងប្រើប្រាស់ ។

**អទោស:** ធ្វើឲ្យដឹងទុក្ខ ព្រោះអ្នកមានអធ្យាស្រ័យមិនក្រោធ ជាអ្នកគ្របសង្កត់នូវអាឃាតវត្ថុបាន រមែងឃើញសង្ខារដោយភាពជាទុក្ខ ។

**អមោហ:** ធ្វើឲ្យដឹងអនត្តា ព្រោះអ្នកមិនវង្វេង ជាអ្នកឆ្លាតក្នុងការកាន់យកនូវសភាវៈតាមសេចក្តីពិត រមែងដឹងខន្ធ ៥ ថាមិនមែនសត្វ មិនមែនតួរខ្លួន ។

ពាក្យថា **អមោហ:** គឺសភាវៈធ្វើឲ្យពពួកសត្វមិនវង្វេង

ន័យម្យ៉ាងទៀត **អមោហ:** គឺសភាវៈមិនវង្វេងក្នុងអារម្មណ៍

ន័យម្យ៉ាងទៀត **អមោហ:** ភាវៈមិនវង្វេងប៉ុណ្ណោះ

[ ពាក្យថា **អមោហ:** មានសេចក្តី ៣ ប្រការគឺ:

- សភាវៈធ្វើឲ្យពពួកសត្វមិនវង្វេង = **តេន សត្តា មុយ្ហន្តីតិ មោហោ, ន មោហោ** > **អមោហោ** ( ករណាសាធន ) ។

- សភាវៈមិនវង្វេងក្នុងអារម្មណ៍ = **អារម្មណេ មុយ្ហតីតិ មោហោ ន មោហោ** > **អមោហោ** ( កត្តុសាធន ) ។

- ភាវៈមិនវង្វេង = **មុយ្ហនំ, ន មោហោ** > **អមោហោ** ( ភាវសាធន ) ] ។

ក្នុងពាក្យថា **តត្រមជ្ឈត្តតា** ( **តត្រ** + **មជ្ឈ** + **អត្ត** + **តា** ) នេះ ពាក្យថា **អត្ត** គឺ សភាវៈ ។

ពាក្យថា **មជ្ឈត្ត** គឺ ធម៌ដែលមានសភាវៈប្រព្រឹត្តទៅជាកណ្តាល ។

ពាក្យថា **មជ្ឈត្តតា** គឺមានសភាពញុំាងចិត្ត និង ចេតសិកឲ្យប្រព្រឹត្តទៅស្មើគ្នា ។

**មជ្ឈត្តតា** គឺភាវៈប្រព្រឹត្តទៅស្មើ ដែលប្រាកដក្នុងសម្បយុត្តធម៌នោះៗ ។

ន័យម្យ៉ាងទៀត **តត្រមជ្ឈត្តតា** គឺការប្រព្រឹត្តិទៅស្មើគ្នារបស់ចិត្ត និង ចេតសិកក្នុងកម្មដែលល្អនោះៗ ។

មាននាទីហាមការមិនស្មើគ្នា ឬ មាននាទីកំចាត់សភាពដែលធ្លាក់ទៅរកការមិនស្មើគ្នា ។

មានភាពកណ្តាលជាគ្រឿងប្រាកដ ។

ដូចមានសាធកៈ ( ក្នុងគម្ពីរ ) ថាៈ

**សា សម្បវត្តានំ សម្បយុត្តធម្មានំ អជ្ឈុបេក្ខនរសេន សប្បវត្តានំ អាជានេយ្យានំ អជ្ឈុបេក្ខនសារថី វិយ ទដ្ឋព្វា ។**

ប្រែថា “ គប្បីជ្រាបតត្រមជ្ឈត្តតានេះថាដូចសារថីអ្នកព្រងើយចំពោះសេះអាជានេយ្យដែលរត់ទៅស្មើ ព្រោះមានការសម្លឹងជាកណ្តាលចំពោះសម្បយុត្តធម៌ ដែលប្រព្រឹត្តទៅស្មើ ” ។

[ ពាក្យថា **តត្រមជ្ឈត្តតា** មានសេចក្តី ២ ប្រការគឺៈ

-ការប្រព្រឹត្តិទៅស្មើដែលប្រាកដក្នុងសម្បយុត្តធម៌នោះៗ = **តេសុ តេសុ សម្បយុត្តធម្មេសុ ទិស្សមានា មជ្ឈត្តតា** > **តត្រមជ្ឈត្តតា** ( **តត្រ** ស័ព្ទសំដៅដល់សម្បយុត្តធម៌ ) ។

-ការប្រព្រឹត្តិទៅស្មើក្នុងកម្មដែលល្អនោះៗ = **តេសុ តេសុ ហិតកម្មេសុ មជ្ឈ-ត្តតា** > **តត្រមជ្ឈត្តតា** ( **តត្រ** ស័ព្ទសំដៅដល់កម្មដែលល្អ ) ] ។

តត្រមជ្ឈត្តតានេះ ហៅថា “ឧបេក្ខា ” ក្នុងព្រហ្មវិហារ ។

**កាយបស្សទ្ធិ** គឺ ការស្ងប់នៃពួកចេតសិក ។

**ចិត្តបស្សទ្ធិ** គឺ ការស្ងប់នៃចិត្ត ។

ម្យ៉ាងទៀត ពាក្យថា **កាយ** ក្នុងទីនេះ បានដល់ នាមក្ខន្ធ ៣ មានវេទនាខន្ធ ជាដើម ។

កាយបស្សទ្ធិ និង ចិត្តបស្សទ្ធិទាំង ២ យ៉ាងនេះកើតរួមគ្នា ។

-មានសភាពស្មើគ្នា គឺ ការស្ងប់នៃសេចក្ដីក្ដៅក្រហាយរបស់នាមក្ខន្ធ ៣ និង ចិត្ត ។

-មាននាទីកំចាត់បង់នូវការក្ដៅក្រហាយរបស់នាមក្ខន្ធ ៣ និង ចិត្ត ។

-មានការមិនក្ដៅអន្ទះអន្ទែង និងមានការស្ងប់ត្រជាក់របស់នាមក្ខន្ធ ៣ និង ចិត្តជាផល។

-មាននាមក្ខន្ធ ៣ និង ចិត្តជាហេតុជិត ។

សូមជ្រាបថា ធម៌ទាំងនេះជាបដិបក្ខដល់កិលេស មានឧទ្ធច្ចជាដើម ដែលធ្វើសភាពមិនស្ងប់ដល់នាមក្ខន្ធ ៣ និង ចិត្ត ។

**កាយលហុតា** គឺសភាពស្រាលនៃនាមក្ខន្ធ ៣ ។

**ចិត្តលហុតា** គឺសភាពស្រាលនៃចិត្ត ។

-ចេតសិកទាំងពីរនេះ មានសភាពស្ងប់នៃភាពធ្ងន់របស់នាមក្ខន្ធ ៣ និង ចិត្ត ។

-មាននាទីកំចាត់ភាពធ្ងន់របស់នាមក្ខន្ធ ៣ និង ចិត្ត ។

-មានភាពស្រាលរបស់នាមក្ខន្ធ ៣ និង ចិត្តជាផល ។

-មាននាមក្ខន្ធ ៣ និង ចិត្តជាហេតុជិត ។

សូមជ្រាបថា ធម៌ទាំងនេះជាបដិបក្ខដល់កិលេសមានថីនមិទ្ធជាដើម ដែលធ្វើសភាពធ្ងន់ដល់នាមក្ខន្ធ ៣ និង ចិត្ត ។

**កាយមុទុតា** ភាពទន់ភ្លន់នៃនាមក្ខន្ធ ៣ ។

**ចិត្តមុទុតា** ភាពទន់ភ្លន់នៃចិត្ត ។

ចេសិកទាំងពីរយ៉ាងនេះ

-មានភាពរម្ងាប់សភាពរឹងរបស់នាមក្ខន្ធ ៣ និង ចិត្ត ។

-មានការកំចាត់ភាពរឹងរបស់នាមក្ខន្ធ ៣ និង ចិត្ត ។

-មានការមិនប៉ះទង្គិច ( ក្នុងអារម្មណ៍ ) របស់នាមក្ខន្ធ ៣ និងចិត្តជាផល។

-មាននាមក្ខន្ធ ៣ និង ចិត្តជាហេតុជិត ។

សូមជ្រាបថា ធម៌ទាំងនេះជាបដិបក្ខដល់កិលេសមានទិដ្ឋិ និង មានះជាដើម ដែលធ្វើភាពរឹងដល់នាមក្ខន្ធ ៣ និង ចិត្ត ។

**កាយកម្មញ្ញតា** គឺ ការសមគួរក្នុងកិរិយានៃនាមក្ខន្ធ ៣ ។

**ចិត្តកម្មញ្ញតា** គឺ ការសមគួរក្នុងកិរិយានៃចិត្ត ។

ចេតសិកទាំងពីរយ៉ាងនេះ

-មានសភាពរម្ងាប់ភាពមិនសមគួរក្នុងកិរិយានៃនាមក្ខន្ធ ៣ និង ចិត្ត ។

-មាននាទីកំចាត់ភាពមិនសមគួរក្នុងកិរិយានៃនាមក្ខន្ធ ៣ និង ចិត្ត ។

-មានការដល់ព្រមនៃការទទួលយកអារម្មណ៍របស់នាមក្ខន្ធ ៣ និង ចិត្តជាផល ។

-មាននាមក្ខន្ធ ៣ និង ចិត្តជាហេតុជិត ។

សូមជ្រាបថា ធម៌ទាំងនេះជាបដិបក្ខដល់កិលេស មាននីវរណជាដើម ( ដែលក្រៅពីឧទ្ធច្ច និង ថីនមិទ្ធ ) ដែលធ្វើឲ្យនាមក្ខន្ធ ៣ និង ចិត្តមិនសមគួរក្នុងកិរិយា ។

ធម៌ទាំងនេះនាំសេចក្ដីជ្រះថ្លាមកឲ្យ ក្នុងវត្ថុដែលជាទីតាំងនៃសេចក្ដីជ្រះថ្លា ( គឺព្រះរតនត្រ័យ ) និង នាំមកនូវភាពសមគួរក្នុងកិរិយាដែលជាប្រយោជន៍ជ្រោមជ្រែង បៀបដូចមាសសុទ្ធ ( មាសសុទ្ធដែលដុតដេញល្អហើយ រមែងគួរ

ដល់ការធ្វើជារូបរាងសណ្ឋានផ្សេងៗ មាន ទុំហ៊ូ ( ក្រវិល ) កងដៃ ខ្សែដៃ ខ្សែក ជាដើម យ៉ាងណាមិញ កម្មញ្ញតាទាំងពីរនេះ ក៏ធ្វើឲ្យចិត្ត និង ចេតសិកសមគួរដល់ការបដិបត្តិ ដែលជាកិច្ចដ៏ល្អ ក៏យ៉ាងនោះដែរ ។

**កាយបាគុញ្ញតា** គឺ ការស្ទាត់ជំនាញនៃនាមក្ខន្ធ ៣ ។

**ចិត្តបាគុញ្ញតា** គឺ ការស្ទាត់ជំនាញនៃចិត្ត ។

ចេតសិកទាំងពីរយ៉ាងនេះ

-មានការមិនឈឺ ( សប្បាយ ) នៃនាមក្ខន្ធ៣ និង ចិត្ត ។

-មាននាទីកំចាត់ភាពមិនសប្បាយនៃនាមក្ខន្ធ៣ និង ចិត្ត ។

-មានភាពមិនមានទោស ( គឺកិលេស ) ជាផល ។

-មាននាមក្ខន្ធ ៣ និង ចិត្តជាហេតុជិត ។

សូមជ្រាបថា ធម៌ទាំងនេះជាបដិបក្ខដល់កិលេស មានការមិនមានសទ្ធាជាដើម ដែលធ្វើឲ្យនាមក្ខន្ធ និង ចិត្តមិនសប្បាយ ។

**កាយុជុកតា** គឺ ភាពទៀងត្រង់នៃនាមក្ខន្ធ ៣ ។

**ចិត្តុជុកតា** គឺ ភាពទៀងត្រង់នៃចិត្ត ។

ចេតសិកទាំងពីរយ៉ាងនេះ

-មានសភាពមិនកោងវៀចនៃនាមក្ខន្ធ ៣ និង ចិត្ត ឬ មានសភាពត្រង់នៃនាមក្ខន្ធ ៣ និង ចិត្ត

-មាននាទីកំចាត់ភាពមិនទៀងត្រង់នៃនាមក្ខន្ធ ៣ និង ចិត្ត ។

-មានភាពត្រង់មិនកោងវៀចជាផល ។

-មាននាមក្ខន្ធ ៣ និង ចិត្តជាហេតុជិត ។

សូមជ្រាបថាធម៌ទាំងនេះជាបដិបក្ខដល់កិលេស មានមាយានិងសាថេយ្យ ( សេចក្តីអួតអាង ) ជាដើម ដែលធ្វើភាពកោងវៀចដល់នាមក្ខន្ធ និង ចិត្ត ។

ពាក្យថា **សាធារណ** គឺចេតសិកដែលទ្រទ្រង់ទុកស្មើគ្នា ( គឺទូទៅ ) ។

ពាក្យថា **សោភណសាធារណ** គឺ ចេតសិកដែលមានទូទៅជាមួយសោភណចិត្តទាំងអស់ ។

ន័យម្យ៉ាងទៀត **សោភណសាធារណ** គឺចេតសិកដែលមានទូទៅដល់សោភណចិត្តទាំងអស់ ។

[ ពាក្យថា **សោភណសាធារណ** មានសេចក្តី ២ ប្រការគឺៈ

-ចេតសិកដែលទូទៅជាមួយសោភណចិត្តទាំងអស់ = **សោភណេហិសាធារណា** > **សោភណសាធារណា** ( តតិយាតប្បុរិសសមាស ) ។

-ចេតសិកដែលទូទៅដល់សោភណចិត្តទាំងអស់ = **សោភណានំ សាធារណា** > **សោភណសាធារណា** ( ចតុត្ថីតប្បុរិសសមាស ) ] ។

# វិរតចេតសិក ៣ ដួង

**[៧] សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ ចេតិ តិស្សោ វិរតិយោ នាម**

ប្រែថា " ចេតសិក ៣ ដួង គឺ **សម្មាវាចា** ( ការពោលត្រូវ ) **សម្មាកម្មន្តោ** ( ការងារត្រូវ ) **និង សម្មាអាជីវោ** ( ការចិញ្ចឹមជីវិតត្រូវ ) ឈ្មោះថា វិរតិចេតសិក " ។

# អធិប្បាយ

ក្នុងពាក្យថា **សម្មាវាចា** នេះ មាន ៣ យ៉ាង ដោយចែកជា

**កថាសម្មាវាចា** គឺ ការពោលល្អ ( ប្រពៃ ) ប្រកបដោយហេតុ ផល ។

**ចេតនាសម្មាវាចា**គឺ ចេតនាដែលជាកុសល ឬ កិរិយា ដែលញ៉ាំងការពោលឲ្យកើតឡើង ។

**វិរតិសម្មាវាចា** គឺការប្រព្រឹត្តិទៅនៃចិត្តដោយអាការៈវៀរចាកបាបរបស់បុគ្គលអ្នកសមាទានសិក្ខាបទ ( មានការវៀរចាកការពោលកុហកជាដើម ) ឬ អធិដ្ឋានដោយខ្លួនឯង ឬ មិនកន្លងអារម្មណ៍ដែលមកដល់។ក្នុងទីនេះសំដៅយកវិរតិសម្មាវាចា ។

**សម្មាវាចា** ( ការពោលប្រពៃ ) គឺសភាវៈធ្វើឲ្យពោលល្អ ។

ន័យម្យ៉ាងទៀត សម្មាវាចានេះ រមែងធ្វើឲ្យពោលល្អ មិនឲ្យពោលមិនល្អ សភាវធម៌នេះទើបបានឈ្មោះថា **សម្មាវាចា** ។

សភាវធម៌នេះ ប្រព្រឹត្តទៅដោយការកម្ចាត់វចីទុច្ចរិត រមែងមាន ដើម្បីសេចក្តីបរិសុទ្ធនៃវចីទ្វារទើបបានឈ្មោះថា **សម្មាវាចា** ។

ក្នុងពាក្យថា **សម្មាកម្មន្តោ** នេះមាន ៣ យ៉ាងដោយចែកជា៖

**កិរិយាសម្មាកម្មន្ត** គឺ ការធ្វើតាមផ្លូវកាយរបស់អ្នកធ្វើកម្មដែលមិនមានទោសយ៉ាងណាមួយ ។

**ចេតនាសម្មាកម្មន្ត** គឺ ចេតនាដែលញុំាងការធ្វើឲ្យកើតឡើង ។

**វិរតិសម្មាកម្មន្ត** គឺ ការប្រព្រឹត្តិទៅនៃចិត្តដោយអាការវៀរចាកបាប របស់បុគ្គលអ្នកសមាទានសិក្ខាបទ មានការវៀរចាកការសម្លាប់សត្វជាដើម ឬអធិដ្ឋានខ្លួនឯង ឬ មិនកន្លងអារម្មណ៍ដែលមកដល់ ។ក្នុងទីនេះសំដៅយកវិរតិសម្មាកម្មន្ត ។

ពាក្យថា **សម្មាកម្ម** គឺ សភាវៈធ្វើឲ្យធ្វើល្អ ។

ពាក្យថា **សម្មាកម្មន្ត** ( ការធ្វើប្រពៃ ) គឺ សភាវៈធ្វើឲ្យធ្វើនុ៎ះៗល្អឯង ដូចពាក្យថា **សុត្តន្ត** ( ព្រះសូត្រ ) **វនន្ត** ( ព្រៃ ) ។

( **អន្ត** ស័ព្ទ ក្នុង **សម្មាកម្មន្ត** = **សម្មាកម្ម** + **អន្ត** ជាតព្ភាវៈ គឺ បទនាមដែលមិនមានសេចក្តីណាៗឡើយ ) ។

សូម្បីសម្មាអាជីវៈ ក៏មាន ២ យ៉ាង ដោយចែកជា ៖

**វិរិយសម្មាអាជីវៈ** គឺ ការព្យាយាម ដែលកំពុងពុះពាររបស់អ្នកចិញ្ចឹមជីវិត ធ្វើកសិកម្ម ឬ ត្រាច់ទៅបិណ្ឌបាតជាដើម ដែលមិនមានទោសជាប្រក្រតី ។

**វិរតិសម្មាអាជីវៈ** គឺ ការប្រព្រឹត្តិទៅនៃចិត្តដោយអាការៈវៀរចាកបាបរបស់បុគ្គលអ្នកសម្លឹងសេចក្តីបរិសុទ្ធិនៃការចិញ្ចឹមជីវិត ហើយកម្ចាត់កាយទុច្ចរិត និង វចីទុច្ចរិត ដែលធ្វើឲ្យអាជីវសីលវិបត្តិទៅ ក្នុងទីនេះសំដៅយកវិរតិសម្មាអាជីវនេះ ។

បណ្តាវិរតិពួកនេះសូម្បីវិរតិមួយៗមាន ៣ ប្រភេទទៀត គឺ ៖

**១- សម្បត្តិវិរតិ** ( ការវៀរក្នុងខណៈដែលមានអារម្មណ៍មកដល់ ) គឺការវៀរដែលកើតឡើងដល់បុគ្គលអ្នកមិនបានសមាទានសិក្ខាបទ តែពិចារណាជាតិ ត្រកូល វ័យ និង វិជ្ជា របស់ខ្លួន ហើយមិនប្រព្រឹត្តកន្លងនូវវត្ថុដែលមកដល់ ដោយគិតថា " យើងមិនគួរធ្វើបាបយ៉ាងនេះ " ដូចការវៀររបស់ឧបាសក ឈ្មោះ **ចក្កន** នៅលើកោះសីហឡៈ ។

ដូចបានស្តាប់មកថាៈ រោគកើតឡើងដល់មាតារបស់ឧបាសកនោះ ឧបាសកនោះ នៅតូចនៅឡើយ ហើយគ្រូពេទ្យ បានពោលថា " គួរបាន សាច់ទន្សាយស្រស់ៗ " លំដាប់នោះ បងប្រុសរបស់គាត់បានប្រើគាត់ឲ្យទៅ ចាប់ទន្សាយ ឲ្យទៅរកទីវាលស្រែ គាត់ក៏បានទៅក្នុងទីនោះ ហើយនៅពេល នោះ គាប់ជួនមានទន្សាយមួយមកស៊ីសំណាប វាបានឃើញឧបាសកនោះ ហើយ ក៏រត់យ៉ាងលឿន តែត្រូវទាក់ជាប់នឹងវល្លិ៍ ក៏បានស្រែកឡើងថា **កិរិ កិរិ ឧបាសក ចក្កន** បានដើរទៅតាមសម្លេងនោះ ចាប់បានវាហើយគិតថា " យើង នឹងយកទៅធ្វើថ្នាំឲ្យមាតា" ហើយក៏បានគិតទៀតថា " យើងសម្លាប់សត្វដទៃ ព្រោះតែជីវិតមាតាជាហេតុនេះមិនសមគួរដល់យើងឡើយ " លំដាប់នោះក៏ បានដោះលែងទន្សាយនោះទៅ ដោយពោលថា "ឯងចូរទៅស៊ីស្មៅ ផឹកទឹក ជាមួយទន្សាយទាំងឡាយដែលនៅក្នុងព្រៃចុះ " ។

នៅពេលគាត់ត្រឡប់ទៅផ្ទះវិញបងប្រុសរបស់គាត់ក៏បានសួរថា " អ្នក បានទន្សាយហើយឬ ? " គាត់ក៏បានប្រាប់រឿងរ៉ាវទាំងនោះដល់បងប្រុសរបស់ គាត់ឲ្យបានជ្រាប លំដាប់នោះបងប្រុសរបស់គាត់បានស្តីបន្ទោសគាត់ គាត់ក៏ បានចូលទៅរកម្តាយគាត់ ហើយក៏បានឈរនៅក្នុងទីនោះ ដោយបានពោល នូវសច្ចវាចាថា " តាំងពីខ្ញុំកើតមក មិនដែលមានចិត្តក្លែងសម្លាប់សត្វឡើយ ដោយសច្ចវាចានេះ សូមឲ្យមាតាបានជាសះស្បើយពីរោគទៅចុះ " ភ្លាមនោះ មាតារបស់គាត់ ក៏បានជាសះស្បើយពីរោគ ។

សម្បត្តិវិរតិមានអារម្មណ៍ជាបច្ចុប្បន្នតែម្យ៉ាង ។

**២- សមាទានវិរតិ** ( ការវៀរចាកដោយការសមាទាន ) គឺការវៀរចាកដែលកើតឡើងដល់បុគ្គលអ្នកសមាទានសិក្ខាបទហើយ ទោះបីមានហេតុដល់ជីវិតក៏មិនប្រព្រឹត្តកន្លងវត្ថុក្នុងពេលសមាទាន និង ពេលបន្ទាប់ពីនោះ ដូចការវៀរចាករបស់ឧបាសកអាស្រ័យនៅភ្នំ ឈ្មោះ **ឧត្តរវឌ្ឍមាន** ។

បានឮមកថាៈ ឧបាសកនោះទទួលសិក្ខាបទក្នុងសម្នាក់របស់ព្រះថេរឈ្មោះ **បិង្គលពុទ្ធរក្ខិត** អ្នកនៅក្នុងវត្តអម្ពរិយ ហើយក៏ចេញទៅភ្ជួរស្រែ គ្រានោះគោរបស់គាត់បាត់ គាត់ក៏តាមរកគោនោះ បានឡើងទៅដល់លើភ្នំឧត្តរវឌ្ឍមាន ត្រូវបានពស់ធំរុំរឹតគាត់ក្នុងទីនោះ គាត់គិតថា “ យើងនឹងកាត់ក្បាលវាដោយកាំបិតដ៏មុតនេះ ” ហើយក៏បានគិតទៀតថា “ យើងបានទទួលសិក្ខាបទក្នុងសម្នាក់ព្រះថេរៈដែលជាបុគ្គលគួរគោរពបូជា បែរជាធ្វើឲ្យវិនាស សេចក្ដីនេះមិនសមគួរដល់យើងឡើយ ” គាត់គិតយ៉ាងនេះរហូតដល់ទៅ ៣ ដង ហើយក៏បានសម្រេចចិត្តថា “ យើងសុខចិត្តលះបង់ជីវិត មិនលះបង់នូវសិក្ខាបទឡើយ” ទើបគាត់គ្រវែងនូវកាំបិតដ៏មុតដែលនៅនឹងស្មារបស់គាត់នោះទៅក្នុងព្រៃ ភ្លាមនោះឯង ពស់ដ៏ធំនោះ ក៏បានរុំសាយការរុំរឹតនោះ ហើយក៏លែងគាត់ឲ្យចេញទៅ ។

**សមាទានវិរតិ** មានអារម្មណ៍ជាបច្ចុប្បន្ន ឬ អនាគត ។

**៣- សមុច្ឆេទវិរតិ** ( ការវៀរចាកដោយដាច់ខាត ) គឺវិរតិដែលកើតឡើងដោយកម្ចាត់មូលនៃទុច្ចរិតទាំងអស់ ក្នុងខណៈមគ្គចិត្តកើត មាននិព្វានជាអារម្មណ៍ សូម្បីក្នុងផលចិត្តក៏រាប់ចូលក្នុងសមុច្ឆេទវិរតិនេះ ចាប់តាំងពីសមុច្ឆេទវិរតិនេះកើតឡើងពេលណា ចិត្តរបស់ព្រះអរិយបុគ្គលទាំងនោះក៏មិនកើតឡើងថា “ យើងនឹងសម្លាប់សត្វ ” ឡើយ ។

## អប្បមញ្ញាចេតសិក ២ និង បញ្ញិន្ទ្រិយចេតសិក ១

**[៨] ករុណា មុទិតា អប្បមញ្ញាយោ នាមាតិ សព្វថាបិ បញ្ញិន្ទ្រិយេន សទ្ធឹ បញ្ចវីសតិមេ ចេតសិកា សោភណាតិ វេទិតព្វា។**

ប្រែថា “ **ករុណា** ( ការអាណិត ) **មុទិតា** ( ការត្រេកអរតាម ) ឈ្មោះថា **អប្បមញ្ញាចេតសិក** ព្រមជាមួយ **បញ្ញិន្ទ្រិយចេតសិក** ( ការដឹងសព្វ ) ចេតសិកទាំងអស់ ២៥ ដួង គប្បីជ្រាបថា ជាសោភណចេតសិក ដោយប្រការដូច្នេះឯង ”។

# អធិប្បាយ

**ករុណា** គឺ សភាវៈធ្វើសេចក្តីលំបាកចិត្តដល់បុគ្គលអ្នកអាណិត កាលបើបានឃើញអ្នកដទៃមានទុក្ខ ។

ន័យម្យ៉ាងទៀត **ករុណា** គឺ សភាវៈកម្ចាត់ទុក្ខរបស់អ្នកដទៃ ។

ន័យម្យ៉ាងទៀត **ករុណា** គឺ សភាវៈទម្លាយទុក្ខរបស់អ្នកដទៃ ។

ន័យម្យ៉ាងទៀត **ករុណា** គឺ សភាវៈដែលបុគ្គលផ្សាយទៅក្នុងទុក្ខិតសត្វ ( សត្វអ្នកប្រសព្វទុក្ខ ) ។

ន័យម្យ៉ាងទៀត ករុណា គឺ សភាវៈការពាររក្សានូវទុក្ខ បាប ឬ សេចក្តីវិនាស ( តាមន័យនេះ ពាក្យថា **ករុណា** កាត់បទជា **កលិ** + **ឧណា** លុបស្រៈ **ឥ** ក្នុង **លិ** ហើយផ្លាស់**ល** ជា **រ** ) **កលិ** គឺ ទុក្ខ ដូចពាក្យថា **កលិសម្ភវេ ភវេ** ( ក្នុងភពដែលជាហេតុនៃទុក្ខ ) ។

ន័យម្យ៉ាងទៀត **ករុណា** គឺ សភាវៈការពារពពួកសត្វឲ្យគេចផុតពីទុក្ខ បាប និង សេចក្តីវិនាស ។

[ ពាក្យថា **ករុណា** មានសេចក្តី ៦ ប្រការគឺ៖

-សភាវៈធ្វើសេចក្តីលំបាកចិត្តដល់បុគ្គលអ្នកអាណិត = **ការុណិកានំ ហទយ-ខេទំ ករោតីតិ** > **ករុណា** ( **ករុ** ធាតុ = ការធ្វើ + **រុណ** បច្ច័យ )។

-សភាវៈកម្ចាត់ទុក្ខរបស់អ្នកដទៃ = **កិរតិ បរទុក្ខំ វិក្ខិបតីតិ** > **ករុណា** ( **កិ** ធាតុ = កម្ចាត់ + **រុណ** បច្ច័យ ) ។

-សភាវៈទម្លាយទុក្ខរបស់អ្នកដទៃ = **កិណាតិ បរទុក្ខំ ហឹសតីតិ** > **ករុណា** ( **កិ** ធាតុ = ទម្លាយ + **រុណ** បច្ច័យ )។

-សភាវៈដែលបុគ្គលផ្សាយទៅក្នុងទុក្ខិតសត្វ = **កិរីយតិ ទុក្ខិតេសុ បសារីយ-តីតិ** > **ករុណា** ( **កិរ** ធាតុ = ផ្សាយទៅ + **រុណ** បច្ច័យ ) ។

-សភាវៈការពារទុក្ខ បាប ឬ សេចក្ដីវិនាស = **កលី សត្តេហិ អវន្តិ រក្ខន្តិ ឯតាយាតិ** > **ករុណា** ( **កលិ** បុព្វបទ + **អវ** ធាតុ = រក្សា + **យុ** បច្ច័យ ) ។

-សភាវៈការពារពពួកសត្វឲ្យគេចផុតពីទុក្ខ បាប និង សេចក្ដីវិនាស = **សត្តេ កលិតោ អវន្តិ រក្ខន្តិ ការុណិកា ជនា ឯតាយាតិ** > **ករុណា** ( **កលិ** បុព្វបទ + **អវ** ធាតុ = រក្សា + **យុ** បច្ច័យ ) ] ។

**ករុណាៈ**

-មានការប្រព្រឹត្តិទៅដោយអាការៈកម្ចាត់ទុក្ខរបស់អ្នកដទៃ ជាលក្ខណៈ

-មាននាទីអត់ទ្រាំឃើញទុក្ខរបស់សត្វដទៃមិនបាន ។

-មានសេចក្ដីមិនបៀតបៀន ជាផល ។

-មានការឃើញសត្វត្រូវទុក្ខគ្របសង្កត់ មិនមានទីពឹង ជាហេតុជិត ។

-មានសេចក្ដីស្ងប់ពីសេចក្ដីបៀតបៀន ជាសម្បត្តិ ។

-មានសេចក្ដីសោកកើតឡើង ជាវិបត្តិ ។

**មុទិតា** ( ការត្រេកអរតាម ) គឺ សភាវៈធ្វើឲ្យត្រេកអរ ព្រោះឃើញសម្បត្តិរបស់អ្នកដទៃ ។

ន័យម្យ៉ាងទៀត **មុទិតា** គឺ សភាវៈត្រេកអរ ។

ន័យម្យ៉ាងទៀត **មុទិតា** គឺ ការត្រេកអរ ។

[ ពាក្យថា **មុទិតា** មានសេចក្ដី ៣ ប្រការគឺៈ

-សភាវៈធ្វើឲ្យត្រេកអរ = **មោទន្តិ តាយតិ** > **មុទិតា** ( ចុះ **ត** បច្ច័យ ក្នុងករណ-សាធន ) ។

-សភាវៈត្រេកអរ = **មោទតីតិ** > **មុទិតា** ( ចុះ **ត** បច្ច័យ ក្នុងកត្តុសាធន )។

- ការត្រេកអរ = **មោទនំ** > **មុទិតា** ( ចុះ **ត** បច្ច័យភាវសាធន ) ] ។

**មុទិតាៈ**

-មានការត្រេកអរ ជាលក្ខណៈ ។

-មាននាទីមិនច្រណែន ។

-មានការកម្ចាត់សេចក្ដីមិនរីករាយក្នុងកុសល ជាផល ។

-មានការឃើញសម្បត្តិរបស់ពពួកសត្វ ជាហេតុជិត ។

-មានការស្ងប់អរតិ ( មិនត្រេកអរ ) ជាសម្បត្តិ ។

-មានសេចក្ដីរីករាយកើតឡើង ( ដោយលោភ ) ជាវិប្បត្តិ ។

ពាក្យថា **អប្បមាណ** គឺពពួកសត្វមិនមានប្រមាណ ។

**អប្បមញ្ញា** គឺ ចេតសិកដែលប្រព្រឹត្តទៅក្នុងពពួកសត្វមិនមានប្រមាណ ។ ការពិត ចេតសិកទាំងនេះ សូម្បីប្រព្រឹត្តទៅក្នុងបុគ្គលម្នាក់ ក៏ឈ្មោះថា**អប្បមញ្ញា** ព្រោះមិនមានប្រមាណក្នុងការកំណត់ថា គប្បីចម្រើនក្នុងបុគ្គលមានប្រមាណប៉ុណ្ណោះ មិនគប្បីចម្រើនក្នុងបុគ្គលក្រៅពីនេះឡើយ ។

## បញ្ញិន្ទ្រិយ

ពាក្យថា **បញ្ញិន្ទ្រិយ** ( បញ្ញា + ឥន្ទ្រិយ ) គឺអមោហៈដែលពោលទុកហើយ អមោហៈ ឈ្មោះថា **បញ្ញា** ព្រោះជាសភាវៈធ្វើឲ្យប្រត្យ័ក្ស គឺ ធ្វើសេចក្ដីនោះៗឲ្យជាក់ច្បាស់ ។ ន័យម្យ៉ាងទៀត **បញ្ញា** ព្រោះដឹងធម៌ដោយប្រការផ្សេងៗ មានការមិនទៀងជាដើម ។

[ ពាក្យថា **បញ្ញា** មានសេចក្ដី ២ ប្រការគឺៈ

-សភាវៈធ្វើឲ្យប្រត្យក្ស = **បញ្ញាបេតីតិ** > **បញ្ញា** ( **ប** បុព្វបទ + **ញា** ធាតុ = ប្រត្យក្ស + **ណាបេ** ការិតបច្ច័យ + **អ** បច្ច័យ + **អា** ឥត្ថីបច្ច័យ )។

-សភាវៈដឹងធម៌ដោយប្រការផ្សេងៗ = **បការេន ធម្មេ ជានាតីតិ** > **បញ្ញា** ( **ប** បុព្វបទ + **ញា** ធាតុ = ដឹង + **អ** បច្ច័យ + **អា** ឥត្ថីបច្ច័យ ) ] ។

ពាក្យថា **បជាននា** គឺ ការដឹងច្បាស់ដោយប្រការផ្សេងៗ ។

ពាក្យថា **វិចយ** គឺ គន់គិតធម៌មានសភាពមិនទៀងជាដើម ។

ពាក្យថា**បវិចយ** គឺ បទដែលថែមឧបសគ្គចូលមក ( **ប** ឧបសគ្គ ពុំមានសេចក្ដីណាឡើយ ) ។

ពាក្យថា **ធម្មវិចយ** គឺ ការជ្រើសរើសនូវធម៌ (សច្ច ៤ ) ។

ពាក្យថា **សលក្ខណា** គឺ ការកំណត់នូវភាពមិនទៀងជាដើម ។

ពាក្យថា **មេធា** គឺ សភាវៈទម្លាយកិលេស ដូចរន្ទះពុះភ្នំថ្ម ។

ន័យម្យ៉ាងទៀត **មេធា** ព្រោះរៀន និង ទ្រទ្រង់ចាំបានលឿន ។

[ពាក្យថា **មេធា** មានសេចក្ដី ២ ប្រការគឺះ

-សភាវៈទម្លាយកិលេស = **កិលេសេ មេធេតិ ហឹសតីតិ** > **មេធា** ( **មេធ** ធាតុ = បៀតបៀន + **អ** បច្ច័យ + **អា** ឥត្ថីបច្ច័យ )។

-សភាវៈទទួលយកបានលឿន = **មេធតិ ខិប្បំ គណ្ហាតីតិ** > **មេធា** ( **មេធ** ធាតុ = ទទួលយកលឿន + **អ** បច្ច័យ + **អា** ឥត្ថីបច្ច័យ )] ។

ពាក្យថា **វិបស្សនា** គឺ បញ្ញាជាគ្រឿងឃើញច្បាស់ ។

ពាក្យថា **សម្បជញ្ញ** គឺ បញ្ញាជាគ្រឿងដឹងម៉ត់ចត់ ឬ ល្អិតល្អន់។

ពាក្យថា **បតោទ** គឺ បញ្ញាដូចជន្លួញ ព្រោះចាក់ចិត្តដែលកោងវៀចទៅខុសផ្លូវឲ្យឡើងកាន់ផ្លូវត្រូវ ដូចជន្លួញចាក់សេះសិន្ធពដែលរត់ខុសផ្លូវ ឲ្យរត់ត្រូវផ្លូវវិញ។

ពាក្យថា **បញ្ញាពល** ព្រោះមិនញាប់ញ័រក្នុងអវិជ្ជា ។

ពាក្យថា **បញ្ញាសត្ថ** ព្រោះជាសភាវៈទម្លាយកិលេស ។

ពាក្យថា **បញ្ញាបាសាទ** ព្រោះជាសភាវៈខ្ពង់ខ្ពស់ ។

ពាក្យថា **បញ្ញាអាលោក** ព្រោះជាសភាវៈភ្លឺស្វាង ។

ពាក្យថា **បញ្ញាបជ្ជោត** ព្រោះបញ្ញាជាប្រទីបភ្លឺរុងរោចន៍ ។

ពាក្យថា **បញ្ញារតន** បញ្ញាជាសភាវៈត្រេកអរ , ឲ្យត្រេកអរ, ឲ្យកើតសេចក្ដីត្រេកអរ, គួរធ្វើការគោរព, ឃើញបានដោយលំបាក, រកអ្វីប្រៀបពុំបាន, ជាគ្រឿងបរិភោគរបស់សត្វខ្ពង់ខ្ពស់ ។ សមដូចព្រះអដ្ឋកថាពន្យល់ថាៈ

**ចិត្តីកតំ មហគ្ឃញ្ច អតុលំ ទុល្លភទស្សនំ**

**អនោមសត្តបរិភោគំ រតនំ តេន វុច្ចតិ ។**

ប្រែថា “ ព្រះរតនត្រៃ ជាវត្ថុដែលគួរធ្វើការគោរព មានតម្លៃច្រើនរកអ្វីមកប្រៀបពុំបាន ឃើញបានដោយលំបាក ជាគ្រឿងបរិភោគរបស់សត្វខ្ពង់ខ្ពស់ ដូច្នេះហើយ ទើបហៅថារតន ”។

**ចប់ការសម្តែងសេចក្តីបរមត្ថក្នុងសោភណរាសី**

## គាថាសរុប

**[៩] ឯត្តាវតា ច-**

**តេរសញ្ញសមានា ច ចុទ្ទសាកុសលា តថា,**

**សោភណា បញ្ចវីសាតិ ទ្វិបញ្ញាស បវុច្ចរេ ។**

ប្រែថា “ ដោយពាក្យមានប្រមាណប៉ុណ្ណេះ

លោកពោលថាចេតសិក ៥២ ដួងគឺៈ អញ្ញសមានាចេតសិក ១៣ ដួង អកុសលចេតសិក ១៤ ដួង និង សោភណាចេតសិក ២៥ ដួង ” ។

## អធិប្បាយ

ពាក្យថា **ឯត្តាវតា** ( ដោយហេតុមានប្រមាណប៉ុណ្ណេះ ) ជាដើម ជាការរាប់ចំនួនរាសីទាំង ៣ ( អញ្ញសមានារាសី អកុសលរាសី និងសោភណរាសី )។

## សម្បយោគន័យ ១៦

### ( ការប្រកបរបស់ចេតសិកក្នុងចិត្ត )

**[១០] តេសំ ចិត្តាវិយុត្តានំ យថាយោគមិតោ បរំ**

**ចិត្តុប្បាទេសុ បច្ចេកំ សម្បយោគោ បវុច្ចតិ ។**

ប្រែថា “ តពីនេះទៅ ខ្ញុំព្រះករុណានឹងសម្តែងការប្រកបចេតសិកទាំងនោះ ក្នុងចិត្តដែលជាទីកើត ( របស់ចេតសិក ) ក្នុងដួងនីមួយៗ តាមសមគួរ ”។

# អធិប្បាយ

ព្រះអនុរុទ្ធាចារ្យ បានសម្តែងអង្គធម៌របស់ចេតសិក ៥២ ដួង ដូច្នេះហើយ ឥឡូវនេះ នឹងសម្តែងលក្ខណៈដែលចេតសិកប្រកបជាមួយចិត្ត ទើបពោលគាថាថា **តេសំ** ជាដើម ។

**សម្បយោគន័យ** គឺ ការប្រកបរបស់ចេតសិកក្នុងចិត្ត ដើម្បីសម្តែងថា ចេតសិកនីមួយៗ ប្រកបបានក្នុងចិត្តទាំងអស់ប៉ុន្មានដួង គឺអ្វីខ្លះ ? ដូចជា វិតក្កចេតសិក ប្រកបបានក្នុងចិត្តទាំងអស់ ៥៥ ដួង ជាដើម ។

# សង្គហគាថា

**[១១] សត្ត សព្វត្ថ យុជ្ជន្តិ យថាយោគំ បកិណ្ណកា**

**ចុទ្ទសាកុសលេស្វេវ សោភណេស្វេវ សោភណា។**

ប្រែថា “ សព្វចិត្តសាធារណចេតសិក ៧ ដួង ប្រកបបានក្នុងចិត្តទាំងអស់ បកិណ្ណកចេតសិក ៦ ដួង ប្រកបបានក្នុងចិត្តតាមសមគួរ ( មិនគ្រប់ដួង ) អកុសលចេតសិក ១៤ ដួង ប្រកបបានចំពោះ ក្នុងអកុសលចិត្តប៉ុណ្ណោះ សោភណចេតសិក ២៥ ដួង ប្រកបបានចំពោះក្នុងសោភណចិត្តប៉ុណ្ណោះ ” ។

# អញ្ញសមានាចេតសិក សម្បយោគន័យ

## ( ការប្រកបអញ្ញសមានាចេតសិក )

**[១២] កថំ ?** ចេតសិកប្រកបក្នុងចិត្តយ៉ាងដូចម្តេច ?

**សព្វចិត្តសាធារណា តាវ សត្តិមេ ចេតសិកា សព្វេសុបិ ឯកូនននុតិចិត្តុប្បាទេសុ លព្ភន្តិ ។**

ប្រែថា លំដាប់ដំបូង ចេតសិក ៧ ដួង ដែលមានទូទៅដល់ចិត្តទាំងពួង ទាំងអស់នេះ រមែងកើតក្នុងចិត្តដែលជាទីកើត ( របស់ចេតសិក ) ទាំង ៨៩ ដួង។

**[១៣] បកិណ្ណកេសុ បន វិតក្កោ តាវ ទ្វិបញ្ចវិញ្ញាណវជ្ជិតកាមាវចរចិត្តេសុ ចេវ, ឯកាទសសុ បឋមជ្ឈានចិត្តេសុ ចាតិ បញ្ចបញ្ញាសចិត្តេសុ ឧប្បជ្ជតិ ។**

ប្រែថា តែក្នុងបកិណ្ណកចេតសិកទាំងឡាយ លំដាប់ដំបូង វិតក្កចេតសិក កើតបានក្នុងចិត្ត ៥៥ ដួង គឺៈ កាមាវចរចិត្ត ៤៤ ( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ ) និង ក្នុងបឋមជ្ឈានចិត្ត ១១ ។

**[១៤] វិចារោ បន តេសុ ចេវ, ឯកាទសសុ ទុតិយជ្ឈានចិត្តេសុ ចាតិ ឆសដ្ឋិចិត្តេសុ ។**

ប្រែថា ចំណែកវិចារចេតសិក កើតបានក្នុងចិត្ត ៦៦ ដួង គឺៈ ក្នុងចិត្ត ( ៥៥ ដួង ដែលវិតក្កចេតសិកកើតបាន ) ពួកនោះ និង ក្នុងទុតិយជ្ឈានចិត្ត ១១ ។

**[១៥] អធិមោក្ខោ ទ្វិបញ្ចវិញ្ញាណវិចិកិច្ឆាសហគតវជ្ជិតចិត្តេសុ ។**

ប្រែថា រីឯអធិមោក្ខចេតសិក កើតបានក្នុងចិត្តដែលវៀរទ្វិបញ្ចវិញ្ញាណ-ចិត្ត និង វិចិកិច្ឆាសម្បយុត្តចិត្ត ។

**[១៦] វីរិយំ បញ្ចទ្វារាវជ្ជនទ្វិបញ្ចវិញ្ញាណសម្បដិច្ឆនសន្តីរណវជ្ជិតចិត្តេសុ ។**

ប្រែថា ឯវីរិយចេតសិក កើតក្នុងចិត្តដែលវៀរបញ្ចទ្វារាវជ្ជនចិត្ត ១ ដួង ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ដួង សម្បដិច្ឆនចិត្ត ២ ដួង សន្តីរណចិត្ត ៣ ដួង ( គឺចិត្ត ៧៣ វៀរអហេតុកចិត្ត ១៦ ដួង ) ។

**[១៧] បីតិ ទោមនស្សុបេក្ខាសហគតកាយវិញ្ញាណចតុត្ថជ្ឈានវជ្ជិតចិត្តេសុ ។**

ប្រែថា បីតិចេតសិក កើតក្នុងចិត្តដែលវៀរទោមនស្សសហគតចិត្ត ( ២ ដួង ) ឧបេក្ខាសហគតចិត្ត [ ៥៥ ដួង ] កាយវិញ្ញាណចិត្ត [ ២ ដួង ] ចតុត្ថជ្ឈានចិត្ត ( ១១ដួង ) [ គឺចិត្ត ៥១ ដួង ( វៀរ ២, ៥៥, ២, ១១ ) ] ។

**[១៨] ឆន្ទោ អហេតុកមោមូហវជ្ជិតចិត្តេសូតិ ។**

ប្រែថា ឆន្ទចេតសិក កើតក្នុងចិត្តដែលវៀរអហេតុកចិត្ត ( ១៨ ដួង ) មោហមូលចិត្ត (២ ដួង) [ គឺចិត្ត ៦៩ ( វៀរ ១៨ , ២ ) ] ។

# អធិប្បាយ

បកិណ្ណកចេតសិក ៦ ដួង រមែងមិនកើតក្នុងទ្វិបញ្ចវិញ្ញាណចិត្ត ព្រោះមានកម្លាំងតិចជាងចិត្តទាំងអស់ ។

**-វិតក្កៈ** រមែងមិនកើតក្នុងទុតិយជ្ឈានចិត្តជាដើម ។

**-វិចារៈ** រមែងមិនកើតក្នុងតតិយជ្ឈានចិត្តជាដើម ។

**-បីតិ** រមែងមិនកើតក្នុងចតុត្ថជ្ឈានចិត្តជាដើម ព្រោះត្រូវកម្ចាត់ដោយអានុភាពនៃភាវនា ។

**-អធិមោក្ខៈ** រមែងមិនកើតក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ដែលមានសភាពស្ទាក់ស្ទើរ ( មិនចុះស៊ប់ ) ព្រោះអធិមោក្ខមានសភាពចុះចិត្តជឿស៊ប់ ។

**-វិរិយៈ** រមែងមិនកើតក្នុងចិត្ត ១៦ ដួងគឺៈ បញ្ចទ្វារាវជ្ជនចិត្តជាដើម ដែលមានកម្លាំងតិច ព្រោះវិរិយជាប្រធាននៃពលធម៌ ( ធម៌ដែលមានកម្លាំង ) ។

**-បីតិ** រមែងមិនកើតក្នុងចិត្តដែលប្រកបដោយទោមនស្សវេទនា និង ឧបេក្ខាវេទនា ព្រោះបីតិមានសភាពត្រេកអរ ។

**-ឆន្ទៈ** រមែងមិនកើតក្នុងអហេតុកចិត្ត និង មោហមូលចិត្ត ដែលប្រាសចាកសេចក្ដីប្រាថ្នា ព្រោះឆន្ទៈមានសេចក្ដីប្រាថ្នា ហេតុដូច្នេះ លោកទើបពោលថា **បកិណ្ណកេសុ បន ។ ប ។ មោមូហវជ្ជិតចិត្តេសុ** ( តែក្នុងចេសិកទាំងឡាយ ... ... ឆន្ទចេតសិក កើតក្នុងចិត្តវៀរអហេតុកចិត្ត ១៨ ដួង មោហមូលចិត្ត ២ ដួង ) ។

# គាថាសរុប

**[១៩] តេ បន ចិត្តុប្បាទា យថាក្កមំ ៖**

**ឆសដ្ឋិ បញ្ចបញ្ញាស ឯកាទស ច សោឡស**
**សត្តតិ វីសតិ ចេវ បកិណ្ណកវិវជ្ជិតា ។**
**បញ្ចបញ្ញាស ឆសដ្ឋិ- ដ្ឋសត្តតិ តិសត្តតិ**
**ឯកបញ្ញាស ចេកូន- សត្តតិ សបកិណ្ណកា ។**

ប្រែថា “ ចិត្តដែលជាទីកើត [ នៃចេតសិក ] ទាំងនោះ ដែលវៀរពីបកិណ្ណកចេតសិក មាន ៦៦ ដួង ៥៥ ដួង ១១ ដួង ១៦ ដួង ៧០ ដួង និង ២០ ដួងតាមលំដាប់ ។

ចិត្តដែលប្រកបដោយបកិណ្ណកចេតសិកមាន ៥៥ ដួង ៦៦ ដួង ៧៨ ដួង ៧៣ ដួង ៥១ ដួង និង ៦៩ ដួង ” ។

[ **វិតក្កៈ** ប្រកបមិនបានក្នុងចិត្ត ៦៦ ដួងគឺៈ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ទុតិយជ្ឈានចិត្ត ១១ តតិយជ្ឈានចិត្ត ១១ ចតុត្ថជ្ឈានចិត្ត ១១ បញ្ចមជ្ឈានចិត្ត ២៣ ។

**វិចារៈ** ប្រកបមិនបានក្នុងចិត្ត ៥៥ ដួងគឺៈ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ តតិយជ្ឈានចិត្ត ១១ ចតុត្ថជ្ឈានចិត្ត ១១ បញ្ចមជ្ឈានចិត្ត ២៣។

**អធិមោក្ខៈ** ប្រកបមិនបានក្នុងចិត្ត ១១ ដួងគឺៈ វិចិកិច្ឆាសម្បយុត្តចិត្ត ១ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ។

**វីរិយៈ** ប្រកបមិនបានក្នុងចិត្ត ១៦ ដួងគឺៈ អហេតុកចិត្ត ១៦ ( វៀរមនោទ្វារាវជ្ជនចិត្ត ១ ហសិតុប្បាទចិត្ត ១ ) ។

**បីតិ** ប្រកបមិនបានក្នុងចិត្ត ៧០ ដួងគឺៈ ឧបេក្ខាលោភមូលចិត្ត ៤ ទោសមូលចិត្ត ២ មោហមូលចិត្ត ២ ឧបេក្ខាអហេតុកចិត្ត ១៤ កាយវិញ្ញាណចិត្ត ២ ឧបេក្ខាកាមាវចរសោភណចិត្ត ១២ ចតុត្ថជ្ឈានចិត្ត ១១ បញ្ចមជ្ឈានចិត្ត ២៣ ។

**ឆន្ទៈ** ប្រកបមិនបានក្នុងចិត្ត ២០ ដួងគឺៈ មោហាមូលចិត្ត អហេតុកចិត្ត ១៨ ។

**វិតក្កៈ** ប្រកបក្នុងចិត្ត ៥៥ ដួងគឺៈ អកុសលចិត្ត ១២ អហេតុកចិត្ត ៨ ( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ ) កាមាវចរសោភណចិត្ត ២៤ បឋមជ្ឈានចិត្ត ១១ ។

**វិចារៈ** ប្រកបក្នុងចិត្ត ៦៦ ដួងគឺៈ អកុសលចិត្ត ១២ អហេតុកចិត្ត ៨ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ ) កាមាវចរសោភណចិត្ត ២៤ បឋមជ្ឈានចិត្ត ១១ ទុតិយជ្ឈានចិត្ត ១១ ។

**អធិមោក្ខៈ** ប្រកបក្នុងចិត្ត ៧៨ ដួងគឺៈ អកុសលចិត្ត ១១ ( វៀរវិចិកិច្ឆាសម្បយុត្តចិត្ត ១ ) អហេតុកចិត្ត ៨ ( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ ) កាមាវចរសោភណចិត្ត ២៤ មហគ្គតចិត្ត ២៧ លោកុត្តរចិត្ត ៨។

**វីរិយៈ** ប្រកបក្នុងចិត្ត ៧៣ ដួងគឺៈ អកុសលចិត្ត ១២ មនោទ្វារាវជ្ជនចិត្ត ១ ហសិតុប្បាទចិត្ត ១ កាមាវចរសោភណចិត្ត ២៤ មហគ្គតចិត្ត ២៧ លោកុត្តរចិត្ត ៨។

**បីតិ** ប្រកបក្នុងចិត្ត ៥១ ដួងគឺៈ សោមនស្សលោភមូលចិត្ត ៤ សោមនស្សសន្តីរណចិត្ត ១ សោមនស្សហសិតុប្បាទចិត្ត ១ សោមនស្សកាមាវចរសោភណចិត្ត ១២ បឋមជ្ឈានចិត្ត ១១ ទុតិយជ្ឈានចិត្ត ១១ តតិយជ្ឈានចិត្ត ១១ ។

**ឆន្ទៈ** ប្រកបក្នុងចិត្ត ៦៩ ដួង គឺៈ លោភមូលចិត្ត ៨ ទោសមូលចិត្ត ២ កាមាវចរសោភណចិត្ត ២៤ មហគ្គតចិត្ត ២៧ លោកុត្តរចិត្ត ៨ ] ។

# អកុសលចេតសិក សម្បយោគន័យ

## ( ការប្រកបអកុសលចេតសិក )

**[២០] អកុសលេសុ បន មោហោ អហិរិកំ អនោត្តប្បំ ឧទ្ធច្ចញ្ចាតិ ចត្តារោមេ ចេតសិកា សព្វាកុសលសាធារណា នាម សព្វេសុបិ ទ្វាទសាកុសលេសុ លព្ភន្តិ ។**

ប្រែថា “ ម្យ៉ាងទៀត បណ្តាអកុសលចេតសិកទាំងឡាយ ចេតសិក ៤ ដួងទាំងនេះគឺ មោហៈ អហិរិកៈ អនោត្តប្បៈ និង ឧទ្ធច្ចៈ ឈ្មោះថា សព្វា-កុសលសាធារណចេតសិក រមែងកើតក្នុងអកុសលចិត្ត ១២ ដួងទាំងអស់ ” ។

# អធិប្បាយ

ពាក្យថា **អកុសលេសុ** ប្រែថា ក្នុងអកុសលចិត្តទាំងឡាយ ។

គប្បីប្រកប បទថា ចេតសិក ៤ ដួងនេះ គឺៈ **មោហៈ អហិរិកៈ អនោតប្បៈ និង ឧទ្ធច្ចៈ** ឈ្មោះថា សព្វាកុសលសាធារណចេតសិក ( ចេតសិកដែលមានទូទៅក្នុងអកុសលចិត្តទាំងអស់ ) ។

ចំណែកអកុសលចិត្តទាំងអស់ រមែងមិនកើតដោយប្រាសចាកអកុសលចេតសិក ៤ ដួងមានមោហៈជាដើម ព្រោះអកុសលចិត្ត រមែងមិនកើតដល់អ្នកឃើញទោសក្នុងបាប ទាំងមិនកើតដល់អ្នកនឿយណាយដោយការខ្មាស់ ឬតក់ស្លុតដល់អកុសល និង មិនកើតដល់អ្នកតាំងមាំក្នុងកុសលធម៌ ដូច្នេះ អកុសលចេតសិក ៤ ដួងនេះ ទើបកើតក្នុងអកុសលចិត្តទាំងអស់ ។

**[២១] លោភោ អដ្ឋសុ លោភសហគតចិត្តេស្វេវ លព្ភតិ ។**

ប្រែថា លោភចេតសិក រមែងកើតក្នុងលោភមូលចិត្ត ៨ ដួងប៉ុណ្ណោះ ។

**[២២] ទិដ្ឋិ ចតូសុ ទិដ្ឋិគតសម្បយុត្តេសុ ។**

ប្រែថា ទិដ្ឋិចេតសិក រមែងកើតក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង ។

**[២៣] មានោ ចតូសុ ទិដ្ឋិគតវិប្បយុត្តេសុ ។**

ប្រែថា មានចេតសិករមែងកើតក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង ។

# អធិប្បាយ

ទិដ្ឋិ និង មានៈចេតសិក មិនលះសេចក្តីពេញចិត្តក្នុងខន្ធ រមែងប្រព្រឹត្តទៅដោយប្រកាន់មាំក្នុងខន្ធដោយអាការៈនោះៗ ទិដ្ឋិ និង មានៈ ទើបកើតក្នុងលោភមូលចិត្ត ។

ក្នុងរឿងនោះទិដ្ឋិប្រកាន់មាំក្នុងខន្ធទាំងឡាយថាជាតួខ្លួន រមែងប្រព្រឹត្តទៅដោយការប្រកាន់មាំថាជាតួខ្លួន ដោយសភាពមិនត្រូវទំនង គឺយល់ថាមានសភាពទៀងមិនប្រែប្រួលជាដើម, ចំណែកមានះប្រកាន់មាំក្នុងខន្ធថាជាយើង រមែងប្រព្រឹត្តទៅដោយអាការៈប្រកាន់មាំថា ខ្លួនប្រសើរជាងអ្នកដទៃជាដើម, ទិដ្ឋិ និង មានះ ទើបមានការប្រព្រឹត្តិទៅផ្សេងគ្នា ក្នុងអាការៈប្រកាន់មាំដូច្នេះ ទើបលោកពោលថា **ទិដ្ឋិ ចតូសុ ។ បេ ។ វិប្បយុត្តេសុ ។**

ជនទាំងឡាយណានៅមានសក្កាយទិដ្ឋិ ប្រកាន់ខ្លួនតាមកម្លាំងទិដ្ឋិថាជាយើង ទិដ្ឋិ និង មានះរបស់ពួកគេរមែងមានសភាវៈផ្សេង កាលមានអាការៈប្រកាន់មាំ ទិដ្ឋិមិនមានការខ្វល់ខ្វាយក្នុងការលើកតម្កើងខ្លួនដូចមានះ មានះក៏មិនខ្វល់ខ្វាយត្រិះរិះក្នុងការមិនមានពិតដូចទិដ្ឋិ មានះដែលប្រកាន់ខ្លួន ទើបកើតឡើងដល់ព្រះអនាគាមី ចំណែកទិដ្ឋិប្រកាន់មាំថាជាតួខ្លួន រមែងកើតក្នុងបុថុជ្ជនប៉ុណ្ណោះ ។

**[២៤] ទោសោ ឥស្សា មច្ឆរិយំ កុក្កុច្ចញ្ចាតិ ទ្វីសុ បដិឃសម្បយុត្តចិត្តេសុ ។**

ប្រែថា ចេតសិក ៤ ដួងគឺៈ ទោសៈ ឥស្សា មច្ឆរិយៈ និង កុក្កុច្ចៈ រមែងកើតក្នុងបដិឃសម្បយុត្តចិត្ត ២ ដួង ។

## អធិប្បាយ

ចំណែកមច្ឆរិយ សូម្បីកើតឡើងដោយការជាប់ជំពាក់ក្នុងសម្បត្តិរបស់ខ្លួន ក៏ជាសភាវៈប្រកបដោយបដិឃ ព្រោះប្រព្រឹត្តទៅដោយអាការៈទ្រាំមិនបាន ក្នុងការដែលអ្នកដទៃបានទទួលសម្បត្តិទាំងនោះ លោកទើបពោលថា **ទោសោ ។ប។ ចិត្តេសុ ។**

**[២៥] ថីនមិទ្ធំ បញ្ចសុ សសង្ខារិកចិត្តេសុ ។**

ប្រែថា ថីនចេតសិក និង មិទ្ធចេតសិក រមែងកើតក្នុងសសង្ខារិកចិត្ត ៥ ដួង ។

# អធិប្បាយ

ថីនមិទ្ធ មានលក្ខណៈមិនសមគួរក្នុងកិរិយា រមែងមិនមានក្នុងអសង្ខារិក-ចិត្ត ដែលមានសភាពសមគួរក្នុងកិរិយា ដូច្នេះលោកទើបពោលថា **ថីនមិទ្ធំ បញ្ចសុ សសង្ខារិកចិត្តេសុ ។**

[២៦] **វិចិកិច្ឆា វិចិកិច្ឆាសហគតចិត្តេយេវាតិ ។**

ប្រែថា វិចិកិច្ឆាចេតសិក រមែងកើតក្នុងវិចិកិច្ឆាសម្បយុត្តចិត្តប៉ុណ្ណោះ ។

# គាថាសរុប

[២៧] **សព្វាបុញ្ញេសុ ចត្តារោ　　លោភមូលេ តយោ គតា**
**ទោសមូលេសុ ចត្តារោ　　សសង្ខារេ ទ្វយំ តថា ។**
**វិចិកិច្ឆា វិចិកិច្ឆា-　　ចិត្តេ ចាតិ ចតុទ្ទស**
**ទ្វាទសាកុសលេស្វេវ　　សម្បយុជ្ជន្តិ បញ្ចធា ។**

ប្រែថា “ អកុសលចេតសិក ១៤ ប្រកបក្នុងអកុសលចិត្ត ១២ ដួង ប៉ុណ្ណោះ បាន ៥ ន័យ គឺ៖ ចេតសិក ៤ ដួង ប្រកបក្នុងអកុសលចិត្តទាំងអស់ ចេតសិក ៣ ដួង ប្រកបក្នុងលោភមូលចិត្ត ចេតសិក ៤ ដួង ប្រកបក្នុងទោសមូលចិត្ត ចេតសិក ២ ដួង ប្រកបក្នុងសសង្ខារិកចិត្ត វិចិកិច្ឆាចេតសិក ប្រកបក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ” ។

# អធិប្បាយ

ចេតសិក ៤ ដួងគឺ៖ សព្វាកុសលសាធារណចេតសិក ចេតសិក ៣ ដួង គឺ៖ លោភៈ ទិដ្ឋិ មានៈ, ចេតសិក ៤ ដួងគឺ៖ ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ ចេតសិក ២ ដួងគឺ៖ ថីនៈ មិទ្ធៈ ។

**ច** ស័ព្ទក្នុងពាក្យថា **វិចិកិច្ឆាចិត្តេ ច** ( ក្នុងវិចិកិច្ឆាចិត្តប៉ុណ្ណោះ ) ប្រព្រឹត្តទៅក្នុងអត្ថថា **អវធារណ** ( ហាមសេចក្តីដទៃ ) សេចក្តីថា ក្នុងវិចិកិច្ឆាចិត្តប៉ុណ្ណោះ ។

ពាក្យថា **ចតុទ្ទស** ( ចេតសិក ១៤ ដួង ) បានដល់ អកុសលចេតសិក ។

# សោភណចេតសិក សម្បយោគន័យ

## ( ការប្រកបសោភណចេតសិក )

**[២៨] សោភណេសុ បន សោភណសាធារណា តាវ ឯកូនវីសតិមេ ចេតសិកា សព្វេសុបិ ឯកូនសដ្ឋិ សោភណចិត្តេសុ សំវិជ្ជន្តិ ។**

ប្រែថា ម្យ៉ាងទៀត លំដាប់ដំបូង បណ្ដាសោភណចេតសិក ចេតសិក ១៩ ដួង ដែលទូទៅដល់សោភណចិត្ត ប្រកបក្នុងសោភណចិត្ត ៥៩ ដួងទាំងអស់ ។

ពាក្យថា **សោភណេសុ**ប្រែថា ក្នុងសោភណចេតសិក ។

**[២៩] វិរតិយោ បន តិស្សោបិ លោកុត្តរចិត្តេសុ សព្វថាបិ និយតា ឯកតោវ លព្ភន្តិ, លោកិយេសុ បន កាមាវចរកុសលេស្វេវ កទាចិ សន្ទិស្សន្តិ វិសុំ វិសុំ ។**

ប្រែថា វិរតិចេតសិក ៣ ដួង រមែងកើតទៀងទាត់ព្រមគ្នា ក្នុងលោកុត្តរ-ចិត្តដោយប្រការទាំងពួង តែបណ្ដាលោកិយចិត្តទាំងឡាយ ចំពោះក្នុងកាមា-វចរកុសលចិត្តប៉ុណ្ណោះ វិរតិចេតសិក រមែងប្រាកដក្នុងពេលខ្លះ ហើយផ្សេងៗគ្នា ។

# អធិប្បាយ

ក្នុងប្រយោគនោះ ពាក្យថា **និយតាវ** ( ទៀងទាត់ ) បានសេចក្ដីថា មិនមែនកើតក្នុងពេលខ្លះប៉ុណ្ណោះ ដូចក្នុងលោកិយចិត្ត តែកើតទៀងទាត់គ្រប់ពេល ។

-សួរថា: ហេតុដូចម្ដេច ?

-ឆ្លើយថា: ព្រោះធម៌ដែលជាលោកុត្តរៈ ប្រព្រឹត្តទៅដោយការញ៉ាំងសីលឲ្យពេញបរិបូរជានិច្ចជាកាល ដោយពិតហើយ **លោកុត្តរវិរតី** រមែងមិន

ប្រព្រឹត្តទៅដោយសារទានខ្លះ ដោយសារការស្តាប់ខ្លះ និង ការសិក្សាខ្លះ ដោយសារការចម្រើនកសិណជាដើមខ្លះ ដូច**លោកិយវិរតិ**ទាំងឡាយទេ ។

ពាក្យថា **ឯកតោ** ( ក្នុងទីជាមួយគ្នា ) បានសេចក្តីថា មិនបានកើតផ្សេងៗគ្នាដូចក្នុងលោកិយចិត្ត តែកើតរួមគ្នាទាំង ៣ ដួង ។

-សួរថា: ហេតុដូចម្តេចទើបកើតរួមគ្នាទាំង ៣ ដួង ?

-ឆ្លើយថា: ព្រោះវិរតិចេតសិកទាំង ៣ មានអារម្មណ៍មិនផ្សេងគ្នា ការពិត **លោកុត្តរវិរតិ** រមែងមិនប្រព្រឹត្តទៅប្រារព្ធអារម្មណ៍ផ្សេងៗ មានជីវិតិន្ទ្រីយ៍ជាដើម ដែលហៅថា អារម្មណ៍គួរកន្លងល្មើសដូច **លោកិយវិរតិ** តែប្រព្រឹត្តទៅប្រារព្ធនិព្វានតែម្យ៉ាងប៉ុណ្ណោះ ។

ពាក្យថា **សព្វថាបិ** ( សូម្បីដោយប្រការទាំងពួង ) មានសេចក្តីថា វិរតិរមែងមិនកើតដោយការកម្ចាត់អកុសលចំណែកខ្លះ ដូចក្នុងលោកិយចិត្ត តែទាំង ៣ ដួងរមែងកើតឡើងដោយអាការកម្ចាត់ទុច្ចរិត និងទុរាជីពទាំងអស់។ បានសេចក្តីថា សម្មាវាចា ដែលកើតឡើងក្នុងលោកិយចិត្តមួយដង រមែងកម្ចាត់វចីទុច្ចរិតព្រមគ្នាមិនបាន ការវៀរចាកមុសាវាទ រមែងកម្ចាត់មុសាវាទបាន តែកម្ចាត់វចីទុច្ចរិតដទៃទៀតមិនបាន ថែមទាំងមិនអាចកម្ចាត់មុសាវាទដាច់ជាសមុច្ឆេទបានឡើយ ។ ក្នុងវចីទុច្ចរិតដែលនៅសល់ក៏ដូចគ្នា ។ ចំណែកសម្មាវាចាក្នុងលោកុត្តរចិត្ត កាលបើបានកើតឡើងម្តង រមែងកម្ចាត់វចីទុច្ចរិតទាំងអស់ព្រមទាំងឫសគល់ និង អនុស័យ ។ សម្មាកម្មន្ត កាលបើកើតឡើងហើយ រមែងកម្ចាត់កាយទុច្ចរិតទាំងអស់ ព្រមទាំងឫសគល់ និង អនុស័យ ។ សម្មាអាជីវៈ កាលបើកើតឡើងហើយ រមែងកម្ចាត់កាយទុច្ចរិត និង វចីទុច្ចរិតដែលមានការចិញ្ចឹមជីវិតជាហេតុព្រមទាំកនេះ មែងកើតដោយប្រការទាំងពួងក្នុងលោកុត្តរចិត្តប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

**បិ** ស័ព្ទ [ ដែលប្រែថា ( សូម្បី ) ] មានអត្ថរួបរួមចំណែកខ្លះ សម្មាវាចា ១ ដួង កើតឡើងម្ដងដង រមែងកើតដោយការកម្ចាត់មុសាវាទ ទាំងមិនកើតដោយការកម្ចាត់មុសាវាទតែម្យ៉ាង តែនៅកើតដោយការកម្ចាត់បិសុណាវាចាទៀតផង គប្បីជ្រាប វិរតិដែលនៅសល់ ២ ទៀត ក៏ប្រព្រឹត្តទៅដូចសម្មាវាចានេះដែរ ។

ពាក្យថា “ កម្ចាត់ទុច្ចរិតព្រមទាំងឫសគល់ និង អនុស័យ ” នេះ បានសេចក្ដីថា កិលេសទាំងឡាយមានកាមរាគានុស័យជាដើម ដែលធ្វើឲ្យកម្រើកកាយ និង វាចា ដែលបុគ្គលគប្បីកម្ចាត់ដោយមគ្គថ្នាក់ខ្ពស់រមែងមានបានសូម្បីដល់សេក្ខបុគ្គលក្នុងអរូបភូមិ ទើបមិនចាំបាច់ពោលថ្វីដល់សេក្ខបុគ្គលដែលនៅក្នុងកាមភូមិ និង រូបភូមិ ដូច្នោះ វិរតិទើបកម្ចាត់ទុច្ចរិតក្នុងមគ្គផលថ្នាក់ខ្ពស់បានដោយការកម្ចាត់កិលេស ។

ពាក្យថា **កាមាវចរកុសលេស្វេវ** ( ក្នុងកាមាវចរកុសលចិត្តប៉ុណ្ណោះ ) បានសេចក្ដីថា វិរតិចេតសិក រមែងមិនកើតក្នុងកាមាវចរវិបាកចិត្ត និង កាមាវចរ-កិរិយាចិត្ត ទាំងមិនកើតក្នុងមហគ្គតចិត្ត ។

សូម្បីវិរតិក្នុងកាមាវចរកុសលចិត្ត ក៏កើតឡើងក្នុងចិត្តដែលមានក្នុងកា-មាវចរភូមិប៉ុណ្ណោះ មិនកើតក្នុងចិត្តដែលមានក្នុងរូបភូមិ និងអរូបភូមិ ។ សេចក្ដីពិត ទុច្ចរិតតាមផ្លូវកាយ និងផ្លូវវាចា ហៅថា ចេតនាវៀរចាក រមែងមិនមានដល់ព្រហ្មទាំងឡាយ ហើយលោកិយវិរតិ រមែងមិនប្រព្រឹត្តទៅក្នុងបុគ្គលអ្នកប្រាសចាកចេតនាវៀរចាក ។

ពាក្យថា **កទាចិ សន្ទិស្សន្តិ** ( រមែងប្រាកដពេលខ្លះ ) បានសេចក្ដីថា រមែងប្រាកដក្នុងពេលប្រព្រឹត្តទៅដោយវិរតិយ៉ាងណាមួយក្នុងសមាទានវិរតិ និងសម្បត្តិវិរតិ សូម្បីវិរតិទាំងឡាយនឹងប្រាកដយ៉ាងនេះ ក៏ប្រាកដមិនព្រមគ្នាព្រោះមានអារម្មណ៍ផ្សេងគ្នា ដូច្នោះ លោកទើបពោលថា **វិសុំ វិសុំ** ( ផ្សេងៗគ្នា )

ស្ងម្បីប្រាកដមួយយ៉ាងៗ ក៏ប្រាកដដោយការកម្ចាត់ទុច្ចរិតមួយៗប៉ុណ្ណោះ មិនប្រាកដដោយប្រការទាំងពួង ដូចក្នុងលោកុត្តរចិត្ត ។

**[៣០] អប្បមញ្ញាយោ បនទ្វាទសសុ បញ្ចមជ្ឈានវជ្ជិតមហគ្គតចិត្តេសុ ចេវ កាមាវចរកុសលេសុ ច សហេតុកកាមាវចរកិរិយចិត្តេសុ ចាតិ អដ្ឋវីសតិចិត្តេស្វេវ កទាចិ នានា ហុត្វា ជាយន្តិ ឧបេក្ខាសហគតេសុ បនេត្ថ ករុណាមុទិតា ន សន្តីតិ កេចិ វទន្តិ ។**

ប្រែថា ចំណែកអប្បមញ្ញាចេតសិក កើតបែកគ្នា ហើយកើតចំពោះពេលខ្លះក្នុងចិត្ត ២៨ ដួងប៉ុណ្ណោះ គឺៈ មហគ្គតចិត្ត ១២ ដួង ( វៀរបញ្ចមជ្ឈានចិត្ត ) ក្នុងកាមាវចរកុសលចិត្ត ៨ ដួង និង សហេតុកកាមាវចរកិរិយាចិត្ត ៨ ដួង ។ ម្យ៉ាងទៀត ក្នុងចិត្តដែលប្រកបដោយអប្បមញ្ញាចំនួន ២៨ ដួង ពួកទាំងនេះ អាចារ្យខ្លះលោកអាងថា “ ករុណា និង មុទិតា មិនមានក្នុងចិត្តដែលប្រកបដោយឧបេក្ខា ” ។

## អធិប្បាយ

ការដែលអប្បមញ្ញាបន្ទុះដល់អប្បនា ប្រកបដោយសោមនស្សវេទនាតែម្យ៉ាង ទ្រង់ត្រាស់ទុកក្នុងគម្ពីរវិភង្គ ដូច្នេះ លោកទើបពោលថា **បញ្ចមជ្ឈានវជ្ជិតមហគ្គតចិត្តេសុ** ( មហគ្គតចិត្ត វៀរបញ្ចមជ្ឈាន ) ។

ការពិត អប្បមញ្ញាទាំងនេះ មានសេចក្ដីខ្វល់ខ្វាយក្រៃលែង ព្រោះមានសត្វជាអារម្មណ៍ ទើបមិនប្រព្រឹត្តទៅព្រមដោយឧបេក្ខាក្នុងបញ្ចមជ្ឈានដែលស្ងប់ក្រៃលែង មិនមានសេចក្ដីខ្វល់ខ្វាយ ។

ចំណែកអប្បមញ្ញាប្រព្រឹត្តទៅខាងដើមអប្បនា ប្រកបដោយឧបេក្ខាវេទនាបាន មានសម្ដែងទុកក្នុងគម្ពីរអដ្ឋកថា ដូច្នោះ លោកទើបពោលថា **កាមាវចរ ។ បេ ។ ចិត្តេសុ ច** ( កាមាវចរកុសលចិត្ត ៨ និង កាមាវចរកិរិយាចិត្ត ដែលមានហេតុ ៨ ដួង ) ។

ពាក្យថា **កទាចិ** ( ចំពោះពេលខ្លះ ) គឺក្នុងកាលដែលបុគ្គលអ្នកមានសេចក្តីករុណាប្រក្រតី ពេលឃើញវិបត្តិរបស់អ្នកដទៃ និង ក្នុងការដែលបុគ្គលអ្នកមិនមានសេចក្តីច្រណែន ពេលបានឃើញសម្បត្តិរបស់អ្នកដទៃ ។

ពាក្យថា **នានា ហុត្វា ជាយន្តិ** ( កើតបែកគ្នា ) មានសេចក្តីថា ករុណា និង មុទិតាកើតម្តងមួយៗ ដូចជា ករុណារមែងកើតឡើងដោយការអាណិត កាលបើបានឃើញអ្នកដទៃកំពុងជួបវិបត្តិ ពេលនោះ មុទិតាពុំបានកើតឡើងឡើយ។ មុទិតារមែងកើតឡើងដោយការត្រេកអរតាម កាលបើបានឃើញអ្នកដទៃកំពុងបានទទួលលាភ យស សសើរ សុខ ពេលនោះ ករុណាពុំបានកើតឡើងឡើយ

ក្នុងព្រះសូត្រ ព្រះអង្គទ្រង់បានត្រាស់ថា អប្បមញ្ញាទាំងនេះជាគ្រឿងរួចផុតពីការបៀតបៀននិង សេចក្តីមិនពេញចិត្តដែលកើតពីទោសៈទាំងសោមនស្ស ក៏ជាបដិបក្ខជាមួយទោសៈដែរ ទើបអាចារ្យខ្លះពោលថា អប្បមញ្ញានោះ សូម្បីប្រព្រឹត្តខាងដើមអប្បនា ក៏ប្រកបដោយសោមនស្សជានិច្ចជាកាល ដូច្នោះ លោកទើបពោលថា **ឧបេក្ខាសហគតេសុ ។ បេ ។ កេចិ វទន្តិ** ( អាចារ្យពួកខ្លះអះអាងថា ករុណា និង មុទិតា មិនមានក្នុងចិត្តដែលប្រកបដោយឧបេក្ខាវេទនា ) ។

មតិរបស់ពួកអាចារ្យទាំងនោះ ជំទាស់ជាមួយអដ្ឋកថា ទើបបណ្ឌិតទាំងឡាយមិនទទួលស្គាល់មតិនេះ ព្រះអនុរុទ្ធាចារ្យទើបហៅមតិនោះថា “ មតិរបស់អាចារ្យពួកខ្លះ ” ។

**[៣១] បញ្ញា បន ទ្វាទសសុ ញាណសម្បយុត្តកាមាវចរចិត្តេសុ ចេវ សព្វេសុបិ បញ្ចតឹស មហគ្គតលោកុត្តរចិត្តេសុ ចាតិ សត្តចត្តាលីសចិត្តេសុ សម្បយោគំ គច្ឆតីតិ ។**

ប្រែថា ម្យ៉ាងទៀត បញ្ញាចេតសិក រមែងដល់ការប្រកបក្នុងចិត្ត ៤៧ ដួង គឺ កាមាវចរសោភណចិត្តដែលប្រកបដោយញាណ ១២ ដួង មហគ្គតចិត្ត និង លោកុត្តរចិត្ត ៣៥ ដួងទាំងអស់ ។

# គាថាសរុប

[៣២]- ឯកូនវីសតិ ធម្មា ជាយន្តេកូនសដ្ឋីសុ
តយោ សោឡសចិត្តេសុ អដ្ឋវីសតិយំ ទ្វយំ ។
បញ្ញា បកាសិតា សត្ត- ចត្តាលីសវិធេសុបិ
សម្បយុត្តា ចតុធេវំ សោភណេស្វេវ សោភណា ។

ប្រែថា “ចេតសិក ១៩ ដួងកើតក្នុងចិត្ត ៥៩ ដួង ចេតសិក ៣ ដួង កើតក្នុងចិត្ត ១៦ ដួង ចេតសិក ២ ដួងកើតក្នុងចិត្ត ២៨ ដួង បញ្ញាចេតសិកលោកសម្តែងទុកក្នុងចិត្ត ៤៧ ដួង សោភណចេតសិកប្រកបក្នុងសោភណចិត្តប៉ុណ្ណោះ មាន ៤ ន័យ ដោយប្រការដូច្នេះ”។

# សម្បយោគន័យ ១៦ ន័យ

| ចេតសិក | ចិត្ត | ន័យ | ក្រុម |
|---|---|---|---|
| សព្វ.សាធារណចេ.៧ ដួង | ៨៩/១២១, ៨៩/១២១, ៨៩/១២១, ៨៩/១២១, ៨៩/១២១, ៨៩/១២១, ៨៩/១២១ | ១ ន័យ | ៧ ន័យ |
| បកិណ្ណកចេតសិក ៦ ដួង | ៥៥, ៦៦, ៧៨/១១០, ៧៣/១០៥, ៥១, ៦៩/១០១ | ៦ ន័យ | |
| មោចតុកចេតសិក ៤ ដួង | ១២, ១២, ១២, ១២ | ១ ន័យ | ៥ ន័យ |
| លោតិកចេតសិក ៣ ដួង | ៨, ៤, ៤ | ១ ន័យ | |
| ទោចតុកចេតសិក ៤ ដួង | ២, ២, ២, ២ | ១ ន័យ | |
| ថីទុកចេតសិក ២ ដួង | ៥, ៥ | ១ ន័យ | |
| វិចិកិច្ឆាចេតសិក ១ ដួង | ១ | ១ ន័យ | |
| សោ.សាធារណចេ. ១៩ ដួង | ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១, ៥៩/៩១ | ១ ន័យ | ៤ ន័យ |
| វីរតិចេតសិក ៣ ដួង | ១៦/៤៨, ១៦/៤៨, ១៦/៤៨ | ១ ន័យ | |
| អប្បមញ្ញាចេតសិក ២ ដួង | ២៨, ២៨ | ១ ន័យ | |
| បញ្ញិន្ទ្រិយចេតសិក ១ ដួង | ៤៧/៧៩ | ១ ន័យ | |

# តារាងសម្បយោគន័យ ១៦ ន័យ

| ចិត្ត / ចេតសិក | | | កាមាវចរចិត្ត ៥៤ | | | | | | | | | | | | | | | មហគ្គតចិត្ត ២៧ | | | | | លោកុត្តរចិត្ត ៤០ | | | | | រួមចិត្ត | | រួមសម្បយោគន័យ ១៦ន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | អកុសលចិត្ត ១២ | | | | | អហេតុកចិត្ត ១៨ | | | | | | | កាមា. សោ.២៤ | | | រូបាវចរ. -អរូបាវចរ.២៧ | | | | | លោកុត្តរចិត្តពិស្តារ | | | | | ប្រកបដោយសង្ខេប | ប្រកបដោយពិស្តារ | . | |
| | | | លោភទិដ្ឋិ.សំ. ៤ | លោភទិដ្ឋ.វិប្ប.៤ | ទោសមូល ២ | វិចិកិច្ឆាសម្ប.១ | ឧទ្ធច្ចសម្ប. ១ | ទ្វិបញ្ចវិញ្ញា. ១០ | សម្បដិច្ឆន ២ | ឧ.សន្តីរណ ២ | សោ.សន្តីរណ១ | បញ្ចទ្វារាវជ្ជន ១ | មនោទ្វារា. ១ | ហសិតុប្បាទ ១ | មហាកុសល៨ | មហាវិបាក ៨ | មហាកិរិយា ៨ | បឋមជ្ឈាន ៣ | ទុតិយជ្ឈាន ៣ | តតិយជ្ឈាន ៣ | ចតុត្ថជ្ឈាន ៣ | បញ្ចមជ្ឈាន ១៥ | បឋមជ្ឈាន ៨ | ទុតិយជ្ឈាន ៨ | តតិយជ្ឈាន ៨ | ចតុត្ថជ្ឈាន ៨ | បញ្ចមជ្ឈាន ៨ | | | | |
| អញ្ញសមានាចេ.១៣ | សព្វចិត្តសាធារណចេ. ៧ | | ៤ | ៤ | ២ | ១ | ១ | ១០ | ២ | ២ | ១ | ១ | ១ | ១ | ៨ | ៨ | ៨ | ៣ | ៣ | ៣ | ៣ | ១៥ | ៨ | ៨ | ៨ | ៨ | ៨ | ៨៩ | ១២១ | ១ | ៧ ន័យ |
| | បកិណ្ណក ៦ | វិតក្ក | ៤ | ៤ | ២ | ១ | ១ | | ២ | ២ | ១ | ១ | ១ | ១ | ៨ | ៨ | ៨ | ៣ | | | | | ៨ | | | | | | ៥៥ | ១ | |
| | | វិចារ | ៤ | ៤ | ២ | ១ | ១ | | ២ | ២ | ១ | ១ | ១ | ១ | ៨ | ៨ | ៨ | ៣ | ៣ | | | | ៨ | ៨ | | | | | ៦៦ | ១ | |
| | | អធិមោក្ខ | ៤ | ៤ | ២ | | ១ | | ២ | ២ | ១ | ១ | ១ | ១ | ៨ | ៨ | ៨ | ៣ | ៣ | ៣ | ៣ | ១៥ | ៨ | ៨ | ៨ | ៨ | ៨ | ៧៨ | ១១០ | ១ | |
| | | វីរិយៈ | ៤ | ៤ | ២ | ១ | ១ | | | | | | ១ | ១ | ៨ | ៨ | ៨ | ៣ | ៣ | ៣ | ៣ | ១៥ | ៨ | ៨ | ៨ | ៨ | ៨ | ៧៣ | ១០៥ | ១ | |
| | | បីតិ | ២ | ២ | | | | | | | ១ | | | ១ | ៨ | ៨ | ៨ | ៣ | ៣ | ៣ | | | ៨ | ៨ | ៨ | | | | ៥១ | ១ | |
| | | ឆន្ទៈ | ៤ | ៤ | ២ | | | | | | | | | | ៨ | ៨ | ៨ | ៣ | ៣ | ៣ | ៣ | ១៥ | ៨ | ៨ | ៨ | ៨ | ៨ | ៦៩ | ១០១ | ១ | |
| អកុសលចេតសិក ១៤ | មោចតុក ៤ | មោហៈ | ៤ | ៤ | ២ | ១ | ១ | | | | | | | | | | | | | | | | | | | | | ១២ | | ១ | ៥ ន័យ |
| | | អហិរិកៈ | ៤ | ៤ | ២ | ១ | ១ | | | | | | | | | | | | | | | | | | | | | ១២ | | | |
| | | អនោត្តប្បៈ | ៤ | ៤ | ២ | ១ | ១ | | | | | | | | | | | | | | | | | | | | | ១២ | | | |
| | | ឧទ្ធច្ចៈ | ៤ | ៤ | ២ | ១ | ១ | | | | | | | | | | | | | | | | | | | | | ១២ | | | |
| | លោតិក ៣ | លោភៈ | ៤ | ៤ | | | | | | | | | | | | | | | | | | | | | | | | ៨ | | ១ | |
| | | ទិដ្ឋិ | ៤ | | | | | | | | | | | | | | | | | | | | | | | | | ៤ | | | |
| | | មានះ | | ៤ | | | | | | | | | | | | | | | | | | | | | | | | ៤ | | | |
| | ទោចតុក ៤ | ទោសៈ | | | ២ | | | | | | | | | | | | | | | | | | | | | | | ២ | | ១ | |
| | | ឥស្សា | | | ២ | | | | | | | | | | | | | | | | | | | | | | | ២ | | | |
| | | មច្ឆរិយ | | | ២ | | | | | | | | | | | | | | | | | | | | | | | ២ | | | |
| | | កុក្កុច្ចៈ | | | ២ | | | | | | | | | | | | | | | | | | | | | | | ២ | | | |
| | ថីទុក ២ | ថីនៈ | ២ | ២ | ១ | | | | | | | | | | | | | | | | | | | | | | | ៥ | | ១ | |
| | | មិទ្ធៈ | ២ | ២ | ១ | | | | | | | | | | | | | | | | | | | | | | | ៥ | | | |
| | វិចិកិច្ឆា ១ | វិចិកិច្ឆា | | | | ១ | | | | | | | | | | | | | | | | | | | | | | ១ | | ១ | |
| សោភណ ២៥ | សោភណសាធារណចេ. ១៩ | | | | | | | | | | | | | | ៨ | ៨ | ៨ | ៣ | ៣ | ៣ | ៣ | ១៥ | ៨ | ៨ | ៨ | ៨ | ៨ | ៥៩ | ៩១ | ១ | ៤ ន័យ |
| | វិរតិ ៣ | សម្មាវាចា | | | | | | | | | | | | | ៨ | | | | | | | | ៨ | ៨ | ៨ | ៨ | ៨ | ១៦ | ៤៨ | ១ | |
| | | សម្មាកម្មន្តៈ | | | | | | | | | | | | | ៨ | | | | | | | | ៨ | ៨ | ៨ | ៨ | ៨ | ១៦ | ៤៨ | | |
| | | សម្មាអាជីវៈ | | | | | | | | | | | | | ៨ | | | | | | | | ៨ | ៨ | ៨ | ៨ | ៨ | ១៦ | ៤៨ | | |
| | អប្បមញ្ញា ២ |ករុណា | | | | | | | | | | | | | ៨ | | ៨ | ៣ | ៣ | ៣ | ៣ | | | | | | | ២៨ | | ១ | |
| | | មុទិតា | | | | | | | | | | | | | ៨ | | ៨ | ៣ | ៣ | ៣ | ៣ | | | | | | | ២៨ | | | |
| | បញ្ញា ១ | បញ្ញិន្ទ្រិយ | | | | | | | | | | | | | ៤ | ៤ | ៤ | ៣ | ៣ | ៣ | ៣ | ១៥ | ៨ | ៨ | ៨ | ៨ | ៨ | ៤៧ | ៧៩ | ១ | |

 រៀបរៀងដោយ=អ៊ុំ សុជា និង ប៉ោះ សុមាលី

# និយតយោគី អនិយតយោគីចេតសិក

## ( ចេតសិកដែលប្រកបទៀង ឬ មិនទៀង )

**[៣៣] ឥស្សាមច្ឆេរកុក្កុច្ច - វិរតិករុណាទយោ**
**នានា កទាចិ មានោ ច ថិនមិទ្ធំ តថា សហ ។**

ប្រែថា “ ឥស្សាចេតសិក មច្ឆរិយចេតសិក កុក្កុច្ចចេតសិក វិរតិចេតសិក និង ករុណាចេតសិកជាដើម រមែងកើតបែកគ្នា ហើយកើតក្នុងពេលខ្លះ ចំណែកមានចេតសិក រមែងកើតចំពោះពេលខ្លះ និង ថីនមិទ្ធចេតសិក រមែងកើតក្នុងពេលខ្លះ តែព្រមគ្នា ” ។

## អធិប្បាយ

ឥឡូវនេះ ព្រះអនុរុទ្ធាចារ្យពោលពាក្យដែលផ្ដើមឡើងថា **ឥស្សា** ( ឥស្សាចេតសិក មច្ឆរិយចេតសិក កុក្កុច្ចចេតសិក វិរតិចេតសិក និង ករុណា-ចេតសិកជាដើម រមែងកើតបែកគ្នា ហើយកើតក្នុងពេលខ្លះ ) ដើម្បីសម្ដែងប្រភេទដែលប្រកបរួមគ្នា ឬ មិនប្រកបរួមគ្នានៃចិត្ត និង ចេតសិកដែលប្រកបជាមួយចិត្តទាំងអស់ ។

ពាក្យថា **ករុណាទិ** គឺ ចេតសិកដែលមានករុណាជាដើម បានដល់ អប្ប-មញ្ញា ២ ។

ពាក្យថា **ឥស្សាមច្ឆេរកុក្កុច្ចវិរតិករុណាទិ** គឺៈ ឥស្សា មច្ឆរិយ កុក្កុច្ច វិរតិ និង ករុណា ជាដើម ចេតសិកទាំងនេះ រមែងកើតបែកពីគ្នា ហើយកើតក្នុងពេលខ្លះ ។

ម្យ៉ាងទៀត មានះ រមែងកើតក្នុងពេលខ្លះ ។

ថីនមិទ្ធៈ រមែងកើតក្នុងពេលខ្លះ ដូចគ្នា តែកើតរួមគ្នា មិនបែកគ្នា ។

បណ្ដាចេតសិកទាំងនោះ មានះ សូម្បីកើតក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង ក៏កើតឡើងបានក្នុងពេលខ្លះ គឺ ក្នុងពេលដែលចិត្តពួកនេះប្រព្រឹត្តទៅដោយត្រិះរិះថា “ យើងល្អជាងគេ ” ជាដើម រមែងមិនកើតក្នុងកាលដទៃ ។

ថីនមិទ្ធៈ សូម្បីកើតក្នុងសសង្ខារិកចិត្ត ៥ ដួង ក៏កើតបានក្នុងពេលខ្លះ គឺក្នុងពេលដែលចិត្តទាំងនោះ ប្រព្រឹត្តទៅដោយការមិនសមគួរតវិយាបទ ព្រោះត្រូវសភាពងងុយគ្របសង្កត់ ហើយមិនកើតក្នុងកាលដទៃ ។

ចំណែកថីនមិទ្ធៈ ២ ដួងដែលកើតក្នុងកាលនោះរមែងកើតរួមគ្នាជានិច្ចជាកាល មិនកើតបែកគ្នា

**[៣៤] យថាវុត្តានុសារេន សេសា និយតយោគិនោ,**

**សង្គហញ្ច បវក្ខាមិ តេសំ ទានិ យថារហំ។**

ប្រែថា “ តាមន័យដែលបានពោលមកហើយ [ ខាងដើម ] ចេតសិកដែលនៅសល់ ជាចេតសិកទៀងតែប្រកបជាមួយចិត្ត ឥឡូវនេះខ្ញុំព្រះករុណា នឹងពោលសង្គហន័យនៃចេតសិកទាំងនោះ តាមសមគួរ ” ។

# សង្គហន័យ ៣៣ ន័យ

**[៣៥] ឆត្តឹសានុត្តរេ ធម្មា បញ្ចតឹស មហគ្គតេ**

**អដ្ឋតឹសាបិ លព្ភន្តិ កាមាវចរសោភណេ ។**

**សត្តវីសតិបុញ្ញម្ហិ ទ្វាទសាហេតុកេតិ ច**

**យថាសម្ភវយោគេន បញ្ចធា តត្ថ សង្គហោ ។**

ប្រែថា “ សង្គហន័យក្នុងចេតសិកនោះមាន ៥ ន័យ ដោយការប្រកបតាមសមគួរគឺៈ ចេតសិក ៣៦ ដួង ប្រកបបានក្នុងលោកុត្តរចិត្ត ចេតសិក ៣៥ ដួង ប្រកបបានក្នុងមហគ្គតចិត្ត ចេតសិក ៣៨ ដួង ប្រកបបានក្នុងកាមាវចរ-សោភណចិត្ត ចេតសិក ២៧ ដួង ប្រកបបានក្នុងអកុសលចិត្ត និងចេតសិក១២ ដួង ប្រកបបានក្នុងអហេតុកចិត្ត ” ។

# អធិប្បាយ

កាលបើព្រះអនុរុទ្ធាចារ្យបានសម្ដែងសម្បយោគន័យ ដោយកំណត់ឋានៈដែលចេតសិកប្រកប ( ក្នុងចិត្ត ) ដូចនេះហើយ ឥឡូវនេះនឹងសម្ដែងសង្គហន័យ ដោយកំណត់ចំនួន និង ប្រភេទចេតសិកទាំងអស់ ដែលប្រកបរួមគ្នាបានក្នុងចិត្តមួយដួងៗ ទើបពោលបាទគាថាថាៈ **សង្គហញ្ច** ជាដើម ។

គប្បីប្រកបបទថា ឥឡូវនេះខ្ញុំព្រះករុណានឹងពោលសង្គហន័យរបស់ចេតសិកទាំងនោះ តាមសមគួរ ។

## លោកុត្តរចិត្ត សង្គហន័យ

### ( ការរាប់ចំនួនចេតសិកក្នុងលោកុត្តរចិត្ត )

[៣៦] កថំ ?

**លោកុត្តរេសុ តាវ អដ្ឋសុ បឋមជ្ឈានិកចិត្តេសុ អញ្ញសមានា តេរស ចេតសិកា, អប្បមញ្ញាវជ្ជិតា តេវីសតិ សោភណចេតសិកា ចេតិ ឆត្តឹស ធម្មា សង្គហំ គច្ឆន្តិ ។**

ប្រែថា ចេតសិករមែងដល់នូវការរាប់ចូលក្នុងចិត្តដូចម្ដេច ?

លំដាប់ដំបូងក្នុងលោកុត្តរចិត្ត ចេតសិក៣៦ ដួង គឺ អញ្ញសមានាចេតសិក ១៣ ដួង និង សោភណចេតសិក ២៣ ដួង ( វៀរអប្បមញ្ញាចេតសិក ២ ដួង ) រមែងដល់នូវការរាប់ចូលក្នុងបឋមជ្ឈានិកចិត្ត ( ៨ ដួង ) ។

**តថា ទុតិយជ្ឈានិកចិត្តេសុ វិតក្កវជ្ជា ។**

ប្រែថា ដូចគ្នានេះ ចេតសិកដូចដែលបានពោលមក ( វៀរវិតក្កចេតសិក ) រមែងដល់នូវការរាប់ចូលក្នុងទុតិយជ្ឈានិកចិត្ត ( ៨ ដួង ) ។

**តតិយជ្ឈានិកចិត្តេសុ វិតក្កវិចារវជ្ជា ។**

ប្រែថា ចេតសិកដូចដែលបានពោលមក ( វៀរវិតក្កចេតសិក និង វិចារចេតសិក ) រមែងដល់នូវការរាប់ចូលក្នុងតតិយជ្ឈានិកចិត្ត ( ៨ដួង ) ។

**ចតុត្ថជ្ឈានិកចិត្តេសុ វិតក្កវិចារបីតិវជ្ជា ។**

ប្រែថា ចេតសិកដូចដែលបានពោលមក ( វៀរវិតក្កចេតសិក វិចារចេតសិក បីតិចេតសិក ) រមែងដល់នូវការរាប់ចូលក្នុងចតុត្ថជ្ឈានិកចិត្ត ( ៨ដួង )។

**បញ្ចមជ្ឈានិកចិត្តេសុបិ ឧបេក្ខាសហគតា តេ ឯវ សង្គយ្ហន្តីតិ ។**

ប្រែថា ចេតសិកដូចដែលបានពោលមកនោះ ដែលកើតរួមជាមួយ ឧបេក្ខាវេទនា រមែងដល់នូវការរាប់ចូលក្នុងបញ្ចមជ្ឈានិកចិត្ត ( ៨ដួង ) ។

**សព្វថាបិ អដ្ឋសុ លោកុត្តរចិត្តេសុ បញ្ចកជ្ឈានវសេន បញ្ចធាវ សង្គហោ ហោតីតិ**

ប្រែថា ព្រោះហេតុដូច្នោះ សង្គហន័យក្នុងលោកុត្តរចិត្ត ៨ ៗ ដួង មាន ៥ ន័យ ដោយចែកតាមឈាន ៥ ដោយប្រការទាំងពួង ។

# អធិប្បាយ

អប្បមញ្ញាដែលមានសត្វបញ្ញត្តិជាអារម្មណ៍ រមែងមិនមានក្នុងលោកុត្តរ-ចិត្តដែលមាននិព្វានជាអារម្មណ៍ ដូច្នោះ លោកទើបពោលថា **អប្បមញ្ញាវជ្ជិតា** ( វៀរអប្បមញ្ញា ២ ) ។

**តថា** ស័ព្ទ សម្តែងន័យថា ដូចយ៉ាងនោះ គឺចេតសិក ៣៥ ដួង បាន ដល់ អញ្ញសមានាចេតសិក ១២ ( វៀរវិតក្កៈ ) និង សោភណចេតសិក ២៣ ដួង ( វៀរអប្បមញ្ញា ) រមែងដល់នូវការរាប់រួមចូលក្នុង ទុតិយជ្ឈានិកចិត្ត ជាដើម ។

ពាក្យថា **តេ ឯវ** ( ចេតសិកទាំងនោះ ) គឺៈ ចេតសិក ៣២ ដួង ពួកនោះ ដែលប្រកបដោយឧបេក្ខា ( វៀរវិតក្កៈ វិចារៈ បីតិ និង សុខៈ ) ។

ក្នុងពាក្យថា **អដ្ឋសុ** ( ក្នុងលោកុត្តរចិត្ត ៨ ដួងៗ ) គប្បីជ្រាប ការសម្តែង **ឯកសេស** ( ការលុបឲ្យសល់ស័ព្ទមួយ ) ។ ពាក្យថា **អដ្ឋ** បានដល់ ចិត្ត ៨ដួង និង ចិត្ត ៨ដួង ឬ សម្តែងដោយការលុប **វិច្ឆា** ស័ព្ទ ។

[ **ឯកសេសន័យ** គឺការលុបឲ្យសល់ស័ព្ទមួយ ពោលគឺ បទដើមមានពីរស័ព្ទភ្ជាប់សមាសថា **អដ្ឋអដ្ឋ** លុបអដ្ឋស័ព្ទក្រោយដើម្បីឲ្យសល់ស័ព្ទមួយ ។ តាមន័យក្រោយ **វិច្ឆាស័ព្ទ** គឺ ស័ព្ទដែលចុះវិភត្តិនាមទាំងពីរស័ព្ទ មិនមែនសមាសដូចឯកសេសៈ ឲ្យលុបស័ព្ទមួយដើម្បីបំព្រួញពាក្យ សូម្បីថាទាំងពីរន័យ សំដៅដល់ ការលុបឲ្យសល់ស័ព្ទមួយដូចគ្នា លោកក៏សម្តែងទាំងពីរន័យពួកនេះទុកតាមនិរុត្តិន័យ ] ។

ពាក្យថា **បញ្ចកជ្ឈានវសេន** ( ដោយចែកតាមឈាន ៥ ) មានសេចក្តីថា ដោយចែកតាមប្រភេទរបស់ឈានដែលត្រាស់ទុកដោយបញ្ចកន័យ ក្នុងព្រះបាលី បានដល់ សង្គហន័យ មាន ៤ យ៉ាង ដោយចែកតាមប្រភេទរបស់ឈានដែលសម្តែងទុកដោយចតុក្កន័យ ។

បណ្តាអ្នកបានសម្រេចបឋមជ្ឈានហើយចម្រើនទុតិយជ្ឈាន អ្នកមានបញ្ញាយឺត កន្លងវិតក្កៈបានតែម្យ៉ាង ទុតិយជ្ឈានមានអង្គ ៤ រមែងកើតដល់អ្នកនោះ ។

ចំណែកអ្នកមានបញ្ញាលឿន រមែងកន្លងវិតក្កៈ និង វិចារៈព្រមគ្នាបានទុតិយជ្ឈានមានអង្គ ៣ រមែងកើតដល់អ្នកនោះ សេចក្តីផ្សេងគ្នារបស់ន័យទាំងនោះ ប្រព្រឹត្តទៅដោយប្រការដូច្នេះ ។

## គាថាសរុប

**[៣៧] ឆត្តឹស បញ្ចតឹស ច ចតុត្តឹស យថាក្កមំ**

**តេត្តឹសទ្វយមិច្ចេវំ បញ្ចធានុត្តរេ ឋិតា ។**

ប្រែថា “ ចេតសិកទាំងឡាយ តាំងនៅក្នុងលោកុត្តរចិត្ត ៥ ន័យ ដោយប្រការយ៉ាងនេះ គឺ៖ ចេតសិក ៣៦ ដួង ចេតសិក ៣៥ដួង ចេតសិក ៣៤ ដួង ចេតសិក ៣៣ ដួង និង ចេតសិក ៣៣ ដួង តាមលំដាប់ ” ។

[ ក្នុងលោកុត្តរចិត្ត ៤០ មានសង្គហន័យ ៥ ន័យ គឺ៖

**ន័យទី ១** ក្នុងលោកុត្តរបឋមជ្ឈានចិត្ត ៨ ( បឋមជ្ឈានមគ្គចិត្ត ៤ ផលចិត្ត ៤ ) មានចេតសិកប្រកប ៣៦ ដួង គឺៈ អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២៣ ( វៀរអប្បមញ្ញាចេតសិក ២ )។

**ន័យទី ២** ក្នុងលោកុត្តរទុតិយជ្ឈានចិត្ត ៨ ( ទុតិយជ្ឈានមគ្គចិត្ត ៤ ផលចិត្ត ៤ ) មានចេតសិកប្រកប ៣៥ ដួងគឺៈ អញ្ញសមានាចេតសិក ១២ ( វៀរវិតក្កចេតសិក ) សោភណចេតសិក ២៣ ( វៀរអប្បមញ្ញាចេតសិក ២ )។

**ន័យទី ៣** ក្នុងលោកុត្តរតតិយជ្ឈានចិត្ត ៨ ( តតិយជ្ឈានមគ្គចិត្ត ៤ ផលចិត្ត ៤ ) មានចេតសិកប្រកប ៣៤ ដួង គឺៈ អញ្ញសមានាចេតសិក ១១ ( វៀរវិតក្កៈ និង វិចារៈ ) សោភណចេតសិក ២៣ ( វៀរអប្បមញ្ញាចេតសិក ២ ) ។

**ន័យទី ៤** ក្នុងលោកុត្តរចតុត្ថជ្ឈានចិត្ត ៨ ( ចតុត្ថជ្ឈានមគ្គចិត្ត ៤ ផលចិត្ត ៤) មានចេតសិកប្រកប ៣៣ ដួង គឺៈ អញ្ញសមានាចេតសិក ១០ ( វៀរវិតក្កៈ វិចារៈ និង បីតិ ) សោភណចេតសិក ២៣ ( វៀរអប្បមញ្ញាចេតសិក ២ )។

**ន័យទី ៥** ក្នុងលោកុត្តរបញ្ចមជ្ឈានចិត្ត ៨ ( បញ្ចមជ្ឈានមគ្គចិត្ត ៤ ផលចិត្ត ៤) មានចេតសិកប្រកប ៣៣ ដួង គឺៈ អញ្ញសមានាចេតសិក ១០ ( វៀរវិតក្កៈ វិចារៈ និង បីតិ) សោភណចេតសិក ២៣ ( វៀរអប្បមញ្ញាចេតសិក ២ ) ] ។

# មហគ្គតចិត្ត សង្គហន័យ

## ( ការរាប់ចំនួនចេតសិកក្នុងមហគ្គតចិត្ត )

**[៣៨] មហគ្គតេសុ បន តីសុ បឋមជ្ឈានិកចិត្តេសុ តាវ អញ្ញសមានា តេរស ចេតសិកា, វិរតិត្តយវជ្ជិតា ទ្វាវីសតិ សោភណចេតសិកា ចេតិ បញ្ចតឹស ធម្មា សង្គហំ គច្ឆន្តិ ។**

ប្រែថា ចំណែកក្នុងមហគ្គតចិត្តទាំងឡាយ ចេតសិក ៣៥ ដួង គឺៈ អញ្ញសមានាចេតសិក ១៣ ដួង សោភណចេតសិក ២២ ( វៀរវិរតិចេតសិក ៣ដួង ) រមែងដល់នូវការរាប់ចូលក្នុងបឋមជ្ឈានិកចិត្ត ( ៣ ដួង ) ។

**ករុណាមុទិតា បនេត្ថ បច្ចេកមេវ យោជេតព្វា ។**

ប្រែថា ម្យ៉ាងទៀត ក្នុងទីនេះ គប្បីប្រកបករុណាចេតសិក និង មុទិតា-ចេតសិក មួយដួងៗ ជាមួយចិត្ត ។

**តថា ទុតិយជ្ឈានិកចិត្តេសុ វិតក្កវជ្ជា ។**

ប្រែថា ដូចគ្នានេះ ចេតសិកដូចបានពោលមកនេះ ( វៀរវិតក្កចេតសិក ) រមែងដល់នូវការរាប់ចូលក្នុងទុតិយជ្ឈានិកចិត្ត ( ៣ ដួង ) ។

**តតិយជ្ឈានិកចិត្តេសុ វិតក្កវិចារវជ្ជា ។**

ប្រែថាចេតសិកដូចបានពោលមក ( វៀរវិតក្កចេតសិក និង វិចារចេតសិក ) រមែងដល់នូវការរាប់ចូលក្នុងតតិយជ្ឈានិកចិត្ត ( ៣ដួង ) ។

**ចតុត្ថជ្ឈានិកចិត្តេសុ វិតក្កវិចារបីតិវជ្ជា ។**

ប្រែថាចេតសិកដូចបានពោលមក ( វៀរវិតក្កចេតសិក វិចារចេតសិក និង បីតិចេតសិក) រមែងដល់នូវការរាប់ចូលក្នុងចតុត្ថជ្ឈានិកចិត្ត ( ៣ដួង ) ។

**បញ្ចមជ្ឈានិកចិត្តេសុ បន បន្នរសសុ អប្បមញ្ញាយោ ន លព្ភន្តីតិ**

ប្រែថាអប្បមញ្ញាចេតសិក រមែងមិនបានក្នុងបញ្ចមជ្ឈានិកចិត្ត ( ១៥ ដួង )

**សព្វថាបិ សត្តវីសតិមហគ្គតចិត្តេសុ បញ្ចកជ្ឈានវសេន បញ្ចធាវ សង្គហោ ហោតីតិ ។**

ប្រែថា ព្រោះហេតុដូច្នោះ សង្គហន័យក្នុងមហគ្គតចិត្ត ២៧ ដួង មាន ៥ ន័យ ដោយចែកតាមឈាន ៥ ដោយប្រការដូច្នេះ។

# អធិប្បាយ

វិរតិចេតសិករមែងមិនកើតក្នុងមហគ្គតចិត្ត ព្រោះមាននាទី និង អារម្មណ៍ ផ្សេងគ្នា ។ ហេតុដូច្នេះ លោកទើបពោលថា **វិរតិត្តយវជ្ជិតា** ( វៀរវិរតិចេតសិក ៣ ដួង ) បានសេចក្តីថា វីរតិធ្វើនាទីជម្រះកាយ និង វាចា ចំណែកមហគ្គឈាន ធ្វើនាទីជម្រះចិត្តរបស់អ្នកមានកិរិយាផ្លូវកាយ និង វាចា បរិសុទ្ធល្អហើយ វិរតិ រមែងកើតឡើងដោយប្រារព្ធសភាពវៀរចាក ( គឺចេតសិក ) ឬ ព្រះនិព្វាន ចំណែកមហគ្គតឈាន កើតឡើងដោយប្រារព្ធបញ្ញត្តិ ឬ មហគ្គតធម៌ប៉ុណ្ណោះ។

# គាថាសរុប

**[៣៩] បញ្ចត្តឹស ចតុត្តឹស តេត្តឹស ច យថាក្កមំ**

**ពាត្តឹស ចេវ តឹសេតិ បញ្ចធាវ មហគ្គតេ ។**

ប្រែថា “ចេតសិកទាំងឡាយ តាំងនៅក្នុងមហគ្គតចិត្ត មាន ៥ ន័យដូចនេះគឺៈ ចេតសិក ៣៥ ដួង ចេតសិក ៣៤ ដួង ចេតសិក ៣៣ ដួង ចេតសិក ៣២ ដួង និង ចេតសិក ៣០ ដួងតាមលំដាប់ ” ។

[ ក្នុងមហគ្គតចិត្ត ២៧ មានសង្គហៈ ៥ ន័យគឺៈ

**ន័យទី ១** រូបាវចរបឋមជ្ឈានចិត្ត ៣ មានចេតសិកប្រកប ៣៥ ដួង គឺៈ អញ្ញសមានាចេតសិក ១៣ ដួង សោភណចេតសិក ២២ ដួង ( វៀរវិរតិចេតសិក៣ ) ។

**ន័យទី ២** រូបាវចរទុតិយជ្ឈានចិត្ត ៣ មានចេតសិកប្រកប ៣៤ ដួងគឺៈ អញ្ញសមានាចេតសិក ១២ ( វៀរវិតក្កចេតសិក ) សោភណចេតសិក ២២ ដួង ( វៀរវិរតិចេតសិក ៣ ) ។

**ន័យទី ៣** រូបាវចរតតិយជ្ឈានចិត្ត ៣ មានចេតសិកប្រកប ៣៣ ដួង គឺៈ អញ្ញសមានាចេតសិក១១ ( វៀរវិតក្កៈ និង វិចារៈ ) សោភណចេតសិក ២២ ដួង ( វៀរវិរតិចេតសិក ៣ ) ។

**ន័យទី ៤** រូបាវចរចតុត្ថជ្ឈានចិត្ត ៣ មានចេតសិកប្រកប ៣២ ដួង គឺៈ អញ្ញសមានាចេតសិក ១០ ( វៀរវិតក្កៈ វិចារៈ និង បីតិ ) សោភណចេតសិក ២២ ដួង ( វៀរវិរតិចេតសិក ៣ ) ។

**ន័យទី ៥** រូបាវចរបញ្ចមជ្ឈានចិត្ត ៣ និង អរូបាវចរចិត្ត ១២ មានចេតសិកប្រកប ៣០ ដួង គឺៈ អញ្ញសមានាចេតសិក ១០ ( វៀរវិតក្កៈ វិចារៈ និង បីតិ ) សោភណចេតសិក ២២ ដួង ( វៀរវិរតិចេតសិក ៣ និង អប្បមញ្ញា-ចេតសិក ២ ) ]

# កាមាវចរសោភណចិត្ត សង្គហន័យ

## ( ការរាប់ចំនួនចេតសិកក្នុងកាមាវចរសោភណចិត្ត )

**[៤០] កាមាវចរសោភណេសុ បន កុសលេសុ តាវ បឋមទ្វយេ អញ្ញសមានា តេរស ចេតសិកា, បញ្ចវីសតិ សោភណចេតសិកា ចេតិ អដ្ឋតឹស ធម្មា សង្គហំ គច្ឆន្តិ ។**

ប្រែថា ម្យ៉ាងទៀត បណ្ដាកាមាវចរសោភណចិត្ត ចេតសិក ៣៨ ដួង គឺៈ អញ្ញសមានាចេតសិក ១៣ ដួង និង សោភណចេតសិក ២៥ ដួង រមែងដល់នូវការរាប់ចូលក្នុងកុសលចិត្ត ២ ដួងដំបូង ( ដែលប្រកបដោយញាណ ) ។

**អប្បមញ្ញាវិរតិយោ បនេត្ថ បញ្ចបិ បច្ចេកមេវ យោជេតព្វា ។**

ប្រែថាម្យ៉ាងទៀត គប្បីប្រកបអប្បមញ្ញាចេតសិក ( ២ដួង ) និង វិរតិ-ចេតសិក ( ៣ដួង ) រួម ៥ ដួងនេះ ក្នុងកាមាវចរសោភណចិត្ត ម្ដងមួយដួងៗ ប៉ុណ្ណោះ ។

**តថា ទុតិយទ្វយេ ញាណវជ្ជិតា ។**

ប្រែថា ដូចគ្នានេះ ( ចេតសិកដែលពោលមកហើយ ) វៀរបញ្ញាចេតសិក រមែងដល់នូវការរាប់ចូលក្នុង ( កាមាវចរសោភណ ) កុសលចិត្តគូទី ២ ។

**តតិយទ្វយេ ញាណសម្បយុត្តា បីតិវជ្ជិតា ។**

( ចេតសិកដូចដែលបានពោលមកហើយ ) វៀរបីតិចេតសិក ប្រកបដោយញាណ រមែងដល់នូវការរាប់ចូលក្នុង ( កាមាវចរសោភណ ) កុសលចិត្តគូទី ៣ ។

**ចតុត្ថទ្វយេ ញាណបីតិវជ្ជិតា តេ ឯវ សង្គយ្ហន្តិ ។**

( ចេតសិកដូចដែលបានពោលមកហើយ ) វៀរបញ្ញាចេតសិក និងបីតិចេតសិក រមែងដល់នូវការរាប់ចូលក្នុង ( កាមាវចរសោភណ ) កុសលចិត្តគូទី ៤ ។

**កិរិយចិត្តេសុបិ វិរតិវជ្ជិតា តថេវ ចតូសុបិ ទុកេសុ ចតុធាវ សង្គយ្ហន្តិ ។**

( ចេតសិក ៣៥ ដួងដូចដែលបានពោលមកហើយ ) វៀរវិរតិចេតសិក ( ៣ដួង ) រមែងដល់នូវការរាប់ចូលក្នុង ( កាមាវចរសោភណ ) កិរិយាចិត្តទាំង ៤ គូ ដោយប្រការយ៉ាងនោះ ( ៣៥, ៣៤ , ៣៤ , ៣៣ ) ។

**តថា វិបាកេសុ ច អប្បមញ្ញាវិរតិវជ្ជិតា តេ ឯវំ សង្គយ្ហន្តីតិ ។**

ដូចគ្នានេះ ( ចេតសិក ៣៣ ដួង ) ទាំងនោះ វៀរអប្បមញ្ញាចេតសិក ( ២ ដួង ) និង វិរតិចេតសិក ( ៣ដួង ) រមែងដល់នូវការរាប់ចូលក្នុង ( កាមាវចរសោភណ ) វិបាកចិត្ត ៤ គូ ដោយប្រការយ៉ាងនោះ ( ៣៣, ៣២, ៣២, ៣១ ) ។

**សព្វថាបិ ចតុវីសតិកាមាវចរសោភណចិត្តេសុ ទុកវសេន ទ្វាទសធាវ សង្គហោ ហោតីតិ ។**

ព្រោះហេតុដូច្នេះ សង្គហន័យក្នុងកាមាវចរសោភណចិត្ត ២៤ ដួង មាន ១២ ន័យ ដោយចែកតាមចិត្តជាគូៗ ដោយប្រការទាំងពួង ។

# អធិប្បាយ

**វិរតិ** និង **អប្បមញ្ញា** ទាំងពីរយ៉ាងកើតរួមគ្នាក្នុងចិត្តមួយដួងមិនបាន ព្រោះផ្ទុយគ្នាដោយនាទី និង អារម្មណ៍ផ្សេងគ្នា ដូច្នោះ លោកទើបពោលថា **អប្បមញ្ញាវិរតិយោ បនេត្ថ ។ ប ។ យោជេតព្វា** ( ម្យ៉ាងទៀត គប្បីប្រកបអប្បមញ្ញាចេតសិក ២ ដួង និង វិរតិចេតសិក ៣ ដួង រួម ៥ ដួង ក្នុងកាមាវចរសោភណចិត្តនេះម្តងមួយដួងៗប៉ុណ្ណោះ ) ។

វិរតិរមែងមិនកើតក្នុងអព្យាកតចិត្ត ( វិបាកចិត្ត និង កិរិយាចិត្ត ) ដែលជាលោកិយ: ដែលប្រាសចាកនាទីក្នុងការកម្ចាត់ភាពមិនមានសីល ព្រោះវិរតិមាននាទីកម្ចាត់ភាពមិនមានសីល ដូច្នេះ លោកទើបពោលថា **វិរតិវជ្ជិតា** ( វៀរវិរតិចេតសិក ) ដូចមានព្រះពុទ្ធវចនក្នុងព្រះបាលីថា **បញ្ច សិក្ខាបទា កុសលាយេវ** ប្រែថា “ សិក្ខាបទ ៥ ជាកុសលប៉ុណ្ណោះ ” ។

សូមជ្រាបថា ព្រះតម្រាស់នេះ សំដៅដល់សិក្ខាបទ ៥ ដែលជាលោកិយ: ( ព្រោះលោកុត្តរវិរតិ កើតបានក្នុងលោកុត្តរវិបាកចិត្ត ) ។

**អប្បមញ្ញា** រមែងមិនកើតក្នុងមហាវិបាកចិត្ត ព្រោះមានសត្វបញ្ញត្តិជាអារម្មណ៍ ចំណែកមហាវិបាកមានកាមារម្មណ៍ជាអារម្មណ៍ពិតប្រាកដ ដូច្នោះលោកទើបពោលថា **អប្បមញ្ញាវិរតិវជ្ជិតា** ( វៀរអប្បមញ្ញាចេតសិក និង វិរតិចេតសិក ) ។

-សួរថា: កាមាវចរកុសលក៏មានសត្វបញ្ញត្តិជាដើម ជាអារម្មណ៍បាន ដូច្នោះ វិបាករបស់កុសល ក៏គប្បីមានអារម្មណ៍ដូចកុសលដូចគ្នាមែនឬ ?

-ឆ្លើយថា: មិនគប្បីពោលយ៉ាងនោះ ព្រោះមហាវិបាកចិត្ត ប្រាសចាកការត្រិះរិះពិចារណា បានសេចក្តីថា បញ្ញត្តិជាវត្ថុមិនមានពិត ( តែមានដោយការសន្មតិ ) ថែមទាំងធម៌ដែលជាមហគ្គតៈ និង លោកុត្តរៈ ក៏មានសភាពល្អិតសុខុម បញ្ញត្តិ និង ធម៌ពួកនោះ ទើបជាអារម្មណ៍របស់កុសលចិត្តជាដើមដែលទទួលដឹងដោយការត្រិះរិះ ឬ ចាក់ធ្លុះដោយប្រការនោះៗ តែកាមាវចរវិបាកចិត្ត ពុំអាចត្រិះរិះដឹងនូវអារម្មណ៍ទាំងនោះបានឡើយ ព្រោះមានអានុភាពតិច ព្រោះហេតុដូច្នេះ ទើបកាមាវចរវិបាកមានអារម្មណ៍ជាបញ្ញត្តិ ឬ មហគ្គត ឬ លោកុត្តរមិនបាន ចំណែកមហគ្គតវិបាក សូម្បីប្រាសចាកការត្រិះរិះពិចារណា ក៏មានអារម្មណ៍ជាបញ្ញត្តិដោយចំពោះ ដែលកើតឡើងដោយអានុភាពនៃការចម្រើនភាវនា ព្រោះជាផលរបស់កម្មវិសេស ដែលបន្លុះដល់អប្បនាហើយ។

## គាថាសរុប

[៤១] **អដ្ឋតឹស សត្តតឹស ទ្វយំ ឆត្តឹសកំ សុភេ**

**បញ្ចតឹស ចតុត្តឹស ទ្វយំ តេត្តឹសកំ ក្រិយេ ។**

**តេត្តឹស បាកេ ពាត្តឹស ទ្វយេកតឹសកំ ភវេ**

**សហេតុកាមាវចរ- បុញ្ញបាកក្រិយាមនេ ។**

ប្រែថា “ បណ្តាកាមាវចរសោភណចិត្តដែលមានមហាកុសលចិត្ត ( ៨ ដួង ) មហាវិបាកចិត្ត ( ៨ ដួង ) និង មហាកិរិយាចិត្ត ( ៨ ដួង ) ដែលប្រកបដោយហេតុ

ចេតសិក ៣៨ ដួង ៣៧ ដួងពីរដងនិង ៣៦ ដួងរមែងដល់នូវការរាប់ចូលក្នុងកាមាវចរកុសលចិត្ត ។

ចេតសិក ៣៥ ដួង ៣៤ ដួងពីរដង និង ៣៣ ដួងរមែងដល់នូវការរាប់ចូលក្នុងសហេតុកាមាវចរកិរិយាចិត្ត ។

ចេតសិក ៣៣ ដួង ៣២ ដួងពីរដង និង ៣១ ដួង រមែងដល់នូវការរាប់ចូលក្នុងសហេតុកាមាវចរវិបាកចិត្ត ”។

[ ក្នុងកាមាវចរកុសលចិត្ត ៨ មានសង្គហៈ ៤ ន័យគឺះ

**នំយទី ១** ចេតសិក ៣៨ ដួងគឺះ អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២៥ ដួង ប្រកបក្នុងមហាកុសលចិត្តដួងទី ១ និង ដួងទី ២ ។

**នំយទី ២** ចេតសិក ៣៧ ដួងគឺះ អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២៤ ដួង ( វៀរបញ្ញាចេតសិក ) ប្រកបក្នុងមហាកុសលចិត្តដួងទី ៣ និង ដួងទី ៤ ។

**នំយទី ៣** ចេតសិក ៣៧ ដួងគឺះ អញ្ញសមានាចេតសិក ១២ ( វៀរបីតិចេតសិក ) សោភណចេតសិក ២៥ ដួង ប្រកបក្នុងមហាកុសលចិត្តដួងទី ៥ និង ដួងទី ៦ ។

**នំយទី ៤** ចេតសិក ៣៦ ដួង គឺះ អញ្ញសមានាចេតសិក ១២ (វៀរបីតិចេតសិក) សោភណចេតសិក ២៤ ដួង ( វៀរបញ្ញាចេតសិក ) ប្រកបក្នុងមហាកុសលចិត្តដួងទី ៧ និង ដួងទី ៨ ។

ក្នុងសហេតុកកាមាវចរកិរិយាចិត្ត ៨ ដួង មានសង្គហៈ ៤ ន័យគឺះ

**នំយទី ១** ចេតសិក ៣៥ ដួងគឺះ អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២២ ( វៀរវិរតិចេតសិក ៣ ) ប្រកបក្នុងមហាកិរិយាចិត្តដួងទី ១ និង ដួងទី ២ ។

**នំយទី ២** ចេតសិក ៣៤ ដួងគឺៈ អញ្ញសមានាចេតសិក ១៣ សោភណ-ចេតសិក ២១ ( វៀរវិរតិចេតសិក ៣ បញ្ញាចេតសិក ១ ) ប្រកបក្នុងមហាកិរិយា-ចិត្តដួងទី ៣ និង ដួងទី ៤ ។

**នំយទី ៣** ចេតសិក ៣៤ ដួងគឺៈ អញ្ញសមានាចេតសិក ១២ ( វៀរបីតិ-ចេតសិក ) សោភណចេតសិក ២២ ( វៀរវិរតិចេតសិក ៣ ) ប្រកបក្នុងមហា-កិរិយាចិត្តដួងទី ៥ និង ដួងទី ៦ ។

**នំយទី ៤** ចេតសិក ៣៣ ដួងគឺៈ អញ្ញសមានាចេតសិក ១២ ( វៀរបីតិ ចេតសិក ) សោភណចេតសិក ២១ ( វៀរវិរតិចេតសិក ៣ បញ្ញាចេតសិក១ ) ប្រកបក្នុងមហាកិរិយាចិត្តដួងទី ៧ និង ដួងទី ៨ ។

ក្នុងសហេតុកកាមាវចរវិបាកចិត្ត ៨ មានសង្គហៈ ៤ ន័យគឺៈ

**នំយទី ១** ចេតសិក ៣៣ ដួងគឺៈ អញ្ញសមានាចេតសិក ១៣ សោភណ-ចេតសិក ២០ ( វៀរវិរតិចេតសិក ៣ អប្បមញ្ញាចេតសិក ២ ) ប្រកបក្នុងមហា-វិបាកចិត្តដួងទី ១ និង ដួងទី ២ ។

**នំយទី ២** ចេតសិក ៣២ ដួងគឺៈ អញ្ញសមានាចេតសិក ១៣ សោភណ-សាធារណចេតសិក ១៩ ប្រកបក្នុងមហាវិបាកចិត្តដួងទី ៣ និង ដួងទី ៤ ។

**នំយទី ៣** ចេតសិក ៣២ ដួងគឺៈ អញ្ញសមានាចេតសិក ១២ ( វៀរបីតិ ចេតសិក ) សោភណចេតសិក ២០ ( វៀរវិរតិចេតសិក ៣ អប្បមញ្ញាចេតសិក ២ ) ប្រកបក្នុងមហាវិបាកចិត្តដួងទី ៥ និង ដួងទី ៦ ។

**នំយទី ៤** ចេតសិក ៣១ ដួងគឺៈ អញ្ញសមានាចេតសិក ១២ ( វៀរបីតិ ចេតសិក ) សោភណសាធារណចេតសិក ១៩ ប្រកបក្នុងមហាវិបាកចិត្តដួងទី ៧ និង ដួងទី ៨ ។

# អធិប្បាយ

ពាក្យថា **សុភេ** ប្រែថា ក្នុងកុសលចិត្ត ។

ពាក្យថា **មនេ** ប្រែថាបណ្ដាចិត្ត ចុះសត្តមីវិភត្តិ ក្នុងអត្ថនិទ្ធារណៈ ( ក្រុមដែលមានការចែកចេញជាចំណែកតូចៗ ) គប្បីជ្រាប **និទ្ធារណីយ** ( ចំណែកតូច ) ពាក្យថា **សុភេ ក្រិយេ បាកេ** ( ក្នុងកុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត ) ន័យម្យ៉ាងទៀត គប្បីប្រកបបទថា សង្គហន័យក្នុងចិត្តដែលជាកាមាវចរកុសល-វិបាក និង កិរិយា ដែលប្រកបដោយហេតុមាន ១២ ន័យ ។

[ តាមន័យដំបូង ពាក្យថា **មនេ** ចុះសត្តមីវិភត្តិក្នុងអត្ថនិទ្ធារណៈ ន័យក្រោយឲ្យចុះសត្តមីវិភត្តិក្នុងអត្ថ **អាធារណ** តាមប្រក្រតី ] ។

# ចិត្តដែលមិនប្រកបដោយវិរតិ អប្បមញ្ញា

**[៤២] ន វិជ្ជន្តេត្ថ វិរតី ក្រិយេសុ ច មហគ្គតេ**

**អនុត្តរេ អប្បមញ្ញា កាមបាកេ ទ្វយំ តថា ។**

ប្រែថា “ បណ្ដាសោភណចិត្តទាំងនោះ វិរតិចេតសិក ( ៣ដួង ) រមែងមិនប្រកបក្នុងមហាកិរិយាចិត្ត ( ៨ ដួង ) និង ក្នុងមហគ្គតចិត្ត ( ២៧ ដួង )។

អប្បមញ្ញាចេតសិក ( ២ ដួង ) រមែងមិនប្រកបក្នុងលោកុត្តរចិត្ត ( ៨ ដួង ) ម្យ៉ាងទៀត ទាំងវិរតិចេតសិក និង អប្បមញ្ញាចេតសិក ទាំងពីរយ៉ាងនេះ រមែងមិនប្រកបក្នុងមហាវិបាកចិត្ត ” ។

# អធិប្បាយ

ពាក្យថា **ឯត្ថ** គឺបណ្ដាសោភណចិត្ត ។

ពាក្យថា **ទ្វយំ** ( ចេតសិក ២ យ៉ាង ) គឺ វិរតិចេតសិក និង អប្បមញ្ញា-ចេតសិក។

# វិសេសកចេតសិក

## ( ចេតសិកដែលធ្វើឲ្យចិត្តផ្សេងគ្នា )

**អនុត្តរេ ឈានធម្មា អប្បមញ្ញា ច មជ្ឈិមេ**
**វិរតី ញាណបីតី ច បរិត្តេសុ វិសេសកា ។**

ប្រែថា “ ក្នុងលោកុត្តរចិត្ត អង្គឈានទាំង ៥ គឺ៖ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា រមែងធ្វើឲ្យផ្សេងគ្នា ។

ក្នុងមហគ្គតចិត្ត អប្បមញ្ញាចេតសិក ២ និង អង្គឈានទាំង ៥ រមែងធ្វើឲ្យផ្សេងគ្នា ។

ក្នុងកាមាវចរចិត្ត វិរតិចេតសិក ៣ បញ្ញាចេតសិក ១ បីតិចេតសិក ១ អប្បមញ្ញាចេតសិក ២ រមែងធ្វើឲ្យផ្សេងគ្នា ” ។

## អធិប្បាយ

ក្នុងលោកុត្តរចិត្ត អង្គឈានទាំង ៥ ធ្វើឲ្យផ្សេងគ្នានោះគឺ៖

-វិតក្កចេតសិក ធ្វើឲ្យបឋមជ្ឈានចិត្ត ផ្សេងពីឈានចិត្តដទៃដែលនៅសល់។

-វិចារចេតសិក ធ្វើឲ្យទុតិយជ្ឈានចិត្ត ផ្សេងពីឈានចិត្តដែលនៅសល់ ៣ មានតតិយជ្ឈានចិត្តជាដើម ។

-បីតិចេតសិក ធ្វើឲ្យតតិយជ្ឈានចិត្ត ផ្សេងគ្នាពីចតុត្ថជ្ឈានចិត្ត និង បញ្ចមជ្ឈានចិត្ត ។

-សុខវេទនា ធ្វើឲ្យចតុត្ថជ្ឈានចិត្ត ផ្សេងពីបញ្ចមជ្ឈានចិត្ត ។

-ឧបេក្ខាវេទនា ធ្វើឲ្យបញ្ចមជ្ឈានចិត្ត ផ្សេងពីឈានចិត្តដែលនៅសល់ ៤

ក្នុងមហគ្គតចិត្ត អប្បមញ្ញាចេតសិក ២ ធ្វើឲ្យមហគ្គតចិត្ត ១២ គឺៈ បឋមជ្ឈានចិត្ត រហូតដល់ចតុត្ថជ្ឈានចិត្ត ផ្សេងពីបញ្ចមជ្ឈានចិត្ត ១៥ ។ ចំណែកអង្គឈានទាំង ៥ រមែងធ្វើឲ្យមហគ្គតចិត្តផ្សេងគ្នា ដូចលោកុត្តរចិត្ត ។

ក្នុងកាមាវចរសោភណចិត្ត វិរតិចេតសិក ៣ ធ្វើឲ្យមហាកុសលចិត្ត ផ្សេងពីមហាវិបាកចិត្ត និង មហាកិរិយាចិត្ត ។

-បញ្ញាចេតសិក ធ្វើឲ្យញាណសម្បយុត្តចិត្ត ផ្សេងពីញាណវិប្បយុត្តចិត្ត។

-បីតិចេតសិក ធ្វើឲ្យសោមនស្សសហគតចិត្ត ផ្សេងពីឧបេក្ខាសហគតចិត្ត ។

-អប្បមញ្ញាចេតសិក ២ ធ្វើឲ្យមហាកុសលចិត្ត និងមហាកិរិយាចិត្ត ផ្សេងពីមហាវិបាកចិត្ត ។

ពាក្យថា **អនុត្តរេ** ( ក្នុងលោកុត្តរចិត្ត ) ជាការរាប់ធម៌ដែលធ្វើឲ្យមានលក្ខណៈចំពោះ មិនទូទៅ ។

ពាក្យថា **ឈានធម្មា** ( ធម៌ដែលជាឈាន ) គឺ វិតក្កៈជាដើម ។

# អកុសលចិត្ត សង្គហន័យ

## ( ការរាប់ចំនួនចេតសិកក្នុងអកុសលចិត្ត )

**[៤៣] អកុសលេសុ បន លោភមូលេសុ តាវ បឋមេ អសង្ខារិកេ អញ្ញសមានា តេរស ចេតសិកា អកុសលសាធារណា ចត្តារោ ចាតិ សត្តរស លោភទិដ្ឋីហិ សទ្ធឹ ឯកូនវីសតិ ធម្មា សង្គហំ គច្ឆន្តិ ។**

ប្រែថា បណ្ដាអកុសលចិត្តទាំងឡាយ លំដាប់ដំបូង ក្នុងលោភមូលចិត្ត ចេតសិក ២៧ ដួងគឺៈ អញ្ញសមានាចេតសិក ១៣ ដួង និង អកុសលសាធារណចេតសិក ៤ ដួង ព្រមទាំងលោភចេតសិក និង ទិដ្ឋិចេតសិក រួមត្រូវជាចេតសិក ១៩ រមែងដល់នូវការរាប់ចូលក្នុងអសង្ខារិកចិត្តដួងទី ១ ។

**[៤៤] តថេវ ទុតិយេ អសង្ខារិកេ លោភមានេន ។**

ប្រែថា ដូចគ្នានេះ ( ចេតសិក ១៧ ដួង គឺៈ អញ្ញសមានាចេតសិក ១៣ ដួង និង អកុសលសាធារណចេតសិក ៤ ដួង ) ព្រមទាំងលោភចេតសិក និង មានចេតសិក ( រួមត្រូវជា ១៩ ដួង ) រមែដល់នូវការរាប់ចូលក្នុងអសង្ខារិកចិត្ត ដួងទី ២ ( លោភដួងទី ៣ ) ។

**[៤៥] តតិយេ តថេវ បីតិវជ្ជិតា លោភទិដ្ឋីហិ សហ អដ្ឋារស ។**

ប្រែថា ដូចគ្នានេះ ចេតសិក ១៦ ដួង គឺៈ ( អញ្ញសមានាចេតសិក ១២ ដួង ) វៀរបីតិចេតសិក ( និង អកុសលសាធារណចេតសិក ៤ ដួង ) ព្រមទាំង លោភចេតសិក និង ទិដ្ឋិចេតសិក រួមត្រូវជាចេតសិក ១៨ ដួង រមែងដល់នូវការ រាប់ចូលក្នុងអសង្ខារិកចិត្តដួងទី ៣ ( លោភដួងទី៥ ) ។

**[៤៦] ចតុត្ថេ តថេវ លោភមានេន ។**

ប្រែថា ដូចគ្នានេះ [ ចេតសិក ១៦ ដួង គឺៈ អញ្ញសមានាចេតសិក ១២ ដួង ( វៀរបីតិចេតសិក ) និង អកុសលសាធារណចេតសិក ៤ ដួង ] ព្រម ទាំងលោភចេតសិក និង មានចេតសិក ( រួមត្រូវជាចេតសិក ១៨ ដួង ) រមែង ដល់នូវការរាប់ចូលក្នុងអសង្ខារិកចិត្តដួងទី ៤ ( លោភដួងទី ៧ )។

**[៤៧] បញ្ចមេ បន បដិឃសម្បយុត្តេ អសង្ខារិកេ ទោសោ ឥស្សា មច្ឆរិយំ កុក្កុច្ចញ្ចាតិ ចតូហិ សទ្ធឹ បីតិវជ្ជិតា តេ ឯវ វីសតិ ធម្មា សង្គយ្ហន្តិ ។**

ប្រែថា ចេតសិកទាំងឡាយពួកនោះ [ គឺៈ អញ្ញសមានាចេតសិក ១២ ដួង ( វៀរបីតិចេតសិក ) និង អកុសលសាធារណចេតសិក ៤ ដួង ] ព្រមទាំង ចេតសិក ៤ ដួង គឺៈ ទោសៈ ឥស្សាមច្ឆរិយៈកុក្កុច្ចៈរួមត្រូវជា ២០ ដួង រមែង ដល់នូវការរាប់ចូលក្នុងអសង្ខារិកចិត្តដួងទី ៥ ( ទោសមូលដួងទី១ ) ដែល ប្រកបដោយបដិឃៈ។

**ឥស្សាមច្ឆរិយកុក្កុច្ចានិ បនេត្ថ បច្ចេកមេវ យោជេតព្វានិ ។**

ប្រែថា គប្បីប្រកបឥស្សាមច្ឆរិយៈ និង កុក្កុច្ចៈ ក្នុងអសង្ខារិកចិត្តដួងទី ៥ នេះ ម្តងបាន ១ ដួងប៉ុណ្ណោះ ។

[ ចេតសិកទាំង ៣ ដួងនេះ មិនកើតព្រមគ្នា តែងកើតបែកគ្នា ]

**[៤៨] សសង្ខារិកបញ្ចកេបិ តថេវ ថិនមិទ្ធេន វិសេសេត្វា យោជេតព្វា**

ប្រែថា គប្បីប្រកប ( ចេតសិកដូចដែលបានពោលមក ) ក្នុងសសង្ខារិក-ចិត្ត ទាំង ៥ ដួង ដូចយ៉ាងនោះ ។

[ តាមន័យ ៥ យ៉ាងដែលបានសម្តែងមកហើយ ប្តូរតែអសង្ខារិក ជាសសង្ខារិកប៉ុណ្ណោះ ដោយបន្ថែម ថីនចេតសិក និង មិទ្ធចេតសិកចូលមកផង ]

**[៤៩] ឆន្ទបីតិវជ្ជិតា បន អញ្ញសមានា ឯកាទស, អកុសលសាធារណា ចត្តារោ ចាតិ បន្នរស ធម្មា ឧទ្ធច្ចសហគតេ សម្បយុជ្ជន្តិ ។**

ប្រែថា ចេតសិក ១៥ ដួងគឺៈ អញ្ញសមានាចេតសិក ( វៀរឆន្ទចេតសិក និង បីតិចេតសិក ) ត្រូវជា ១១ ដួង និង អកុសលសាធារណចេតសិក ៤ ដួង រមែងដល់នូវការរាប់ចូលក្នុងឧទ្ធច្ចសម្បយុត្តចិត្ត ។

**[៥០] វិចិកិច្ឆាសហគតចិត្តេ ច អធិមោក្ខវិរហិតា វិចិកិច្ឆាសហគតា តថេវ បន្នរស ធម្មា សមុបលព្ភន្តីតិ ។**

ប្រែថា ចេតសិកដូចដែលបានពោលមកនេះ ( វៀរអធិមោក្ខចេតសិក ) ព្រមជាមួយវិចិកិច្ឆាចេតសិក រួមត្រូវជា ១៥ ដួង រមែងដល់នូវការរាប់ចូលក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ។

**សព្វថាបិ ទ្វាទសាកុសលចិត្តុប្បាទេសុ បច្ចេកំ យោជិយមានាបិ គណនវសេន សត្តធាវ សង្គហិតា ភវន្តីតិ ។**

ប្រែថា ដោយប្រការដូច្នេះ ចេតសិកសូម្បីប្រកបបានក្នុងចិត្តដួងនីមួយៗ រួមត្រូវជា ៧ ន័យប៉ុណ្ណោះ ក្នុងអកុសលចិត្តដែលកើតឡើង ១២ ដួង។

## គាថាសង្គហ

**[៥១] ឯកូនវីសាដ្ឋារស វីសេកវីស វីសតិ**
**ទ្វាវីស បន្នរសេតិ សត្តធា កុសលេ ឋិតា ។**

ប្រែថា “ សង្គហន័យឋិតនៅក្នុងអកុសលចិត្ត ( ១២ដួង ) មាន ៧ ន័យ គឺ ចេតសិក ១៩ ដួង ចេតសិក ១៨ ដួង ចេតសិក ២០ ដួង ចេតសិក ២១ ដួង ចេតសិក ២០ ដួង ចេតសិក ២២ ដួង និង ចេតសិក ១៥ ដួង ” ។

[ ក្នុងអកុសលចិត្ត ១២ មានសង្គហៈ ៧ ន័យគឺះ

**ន័យទី ១** អកុសលអសង្ខារិកចិត្តដួងទី ១ និង ទី ២ មានចេតសិកប្រកប ១៩ ដួង គឺ

-លោភមូលចិត្តដួងទី ១ មានចេតសិកប្រកប ១៩ ដួង បានដល់ អញ្ញសមានាចេតសិក ១៣ មោចតុក្កចេតសិក ៤ លោភចេតសិក ១ ទិដ្ឋិចេតសិក ១។

-លោភមូលចិត្តដួងទី ៣ មានចេតសិកប្រកប ១៩ ដួង បានដល់ អញ្ញសមានាចេតសិក ១៣ មោចតុក្កចេតសិក ៤ លោភចេតសិក ១ មានចេតសិក ១ ។

**ន័យទី២** អកុសលអសង្ខារិកចិត្តដួងទី ៣ និង ទី ៤ មានចេតសិកប្រកប ១៨ ដួងគឺះ

-លោភមូលចិត្តដួងទី ៥ មានចេតសិកប្រកប ១៨ ដួង បានដល់ អញ្ញសមានាចេតសិក ១២ ( វៀរបីតិចេតសិក ) មោចតុក្កចេតសិក ៤ លោភចេតសិក ១ ទិដ្ឋិចេតសិក ១។

-លោភមូលចិត្តដួងទី ៧ មានចេតសិកប្រកប ១៨ ដួង បានដល់ អញ្ញសមានាចេតសិក ១២ ( វៀរបីតិចេតសិក ) មោចតុក្កចេតសិក ៤ លោភចេតសិក ១ មានចេតសិក ១ ។

**ន័យទី ៣** អកុសលអសង្ខារិកចិត្តដួងទី ៥ គឺះ ទោសមូលចិត្តដួងទី ១ មានចេតសិកប្រកប ២០ ដួង បានដល់ អញ្ញសមានាចេតសិក ១២ ( វៀរបីតិចេតសិក ) មោចតុក្កចេតសិក ៤ ទោចតុក្កចេតសិក ៤ ។

**ន័យទី៤** អកុសលសសង្ខារិកចិត្តដួងទី ១ និង ទី ២ មានចេតសិកប្រកប ២១ ដួង គឺះ

-លោភមូលចិត្តដួងទី ២ មានចេតសិកប្រកប ២១ ដួង បានដល់ អញ្ញសមានាចេតសិក ១៣ មោចតុក្កចេតសិក ៤ លោភចេតសិក ១ ទិដ្ឋិចេតសិក ១ ថីទុកចេតសិក ២ ។

-លោភមូលចិត្តដួងទី ៤ មានចេតសិកប្រកប ២១ ដួង បានដល់ អញ្ញសមានាចេតសិក ១៣ មោចតុក្កចេតសិក ៤ លោភចេតសិក ១ មានចេតសិក ១ ថីទុកចេតសិក ២ ។

**នំយទី៥** អកុសលសសង្ខារិកចិត្តដួងទី៣ និង ទី៤ មានចេតសិកប្រកប ២០ ដួង គឺៈ

-លោភមូលចិត្តដួងទី ៦ មានចេតសិកប្រកប ២០ ដួង បានដល់ អញ្ញសមានាចេតសិក ១២ ( វៀរបីតិចេតសិក ) មោចតុក្កចេតសិក ៤ លោភចេតសិក ១ ទិដ្ឋិចេតសិក ១ ថីទុកចេតសិក ២ ។

-លោភមូលចិត្តដួងទី ៨ មានចេតសិកប្រកប ២០ ដួង បានដល់ អញ្ញសមានាចេតសិក ១២ ( វៀរបីតិចេតសិក ) មោចតុក្កចេតសិក ៤ លោភចេតសិក ១ មានចេតសិក ១ ថីទុកចេតសិក ២ ។

**នំយទី ៦** អកុសលសសង្ខារិកចិត្តដួងទី ៥ គឺទោសមូលចិត្តដួងទី ២ មានចេតសិកប្រកប ២២ ដួង គឺៈ អញ្ញសមានាចេតសិក ១២ ( វៀរបីតិចេតសិក ) មោចតុក្កចេតសិក ៤ ទោចតុក្កចេតសិក ៤ ថីទុកចេតសិក ២ ។

**នំយទី ៧** មោហាមូលចិត្ត ២ មានចេតសិកប្រកប ១៥ ដួងគឺៈ

-មោហាមូលចិត្តដួងទី ១ គឺ វិចិកិច្ឆាសម្បយុត្តចិត្ត មានចេតសិកប្រកប ១៥ ដួង បានដល់ អញ្ញសមានាចេតសិក ១០ ( វៀរអធិមោក្ខៈ បីតិ និង ឆន្ទៈ ) មោចតុក្កចេតសិក ៤ វិចិកិច្ឆាចេតសិក ១ ។

-មោហាមូលចិត្តដួងទី ២ គឺ ឧទ្ធច្ចសម្បយុត្តចិត្ត មានចេតសិកប្រកប ១៥ ដួង បានដល់ អញ្ញសមានាចេតសិក ១១ ដួង ( វៀរបីតិ និង ឆន្ទៈ ) មោចតុក្កចេតសិក ៤ ] ។

# សព្វាកុសលយោគីចេតសិក

## ( ចេតសិកដែលប្រកបក្នុងអកុសលចិត្តទាំងអស់ )

**[៥២] សាធារណា ច ចត្តារោ សមានា ច ទសាបរេ**
**ចុទ្ទសេតេ បវុច្ចន្តិ សព្វាកុសលយោគិនោ ។**

ប្រែថា “ចេតសិក ១៤ ដួង ពួកនេះ គឺៈ អកុសលសាធារណចេតសិក ៤ ដួង និង អញ្ញសមានាចេតសិក ១០ ដួង ដទៃទៀត ( វៀរអធិមោក្ខៈ បីតិ ឆន្ទៈ ) លោកទើបហៅថា **សព្វាកុសលយោគីចេតសិក** ( ចេតសិកដែលប្រកបក្នុងអកុសលចិត្តទាំងអស់ ) ” ។

## អធិប្បាយ

ពាក្យថា **សាធារណា** គឺ សព្វាកុសលសាធារណចេតសិក ។

ពាក្យថា **សមានា** គឺ អញ្ញសមានាចេតសិក ។

ពាក្យថា **អបរេ** ( អញ្ញសមានាចេតសិកដទៃ ) គឺ អញ្ញសមានាចេតសិក ដែលវៀរពីអធិមោក្ខៈ បីតិ ឆន្ទៈ ។

# អហេតុកចិត្ត សង្គហន័យ

## ( ការរាប់ចំនួនចេតសិកក្នុងអហេតុកចិត្ត )

**[៥៣] អហេតុកេសុ បន ហសនចិត្តេ តាវ ឆន្ទវជ្ជិតា អញ្ញសមានា ទ្វាទស ធម្មា សង្គហំ គច្ឆន្តិ ។**

ប្រែថា បណ្ដាអហេតុកចិត្តទាំងឡាយ លំដាប់ដំបូង អញ្ញសមានា-ចេតសិក ( ១២ ដួង ) វៀរឆន្ទៈ រមែងដល់នូវការរាប់ចូលក្នុងហសិតុប្បាទចិត្ត។

**[៥៤] តថា វោដ្ឋព្វនេ ឆន្ទបីតិវជ្ជិតា ។**

ប្រែថា ដូចគ្នានេះ អញ្ញសមានាចេតសិក ( ១១ ដួង ) វៀរ បីតិ និង ឆន្ទៈ រមែងដល់នូវការរាប់ចូលក្នុងវោដ្ឋព្វនចិត្ត ។

**[៥៥] សុខសន្តីរណេ ឆន្ទវីរិយវជ្ជិតា។**

ប្រែថា អញ្ញសមានាចេតសិក ( ១១ ដួង ) វៀរវីរិយចេតសិក និង ឆន្ទ-ចេតសិក ) រមែងដល់នូវការរាប់ចូលក្នុងសោមនស្សសន្តីរណចិត្ត ។

**[៥៦] មនោធាតុត្តិកាហេតុកបដិសន្ធិយុគឡេ ឆន្ទបីតិវីរិយវជ្ជិតា ។**

ប្រែថា អញ្ញសមានាចេតសិក ( ១០ ដួង ) វៀរវីរិយចេតសិក បីតិ-ចេតសិក និង ឆន្ទចេតសិករមែងដល់នូវការរាប់ចូលក្នុងមនោធាតុ ៣ ដួង និង អហេតុកបដិសន្ធិចិត្តមួយគូ ។

**[៥៧] ទ្វិបញ្ចវិញ្ញាណេ បកិណ្ណកវជ្ជិតា តេយេវ សង្គយ្ហន្តីតិ ។**

ប្រែថា អញ្ញសមានាចេតសិកពួកនោះ នុ៎ះឯង វៀរបកិណ្ណកចេតសិក ( ៦ ដួង ) រមែងដល់នូវការរាប់ចូលក្នុងទ្វិបញ្ចវិញ្ញាណចិត្ត ។

**សព្វថាបិ អដ្ឋារសសុ អហេតុកេសុ គណនវសេន ចតុធាវ សង្គហោ ហោតីតិ**

ប្រែថា សង្គហន័យ ក្នុងអហេតុកចិត្ត ១៨ ដួង មាន ៤ ន័យ ដោយចែកតាមការរាប់ ដោយប្រការទាំងពួង ។

# អធិប្បាយ

ពាក្យថា **ហសនចិត្តេ** គឺ ក្នុងហសិតុប្បាទចិត្ត ។

ពាក្យថា **វោដ្ឋព្វនេ** គឺ ក្នុងមនោទ្វារាវជ្ជនចិត្ត ។

ពាក្យថា **សុខសន្តីរណេ** គឺ ក្នុងសោមនស្សន្តីរណចិត្ត ។

ពាក្យថា **មនោធាតុត្តិកាហេតុកបដិសន្ធិយុគឡេ** ( មនោធាតុ ៣ និង អហេតុក-បដិសន្ធិមួយគូ ) គឺ មនោធាតុ ៣ ដែលហៅថា បញ្ចទ្វារាវជ្ជនចិត្ត ១ សម្ប-ដិច្ឆនចិត្ត ២ ។

និង អហេតុកបដិសន្ធិមួយគូ បានដល់ ឧបេក្ខាសន្តីរណចិត្ត ២ ។

**[៥៨] ទ្វាទសេកាទស ទស សត្ត ចាតិ ចតុព្វិធោ**
**អដ្ឋារសាហេតុកេសុ ចិត្តុប្បាទេសុ សង្គហោ ។**

ប្រែថា “សង្គហន័យក្នុងអហេតុកចិត្ត ១៨ ដួងមាន ៤ ន័យ គឺៈ ចេតសិក ១២ ដួង ចេតសិក ១១ ដួង ចេតសិក ១០ ដួង និង ចេតសិក ៧ដួង ”។

[ ក្នុងអហេតុកចិត្ត ១៨ មានសង្គហៈ ៤ ន័យគឺៈ

**ន័យទី ១** ចេតសិក ១២ ដួង បានដល់ អញ្ញសមានាចេតសិក ១២ ( វៀរឆន្ទៈ ) ប្រកបក្នុងហសិតុប្បាទចិត្ត ។

**ន័យទី ២ ក)** ចេតសិក ១១ ដួង បានដល់អញ្ញសមានាចេតសិក ១១ ( វៀរបីតិ និង ឆន្ទៈ ) ប្រកបក្នុងមនោទ្វារាវជ្ជនចិត្ត ។

**ខ)** ចេតសិក ១១ ដួង បានដល់ អញ្ញសមានាចេតសិក ១១ ( វៀរវីរិយៈ និង ឆន្ទៈ ) ប្រកបក្នុងសោមនស្សសន្តីរណចិត្ត ។

**ន័យទី ៣** ចេតសិក ១០ ដួង បានដល់ អញ្ញសមានាចេតសិក ១០ ( វៀរវីរិយៈ បីតិ និង ឆន្ទៈ ) ប្រកបក្នុងមនោធាតុ ៣ និង ឧបេក្ខាសន្តីរណចិត្ត ២ ។

**ន័យទី ៤** ចេតសិក ៧ ដួង គឺៈ សព្វចិត្តសាធារណចេតសិក ៧ ប្រកបក្នុងទ្វិបញ្ចវិញ្ញាណចិត្ត ១០ ] ។

**[៥៩] អហេតុកេសុ សព្វត្ថ សត្ត សេសា យថារហំ**

**ឥតិ វិត្ថារតោ វុត្តោ តេត្តឹសវិធសង្គហោ ។**

ប្រែថា “សព្វចិត្តសាធារណចេតសិក ៧ ដួង រមែងប្រកបក្នុងអហេតុក-ចិត្តទាំងអស់ បកិណ្ណកចេតសិកដែលនៅសល់ រមែងប្រកបតាមសមគួរ ខ្ញុំព្រះករុណា ( ព្រះអនុរុទ្ធាចារ្យ ) ពោលសង្គហន័យទុក ៣៣ ន័យ ដោយពិស្តារដោយប្រការដូច្នេះ ”។

# សង្គហន័យ ៣៣ ន័យ


អកុសលចិត្ត ១២
អហេតុកចិត្ត ១៨
កាមាវចរសោភណចិត្ត ២៤
មហគ្គតចិត្ត ២៧
លោកុត្តរចិត្ត ៤០
២ន័យ
២ន័យ
២ន័យ
១ន័យ
១ន័យ
១ន័យ
១ន័យ
១ន័យ
៧ន័យ
៤ន័យ
៤ន័យ
៤ន័យ
៤ន័យ
១២ន័យ
១ន័យ
១ន័យ ១ន័យ ១ន័យ ១ន័យ
៥ន័យ
១ន័យ ១ន័យ ១ន័យ ១ន័យ ១ន័យ
៥ន័យ
សង្គ្រោះសង្គហន័យ ៣៣

# តារាងសង្គហន័យ ៣៣ន័យ

| | ចេតសិក / ចិត្ត | អញ្ញសមានាចេតសិក ១៣ | | | | | | | អកុសលចេតសិក ១៤ | | | | | | | សោភណ.២៥ | | | | ចិត្តមានចេតសិកប្រកប | រាប់សង្គហន័យ ៣៣ ន័យ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សព្វចិត្តសាធារណៈ៧ | វិតក្កៈ ១ | វិចារៈ ១ | អធិមោក្ខ ១ | វីរិយ ១ | បីតិ ១ | ឆន្ទៈ ១ | មោចតុក្ក ៤ | លោភៈ ១ | ទិដ្ឋិ ១ | មានៈ ១ | ទោចតុក្ក ៤ | ថីនៈមិទ្ធ ២ | វិចិកិច្ឆា ១ | សោភណសា. ១៩ | វិរតិ ៣ | អប្បមញ្ញា ២ | បញ្ញិន្ទ្រិយ ១ | | | |
| អកុសលចិត្ត ១២ | លោភមូល ដួងទី ១ | ៧ | ១ | ១ | ១ | ១ | ១ | ១ | ៤ | ១ | ១ | | | | | | | | | ១៩ | ១ | ៧ ន័យ |
| | លោភមូល ...៣ | ៧ | ១ | ១ | ១ | ១ | ១ | ១ | ៤ | ១ | | ១ | | | | | | | | ១៩ | | |
| | លោភមូល ...២ | ៧ | ១ | ១ | ១ | ១ | ១ | ១ | ៤ | ១ | ១ | | | ២ | | | | | | ២១ | ១ | |
| | លោភមូល ...៤ | ៧ | ១ | ១ | ១ | ១ | ១ | ១ | ៤ | ១ | | ១ | | ២ | | | | | | ២១ | | |
| | លោភមូល ...៥ | ៧ | ១ | ១ | ១ | ១ | | ១ | ៤ | ១ | ១ | | | | | | | | | ១៨ | ១ | |
| | លោភមូល ...៧ | ៧ | ១ | ១ | ១ | ១ | | ១ | ៤ | ១ | | ១ | | | | | | | | ១៨ | | |
| | លោភមូល ...៦ | ៧ | ១ | ១ | ១ | ១ | | ១ | ៤ | ១ | ១ | | | ២ | | | | | | ២០ | ១ | |
| | លោភមូល ...៨ | ៧ | ១ | ១ | ១ | ១ | | ១ | ៤ | ១ | | ១ | | ២ | | | | | | ២០ | | |
| | ទោសមូល ដួងទី ១ | ៧ | ១ | ១ | ១ | ១ | | ១ | ៤ | | | | ៤ | | | | | | | ២០ | ១ | |
| | ទោសមូល „„ ២ | ៧ | ១ | ១ | ១ | ១ | | ១ | ៤ | | | | ៤ | ២ | | | | | | ២២ | ១ | |
| | មោហមូល ដួងទី ១ | ៧ | ១ | ១ | | ១ | | | ៤ | | | | | | ១ | | | | | ១៥ | ១ | |
| | មោហមូល „„ ២ | ៧ | ១ | ១ | ១ | ១ | | | ៤ | | | | | | | | | | | ១៥ | | |
| អហេតុកចិត្ត ១៨ | ទ្វិបញ្ចវិញ្ញាណ. ១០ | ៧ | | | | | | | | | | | | | | | | | | ៧ | ១ | ៤ ន័យ |
| | ឧ.សន្តីរណ. ២ | ៧ | ១ | ១ | ១ | | | | | | | | | | | | | | | ១០ | ១ | |
| | សម្បដិច្ឆន ២ | ៧ | ១ | ១ | ១ | | | | | | | | | | | | | | | ១០ | | |
| | បញ្ចទ្វារវជ្ជន ១ | ៧ | ១ | ១ | ១ | | | | | | | | | | | | | | | ១០ | | |
| | សោ.សន្តីរណ ១ | ៧ | ១ | ១ | ១ | | ១ | | | | | | | | | | | | | ១១ | ១ | |
| | មនោទ្វារវជ្ជន ១ | ៧ | ១ | ១ | ១ | ១ | | | | | | | | | | | | | | ១១ | | |
| | ហសិតុប្បាទ ១ | ៧ | ១ | ១ | ១ | ១ | ១ | | | | | | | | | | | | | ១២ | ១ | |
| មហាកុសល. ៨ | មហាកុសល គូទី ១ | ៧ | ១ | ១ | ១ | ១ | ១ | ១ | | | | | | | | ១៩ | ៣ | ២ | ១ | ៣៨ | ១ | កាមសោភណ ១២ ន័យ |
| | មហាកុសល ... ២ | ៧ | ១ | ១ | ១ | ១ | ១ | ១ | | | | | | | | ១៩ | ៣ | ២ | | ៣៧ | ១ | |
| | មហាកុសល ...៣ | ៧ | ១ | ១ | ១ | ១ | | ១ | | | | | | | | ១៩ | ៣ | ២ | ១ | ៣៧ | ១ | |
| | មហាកុសល ...៤ | ៧ | ១ | ១ | ១ | ១ | | ១ | | | | | | | | ១៩ | ៣ | ២ | | ៣៦ | ១ | |
| មហាវិបាក. ៨ | មហាវិបាក គូទី ១ | ៧ | ១ | ១ | ១ | ១ | ១ | ១ | | | | | | | | ១៩ | | | ១ | ៣៣ | ១ | |
| | មហាវិបាក ... ២ | ៧ | ១ | ១ | ១ | ១ | ១ | ១ | | | | | | | | ១៩ | | | | ៣២ | ១ | |
| | មហាវិបាក ...៣ | ៧ | ១ | ១ | ១ | ១ | | ១ | | | | | | | | ១៩ | | | ១ | ៣២ | ១ | |
| | មហាវិបាក ...៤ | ៧ | ១ | ១ | ១ | ១ | | ១ | | | | | | | | ១៩ | | | | ៣១ | ១ | |
| មហាកិរិយា.៨ | មហាកិរិយា គូទី ១ | ៧ | ១ | ១ | ១ | ១ | ១ | ១ | | | | | | | | ១៩ | | ២ | ១ | ៣៥ | ១ | |
| | មហាកិរិយា .. ២ | ៧ | ១ | ១ | ១ | ១ | ១ | ១ | | | | | | | | ១៩ | | ២ | | ៣៤ | ១ | |
| | មហាកិរិយា ...៣ | ៧ | ១ | ១ | ១ | ១ | | ១ | | | | | | | | ១៩ | | ២ | ១ | ៣៤ | ១ | |
| | មហាកិរិយា ...៤ | ៧ | ១ | ១ | ១ | ១ | | ១ | | | | | | | | ១៩ | | ២ | | ៣៣ | ១ | |
| ឈានលោកិយ. ២៧ | បឋមជ្ឈាន ៣ | ៧ | ១ | ១ | ១ | ១ | ១ | ១ | | | | | | | | ១៩ | | ២ | ១ | ៣៥ | ១ | ៥ ន័យ |
| | ទុតិយជ្ឈាន ៣ | ៧ | | ១ | ១ | ១ | ១ | ១ | | | | | | | | ១៩ | | ២ | ១ | ៣៤ | ១ | |
| | តតិយជ្ឈាន ៣ | ៧ | | | ១ | ១ | ១ | ១ | | | | | | | | ១៩ | | ២ | ១ | ៣៣ | ១ | |
| | ចតុត្ថជ្ឈាន ៣ | ៧ | | | ១ | ១ | | ១ | | | | | | | | ១៩ | | ២ | ១ | ៣២ | ១ | |
| | បញ្ចមជ្ឈាន ១៥ | ៧ | | | ១ | ១ | | ១ | | | | | | | | ១៩ | | | ១ | ៣០ | ១ | |
| ឈានលោកុត្តរ. ៤០ | បឋមជ្ឈាន៨ | ៧ | ១ | ១ | ១ | ១ | ១ | ១ | | | | | | | | ១៩ | ៣ | | ១ | ៣៦ | ១ | ៥ ន័យ |
| | ទុតិយជ្ឈាន ៨ | ៧ | | ១ | ១ | ១ | ១ | ១ | | | | | | | | ១៩ | ៣ | | ១ | ៣៥ | ១ | |
| | តតិយជ្ឈាន ៨ | ៧ | | | ១ | ១ | ១ | ១ | | | | | | | | ១៩ | ៣ | | ១ | ៣៤ | ១ | |
| | ចតុត្ថជ្ឈាន ៨ | ៧ | | | ១ | ១ | | ១ | | | | | | | | ១៩ | ៣ | | ១ | ៣៣ | ១ | |
| | បញ្ចមជ្ឈាន ៨ | ៧ | | | ១ | ១ | | ១ | | | | | | | | ១៩ | ៣ | | ១ | ៣៣ | ១ | |

# តារាងសម្បយោគន័យ និង សង្គហន័យរួមគ្នា

| ចិត្ត / ចេតសិក | អកុសលចិត្ត ១២ | | | | | | | | | | | | អហេតុកចិត្ត ១៨ | | | | | | កាមាវចរសោភណចិត្ត ២៤ | | | | | | | | | | | | មហគ្គតចិត្ត ២៧ | | | | | លោកុត្តរចិត្ត ៤០ | | | | | រួមចេ.ប្រកបក្នុងចិត្តសង្ខេប | រួមចេ.ប្រកបក្នុងចិត្តពិស្តារ | រួមសម្បយោគន័យ ១៦ ន័យ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | លោភមូលដួងទី ១ | លោភមូលដួងទី ៣ | លោភមូលដួងទី ២ | លោភមូលដួងទី ៤ | លោភមូលដួងទី ៥ | លោភមូលដួងទី ៧ | លោភមូលដួងទី ៦ | លោភមូលដួងទី ៨ | ទោសមូលដួងទី ១ | ទោសមូលដួងទី ២ | មោហមូលដួងទី ១ | មោហមូលដួងទី ២ | ទ្វិបញ្ចវិញ្ញាណ ១០ | មនោធាតុ ៣ | ឧ.សន្តីរណ ២ | សោ.សន្តីរណ ១ | មនោទ្វារាវជ្ជន ១ | ហសិតុប្បាទ ១ | មហាកុសលគូទី ១ | មហាកុសលគូទី ២ | មហាកុសលគូទី ៣ | មហាកុសលគូទី ៤ | មហាវិបាកគូទី ១ | មហាវិបាកគូទី ២ | មហាវិបាកគូទី ៣ | មហាវិបាកគូទី ៤ | មហាកិរិយាគូទី ១ | មហាកិរិយាគូទី ២ | មហាកិរិយាគូទី ៣ | មហាកិរិយាគូទី ៤ | បឋមជ្ឈាន ៣ | ទុតិយជ្ឈាន ៣ | តតិយជ្ឈាន ៣ | ចតុត្ថជ្ឈាន ៣ | បញ្ចមជ្ឈាន ១៥ | បឋមជ្ឈាន៨ | ទុតិយជ្ឈាន ៨ | តតិយជ្ឈាន ៨ | ចតុត្ថជ្ឈាន ៨ | បញ្ចមជ្ឈាន ៨ | | | | |
| សព្វចិត្តសាធា.ចេ. ៧ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | ៨៩ | ១២១ | ១ | ៧ ន័យ |
| វិតក្កចេ. ១ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | | | | √ | | | | | | ៥៥ | ១ | |
| វិចារចេ. ១ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | | | √ | √ | | | | | ៦៦ | ១ | |
| អធិមោក្ខចេ. ១ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | √ | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | ៧៨ | ១១០ | ១ | |
| វីរិយចេ. ១ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | | | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | ៧៣ | ១០៥ | ១ | |
| បីតិចេ. ១ | √ | √ | √ | √ | | | | | | | | | | | | √ | | √ | √ | √ | | | √ | √ | | | √ | √ | | | √ | √ | √ | | | √ | √ | √ | | | | ៥១ | ១ | |
| ឆន្ទចេ. ១ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | | | | | | | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | ៦៩ | ១០១ | ១ | |
| មោចតុកចេ. ៤ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | | | | | | | | | | | | | | | | | | | | | | | | | | | | ១២ | | ១ | ៥ ន័យ |
| លោភចេ. ១ | √ | √ | √ | √ | √ | √ | √ | √ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | ៨ | | ១ | |
| ទិដ្ឋិចេ. ១ | √ | | √ | | √ | | √ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | ៤ | | | |
| មានះចេ. ១ | | √ | | √ | | √ | | √ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | ៤ | | | |
| ទោចតុកចេ. ៤ | | | | | | | | | √ | √ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | ២ | | ១ | |
| ថីនទុកចេ. ២ | | | √ | √ | | | √ | √ | | √ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | ៥ | | ១ | |
| វិចិកិច្ឆាចេ. ១ | | | | | | | | | | | √ | | | | | | | | | | | | | | | | | | | | | | | | | | | | | | ១ | | ១ | |
| សោភណ.ចេ. ១៩ | | | | | | | | | | | | | | | | | | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | ៥៩ | ៩១ | ១ | ៤ ន័យ |
| វិរតិចេ. ៣ | | | | | | | | | | | | | | | | | | | √ | √ | √ | √ | | | | | | | | | | | | | | √ | √ | √ | √ | √ | ១៦ | ៤៨ | ១ | |
| អប្បមញ្ញាចេ. ២ | | | | | | | | | | | | | | | | | | | √ | √ | √ | √ | | | | | √ | √ | √ | √ | √ | √ | √ | √ | | | | | | | ២៨ | | ១ | |
| បញ្ញាចេ. ១ | | | | | | | | | | | | | | | | | | | √ | | √ | | √ | | √ | | √ | | √ | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | ៤៧ | ៧៩ | ១ | |
| រួមចិត្តមានចេ.ប្រកប | ១៩ | ១៩ | ២១ | ២១ | ១៨ | ១៨ | ២០ | ២០ | ២០ | ២២ | ១៥ | ១៥ | ៧ | ១០ | ១០ | ១១ | ១១ | ១២ | ៣៨ | ៣៧ | ៣៧ | ៣៦ | ៣៣ | ៣២ | ៣២ | ៣១ | ៣៥ | ៣៤ | ៣៤ | ៣៣ | ៣៥ | ៣៤ | ៣៣ | ៣២ | ៣០ | ៣៦ | ៣៥ | ៣៤ | ៣៣ | ៣៣ | សម្បយោគន័យ | | | |
| រួមសង្គហន័យ ៣៣ន័យ | ១ | | ១ | | ១ | | ១ | | ១ | ១ | ១ | | ១ | ១ | | ១ | | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | សង្គហន័យ | | | |
| | ៧ ន័យ | | | | | | | | | | | | ៤ ន័យ | | | | | | ១២ ន័យ | | | | | | | | | | | | ៥ ន័យ | | | | | ៥ ន័យ | | | | | | | | |

# ការរាប់ចំនួនចេតសិកស្មើនឹងចំនួនចិត្ត

**[៦០] ឥត្ថំ ចិត្តាវិយុត្តានំ សម្បយោគញ្ច សង្គហំ**

**ញត្វា ភេទំ យថាយោគំ ចិត្តេន សមមុទ្ទិសេ ។**

ប្រែថា “ បុគ្គលកាលបើជ្រាបសម្បយោគន័យ ( ១៦ន័យ ) និង សង្គហន័យ ( ៣៣ន័យ ) នៃចេតសិកហើយ គប្បីសម្តែងប្រភេទ ( របស់ចេតសិកទាំងនោះ ) ឲ្យស្មើនឹងចំនួនរបស់ចិត្ត តាមសមគួរ ”។

[ **សម្បយោគន័យ ១៦ ន័យគឺ៖**

| | | |
|---|---|---|
| សព្វចិត្តសាធារណចេតសិក | ៧ | មានសម្បយោគន័យ ១ន័យ ។ |
| បកិណ្ណកចេតសិក | ៦ | មានសម្បយោគន័យ ៦ន័យ ។ |
| អកុសលចេតសិក | ១៤ | មានសម្បយោគន័យ ៥ ន័យ ។ |
| សោភណចេតសិក | ២៥ | មានសម្បយោគន័យ ៤ ន័យ ។ |
| រួមចេតសិក | ៥២ | មានសម្បយោគន័យ ១៦ ន័យ ] ។ |

[ **សង្គហន័យ ៣៣ ន័យគឺ៖**

| | | |
|---|---|---|
| លោកុត្តរចិត្ត | ៤០ | មានសង្គហន័យ ៥ ន័យ ។ |
| មហគ្គតចិត្ត | ២៧ | មានសង្គហន័យ ៥ ន័យ ។ |
| កាមាវចរសោភណចិត្ត | ២៤ | មានសង្គហន័យ ១២ ន័យ ។ |
| អកុសលចិត្ត | ១២ | មានសង្គហន័យ ៧ ន័យ ។ |
| អហេតុកចិត្ត | ១៨ | មានសង្គហន័យ ៤ ន័យ ។ |
| រួមចិត្ត | ១២១ | មានសង្គហន័យ ៣៣ ន័យ ។ |

[ ពាក្យថា “ ឲ្យស្មើគ្នានឹងចំនួនរបស់ចិត្ត ” បានសេចក្តីថា ឲ្យរាប់ចំនួនចេតសិកស្មើនឹងចំនួនចិត្តដែលខ្លួនប្រកប ដូចជា ៖

ផស្ស: ប្រកបក្នុងចិត្ត ៨៩ ឬ ១២១ ដួង ឲ្យរាប់ផស្សចេតសិក ៨៩ ឬ ១២១ ដួង ស្មើនឹងចំនួនរបស់ចិត្ត ។

ពាក្យថា “ តាមសមគួរ ” បានសេចក្តីថា តាមសមគួរនៃចេតសិកនីមួយៗ ដែលអាចប្រកបបានក្នុងចិត្ត ដូចជា វិតក្កចេតសិក ប្រកបបានក្នុងចិត្ត ៥៥ ដួង ។

វិចារចេតសិក ប្រកបបានក្នុងចិត្ត ៦៦ ដួង ជាដើម ]។

**ឥតិ អភិធម្មត្ថសង្គហេ ចេតសិកសង្គហវិភាគោ នាម ទុតិយោ បរិច្ឆេទោ។**

## ចប់បរិច្ឆេទទី ២ ឈ្មោះចេតសិកសង្គហវិភាគ

## ក្នុងគម្ពីរអភិធម្មត្ថសង្គហៈ

# ពាក្យប្រារព្ធ

បន្ទាប់ពីបានដឹងចិត្ត និង ចេតសិកហើយ ព្រះអនុរុទ្ធាចារ្យលោកបានរួបរួមបរិច្ឆេទទាំងពីរឲ្យចូលគ្នា ដើម្បីអ្នកសិក្សាបានងាយស្រួល ជ្រាបច្បាស់ពីតួនាទីនៃធម្មជាតិទាំងពីរនេះមានការសហការគ្នាយ៉ាងស្អិតរមួតមិនអាចប្រាសចាកគ្នាបាន ទើបលោករួបរួមធម៌ទាំងនោះឲ្យបានឃើញការសំខាន់ៗដែលត្រូវយល់ដឹងមាន ៦ ចំណុច គឺហេតុទាំង ៦ ដែលមានសារៈសំខាន់ក្នុងការញ៉ាំងចិត្ត ចេតសិកឲ្យប្រព្រឹត្តទៅបានក្នុងដំណើរនៃសង្សារវដ្តនេះ មិនតែប៉ុណ្ណោះ លោកបានចងក្រងវេទនាដែលមានតួនាទីសំខាន់ក្នុងការធ្វើសត្វឲ្យដឹងសុខ ទុក្ខ សោមនស្ស ទោមនស្ស និងឧបេក្ខា ដែលជាធម្មជាតិមានពិតក្នុងជីវិតរបស់សត្វលោក ក្រោយពីបានដឹងសុខ ទុក្ខជាដើមហើយ លោកមានការបញ្ជាក់បន្ថែមទៀតថា ធម៌ទាំងពីរនោះ ( ចិត្ត ចេតសិក ) មានតួនាទីញ៉ាំងកិច្ចទាំងឡាយ មានកិច្ចឃើញជាដើមឲ្យសម្រេចទៅបាន ដែលប្រព្រឹត្តទៅក្នុងជីវិតប្រចាំថ្ងៃ ដើម្បីកំចាត់ការយល់ខុសថាមានយើងជាដើម ហើយធម៌ទាំងអស់នេះ ប្រព្រឹត្តទៅតាមសមគួរនៃទ្វាររបស់ខ្លួន មិនអាចលើសលួសពីទ្វាររបស់ខ្លួនបានឡើយ កាលបើធម៌ទាំងនោះកើតឡើងហើយ ត្រូវមានអារម្មណ៍ជានិច្ចជាកាល ថែមទាំងមាននាទីអាស្រ័យ ( ក្នុងភូមិរូប ) តាមសមគួរនៃធម៌នោះៗផង ។

គួរឱ្យមោទនភាពចំពោះស្នាដៃដ៏ពិសិដ្ឋរបស់ព្រះថេរៈណាស់ ។ យើងទាំងពីរបានសិក្សាហើយ យល់ដឹងនូវបកិណ្ណកសង្គហនេះ បានមួយចំណែក ល្មមសមគួរ ក៏កើតសេចក្តីជ្រះថ្លានឹកថានឹងបន្តចងក្រងមាតិកាធម៌នេះតទៅទៀត ទើបផ្តើមរៀបរៀងបកិណ្ណកសង្គហនេះ ដើម្បីជាប្រយោជន៍ដល់មនុស្សជាតិ អ្នកចង់ស្គាល់ជីវិតច្បាស់លាស់ ។

ហេតុនេះហើយ សូមសាធុជនគ្រប់រូប មេត្តារូតរះឡើង ទាន់ព្រះធម៌នៅមាន ប្រញាប់ចូលទៅសិក្សា សាកសួរ ទន្ទេញ ទ្រទ្រង់ ពិចារណាសេចក្តី ដើម្បីចម្រើនចំណេះ ផ្នែកខាងស្គាល់ជីវិតនេះ ដែលជាផ្លូវបាននូវសេចក្តីសុខទាំងក្នុងពេលកំពុងរស់នៅ ទាំងក្នុងបរលោក ធ្វើជីវិតនេះ ឱ្យមានខ្លឹមសារ ។ កុំបណ្តែតបណ្តោយឱ្យពេលវេលាកន្លងទៅ ដោយមិនបានស្គាល់នូវជីវិតនេះ ស្មើនឹងវែកក្នុងឆ្នាំងសម្ល ឡើយ ។

ដោយអំណាចនៃធម្មទាននេះ ចូរជាប្រយោជន៍ដល់សព្វសត្វ សូមបានជាពន្លឺ ពោលគឺប្រាជ្ញា ដឹកនាំជីវិតឆ្ពោះទៅរកសន្តិសុខ គឺព្រះនិព្វាន កុំបីអាក់ខានឡើយ ។

ថ្ងៃ សុក្រ ១៥ កើត ខែ ចេត្រ ព.ស.២៥៥៨

អ៊ុំ សុជា

ប៉ោរ សុមាលី

# ព្រះអភិធម្មត្ថសង្គហបាលី

# បរិច្ឆេទទី ៣

# បកិណ្ណកសង្គហវិភាគ

[១] សម្បយុត្តា យថាយោគំ តេបញ្ញាស សភាវតោ
ចិត្តចេតសិកា ធម្មា តេសំ ទានិ យថារហំ ។
[២] វេទនាហេតុតោ កិច្ច- ទ្វារាលម្ពណវត្ថុតោ
ចិត្តុប្បាទវសេនេវ សង្គហោ នាម នីយតេ ។

[៣] តត្ថ វេទនាសង្គហេ តាវ តិវិធា វេទនា សុខំ ទុក្ខំ អទុក្ខមសុខា ចេតិ, សុខំ ទុក្ខំ សោមនស្សំ ទោមនស្សំ ឧបេក្ខាតិ ច ភេទេន បន បញ្ចធា ហោតិ ។

[៤] តត្ថ សុខសហគតំ កុសលវិបាកំ កាយវិញ្ញាណមេកមេវ, តថា ទុក្ខសហគតំ អកុសលវិបាកំ ។

[៥] សោមនស្សសហគតចិត្តានិ បន លោភមូលានិ ចត្តារិ ទ្វាទស កាមាវចរសោភណានិ សុខសន្តីរណហសនានិ ច ទ្វេតិ អដ្ឋារស កាមាវចរ សោមនស្សសហគតចិត្តានិ ចេវ បឋមទុតិយតតិយចតុត្ថជ្ឈានសង្ខាតានិ ចតុចត្តាលីស មហគ្គតលោកុត្តរចិត្តានិ ចេតិ ទ្វាសដ្ឋីវិធានិ ភវន្តិ ។

[៦] ទោមនស្សសហគតចិត្តានិ បន ទ្វេ បដិឃសម្បយុត្តចិត្តានេវ ។

[៧] សេសានិ សព្វានិបិ បញ្ចបញ្ញាស ឧបេក្ខាសហគតចិត្តានេវាតិ ។

[៨] សុខំ ទុក្ខមុបេក្ខាតិ តិវិធា តត្ថ វេទនា
សោមនស្សំ ទោមនស្ស- មិតិ ភេទេន បញ្ចធា ។
[៩] សុខមេកត្ថ ទុក្ខញ្ច ទោមនស្សំ ទ្វយេ ឋិតំ
ទ្វាសដ្ឋីសុ សោមនស្សំ បញ្ចបញ្ញាសកេតរា ។

[១០] ហេតុសង្គហេ ហេតូ នាម លោភោ ទោសោ មោហោ អលោភោ អទោសោ អមោហោ ចេតិ ឆព្វិធា ភវន្តិ ។

[១១] តត្ថ បញ្ចទ្វារាវជ្ជនទ្វិបញ្ចវិញ្ញាណសម្បដិច្ឆនសន្តីរណវោដ្ឋព្វនហសនវសេន អដ្ឋារស អហេតុកចិត្តានិ នាម ។

[១២] សេសានិ សព្វានិបិ ឯកសត្តតិ ចិត្តានិ សហេតុកានេវ ។

[១៣] តត្ថាបិ ទ្វេ មោមូហចិត្តានិ ឯកហេតុកានិ ។

[១៤] សេសានិ ទស អកុសលចិត្តានិ ចេវ ញាណវិប្បយុត្តានិ ទ្វាទស កាមាវចរសោភនានិ ចេតិ ទ្វាវីសតិ ទ្វិហេតុកចិត្តានិ ។

[១៥] ទ្វាទស ញាណសម្បយុត្តកាមាវចរសោភណានិ ចេវ បញ្ចតឹស មហគ្គត-លោកុត្តរចិត្តានិ ចេតិ សត្តចិត្តាលីស តិហេតុកចិត្តានីតិ ។

[១៦] លោភោ ទោសោ ច មោហោ ច ហេតូ អកុសលា តយោ
អលោភាអទោសាអមោហា ច កុសលាព្យាកតា តថា ។

[១៧] អហេតុកាដ្ឋារសេក - ហេតុកា ទ្វេ ទ្វាវីសតិ
ទ្វិហេតុកា មតា សត្ត - ចត្តាលីស តិហេតុកា ។

[១៨] កិច្ចសង្គហេ កិច្ចានិ នាម បដិសន្ធិភវង្គាវជ្ជនទស្សនសវនឃាយន - សាយនផុសនសម្បដិច្ឆនសន្តីរណវោដ្ឋព្វនជវនតទារម្មណចុតិវសេន ចុទ្ទសវិធានិ ភវន្តិ ។

[១៩] បដិសន្ធិភវង្គាវជ្ជនបញ្ចវិញ្ញាណឋានាទិវសេន បន តេសំ ទសធា ឋានភេទោ វេទិតព្វោ

[២០] តត្ថ ទ្វេ ឧបេក្ខាសហគតសន្តីរណានិ ចេវ អដ្ឋ មហាវិបាកានិ ច នវ រូបារូបវិបាកានិ ចេតិ ឯកូនវីសតិ ចិត្តានិ បដិសន្ធិភវង្គចុតិកិច្ចានិ នាម ។

[២១] អាវជ្ជនកិច្ចានិ បន ទ្វេ ។

[២២] តថា ទស្សនសវនឃាយនសាយនផុសនសម្បដិច្ឆនកិច្ចានិ ច ។

[២៣] តីណិ សន្តីរណកិច្ចានិ ។

[២៤] មនោទ្វារាវជ្ជនមេវ បញ្ចទ្វារេ វោដ្ឋព្ពនកិច្ចំ សាធេតិ ។

[២៥] អាវជ្ជនទ្វយវជ្ជិតានិ កុសលាកុសលផលកិរិយចិត្តានិ បញ្ចបញ្ញាស ជវនកិច្ចានិ ។

[២៦] អដ្ឋ មហាវិបាកានិ ចេវ សន្តីរណត្តយញ្ចេតិ ឯកាទស តទារម្មណកិច្ចានិ ។

[២៧] តេសុ បន ទ្វេ ឧបេក្ខាសហគតសន្តីរណចិត្តានិ បដិសន្ធិភវង្គចុតិតទារម្មណសន្តីរណវសេន បញ្ចកិច្ចានិ នាម ។

[២៨] មហាវិបាកានិ អដ្ឋ បដិសន្ធិភវង្គចុតិតទារម្មណវសេន ចតុកិច្ចានិ នាម ។

[២៩] មហគ្គតវិបាកានិ នវ បដិសន្ធិភវង្គចុតិវសេន តិកិច្ចានិ នាម ។

[៣០] សោមនស្សសហគតសន្តីរណំ សន្តីរណតទារម្មណវសេន ទុកិច្ចំ ។

[៣១] តថា វោដ្ឋព្ពនំ វោដ្ឋព្ពនាវជ្ជនវសេន ។

[៣២] សេសានិ បន សព្វានិបិ ជវនមនោធាតុត្តិកទ្វិបញ្ចវិញ្ញាណានិ យថាសម្ភវមេកកិច្ចានីតិ ។

[៣៣] បដិសន្ធាទយោ នាម          កិច្ចភេទេន ចុទ្ទស
ទសធា ឋានភេទេន          ចិត្តុប្បាទា បកាសិតា ។

[៣៤] អដ្ឋសដ្ឋិ តថា ទ្វេ ច          នវាដ្ឋ ទ្វេ យថាក្កមំ
ឯកទ្វិតិចតុបញ្ច-          កិច្ចឋានានិ និទ្ទិសេ ។

[៣៥] ទ្វារសង្គហេ ទ្វារានិ នាម ចក្ខុទ្វារំ សោតទ្វារំ ឃានទ្វារំ ជិវ្ហាទ្វារំ កាយទ្វារំ មនោទ្វារញ្ចេតិ ឆព្វិធានិ ភវន្តិ ។

[៣៦] តត្ថ ចក្ខុមេវ ចក្ខុទ្វារំ ។

[៣៧] តថា សោតាទយោ សោតទ្វារាទីនិ ។

[៣៨] មនោទ្វារំ បន ភវង្គន្តិ បវុច្ចតិ ។

[៣៩] តត្ថ បញ្ចទ្វារាវជ្ជនចក្ខុវិញ្ញាណសម្បដិច្ឆនសន្តីរណវោដ្ឋព្ពនកាមាវចរជវនតទារម្មណវសេន ឆចត្តាលីស ចិត្តានិ ចក្ខុទ្វារេ យថារហំ ឧប្បជ្ជន្តិ ។ តថា

បញ្ចទ្វារាវជ្ជនសោតវិញ្ញាណាទិវសេន សោតទ្វារាទីសុបិ ឆចត្តាលីសេវ ភវន្តីតិ សព្វថាបិ បញ្ចទ្វារេ ចតុបញ្ញាស ចិត្តានិ កាមាវចរានេវ ។

[៤០] មនោទ្វារេ បន មនោទ្វារាវជ្ជនបញ្ចបញ្ញាសជវនតទារម្មណាវសេន សត្តសដ្ឋិ ចិត្តានិ ភវន្តិ ។

[៤១] ឯកូនវីសតិ បដិសន្ធិភវង្គចុតិវសេន ទ្វារវិមុត្តានិ ។

[៤២] តេសុ បន បញ្ចវិញ្ញាណានិ ចេវ មហគ្គតលោកុត្តរជវនានិ ចេតិ ឆត្តឹស យថារហមេកទ្វារិកចិត្តានិ នាម ។

[៤៣] មនោធាតុត្តិកំ បន បញ្ចទ្វារិកំ ។

[៤៤] សុខសន្តីរណវោដ្ឋព្វនកាមាវចរជវនានិ ឆទ្វារិកចិត្តានិ ។

[៤៥] ឧបេក្ខាសហគតសន្តីរណមហាវិបាកានិ ឆទ្វារិកានិ ចេវ ទ្វារវិមុត្តានិ ច ។

[៤៦] មហគ្គតវិបាកានិ ទ្វារវិមុត្តានេវាតិ ។

[៤៧] ឯកទ្វារិកចិត្តានិ បញ្ចឆទ្វារិកានិ ច
ឆទ្វារិកវិមុត្តានិ វិមុត្តានិ ច សព្វថា ។
ឆត្តឹសតិ តថា តីណិ ឯកតឹស យថាក្កមំ
ទសធា នវធា ចេតិ បញ្ចធា បរិទីបយេ ។

[៤៨] អាលម្ពណសង្គហេ អារម្មណានិ នាម រូបារម្មណំ សទ្ទារម្មណំ គន្ធារម្មណំ រសារម្មណំ ផោដ្ឋព្វារម្មណំ ធម្មារម្មណញ្ចេតិ ឆព្ពិធានិ ភវន្តិ ។

[៤៩] តត្ថ រូបមេវ រូបារម្មណំ តថា សទ្ទាទយោ សទ្ទារម្មណាទីនិ ។

[៥០] ធម្មារម្មណំ បន បសាទសុខុមរូបចិត្តចេតសិកនិព្វានបញ្ញត្តិវសេន ឆធា សង្គយ្ហតិ ។

[៥១] តត្ថ ចក្ខុទ្វារិកចិត្តានំ សព្វេសម្បិ រូបមេវ អារម្មណំ តញ្ច បច្ចុប្បន្នំ ។ តថា សោតទ្វារិកចិត្តាទីនម្បិ សទ្ទាទីនិ តានិ ច បច្ចុប្បន្នានិយេវ ។

[៥២] មនោទ្វារិកចិត្តានំ បន ឆព្វិធម្បិ បច្ចុប្បន្នមតីតំ អនាគតំ កាលវិមុត្តញ្ច យថារហមារម្មណំ ហោតិ ។

[៥៣] ទ្វារវិមុត្តានញ្ច បដិសន្ធិភវង្គចុតិសង្ខាតានំ ឆព្វិធម្បិ យថាសម្ភវំ យេភុយ្យេន ភវន្តរេ ឆទ្វារគ្គហិតំ បច្ចុប្បន្នមតីតំ បញ្ញត្តិភូតំ វា កម្មកម្មនិមិត្តគតិនិមិត្តសម្មតំ អារម្មណំ ហោតិ ។

[៥៤] តេសុ ចក្ខុវិញ្ញាណាទីនិ យថាក្កមំ រូបាទិឯកេការម្មណានេវ ។

[៥៥] មនោធាតុត្តិកំ រូបាទិបញ្ចារម្មណំ ។

[៥៦] សេសានិ កាមាវចរវិបាកានិ ហសនចិត្តញ្ចេតិ សព្វថាបិ កាមាវចរារម្មណានេវ ។

[៥៧] អកុសលានិ ចេវ ញាណវិប្បយុត្តកាមាវចរជវនានិ ចេតិ លោកុត្តរវជ្ជិតសព្វារម្មណានិ ។

[៥៨] ញាណសម្បយុត្តកាមាវចរកុសលានិ ចេវ បញ្ចមជ្ឈានសង្ខាតំ អភិញ្ញាកុសលញ្ចេតិ អរហត្តមគ្គផលវជ្ជិតសព្វារម្មណានិ ។

[៥៩] ញាណសម្បយុត្តកាមាវចរកិរិយានិ ចេវ កិរិយាភិញ្ញាវោដ្ឋព្វនញ្ចេតិ សព្វថាបិ សព្វារម្មណានិ ។

[៦០] អារុប្បេសុ ទុតិយចតុត្ថានិ មហគ្គតារម្មណានិ ។

[៦១] សេសានិ បន មហគ្គតចិត្តានិ សព្វានិបិ បញ្ញត្តារម្មណានិ ។

[៦២] លោកុត្តរចិត្តានិ និព្វានារម្មណានីតិ ។

[៦៣] បញ្ចវីស បរិត្តម្ហិ ឆ ចិត្តានិ មហគ្គតេ
ឯកវីសតិ វោហារេ អដ្ឋ និព្វានគោចរេ ។
វីសានុត្តរមុត្តម្ហិ អគ្គមគ្គផលុជ្ឈិតេ
បញ្ច សព្វត្ថ ឆច្ចេតិ សត្តធា តត្ថ សង្គហោ ។

[៦៤] វត្ថុសង្គហេ វត្ថូនិ នាម ចក្ខុសោតឃានជិវ្ហាកាយហទយវត្ថុ ចេតិ ឆព្វិធានិ ភវន្តិ ។

[៦៥] តានិ កាមលោកេ សព្វានិបិ លព្ភន្តិ ។

[៦៦] រូបលោកេ បន ឃានាទិត្តយំ នត្ថិ ។

[៦៧] អរូបលោកេ បន សព្វានិបិ ន សំវិជ្ជន្តិ ។

[៦៨] តត្ថ បញ្ចវិញ្ញាណធាតុយោ យថាក្កមំ ឯកន្តេន បញ្ច បសាទវត្ថូនិ និស្សាយេវ បវត្តន្តិ

[៦៩] បញ្ចទ្វារាវជ្ជនសម្បដិច្ឆនសង្ខាតា បន មនោធាតុ ច ហទយំ និស្សិតាយេវ បវត្តន្តិ ។

[៧០] អវសេសា បន មនោវិញ្ញាណធាតុសង្ខាតា ច សន្តីរណមហាវិបាក-បដិឃទ្វយបឋមមគ្គហសនរូបាវចរវសេន ហទយំ និស្សាយេវ បវត្តន្តិ ។

[៧១] អវសេសា កុសលាកុសលកិរិយានុត្តរវសេន បន និស្សាយ វា អនិស្សាយ វា ។

[៧២] អារុប្បវិបាកវសេន ហទយំ អនិស្សាយេវាតិ ។

[៧៣] ឆវត្ថុំ និស្សិតា កាមេ សត្ត រូបេ ចតុព្វិធា
តិវត្ថុំ និស្សិតារុប្បេ ធាត្វេកា និស្សិតា មតា ។

[៧៤] តេចត្តាលីស និស្សាយ ទ្វេចត្តាលីស ជាយរេ
និស្សាយ ច អនិស្សាយ បាការុប្បា អនិស្សិតា ។

ឥតិ អភិធម្មត្ថសង្គហេ បកិណ្ណកសង្គហវិភាគោ នាម តតិយោ បរិច្ឆេទោ ។

# នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

# បរិច្ឆេទទី ៣

# បកិណ្ណកសង្គហវិភាគ

( ការចែកចិត្ត  និងចេតសិកជាពួកដោយទូទៅ )

## ការសង្គ្រោះ ៦ ប្រភេទ

[១] សម្បយុត្តា យថាយោគំ    តេបញ្ញាស សភាវតោ
ចិត្តចេតសិកា ធម្មា    តេសំ ទានិ យថារហំ ។
[២] វេទនាហេតុតោ កិច្ច-    ទ្វារាលម្ពណវត្ថុតោ
ចិត្តុប្បាទវសេនេវ    សង្គហោ នាម នីយតេ ។

ប្រែថា: “ ធម៌ គឺចិត្តនិងចេតសិក ពោលដោយសភាវៈបាន ៥៣ ដែលប្រកបជាមួយគ្នា តាមសមគួរ ។ ឥឡូវនេះ ខ្ញុំព្រះករុណា នឹងសម្តែងសង្គហៈ ( ការរួបរួម ) ចិត្ត និងចេតសិកទាំងនេះ តាមប្រភេទនៃចិត្តដែលកើតឡើង ដោយវេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍ និងវត្ថុ តាមសមគួរ ” ។

## អធិប្បាយ

ព្រះអនុរុទ្ធាចារ្យ បានសម្តែងនិទ្ទេសនៃចិត្ត និងចេតសិកម្យ៉ាងៗ ដូច្នេះហើយ ឥឡូវនេះ នឹងសម្តែងនិទ្ទេសនៃចិត្ត និងចេតសិកទាំងពីរយ៉ាងនោះទៀត ទើបពោលពាក្យជាដើមថា **សម្បយុត្តា យថាយោគំ** ( ធម៌ គឺចិត្ត និងចេតសិករួមជា ៥៣ដួង ដោយសភាវៈ ប្រកបជាមួយគ្នាតាមសមគួរ ) ។

គប្បីប្រកបបទថា ឥឡូវនេះ ខ្ញុំព្រះករុណា [ ព្រះអនុរុទ្ធាចារ្យ ] នឹងសម្តែងការប្រមូលចិត្ត និងចេតសិក ដែលរួមចូលគ្នាជា ៥៣ ដោយសភាវៈប្រកបចូលគ្នាតាមសមគួរ ដែលខ្ញុំបានសម្តែងជាម្យ៉ាងទុកតាមសមគួរ ។

ក្នុងគាថានោះ **សភាវំ** គឺភាវៈរបស់ខ្លួនៗ ពោលគឺ លក្ខណៈចំពោះរបស់ធម៌ទាំងឡាយ ដែលរួមគ្នាជា ៥៣ ដោយសភាវៈយ៉ាងនេះថាៈ

លំដាប់ដំបូង ចិត្តសូម្បីមាន ៨៩ ដួង ដោយចែកតាមភូមិ ជាតិ និងសម្បយោគន័យជាដើម ក៏ជាសភាវៈតែមួយ ដោយលក្ខណៈចំពោះ គឺការដឹងអារម្មណ៍របស់ខ្លួន សូម្បីផស្សៈមាន ៨៩ ដួង ដោយចែកតាមភូមិ ជាតិ សម្បយោគន័យជាដើម ក៏ជាសភាវៈម្យ៉ាង ដោយលក្ខណៈប៉ះខ្ទប់ [ អារម្មណ៍ ] វេទនា និងសញ្ញាជាដើម ក៏ដូចគ្នា ។

គប្បីសម្ព័ន្ធ [ បទដែលឃ្លាតពីគ្នា ] ថា ការរួបរួមដែលប្រព្រឹត្តទៅ ដោយវេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍ និងវត្ថុ ។

ក្នុងគាថានោះ ពាក្យថា **វេទនាហេតុតោ** ( ដោយវេទនា និងហេតុ ) មានសេចក្ដីថា ដោយប្រភេទរបស់វេទនា និងដោយប្រភេទរបស់ហេតុ ។

ពាក្យថា **កិច្ចទ្វារាលម្ពណវត្ថុតោ** ( ដោយកិច្ច ទ្វារ អារម្មណ៍ និងវត្ថុ ) ក៏ដូចគ្នា ។

ពាក្យថា **ចិត្តុប្បាទវសេនេវ** ( តាមប្រភេទនៃចិត្តដែលកើតឡើងនុ៎ះឯង )

**ឯវ** ( នុ៎ះឯង ) ស័ព្ទ [ ក្នុងពាក្យថា **ចិត្តុប្បាទវសេនេវ = ចិត្តុប្បាទវសេន + ឯវ** ] ធ្វើនាទីបដិសេធចេតសិក ។

ដោយពាក្យដូចនេះ ព្រះអនុរុទ្ធត្ថេរ សម្ដែងរូបវិគ្គហរបស់បកិណ្ណកសង្គហៈ ៦ ប្រភេទ ក្នុងបរិច្ឆេទនេះមុន ដោយន័យថា **វេទនាសង្គហ** គឺការរួបរួមចិត្ត និងចេតសិក ដោយចែកតាមវេទនា, **ហេតុសង្គហ** គឺការរួបរួមចិត្ត និងចេតសិក ដោយចែកតាមហេតុជាដើម ។

[ គម្ពីរបរមត្ថទីបនី សម្ដែងរូបវិគ្គហ តតិយាតប្បុរិសសមាសថា **វេទនាភេទេន សង្គហោ** > **វេទនាសង្គហោ** ប្រែថាៈ ( ការរួបរួមដោយចែកតាមវេទនា ឈ្មោះថា វេទនាសង្គហៈ ) លោកអាងសេចក្ដីក្នុងគាថាផ្ដើមឡើងថា **វេទនា**

**ហេតុតោ កិច្ចទ្វារាលម្ពណវត្ថុតោ សង្គហោ** ( ការរួបរួមដោយ វេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍ និងវត្ថុ ) ] ។

ក្នុងគម្ពីរវិភាវនី កាន់យកចេតសិកធម៌ទៀតផង ដោយអាងពាក្យថា **ចិត្តុប្បាទ** [ ដែលប្រែថាចិត្ត និងចេតសិក តាមមតិនោះ ] ទើបមិនមានធម៌ដទៃដែលគួរបដិសេធ បានពោលថា " **ដោយមិនប្រាសចាកចិត្ត និងចេតសិកទាំងនោះក្នុងទីណាមួយឡើយ** " សេចក្ដីនោះមិនសមគួរ ព្រោះមិនមានសង្គហសូម្បីយ៉ាងណាមួយក្នុងបរិច្ឆេទនេះ សម្ដែងទុកជាមួយនឹងចេតសិកដោយន័យថា " **ចេតសិកប៉ុណ្ណោះប្រកបដោយសុខវេទនា ចេតសិកប៉ុណ្ណោះ ប្រកបដោយទុក្ខវេទនា** " ជាដើម តែមានសង្គហសម្ដែងជាមួយនឹងចិត្តប៉ុណ្ណោះដោយន័យថា " ចិត្តដែលប្រកបជាមួយនឹងសុខវេទនា ជាកាយវិញ្ញាណចិត្ត ដែលជាផល របស់កុសលកម្មមួយដួងប៉ុណ្ណោះ " ជាដើម ម្យ៉ាងទៀត កាលបើចិត្តសម្រេចហើយ សូម្បីចេតសិកក៏សម្រេចបានដូចគ្នា ដូច្នោះ លោកទើបពោលថា **ចិត្តុប្បាទវសេនេវ** ( តាមប្រភេទនៃចិត្ត ដែលកើតឡើងនុ៎ះឯង ) នេះ ។

[ ពាក្យថា **ចិត្តុប្បាទ** ស័ព្ទ កាត់បទជា **ចិត្ត** + **ឧប្បាទ** គម្ពីរបរមត្ថទីបនីយល់ថា **ឧប្បាទ** ស័ព្ទ ជាបទពង្រីកសេចក្ដីរបស់ **ចិត្ត** ស័ព្ទ ទើបប្រែថា " ចិត្តដែលកើតឡើង " **ឯវ** ( នុ៎ះឯង ) ស័ព្ទ ក្នុងពាក្យថា **ចិត្តុប្បាទវសេនេវ** ធ្វើនាទីបដិសេធចេតសិក មានសេចក្ដីថា លោកនឹងសម្ដែងការរួបរួមចិត្ត និងចេតសិកទាំងនោះ តាមប្រភេទនៃចិត្តដែលកើតឡើងដោយវេទនាជាដើម តាមសមគួរ កាលយល់ការប្រកបរបស់ចិត្តក្នុងវេទនាហើយ ក៏ជាការយល់ការប្រកបរបស់ចេតសិកក្នុងវេទនាបាន ដូចនេះជាដើម ចំណែកគម្ពីរវិភាវនីយល់ថា ពាក្យថា **ឧប្បាទ** បានដល់ ចេតសិក ដូច្នេះ **ចិត្តុប្បាទ** ទើបសំដៅដល់ចិត្ត និងចេតសិក តាមមតិនេះ **ឯវ** ស័ព្ទ ធ្វើនាទីបដិសេធកិរិយា គឺការមិនប្រាសចាកចិត្ត និងចេតសិក ] ។

# វេទនាសង្គហ

## ( ការរួបរួមចិត្ត និងចេតសិក ដោយវេទនា )

**[៣] តត្ថ វេទនាសង្គហេ តាវ តិវិធា វេទនា សុខំ ទុក្ខំ អទុក្ខមសុខា ចេតិ, សុខំ ទុក្ខំ សោមនស្សំ ទោមនស្សំ ឧបេក្ខាតិ ច ភេទេន បន បញ្ចធា ហោតិ។**

ប្រែថាៈ បណ្តាសង្គហទាំងនោះ លំដាប់ដំបូង ក្នុងវេទនាសង្គហនេះ វេទនាមាន ៣ យ៉ាងគឺៈ សុខវេទនា ទុក្ខវេទនា និងអទុក្ខមសុខវេទនា ចែកជា ៥ យ៉ាងគឺៈ សុខវេទនា ទុក្ខវេទនា សោមនស្សវេទនា ទោមនស្សវេទនា និងឧបេក្ខាវេទនា ។

[ វេទនាមាន ៣ យ៉ាង ដោយប្រភេទនៃការសោយអារម្មណ៍គឺៈ

- **សុខវេទនា** = សុខតាមផ្លូវកាយ និងចិត្ត
- **ទុក្ខវេទនា** = ទុក្ខតាមផ្លូវកាយ និងចិត្ត
- **អទុក្ខមសុខវេទនា** =ការសោយអារម្មណ៍ជាកណ្តាល ។

ន័យម្យ៉ាងទៀត វេទនាមាន ៥ យ៉ាង ដោយប្រភេទនៃឥន្ទ្រិយគឺៈ

- **សុខវេទនា** = សុខតាមផ្លូវកាយ
- **ទុក្ខវេទនា** = ទុក្ខតាមផ្លូវកាយ
- **សោមនស្សវេទនា** = សុខតាមផ្លូវចិត្ត
- **ទោមនស្សវេទនា** = ទុក្ខតាមផ្លូវចិត្ត
- **ឧបេក្ខាវេទនា** = ការដឹងអារម្មណ៍ជាកណ្តាល ។

ការចែកវេទនាជា ៥ យ៉ាងនេះ លោកចែកតាមប្រភេទនៃឥន្ទ្រិយក៏មាន ៥ យ៉ាងផងគឺ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ] ។

**[៤] តត្ថ សុខសហគតំ កុសលវិបាកំ កាយវិញ្ញាណមេកមេវ តថា ទុក្ខសហគតំ អកុសលវិបាកំ ។**

ប្រែថា: បណ្តាវេទនាទាំងនោះ ចិត្តដែលប្រកបដោយសុខវេទនា ជាកាយវិញ្ញាណចិត្ត ដែលជាផលរបស់កុសលកម្មមួយដួងប៉ុណ្ណោះ ដូចគ្នានេះ ចិត្តដែលប្រកបជាមួយទុក្ខវេទនា ជាកាយវិញ្ញាណចិត្ត ដែលជាផលរបស់អកុសលកម្ម ។

**[៥] សោមនស្សសហគតចិត្តានិ បន លោភមូលានិ ចត្តារិ , ទ្វាទស កាមាវចរសោភណានិ សុខសន្តីរណហសនានិ ច ទ្វេតិ អដ្ឋារស កាមាវចរសោមនស្សសហគតចិត្តានិ ចេវ បឋមទុតិយតតិយចតុត្ថជ្ឈានសង្ខាតានិ ចតុចត្តាលីស មហគ្គតលោកុត្តរចិត្តានិ ចេតិ ទ្វាសដ្ឋីវិធានិ ភវន្តិ ។**

ប្រែថា: ចំណែកចិត្តដែលប្រកបដោយសោមនស្សវេទនាមាន ៦២ ដួងគឺ៖ កាមាវចរសោមនស្សចិត្ត ១៨ ដួង បានដល់ ចិត្តដែលប្រកបដោយសោមនស្សលោភមូល ៤ ដួង សោមនស្សកាមាវចរសោភណចិត្ត ១២ ដួង សោមនស្សសន្តីរណចិត្ត និងសោមនស្សហសិតុប្បាទចិត្ត ២ ដួង និងមហគ្គតលោកុតរចិត្ត ៤៤ ដួង ពោលគឺ បឋមជ្ឈានចិត្ត ១១ ទុតិយជ្ឈានចិត្ត ១១ តតិយជ្ឈានចិត្ត ១១ នឹងចតុត្ថជ្ឈានចិត្ត ១១ ។

**[៦] ទោមនស្សសហគតចិត្តានិ បន ទ្វេ បដិឃសម្បយុត្តចិត្តានេវ ។**

ប្រែថា: ចំណែកចិត្តដែលប្រកបដោយទោមនស្សវេទនា គឺចិត្តប្រកបដោយបដិឃៈ ២ ដួងប៉ុណ្ណោះ ។

**[៧] សេសានិ សព្វានិបិ បញ្ចបញ្ញាស ឧបេក្ខាសហគតចិត្តានេវាតិ ។**

ប្រែថា: ចិត្តដែលនៅសល់ទាំងអស់ ៥៥ ដួង ជាចិត្តប្រកបដោយឧបេក្ខាវេទនា។

[ ចិត្ត ៥៥ ដួងគឺ៖ អកុសលចិត្ត ៦ ដួង អហេតុកចិត្ត ១៤ ដួង កាមាវចរសោភណចិត្ត ១២ ដួង បញ្ចមជ្ឈានចិត្ត ២៣ ដួង ] ។

## គាថាសង្ខេប

**[៨] សុខំ ទុក្ខមុបេក្ខាតិ តិវិធា តត្ថ វេទនា**

**សោមនស្សំ ទោមនស្ស- មិតិ ភេទេន បញ្ចធា ។**

ប្រែថា: ក្នុងវេទនាសង្គហនោះ វេទនាមាន ៣ យ៉ាងគឺ សុខវេទនា ទុក្ខវេទនា និងឧបេក្ខាវេទនា មានវេទនា ៥ យ៉ាង ដោយចែកជាសុខវេទនា ទុក្ខវេទនា សោមនស្សវេទនា ទោមនស្សវេទនា និងឧបេក្ខាវេទនា ។

**[៩] សុខមេកត្ថ ទុក្ខញ្ច ទោមនស្សំ ទ្វយេ ឋិតំ**

**ទ្វាសដ្ឋីសុ សោមនស្សំ បញ្ចបញ្ញាសកេតរា ។**

ប្រែថា: សុខវេទនា និងទុក្ខវេទនា តាំងនៅក្នុងចិត្តមួយដួង, ទោមនស្ស-វេទនា តាំងនៅក្នុងចិត្តពីរដួង , សោមនស្សវេទនា តាំងនៅក្នុងចិត្ត ៦២ ដួង , ឧបេក្ខាវេទនាក្រៅនេះ តាំងនៅក្នុងចិត្ត ៥៥ ដួង ។

## អធិប្បាយវេទនាសង្គហ

៣- ពាក្យថា **តត្ថ** គឺសង្គហ ៦ ប្រភេទនោះ

**វេទនាសង្គហ** គឺការរួបរួមចិត្ត និងចេតសិក ដែលប្រកបដោយវេទនាទាំងនោះ ដោយចែកតាមវេទនា ។

-សួរថា: ក្នុងសំយុត្តនិកាយ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់វេទនាពីរយ៉ាងខ្លះ បីយ៉ាងខ្លះ ប្រាំយ៉ាងខ្លះ ប្រាំមួយយ៉ាងខ្លះ ដប់ប្រាំបីយ៉ាងខ្លះ សាម-សិបប្រាំមួយយ៉ាងខ្លះ មួយរយប្រាំបីយ៉ាងខ្លះ ហេតុដូចម្តេច បានជាព្រះអនុរុទ្ធាចារ្យ ពោលថា **តិវិធា វេទនា** ( វេទនាមាន ៣ យ៉ាង ) ?

-ឆ្លើយថា: ត្រូវហើយ តែវេទនាមានបីយ៉ាង ដោយលក្ខណៈរបស់ការសោយ [ អារម្មណ៍ ] សេចក្តីថា បុគ្គលដែលសោយអារម្មណ៍ណាមួយ

តែងតែ សោយអារម្មណ៍ដោយសភាពពេញចិត្ត មិនពេញចិត្ត ឬព្រងើយ មិនមានប្រការដទៃក្រៅពីនេះ ។

ចំណែកប្រភេទដទៃ ទ្រង់ត្រាស់ទុកដោយបរិយាយនោះៗ សេចក្តីពិស្តារមានដូចតទៅនេះ បណ្តាវេទនាពួកនោះ វេទនាពីរយ៉ាង ត្រាស់ទុកដោយចែកជាវេទនាតាមផ្លូវកាយ និងតាមផ្លូវចិត្ត ដូចព្រះពុទ្ធវចនថា:

**កតមា ច ភិក្ខវេ ទ្វេ វេទនា កាយិកា ច ចេតសិកា ច ។**

ប្រែថា: ម្នាលភិក្ខុទាំងឡាយ វេទនាពីរយ៉ាងតើដូចម្តេច ? គឺវេទនាតាមផ្លូវកាយ និងវេទនាតាមផ្លូវចិត្ត ។

ន័យម្យ៉ាងទៀត វេទនាពីរយ៉ាង ទ្រង់ត្រាស់ទុកដោយរួមឧបេក្ខាចូលក្នុងសុខ ដូចព្រះតម្រាស់ថា:

**ទ្វេ វេទនា វុត្តា ភគវតា សុខា វេទនា, ទុក្ខា វេទនា យាយំ ភន្តេ អទុក្ខមសុខា វេទនា, សន្តស្មឹ ឯសា បណីតេ សុខេ វុត្តា ភគវតា ។**

ប្រែថា: ព្រះដ៏មានព្រះភាគទ្រង់ត្រាស់វេទនាពីរយ៉ាង គឺសុខវេទនា និងទុក្ខវេទនា អ្នកដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ឧបេក្ខាវេទនាទុកក្នុងសុខ ដ៏ស្ងប់ប្រណីត ។

ចំណែកក្នុងគម្ពីរវិភាវនីពោលថា “ ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់វេទនាពីរយ៉ាងទុក ដោយរួមឧបេក្ខាវេទនា ដែលប្រព្រឹត្តទៅក្នុងផ្នែកមិនមានទោសទុកក្នុងសុខ និងរួមឧបេក្ខាវេទនា ដែលប្រព្រឹត្តទៅក្នុងផ្នែកមានទោសទុកក្នុងទុក្ខ ” សេចក្តីនោះ សូម្បីមិនប្រាកដក្នុងព្រះបាលីក៏សមគួរ ។

វេទនាមានប្រាំយ៉ាង ដោយចែកតាមឥន្ទ្រិយ ( ភាពជាធំដែលប្រាកដច្បាស់ ) [ ជាសុខវេទនា ទុក្ខវេទនា សោមនស្សវេទនា ទោមនស្សវេទនា និងឧបេក្ខាវេទនា ] ។

វេទនាមានប្រាំមួយយ៉ាង ដោយចែកតាមផស្សៈ [ **ចក្ខុសម្ផស្សជាវេទនា** គឺវេទនាដែលកើតពីការប៉ះខ្ទប់តាមចក្ខុបសាទ **សោតសម្ផស្សជាវេទនា** គឺវេទនាដែលកើតពីការប៉ះខ្ទប់តាមសោតបសាទ **ឃានសម្ផស្សជាវេទនា** គឺវេទនា

ដែលកើតពីការប៉ះខ្ទប់តាមឃានបសាទ **ជិវ្ហាសម្ផស្សជាវេទនា** គឺវេទនាដែលកើតពីការប៉ះខ្ទប់តាមជិវ្ហាបសាទ **កាយសម្ផស្សជាវេទនា** គឺវេទនាដែលកើតពីការប៉ះខ្ទប់តាមផ្លូវកាយ **និងមនោសម្ផស្សជាវេទនា** គឺវេទនាដែលកើតពីការប៉ះខ្ទប់តាមផ្លូវចិត្ត ] ។

វេទនាមាន ១៨ យ៉ាង តាមប្រភេទនៃ **ឧបវិចារ** [ ការពិចារណាអារម្មណ៍គឺ សុខវេទនា ទុក្ខវេទនា និងឧបេក្ខាវេទនា ក្នុងមួយយ៉ាងៗ កើតតាមទ្វារទាំង ៦ ] ។

វេទនាមាន ៣៦ យ៉ាង តាមប្រភេទនៃសោមនស្សវេទនា ទោមនស្សវេទនា និងឧបេក្ខាវេទនា ម្យ៉ាងៗ មាន ១២ ប្រភេទដូច្នេះគឺៈ វេទនាដែលអាស្រ័យផ្ទះ [ គឺកិលេស ] ៦ វេទនាដែលអាស្រ័យកុសល ៦ ។

វេទនាទាំងនោះមាន ១០៨ ដោយប្រភេទនៃកាល ៣ ។

វេទនាដែលព្រះអង្គទ្រង់ត្រាស់ទុកក្នុងព្រះសូត្រខ្លះថាៈ **យំ កិញ្ចិ វេទយិតំ សព្វំ តំ ទុក្ខស្មឹ** ប្រែថាៈ " វេទនាឯណានីមួយ ដែលបុគ្គលសោយហើយ វេទនាទាំងអស់នោះ រមែងរាប់ចូលក្នុងទុក្ខ " ទ្រង់ត្រាស់ទុកដោយភាពជាសង្ខារទុក្ខ ។

ព្រះអនុរុទ្ធាចារ្យសម្តែងចិត្ត ដោយប្រភេទរបស់ឥន្ទ្រិយក្នុងចិត្តនិទ្ទេសជាមុនសិន ដូច្នោះទើបពោលថា **សុខំ ។ បេ ។ បញ្ចធា ហោតិ** ( ចែកចេញជា ៥ យ៉ាង គឺសុខវេទនា ទុក្ខវេទនា សោមនស្សវេទនា ទោមនស្សវេទនា និងឧបេក្ខាវេទនា ) ទៀត ដើម្បីរួបរួមចិត្តតាមប្រភេទរបស់ឥន្ទ្រិយក្នុងវេទនាសង្គហនេះ ។

សុខវេទនា និងទុក្ខវេទនា ឈ្មោះថា **ឥន្ទ្រិយ** ព្រោះភាវៈជាធំក្នុងសម្បយុត្តធម៌ទាំងឡាយ សុខវេទនា និងទុក្ខវេទនានោះ ទ្រង់ត្រាស់ទុកជាពីរយ៉ាងថា សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ និងទោមនស្សិន្ទ្រិយ ព្រោះសម្បយុត្តធម៌ទាំងនោះ មានពីរយ៉ាង ដោយចែកតាមវេទនាផ្លូវកាយ

និងចិត្ត ចំណែកសម្បយុត្តធម៌ ដែលមានឧបេក្ខាវេទនាជាធំ រមែងកើតឡើងតាមផ្លូវចិត្ត ដូច្នេះ ឧបេក្ខាវេទនានោះ ទើបពោលថាមានតែម្យ៉ាង គឺ ឧបេក្ខិន្ទ្រិយ ។

សម្បយុត្តធម៌មានពីរយ៉ាង ដោយបរិយាយ [ គឺសម្បយុត្តធម៌ ដែលកើតតាមផ្លូវកាយ និងផ្លូវចិត្ត ] ព្រោះប្រាកដសម្បយុត្តធម៌ដែលអាស្រ័យបសាទរូប មានចក្ខុបសាទជាដើម តែព្រះអង្គទ្រង់សម្តែងវេទនាទុកមួយយ៉ាង ព្រោះមាននាទីតែមួយ [ គឺការសោយអារម្មណ៍ ] ។

ចំណែកក្នុងគម្ពីរវិភាវនីពោលថា “ ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សុខវេទនា និងទុក្ខវេទនាពីរយ៉ាង តាមប្រភេទនៃការពេញចិត្ត និងការមិនពេញចិត្ត ដែលកើតតាមផ្លូវកាយ និងផ្លូវចិត្ត ” ។

បណ្តាវេទនាទាំងនោះ **សុខវេទនា** មានលក្ខណៈសោយឥដ្ឋារម្មណ៍ជាទីប្រាថ្នា ដោយសភាវៈ ។

**ទុក្ខវេទនា** មានលក្ខណៈសោយឥដ្ឋារម្មណ៍ មិនជាទីប្រាថ្នាដោយសភាវៈ ។

**វេទនាដទៃ** [ គឺសោមនស្សវេទនា ទោមនស្សវេទនា ឧបេក្ខាវេទនា ] មានលក្ខណៈសោយអារម្មណ៍ដែលគួរប្រាថ្នា មិនគួរប្រាថ្នា ឬព្រងើយ ដោយសភាវៈ ឬដោយការត្រិះរិះ ។

**៧**- ពាក្យថា **សេសានិ** ( ចិត្តដែលនៅសល់ ) គឺចិត្ត ៥៥ ដួងទាំងអស់ពោលគឺ កាមាវចរចិត្ត ៣២ ដួង ដែលសល់អំពីចិត្តដែលប្រកបជាមួយសុខ-វេទនា ទុក្ខវេទនា សោមនស្សវេទនា ទោមនស្សវេទនា និងបញ្ចមជ្ឈានិក-ចិត្ត ២៣ ដួង ។

## អធិប្បាយគាថាសរុប

**៨**- ពាក្យថា **ឯកត្ថ** ប្រែថា: ក្នុងចិត្តមួយដួង

**៩**- ពាក្យថា **ឥតរា** ប្រែថា ( វេទនាក្រៅពីនេះ ) គឺឧបេក្ខាវេទនា។

## ចែកចិត្ត ១២១ ដោយវេទនា ៥




## បញ្ជាក់

ចិត្តដួងណាអាចកើតជាមួយវេទនាអ្វី ក៏មានអក្សរសង្ខេបរបស់វេទនានោះៗក្នុងរង្វង់ចិត្តដួងនោះ។

## ចែកចេតសិក ៥២ ដោយវេទនា ៥




## សង្កេត

សោ. = សោមនស្សវេទនា
ទោ. = ទោមនស្សវេទនា
ឧ. = ឧបេក្ខាវេទនា
សុ. = សុខវេទនា
ទុ. = ទុក្ខវេទនា
៥ = វេទនា ៥ យ៉ាង

# ហេតុសង្គហ

## ( ការរួបរួមចិត្ត និងចេតសិកដោយហេតុ )

**[១០] ហេតុសង្គហេ ហេតូ នាម លោភោ ទោសោ មោហោ អលោភោ អទោសោ អមោហោ ចេតិ ឆព្វិធា ភវន្តិ ។**

ប្រែថាៈ ក្នុងហេតុសង្គហនេះ ដែលឈ្មោះថាហេតុទាំងឡាយមាន ៦ យ៉ាងគឺៈ លោភហេតុ ទោសហេតុ មោហហេតុ អលោភហេតុ អទោសហេតុ និង អមោហហេតុ។

**[១១] តត្ថ បញ្ចទ្វារាវជ្ជនទ្វិបញ្ចវិញ្ញាណសម្បដិច្ឆនសន្តីរណវោដ្ឋព្វនហសនវសេន អដ្ឋារស អហេតុកចិត្តានិ នាម ។**

ប្រែថាៈ បណ្តាហេតុទាំងនោះ អហេតុកចិត្តទាំងឡាយមាន ១៨ ដួង តាមប្រភេទនៃបញ្ចទ្វារាវជ្ជនចិត្ត ( ១ ដួង ) ទ្វិបញ្ចវិញ្ញាណចិត្ត ( ១០ ដួង ) សម្បដិច្ឆនចិត្ត ( ២ ដួង ) សន្តីរណចិត្ត ( ៣ ដួង ) វោដ្ឋព្វនចិត្ត ( ១ ដួង ) និងហសិតុប្បាទចិត្ត ( ១ ដួង ) ឈ្មោះថា អហេតុកចិត្ត ( ចិត្តមិនមានហេតុ ៦ នោះណាមួយប្រកប ) ។

**[១២] សេសានិ សព្វានិបិ ឯកសត្តតិ ចិត្តានិ សហេតុកានេវ ។**

ប្រែថាៈ ចិត្តដែលនៅសល់ទាំងអស់ ៧១ ដួង ឈ្មោះថា សហេតុកចិត្ត ( ចិត្តមានហេតុប្រកប ) ។

**[១៣] តត្ថាបិ ទ្វេ មោមូហចិត្តានិ ឯកហេតុកានិ ។**

ប្រែថាៈ សូម្បីក្នុងសហេតុកចិត្តទាំងនោះ មោហមូលចិត្ត ២ ដួង ជាចិត្តមានហេតុ ១ ( គឺមោហហេតុ ) ។

**[១៤] សេសានិ ទស អកុសលចិត្តានិ ចេវ ញាណវិប្បយុត្តានិ ទ្វាទស កាមាវចរសោភនានិ ចេតិ ទ្វាវីសតិ ទ្វិហេតុកចិត្តានិ ។**

ប្រែថា: ចិត្ត ២២ ដួងគឺៈ អកុសលចិត្ត ១០ ដួង ដែលនៅសល់ [ វៀរមោហមូលចិត្ត ២ ដួង ] និងកាមាវចរសោភណចិត្ត ១២ ដួង ដែលមិនប្រកបដោយញាណ ជាចិត្តមានហេតុ ២ ។

[ ក្នុងបណ្ដាអកុសលចិត្ត ១០ ដួងនោះ លោភមូលចិត្ត ៨ ប្រកបដោយហេតុ ២ គឺលោភហេតុ និងមោហហេតុ ។ ទោសមូលចិត្ត ២ ប្រកបដោយហេតុ ២ គឺទោសហេតុ និងមោហហេតុ ។ ចំណែកកាមាវចរសោភណញាណវិប្បយុត្តចិត្ត ១២ ដួងនោះ ប្រកបដោយហេតុ ២ គឺអលោភហេតុ និងអទោសហេតុ ] ។

**[១៥] ទ្វាទស ញាណសម្បយុត្តកាមាវចរសោភណានិ ចេវ បញ្ចត្តឹស មហគ្គតលោកុត្តរចិត្តានិ ចេតិ សត្តចត្តាលីស តិហេតុកចិត្តានីតិ ។**

ប្រែថា: ចិត្ត ៤៧ ដួងគឺៈ កាមាវចរសោភណចិត្ត ដែលប្រកបដោយញាណ ១២ដួង មហគ្គតចិត្ត [ ២៧ ដួង ] និងលោកុត្តរចិត្ត [ ៨ដួង ] រួមត្រូវជា ៤៧ ដួង ជាចិត្តមានហេតុ ៣ [ គឺៈ អលោភហេតុ អទោសហេតុ និងអមោហហេតុ ] ។

## គាថាសរុប

**[១៦] លោភោ ទោសោ ច មោហោ ច ហេតូ អកុសលា តយោ**
**អលោភាទោសាមោហា ច កុសលាព្យាកតា តថា ។**

ប្រែថា: ហេតុជាអកុសលមាន ៣ យ៉ាង គឺលោភហេតុ ទោសហេតុ មោហហេតុ ដូចគ្នានេះ ហេតុជាកុសល និងអព្យាកតមាន ៣ យ៉ាងគឺៈ អលោភហេតុ អទោសហេតុ និងអមោហហេតុ ។

**[១៧] អហេតុកាដ្ឋារសេក - ហេតុកា ទ្វេ ទ្វាវីសតិ**
**ទ្វិហេតុកា មតា សត្ត - ចត្តាលីស តិហេតុកា ។**

ប្រែថា: អហេតុកចិត្តមាន ១៨ ដួង ចិត្តមានហេតុមួយមាន ២ ដួង ចិត្តមានហេតុពីរមាន ២២ ដួង ចិត្តមានហេតុបីមាន ៤៧ ដួង ។

# អធិប្បាយហេតុសង្គហ

**១០- ហេតុសង្គហ** គឺការរួបរួមចិត្ត និងចេតសិក ដែលប្រកបជាមួយហេតុនោះ ដោយចែកតាមហេតុ ។

ការញុំាំងសម្បយុត្តធម៌ឲ្យតាំងមាំក្នុងអារម្មណ៍ ជានាទីរបស់ហេតុ ក្នុងរឿងនេះ សេចក្តីថា ឫសឈើចម្រើនលូតលាស់ក្នុងផែនដី បឺតយកឱជាធាតុរបស់ផែនដី និងទឹក ហើយផ្តល់ទៅដល់ដើម រហូតដល់ត្រួយ ពេលខ្យល់ព្យុះ ឬទឹកធំលិច ឫសឈើក៏នៅទាញទប់ដើមទុកយ៉ាងមាំ ដើមឈើរមែងលូតលាស់បរិបូណ៌តាំងនៅបានយូរ យ៉ាងណាមិញ ធម៌ទាំងនេះក៏ដល់នូវភាពតាំងមាំក្នុងអារម្មណ៍ រមែងញុំាំងសម្បយុត្តធម៌ ឲ្យចម្រើនលូតលាស់តាំងនៅយូរបាន ក៏យ៉ាងនោះដែរ ចំណែកអហេតុកចិត្ត រមែងមិនតាំងមាំល្អក្នុងអារម្មណ៍ ដូចសារាយដែលមិនមានឫស អណ្តែតលើទឹក។

ចំណែកអាចារ្យដទៃ ( ព្រះរេវតត្ថេរ ) ពោលថា **ធម្មានំ កុសលាទិភាវសាធនំ ហេតុកិច្ចំ** ប្រែថាៈ កិរិយាញុំាំងសម្បយុត្តធម៌ឲ្យសម្រេចជាកុសលជាដើម (ដោយភាពជាកុសល ។ ល ។) ជានាទីរបស់ហេតុ ។

[ អាចារ្យពួកខ្លះ ] ពោលជំទាស់ថា " ប្រសិនបើដូចនេះ ភាពជាអកុសល និងអព្យាកត របស់ធម៌ដែលមិនមានហេតុកើតព្រមគ្នា ក៏មិនគប្បីមាន [ គឺមោហៈមិនគួរជាអកុសល និងអហេតុកចិត្ត រូប និព្វាន ក៏មិនគួរជាអព្យាកត ព្រោះមិនមានហេតុដទៃកើតរួមជាមួយ ] ទាំងរូបដែលបានទទួលហេតុបច្ច័យ ហើយជាកុសលជាដើម ក៏គប្បីមានបាន " ទើបបដិសេធមតិនោះ ។

ភាពងងឹតក្នុងលោក មិនមែនកើតពីបច្ច័យពិសេសឯណានីមួយឡើយ ទីណាដែលប្រាសចាកពន្លឺ ភាពងងឹតនោះក៏កើតឡើងជាធម្មតារបស់ខ្លួនក្នុងទី

នោះ យ៉ាងណាមិញ ភាពងងឹតគឺមោហៈ ដែលជាសភាវៈវង្វេងក្នុង ( សច្ច ) ធម៌ ក៏គួរជាអកុសលតាមប្រក្រតីរបស់ខ្លួន ក៏យ៉ាងនោះដែរ បានសេចក្តីថា សភាវៈដែលឈ្មោះថាការប្រាថ្នា កាលបើប្រកបដោយសភាវៈវង្វេងហើយ ចូលដល់ការជាប់ជំពាក់ រមែងឈ្មោះថាអកុសល គឺភាវៈលោភ តែបើប្រកបដោយសទ្ធា រមែងចូលដល់ភាពជាឆន្ទក្នុងធម៌ បានឈ្មោះថា ឆន្ទដែលជាកុសល សូម្បីការមិនពេញចិត្តក៏ដូចគ្នា កាលបើប្រកបដោយសភាវវង្វេង ហើយចូលដល់ការខ្ទាំងខ្ទប់អារម្មណ៍ រមែងឈ្មោះថាអកុសល គឺទោសៈ តែបើប្រកបដោយសទ្ធា រមែងចូលដល់ភាពប្រឆាំងនឹងអកុសលធម៌ ( មានមេថុនសំយោគ ៧ ជាដើម ) និងអារម្មណ៍ ដែលជាអកុសល ( គឺកាមគុណ ៥ ) ដោយន័យថា:

**ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ។**

ប្រែថា: “ មិនបណ្តោយឲ្យកាមវិតក្កកើត ” ជាដើម ។

ចំណែកសភាវៈវង្វេងរមែងមិនមាន ដែលថាអាចប្រកបដោយធម៌ឯណោះឈ្មោះថាអកុសល តែកាលប្រកបដោយធម៌ឯណោះឈ្មោះថាកុសល សភាវៈវង្វេងជាអកុសលតាមប្រក្រតី ដូចជារសជូរប្រក្រតីដោយប្រាសចាកវត្ថុដទៃ ដែលផ្សំឡើងដើម្បីធ្វើឲ្យជូរ ។

ធម៌ណាមិនមែនជាកុសល និងអកុសល ធម៌នោះជាអព្យាកត សេចក្តីនេះទើបជាហេតុនៃការធ្វើឲ្យកើតភាពជាអព្យាកតរបស់ធម៌បាន ដូច្នោះការដែលអហេតុកចិត្ត រូប និងនិព្វាន ជាអព្យាកត ទើបកើតឡើងតាមប្រក្រតីរបស់ខ្លួន ។

ក្នុងសេចក្តីនោះ មោហៈ ជាមូល ( ហេតុ ) នៃធម៌ដែលជាហេតុសូម្បីដទៃទៀតផង ព្រោះសេចក្តីត្រេកអរនិងការប្រទូសរ៉ាយ ជាផលរបស់ការវង្វេង

និងការដែលអលោភហេតុជាដើម ជាកុសល រមែងកើតឡើងព្រមដោយអវិជ្ជានុស័យ។

[ សេចក្តីថា បើមានអវិជ្ជានុស័យ គឺមោហៈ អលោភហេតុជាដើម ក៏ជាកុសល តែបើមិនមានអវិជ្ជានុស័យ ហេតុដូចដែលបានពោលក៏ជាអព្យាកត ] ។

លោភហេតុជាដើម ជាមូលពិសេសរបស់ចិត្តដែលប្រកបដោយសេចក្តីលោភជាដើម ព្រោះទិដ្ឋិ និងមានះ ជាអាទិ ជាផលរបស់សេចក្តីត្រេកអរ ទាំងសទ្ធាជាដើម ក៏ជាផលនៃការមិនត្រេកអរ ។

ធម្មតាហេតុទាំងឡាយ ជាប្រធានក្នុងសម្បយុត្តធម៌ ដូច្នោះ ការដែលវិបាកចិត្ត និងកិរិយាចិត្ត ដែលប្រកបដោយហេតុជាអព្យាកត គប្បីពោលដោយភាពមានហេតុជាប្រធានទៀតផង ។

[ បានសេចក្តីថាៈ អហេតុកចិត្ត រូប និង និព្វាន ជាអព្យាកតតាមប្រក្រតី រីឯវិបាកចិត្ត និងកិរិយាចិត្ត ដែលប្រកបដោយហេតុ ក៏ចាត់ជាអព្យាកតតាមប្រក្រតី ឬជាអព្យាកត ព្រោះប្រកបដោយអលោភហេតុជាដើម ] ។

បណ្តារូបធម៌ និងនាមធម៌ ដែលបានទទួលពីឈានបច្ច័យ ( **បច្ច័យដែលជាឈាន** ) អង្គឈានទាំងឡាយ រមែងផ្សាយទៅកាន់ភាវៈដែលចូលទៅសម្លឹងក្នុងនាមធម៌ប៉ុណ្ណោះ មិនផ្សាយទៅក្នុងរូបធម៌ តែរូបធម៌ព្រះអង្គទ្រង់ត្រាស់ទុកក្នុងបច្ចយុប្បន្ន ( **ផល** ) របស់ឈាន ព្រោះកើតឡើងពីឈាន យ៉ាងណាមិញ ហេតុទាំងឡាយក៏ផ្សាយទៅកាន់ភាពជាកុសលជាដើមក្នុងនាមធម៌ប៉ុណ្ណោះ មិនផ្សាយទៅកាន់រូបធម៌ តែរូបធម៌ទ្រង់ត្រាស់ទុកក្នុងបច្ចយុប្បន្នរបស់ហេតុ ព្រោះកើតឡើងពីហេតុ ក៏យ៉ាងនោះដែរ ដូច្នោះ ទើបមិនគប្បីជំទាស់ ក្នុងការដែលរូបធម៌ដល់នូវភាពជាកុសលជាដើម ។

សូម្បីសេចក្តីក្នុងគម្ពីរវិភាវនីថា “ ភាពជាកុសលជាដើម របស់កុសល និងអកុសលធម៌ ទាក់ទងយោនិសោមនសិការៈ និងអយោនិសោមនសិការៈ ” សេចក្តីនោះគប្បីពិចារណា សេចក្តីថា ពេលដែលពន្លឺព្រះអាទិត្យ

ប្រាកដឡើងហើយ ហង្សជាដើមដែលមានកម្លាំងក្នុងពេលថ្ងៃ រមែងបានឱកាស កាលបើភាពងងឹតក្នុងពេលរាត្រីមកដល់ សត្វមៀមជាដើម ដែលមានកម្លាំងក្នុងយាមរាត្រី រមែងបានឱកាស ទាំងពន្លឺ ទាំងភាពងងឹត ក៏មិនបានធ្វើឲ្យកើតភាពពិសេស មានពណ៌ជាដើមរបស់សត្វទាំងនោះ តែកំណើតរបស់សត្វទាំងនោះ ធ្វើឲ្យកើតភាពពិសេសនោះ គប្បីជ្រាបថា យោនិសោ-មនសិការៈដូចពន្លឺ អយោនិសោមនសិការៈដូចភាពងងឹត កុសល និងអកុសលដូចសត្វទាំងនោះ ភាពជាកុសលជាដើមដូចភាពពិសេសមានពណ៌ជាដើម ហេតុទាំងឡាយដូចជាកំណើត ។

១១- ពាក្យថា **តត្ថ** គឺក្នុងហេតុសង្គហ

១២- ព្រះអនុរុទ្ធាចារ្យលើកឡើងសម្តែងអហេតុកចិត្ត ដែលគួរវៀរក្នុងទីនេះជាមុនសិន ដើម្បីងាយស្រួលក្នុងការកំណត់សហេតុកចិត្ត ដូច្នោះទើបពោលថា **សេសានិ បន ។ បេ ។ សហេតុកានេវ** ( ចិត្តដែលនៅសល់ទាំងអស់ ៧១ ដួង ជាសហេតុកចិត្ត ) ។

ន័យម្យ៉ាងទៀត ឈ្មោះថា អហេតុករបស់ចិត្តពួកនោះ រមែងកើតឡើងដោយចំពោះ ទាក់ទងជាមួយហេតុ ការរួបរួមអហេតុកចិត្ត ទើបមិនជំទាស់គ្នាក្នុងទីនេះ ដូច្នោះទើបលោកពោលថា **អហេតុកាដ្ឋារសេក** ( អហេតុក-ចិត្តមាន ១៨ដួង ចិត្តដែលមានហេតុមួយមានពីរដួង ) ជាដើម ។

# អធិប្បាយគាថាសរុប

១៦- ហេតុសូម្បីមាន ៦ យ៉ាង ចែកតាមសភាវៈ មាន ៩ យ៉ាង ចែកតាមប្រភេទជាកុសល អកុសល និងអព្យាកត ដូច្នោះ ទើបលោកពោលពាក្យជាដើមថា **លោភោ ទោសោ ច** ( ហេតុដែលជាអកុសលមាន ៣ គឺៈ លោភហេតុ ទោសហេតុ និងមោហហេតុ ដូចគ្នានេះហេតុជាកុសល និងអព្យាកតក៏មាន ៣ យ៉ាង គឺៈ អលោភហេតុ អទោសហេតុ និងអមោហហេតុ ) ។

# កិច្ចសង្គហ

## ( ការរួបរួមចិត្ត និងចេតសិកដោយកិច្ច )

**[១៨] កិច្ចសង្គហេ កិច្ចានិ នាម បដិសន្ធិភវង្គាវជ្ជនទស្សនសវនឃាយនសា-យនផុសនសម្បដិច្ឆនសន្តីរណវោដ្ឋព្វនជវនតទារម្មណចុតិវសេន ចុទ្ទសវិធានិ ភវន្តិ ។**

ប្រែថាៈ ក្នុងការរួបរួមដោយកិច្ចមាន ១៤ យ៉ាង ដោយចែកតាម បដិសន្ធិកិច្ច ភវង្គកិច្ច អាវជ្ជនកិច្ច ទស្សនកិច្ច សវនកិច្ច ឃាយនកិច្ច សាយនកិច្ច ផុសនកិច្ច សម្បដិច្ឆនកិច្ច សន្តីរណកិច្ច វោដ្ឋព្វនកិច្ច ជវនកិច្ច តទាលម្ពណកិច្ច និងចុតិកិច្ច ។

**[១៩] បដិសន្ធិភវង្គាវជ្ជនបញ្ចវិញ្ញាណដ្ឋានាទិវសេន បន តេសំ ទសធា ឋានភេទោ វេទិតព្វោ។**

ប្រែថាៈ គប្បីជ្រាបប្រភេទនៃឋាន ( របស់ចិត្តដែលធ្វើនាទី ) ទាំងនោះ មាន ១០ យ៉ាង ដោយចែកតាមបដិសន្ធិឋាន ភវង្គឋាន អាវជ្ជនឋាន និងបញ្ចវិញ្ញាណឋានជាដើម ( គឺសម្បដិច្ឆនឋាន សន្តីរណឋាន វោដ្ឋព្វនឋាន ជវនឋាន តទារម្មណឋាន ចុតិឋាន ) ។

**[២០] តត្ថ ទ្វេ ឧបេក្ខាសហគតសន្តីរណានិ ចេវ អដ្ឋ មហាវិបាកានិ ច នវ រូបារូបវិបាកានិ ចេតិ ឯកូនវីសតិ ចិត្តានិ បដិសន្ធិភវង្គចុតិកិច្ចានិ នាម ។**

ប្រែថាៈ ក្នុងកិច្ចសង្គហនោះ ចិត្ត ១៩ ដួងគឺៈ សន្តីរណចិត្ត ដែលប្រកបជាមួយឧបេក្ខាវេទនា ២ ដួង មហាវិបាកចិត្ត ៨ ដួង រូបាវចរវិបាក-ចិត្ត និងអរូបាវចរវិបាកចិត្ត ៩ ដួង ឈ្មោះថា ធ្វើនាទីបដិសន្ធិ ភវង្គ និងចុតិ ។

**[២១] អាវជ្ជនកិច្ចានិ បន ទ្វេ ។**

ប្រែថាៈ រីឯចិត្តដែលធ្វើនាទីអាវជ្ជនមាន ២ ដួង ( គឺបញ្ចទ្វារាវជ្ជនចិត្ត និងមនោទ្វារាវជ្ជនចិត្ត ) ។

**[២២] តថា ទស្សនសវនឃាយនសាយនផុសនសម្បដិច្ឆនកិច្ចានិ ច ។**

ប្រែថាៈ ចិត្តដែលធ្វើនាទីឃើញ ឮ ធុំក្លិន ភ្លក្សរស ដឹងការពាល់ត្រូវតាមផ្លូវកាយ ទទួលអារម្មណ៍តាមបញ្ចទ្វារ ( ក្នុងកិច្ចនីមួយៗ ) មាន២ដូចគ្នា ( ផ្នែកអកុសលវិបាក ១ ដួង និងកុសលវិបាក ១ ដួង ) ។

**[២៣] តីណិ សន្តីរណកិច្ចានិ ។**

ប្រែថាៈ ចិត្ត ៣ ដួង ( គឺសន្តីរណចិត្តជាកុសលវិបាក ២ ដួង និងជាអកុសលវិបាក ១ ដួង ) ធ្វើនាទីសន្តីរណ ។

**[២៤] មនោទ្វារាវជ្ជនមេវ បញ្ចទ្វារេ វោដ្ឋព្វនកិច្ចំ សាធេតិ ។**

ប្រែថាៈ មនោទ្វារាវជ្ជនចិត្ត រមែងញុំាងវោដ្ឋព្វនកិច្ចឲ្យសម្រេចក្នុងបញ្ចទ្វារ ។

**[២៥] អាវជ្ជនទ្វយវជ្ជិតានិ កុសលាកុសលផលកិរិយចិត្តានិ បញ្ចបញ្ញាស ជវនកិច្ចានិ**

ប្រែថាៈ កុសលចិត្ត អកុសលចិត្ត ផលចិត្ត និងកិរិយាចិត្ត វៀរអាវជ្ជនចិត្ត ២ ដួង រួមត្រូវជា ៥៥ ដួង ធ្វើនាទីជវន ។

**[២៦] អដ្ឋ មហាវិបាកានិ ចេវ សន្តីរណត្តយញ្ចេតិ ឯកាទស តទារម្មណ-កិច្ចានិ ។**

ប្រែថាៈ មហាវិបាកចិត្ត ៨ ដួង សន្តីរណចិត្ត ៣ ដួង រួមត្រូវជា ១១ ដួង ធ្វើនាទីតទារម្មណ ។

**[២៧] តេសុ បន ទ្វេ ឧបេក្ខាសហគតសន្តីរណចិត្តានិ បដិសន្ធិភវង្គចុតិ-តទារម្មណសន្តីរណវសេន បញ្ចកិច្ចានិ នាម ។**

ប្រែថាៈ ម្យ៉ាងទៀត បណ្តាកិច្ចទាំងនោះ សន្តីរណចិត្ត ដែលប្រកបដោយឧបេក្ខាវេទនា ២ ដួង ឈ្មោះថា ធ្វើនាទីបាន ៥ យ៉ាង ដោយប្រភេទនៃបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច តទារម្មណកិច្ច និងសន្តីរណកិច្ច ។

**[២៨] មហាវិបាកានិ អដ្ឋ បដិសន្ធិភវង្គចុតិតទារម្មណវសេន ចតុកិច្ចានិ នាម ។**

ប្រែថាៈ មហាវិបាកចិត្ត ៨ ដួង ឈ្មោះថា ធ្វើនាទីបាន ៤ យ៉ាង ដោយប្រភេទនៃបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច និងតទារម្មណកិច្ច ។

**[២៩] មហគ្គតវិបាកានិ នវ បដិសន្ធិភវង្គចុតិវសេន តិកិច្ចានិ នាម ។**

ប្រែថាៈ មហាគ្គតវិបាកចិត្ត ៩ ដួង ឈ្មោះថាធ្វើនាទីបាន ៣ យ៉ាង ដោយប្រភេទនៃបដិសន្ធិកិច្ច ភវង្គកិច្ច និងចុតិកិច្ច ។

**[៣០] សោមនស្សសហគតសន្តីរណំ សន្តីរណតទារម្មណវសេន ទុកិច្ចំ ។**

ប្រែថាៈ សន្តីរណចិត្តដែលប្រកបដោយសោមនស្ស ធ្វើនាទីបាន ២ យ៉ាង ដោយប្រភេទនៃសន្តីរណកិច្ច និងតទារម្មណកិច្ច ។

**[៣១] តថា វោដ្ឋព្វនំ វោដ្ឋព្វនាវជ្ជនវសេន ។**

ប្រែថាៈ វោដ្ឋព្វនចិត្ត ( ដែលហៅថាមនោទ្វារាវជ្ជនចិត្ត ) ធ្វើនាទីបាន ២យ៉ាង ដូចគ្នា ដោយប្រភេទនៃវោដ្ឋព្វនកិច្ច និងអាវជ្ជនកិច្ច ។

**[៣២] សេសានិ បន សព្វានិបិ ជវនមនោធាតុត្តិកទ្វិបញ្ចវិញ្ញាណានិ យថាសម្ភវមេកកិច្ចានីតិ ។**

ប្រែថាៈ ចំណែកចិត្តដែលនៅសល់ទាំងអស់ គឺជវនចិត្ត មនោធាតុ ៣ ដួង ទ្វិបញ្ចវិញ្ញាណចិត្ត ( ១០ដួង ) មាននាទីមួយៗតាមសមគួរ ។

## គាថាសរុប

**[៣៣] បដិសន្ធាទយោ នាម កិច្ចភេទេន ចុទ្ទស**
**ទសធា ឋានភេទេន ចិត្តុប្បាទា បកាសិតា ។**

ប្រែថាៈ ( បណ្ឌិត ) គប្បីសម្ដែងចិត្ត មានឈ្មោះថាបដិសន្ធិចិត្តជាដើម ថា មាន ១៤ តាមប្រភេទនៃកិច្ច និងមាន ១០ តាមប្រភេទនៃឋាន ។

**[៣៤] អដ្ឋសដ្ឋិ តថា ទ្វេ ច　　នវាដ្ឋ ទ្វេ យថាក្កមំ**

**ឯកទ្វិតិចតុបញ្ច-　　កិច្ចឋានានិ និទ្ទិសេ ។**

ប្រែថាៈ គប្បីសម្ដែងកិច្ច និងឋានរបស់ចិត្ត ដែលមានចំនួន ១ - ២ - ៣ - ៤ និង ៥ ( តាមសមគួរ ដែលមានក្នុងចិត្តទាំងនេះគឺ ) ៦៨ ដួង ២ ដួង ៩ ដួង ៨ ដួង និង ២ ដួងតាមលំដាប់ ។

# អធិប្បាយកិច្ចសង្គហ

**១៨- កិច្ចសង្គហ** គឺការរួបរួមចិត្ត និងចេតសិក ដែលមានកិច្ចទាំងនោះ ដោយចែកតាមកិច្ច ១៤ ។

ឧបបត្តិភពមួយ រមែងកើតឡើងព្រោះកម្មតែម្យ៉ាង កាលបើកម្មអស់ទៅដោយនាទីរបស់ខ្លួន ឬព្រោះបានទទួលការបៀតបៀន ភពរមែងរលត់ទៅ ឱកាសរបស់កម្មមួយទៀតរមែងមាន ដូច្នោះ ការកើតឡើងថ្មីរបស់សត្វអ្នកឃ្លាតពីភព ដែលកើតឡើងហើយដោយអំណាចនៃការបន្តភពដទៃជាដើម ដោយកម្មមួយដែលបានទទួលឱកាស ដោយមិនតាំងនៅសូម្បីត្រឹមតែមួយខណៈ ក្នុងរវាងចន្លោះ ឈ្មោះថា **បដិសន្ធិកិច្ច** ។

**ភវង្គកិច្ច** ការប្រព្រឹត្តិទៅដោយភាពជាចំណែក ប្រកបដែលជាបច្ច័យក្នុងការធ្វើឲ្យក្រសែចិត្តក្នុងឧបបត្តិភព ដែលកើតឡើងដូចយ៉ាងនោះប្រព្រឹត្តទៅបានមិនដាច់រហូតដល់កម្មអស់ទៅ ។ ការពិត នាកាលការប្រព្រឹត្តិទៅនៃភវង្គកិច្ច មាននៅជាយ៉ាងនោះ ការបន្តនៃអាយុ និងភ្លើងធាតុ រមែងមានពិតប្រាកដ ធម៌ ៣ យ៉ាងនោះ ទើបរក្សាកាយនេះមិនឲ្យរលត់ ដូចព្រះពុទ្ធវចនថាៈ

**អាយុ ឧស្មា ច វិញ្ញាណំ　　យទា កាយំ ជហន្តិមំ**
**អបវិទ្ធោ តទា សេតិ　　និរត្ថំវ កលិង្គរំ**

ប្រែថាៈ អាយុ ( ជីវិតរូប ) ក្តី ឧស្មា ( តេជោធាតុ ) ក្តី និងវិញ្ញាណ ( ភវង្គ-ចិត្ត ) ក្តី តែលះបង់នូវកាយនេះទៅក្នុងកាលណាហើយ ( កាយនេះក៏ដល់នូវសេចក្តី មិនគួរនឹងទុកដាក់ឲ្យនៅលើផ្ទះសម្បែងបានឡើយ ) គេតែងនាំយកទៅចោលឲ្យ ដេកនៅ ( លើផែនដី ) ក្នុងកាលណោះឯង ដូចជាអង្កត់-អុសរកប្រយោជន៍គ្មានឡើយ ។

**អាវជ្ជន** គឺការវិលមកនៃក្រសែចិត្ត ។

ន័យម្យ៉ាងទៀត **អាវជ្ជន** គឺកិច្ចញុំាងក្រសែចិត្តឲ្យវិលមក ។

ន័យម្យ៉ាងទៀត **អាវជ្ជន** គឺកិច្ចជាទីវិលមកនៃក្រសែចិត្ត ។

ន័យម្យ៉ាងទៀត **អាវជ្ជន** គឺកិច្ចធ្វើឲ្យក្រសែចិត្តវិលមក សេចក្តីថា កិច្ចដែលឃ្លាតពីវិថីរបស់ភវង្គចិត្ត ហើយប្រព្រឹត្តឆ្ពោះមុខទៅកាន់អារម្មណ៍ដទៃ ។

ន័យម្យ៉ាងទៀត **អាវជ្ជន** គឺកិច្ចរំពឹងគិត ( នឹករាវរក ) ពោលគឺ បង្អោនចិត្តទៅក្នុងអារម្មណ៍ដទៃ ( គឺក្រៅពីអារម្មណ៍របស់ភវង្គ ) ។

[ ពាក្យថា **អាវជ្ជន** មានសេចក្តី ៥ ប្រការគឺៈ

១- ការវិលមកនៃក្រសែចិត្ត = **អាវជ្ជនំ ចិត្តសន្តានស្ស អាវដ្ដនំ** > **អាវជ្ជនំ** ( ចុះ **យុ** បច្ច័យ ក្នុងភាវសាធន ) ។

២- កិច្ចញុំាងក្រសែចិត្តឲ្យវិលមក = **អាវជ្ជេតិ អាវដ្ដេតីតិ** > **អាវជ្ជនំ** ( ចុះ **យុ** បច្ច័យ ក្នុងកត្តុសាធន ) ។

៣- កិច្ចជាទីវិលមកនៃក្រសែចិត្ត = **អាវដ្ដតិ ឯត្ថាតិ** > **អាវជ្ជនំ** ( ចុះ **យុ** បច្ច័យ ក្នុងអធិករណសាធន ) ។

៤- កិច្ចធ្វើឲ្យក្រសែចិត្តវិលមក = **អាវដ្ដតិ ឯតេនាតិ** > **អាវជ្ជនំ** ( ចុះ **យុ** បច្ច័យ ក្នុងករណសាធន ) ។

៥- កិច្ចរំពឹងគិត = **អាវជ្ជេតីតិ** > **អាវជ្ជនំ** ( ចុះ **យុ** បច្ច័យ ក្នុងកត្តុសាធន )។

**ទស្សនកិច្ច** ( កិច្ចមានការឃើញ ) ជាដើម ប្រាកដច្បាស់ហើយ ។

ពាក្យថា **វោដ្ឋព្វនំ** មានសេចក្ដីថា ការកំណត់ទុកចំពោះ ពោលគឺការបំបែកចេញទុកមិនឲ្យលាយឡំគ្នា សេចក្ដីក៏គឺកំណត់ថា នេះពណ៌ខៀវ ពណ៌លឿង ល្អ ឬមិនល្អ ( ដោយសេចក្ដី គឺការកំណត់អារម្មណ៍ ) ។

ពាក្យថា **ជវន ជវ វេគ** ( សន្ទុះ ) មានអត្ថដូចគ្នា ។

**ជវនកិច្ច** គឺការប្រព្រឹត្តិទៅនៃចិត្តមួយដួងៗ ដែលប្រកបដោយសភាពលឿនរហ័សដូចរន្ទះ ។ ការពិត ភវង្គចិត្ត សូម្បីប្រព្រឹត្តទៅអស់កាលដ៏យូរ ក៏ប្រាសចាកសភាពលឿនរហ័ស ដូចស្លឹកឈើស្ងួតដែលអណ្ដែតទៅតាមក្រសែទឹក តែជវនចិត្តមួយដួងៗ រមែងប្រកបដោយសភាពលឿនរហ័ស ដូច **គទា** ( ដំបង ) ពេជ្រ ដែលព្រះឥន្ទចោលទៅ បណ្ឌិតគប្បីជ្រាបយ៉ាងនេះ ។

**តទារម្មណ** គឺចិត្តដែលមានអារម្មណ៍របស់ជវននោះ សេចក្ដីក៏គឺអារម្មណ៍ដែលជវនចិត្តកាន់យកនោះជាអារម្មណ៍របស់តទារម្មណចិត្ត សម-ដូចសាធកថា:

**យំ ជវនេន គហិតារម្មណំ, តស្សេវ គហិតត្តា តទារម្មណំ នាម។**

ប្រែថា: ចិត្តណាមានអារម្មណ៍ដែលជវនចិត្តកាន់យកហើយ ចិត្តនោះឈ្មោះថា តទារម្មណ ព្រោះកាន់យកអារម្មណ៍ដែលជវនចិត្តកាន់យកហើយ ។

ន័យម្យ៉ាងទៀត **តទារម្មណ** គឺចិត្តដែលមានអារម្មណ៍ដូចអារម្មណ៍របស់ជវនចិត្តនោះ។

[ ពាក្យថា **តទារម្មណ** មានសេចក្ដី ២ ប្រការគឺៈ

១- ចិត្តដែលមានអារម្មណ៍របស់ជវនចិត្ត = **តំ អារម្មណំ ឯតស្សាតិ** > **តទារម្មណំ** ( មកពី **ត** + **អារម្មណ** + **ឯត** ) ។

២- ចិត្តដែលមានអារម្មណ៍ដូចអារម្មណ៍របស់ជវនចិត្តនោះ = **តស្ស ជវនស្ស អារម្មណំ អស្ស អារម្មណន្តិ > តទារម្មណំ** ( មកពី **ត** + **អារម្មណ** + **អារម្មណ** + **ត** ) ] ។

ព្រះអនុរុទ្ធាចារ្យ សំដៅយកភាវៈ [ គឺតទារម្មណកិច្ច ] ដែលចិត្តមានអារម្មណ៍ដូចអារម្មណ៍របស់ជវននោះ ក្នុងទីនេះ ។

**ចុតិ** គឺការឃ្លាត ពោលគឺ **ច្យុត** ឃ្លាតពីភពដែលកើតនៅ ។

**១៩**- ឥឡូវនេះ ព្រះអនុរុទ្ធាចារ្យ សម្ដែងប្រភេទរបស់ឋាន ដើម្បីបញ្ជាក់ថា កិច្ចទាំងនោះ រមែងមិនប្រព្រឹត្តទៅដោយមិនមានកំណត់ តែប្រព្រឹត្តទៅដោយការកំណត់ឋានន៎ុះឯង ។

**ឋាន** គឺទីតាំង ពោល គឺទីកន្លែងកើតប្រក្រតីរបស់ចិត្ត ដែលមានកិច្ចនោះៗ ( ទីកន្លែងដែលចិត្តធ្វើនាទីនៅទីនោះៗ ) សេចក្ដីនេះក៏គឺ រយៈកាលក្នុងរវាងនោះៗ ការពិតរយៈកាល ក៏បានឈ្មោះថា **ឋាន** ព្រោះជាទីកន្លែងដែលប្រព្រឹត្តទៅតជាប់គ្នា នៃធម៌ដែលមានរយៈកាល ។

**បដិសន្ធិឋាន** គឺទីតាំងរបស់បដិសន្ធិកិច្ច បានដល់ រយៈកាលនៃបដិសន្ធិចិត្ត សេចក្ដីក៏ គឺខណៈកើតបដិសន្ធិចិត្ត ឋានដទៃក្រៅពីនេះក៏ដូចគ្នា ( គឺជាទីតាំងធ្វើកិច្ច ឬជាខណៈកើតរបស់ចិត្តដែលមានកិច្ចនោះ ) ។

ចំណែកការចែកឋានដោយពិស្ដារ គប្បីជ្រាបតាមសង្ខេបវណ្ណនាដីកាទុកថា:

**សន្ធិ ឯកំ ឆ ភវង្គំ ទ្វារជ្ឈំ បញ្ចាទ្យេកំ**

**ទ្វេ វោ ជោ ឆ តទា ទ្វេ តិ ចុតីតិ បញ្ចវីសតិ**

ប្រែថា: បដិសន្ធិឋានមាន ១ ភវង្គឋានមាន ៦ អាវជ្ជនឋានមាន ២ បញ្ចវិញ្ញាណឋានជាដើមមានឋាន ១ ( គឺសម្បដិច្ឆនឋានមាន ១ សន្តីរណឋាន

មាន ១ ) វោដ្ឋព្វនឋានមាន ២ ជវនឋានមាន ៦ តទារម្មណឋានមាន ២ ចុតិឋានមាន ៣ រួមត្រូវជា ២៥ ឋាន ។

ឋានដោយពិស្តារទាំង ២៥ នេះ គប្បីជ្រាបបាន ដោយចែកតាមវិថីមានដូចនេះគឺ៖

**១- សន្ធិដ្ឋានំ ចុភន្តរំ — បអា តអា ជអា វោអា**
**តចុ ជចុន្តរំ ភស្ស — ឆ ឋានំ បរិទីបយេ ។**
**២- ភវិ ភជន្តរំ យេវ — ទុ អាឋានំ អាសន្តរំ**
**វិឋានេកំ វិតិន្តរំ — សំ ឋានេកំ សំវោន្តរំ ។**
**៣- តី ឋានេកំ ទុ វោឋានំ — តីជ តីភន្តរំ តថា**
**វោត វោភ វោចុន្តរំ — អាត អាភ អាចុន្តរំ ។**
**៤- ជឋានំ ឆ ជភ ជចុ- — ន្តរំ ញេយ្យំ ទុ តឋានំ**
**តប ជប ភបន្តរំ — ចុតិឋានំ តិធា មតំ ។**

ប្រែថា: **បដិសន្ធិឋាន** មានឋាន ១ គឺ៖

រវាងចុតិចិត្ត និងភវង្គចិត្ត ( ក្នុងមរណាសន្នវិថី )

**ភវង្គឋាន** មានឋាន ៦ គឺ៖

-រវាងបដិសន្ធិចិត្ត និងអាវជ្ជនចិត្ត ( ដែលកើតតពីមរណាសន្នវិថី រហូតដល់ភវនិកន្តិកលោភជវនវិថី )

-រវាងតទារម្មណចិត្ត និងអាវជ្ជនចិត្ត ( ក្នុងរវាងតទារម្មណវារៈវិថី និងវិថីដទៃៗកើតជាប់តគ្នា )

-រវាងជវនចិត្ត និងអាវជ្ជនចិត្ត ( ក្នុងរវាងជវនវារៈវិថី និងវិថីចិត្តដទៃៗដែលកើតជាប់តគ្នា )

-រវាងវោដ្ឋព្វនចិត្ត និងអាវជ្ជនចិត្ត ( ក្នុងរវាងបញ្ចទ្វារវិថី ដែលជាវោដ្ឋព្វនវារៈ និងវិថីចិត្តដទៃៗ ដែលកើតជាប់តគ្នា )

-រវាងតទារម្មណចិត្ត និងចុតិចិត្ត ( ក្នុងមរណាសន្នវិថី ដែលជាតទារម្មណវារៈ )

-រវាងជវនចិត្ត និងចុតិចិត្ត ( ក្នុងមរណាសន្នវិថី ដែលជាជវនវារៈ ) ។

**អាវជ្ជនឋាន** មាន ២ ឋាន គឺៈ

-រវាងភវង្គចិត្ត និងបញ្ចវិញ្ញាណចិត្ត ( ក្នុងបញ្ចទ្វារវិថី )

-រវាងភវង្គចិត្ត និងជវនចិត្ត ( ក្នុងមនោទ្វារវិថី ) ។

**បញ្ចវិញ្ញាណឋាន** មាន ១ ឋានគឺៈ

-រវាងអាវជ្ជនចិត្ត និងសម្បដិច្ឆនចិត្ត ( ក្នុងបញ្ចទ្វារវិថី ) ។

**សម្បដិច្ឆនឋាន** មាន ១ ឋានគឺៈ

-រវាងបញ្ចវិញ្ញាណចិត្ត និងសន្តីរណចិត្ត ( ក្នុងបញ្ចទ្វារវិថី ) ។

**សន្តីរណឋាន** មាន ១ ឋានគឺៈ

-រវាងសម្បដិច្ឆនចិត្ត និងវោដ្ឋព្វនចិត្ត ( ក្នុងបញ្ចទ្វារវិថី ) ។

**វោដ្ឋព្វនឋាន** មាន ២ ឋានគឺៈ

-រវាងសន្តីរណចិត្ត និងជវនចិត្ត ( ក្នុងបញ្ចទ្វារវិថី ដែលជាតទារម្មណវារៈ និងជវនវារៈ )

-រវាងសន្តីរណចិត្ត និងភវង្គចិត្ត ( ក្នុងបញ្ចទ្វារវិថី ដែលជាវោដ្ឋព្វនវារៈ )

**ជវនឋាន** មាន ៦ ឋានគឺៈ

-រវាងវោដ្ឋព្វនចិត្ត និងតទារម្មណចិត្ត ( ក្នុងបញ្ចទ្វារវិថី ដែលជាតទារម្មណវារៈ )

-រវាងវោដ្ឋព្វនចិត្ត និងភវង្គចិត្ត ( ក្នុងបញ្ចទ្វារវិថី ដែលជាជវនវារៈ )

-រវាងវោដ្ឋព្វនចិត្ត និងចុតិចិត្ត ( ក្នុងបញ្ចទ្វារមរណាសន្នវិថី ដែលជាជវនវារៈ )

-រវាងអាវជ្ជនចិត្ត និងតទារម្មណចិត្ត ( ក្នុងមនោទ្វារវិថី ដែលជាតទារម្មណវារៈ )

-រវាងអាវជ្ជនចិត្ត និងភវង្គចិត្ត ( ក្នុងមនោទ្វារវិថី ដែលជាជវនវារៈ )

-រវាងអាវជ្ជនចិត្ត និងចុតិចិត្ត ( ក្នុងមនោទ្វារមរណាសន្នវិថី ដែលជាជវនវារៈ ) ។

**តទារម្មណឋាន** មាន ២ ឋានគឺ៖

-រវាងជវនចិត្ត និងភវង្គចិត្ត ( ក្នុងបញ្ចទ្វារវិថី និងមនោទ្វារវិថី ដែលជាតទារម្មណវារៈ )

-រវាងជវនចិត្តនិងចុតិចិត្ត ( ក្នុងមរណាសន្នវិថី ដែលជាតទារម្មណវារៈ )

**ចុតិឋាន** មាន ៣ ឋានគឺ៖

-រវាងតទារម្មណចិត្ត និងបដិសន្ធិចិត្ត ( ក្នុងមរណាសន្នវិថី ដែលជាតទារម្មណវារៈ )

-រវាងជវនចិត្ត និងបដិសន្ធិចិត្ត ( ក្នុងមរណាសន្នវិថី ដែលជាជវនវារៈ )

-រវាងភវង្គចិត្ត និងបដិសន្ធិចិត្ត ( ក្នុងមរណាសន្នវិថី ) ។

## សេចក្តីប្រែបាលីនីមួយៗក្នុងគាថានេះ

| | | | |
|---|---|---|---|
| **សន្ធិដ្ឋានំ** | = បដិសន្ធិឋាន | **ភវស្សឋានំ** | = ភវង្គឋាន |
| **អាឋានំ** | = អាវជ្ជនឋាន | **វិឋានំ** | = បញ្ចវិញ្ញាណឋាន |
| **សំឋានំ** | = សម្បដិច្ឆនឋាន | **តីឋានំ** | = សន្តីរណឋាន |
| **វោឋានំ** | = វោដ្ឋព្វនឋាន | **ជឋានំ** | = ជវនឋាន |
| **តឋានំ** | = តទារម្មណឋាន | **ចុតិឋានំ** | = ចុតិឋាន |
| **ឯកំ** | = មួយ | **ទុ** | = ពីរ |
| **តិធា** | = បី | **ឆ** | = ប្រាំមួយ |
| **បរិទីបយេ** | = រមែងសម្តែង | **ញេយ្យំ** | = រមែងដឹង |
| **មតំ** | = គប្បីជ្រាប | **តថា** | = ជានិបាត |

**ចុភន្តរំ** = ( **ចុភ** + **អនន្តំ** ) = រវាងចុតិ និងភវង្គ

| | |
|---|---|
| **បអា** | = រវាងបដិសន្ធិ និងអាវជ្ជន |
| **តអា** | = រវាងតទារម្មណ និងអាវជ្ជន |
| **ជអា** | = រវាងជវន និងអាវជ្ជន |
| **វោអា** | = រវាងវោដ្ឋព្វន និងអាវជ្ជន |
| **តចុ** | = រវាងតទារម្មណ និងចុតិ |
| **ជចុន្តរំ ( ជចុ +អន្តរំ )** | = រវាងជវន និងចុតិ |
| **ភវិ** | = រវាងភវង្គ និងបញ្ចវិញ្ញាណ |
| **ភជន្តរំ ( ភជ + អន្តរំ )** | = រវាងភវង្គ និងជវន |
| **អាសន្តរំ ( អាសំ + អន្តរំ )** | = រវាងអាវជ្ជន និងសម្បដិច្ឆន |
| **វិតិន្តរំ ( វិតី + អន្តរំ )** | **=** រវាងបញ្ចវិញ្ញាណ និងសន្តីរណ |
| **សំវោន្តរំ ( សំវោ + អន្តរំ )** | = រវាងសម្បដិច្ឆន និងវោដ្ឋព្វន |
| **តីជ** | = រវាងសន្តីរណ និងជវន |
| **តីភន្តរំ ( តីភ + អន្តរំ )** | = រវាងសន្តីរណ និងភវង្គ |
| **វោត** | = រវាងវោដ្ឋព្វន និងតទារម្មណ |
| **វោភ** | = រវាងវោដ្ឋព្វន និងភវង្គ |
| **វោចុន្តរំ ( វោចុ + អន្តរំ )** | = រវាងវោដ្ឋព្វន និងចុតិ |
| **អាត** | = រវាងអាវជ្ជន និងតទារម្មណ |
| **អាភ** | = រវាងអាវជ្ជន និងភវង្គ |
| **អាចុន្តរំ ( អាចុ + អន្តរំ )** | = រវាងអាវជ្ជន និងចុតិ |
| **ជភ** | = រវាងជវន និងភវង្គ |
| **ជចុន្តរំ ( ជចុ + អន្តរំ )** | = រវាងជវន និងចុតិ |
| **តប** | = រវាងតទារម្មណ និងបដិសន្ធិ |
| **ជប** | = រវាងជវន និងបដិសន្ធិ |

**ភវន្តរំ ( ភវ + អន្តរំ )** = រវាងភវង្គ និងបដិសន្ធិ ។

**២០-** កុសលដែលមានហេតុ២ ( អលោភហេតុ និងអទោសហេតុ ) យ៉ាងខ្សោយ សូម្បីប្រកបដោយសោមនស្ស ក៏ឲ្យផលបដិសន្ធិជាសោមន-ស្សវេទនាមិនបាន ព្រោះមានកម្លាំងតិចពេក ។ សោមនស្សសន្តីរណចិត្ត មិនចូលដល់បដិសន្ធិឋាន ដូច្នោះ លោកទើបពោលថា **ទ្វេ ឧបេក្ខាសហគត-សន្តីរណចិត្តានិ ចេវ** ( សន្តីរណចិត្ត ដែលប្រកបជាមួយឧបេក្ខាវេទនា ២ដួង... ឈ្មោះថាធ្វើនាទីបដិសន្ធិ ភវង្គ និងចុតិ ) ។ ដោយពិតហើយ សោមនស្សសន្តីរណចិត្ត មិនមានសម្តែងទុកក្នុងបដិសន្ធិឋានរបស់គម្ពីរបដ្ឋាន បីតិសហគតតិក បដិច្ចវារៈ ហេតុបច្ចនីកៈ ។

**២៥-** មនោទ្វារាវជ្ជនចិត្ត សូម្បីប្រព្រឹត្តទៅ ២ ឬ ៣ ខណៈ ក្នុងបរិត្តារម្មណ៍ ឬអវិភូតារម្មណ៍ ក៏ប្រាសចាកសភាពលឿនរហ័សរបស់ជវនចិត្ត ព្រោះមាន កម្លាំងតិច ដោយសារបានទទួលបច្ច័យពីក្រសែវិបាក ដូច្នេះ លោកទើប ពោលថា **អាវជ្ជនទ្វយវជ្ជិតានិ** ( វៀរអាវជ្ជនចិត្ត២ ដួង ) ។

សូម្បីផលចិត្ត មិនមានសភាពរបស់អាសេវនបច្ច័យក៏ដោយ ក៏ប្រកប ដោយសភាពលឿនរហ័ស រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍បាន ព្រោះមគ្គ-ចេតនាមានអានុភាពច្រើន និងប្រព្រឹត្តទៅដោយអានុភាពរបស់បរិកម្មភាវនា ទើបលោកកាន់យកផលចិត្តក្នុងជវនចិត្តទាំងឡាយ ។

**២៧-** ឥឡូវនេះ ព្រះអនុរុទ្ធាចារ្យលោកពោលថា **តេសុ បន** ( ម្យ៉ាង ទៀត បណ្តាកិច្ចទាំងនោះ សន្តីរណចិត្តដែលប្រកបដោយឧបេក្ខាវេទនា ២ ដួង ឈ្មោះថាធ្វើនាទីបាន ៥ យ៉ាង ដោយប្រភេទនៃបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច តទារម្មណកិច្ច និងសន្តីរណកិច្ច ) ជាដើម ដើម្បីរួបរួមចិត្ត ដែលមានចំនួនកិច្ចស្មើគ្នា ។

# អធិប្បាយគាថាសរុប

**៣៣-** គប្បីសម្ព័ន្ធ ( បទដែលឃ្លាតពីគ្នា ) ថា ចិត្តមានបដិសន្ធិចិត្តជាដើម ។

**៣៤-** គប្បីប្រកបបទថាៈ គប្បីសម្តែងកិច្ច និងឋានរបស់ចិត្ត ដែលមានចំនួន១ - ២ - ៣ - ៤ និង៥ ( តាមសមគួរដល់ចិត្តទាំងនោះគឺ ) ៦៨ ដួង ២ ដួង ៩ ដួង ៨ ដួង និង ២ ដួង តាមលំដាប់ ។

## ទ្វារសង្គហ

( ការរួបរួមចិត្ត និងចេតសិកដោយទ្វារ )

**[៣៥] ទ្វារសង្គហេ ទ្វារានិ នាម ចក្ខុទ្វារំ , សោតទ្វារំ ឃានទ្វារំ ជិវ្ហាទ្វារំ កាយទ្វារំ មនោទ្វារញ្ចេតិ ឆព្វិធានិ ភវន្តិ ។**

ប្រែថាៈ ក្នុងទ្វារសង្គហនេះ ដែលឈ្មោះថាទ្វារទាំងឡាយមាន ៦ គឺចក្ខុទ្វារ សោតទ្វារ ឃានទ្វារ ជិវ្ហាទ្វារ កាយទ្វារ និងមនោទ្វារ ។

**[៣៦] តត្ថ ចក្ខុមេវ ចក្ខុទ្វារំ ។**

ប្រែថាៈ បណ្តាទ្វារទាំងនោះ ចក្ខុបសាទនុ៎ះឯង ឈ្មោះថាចក្ខុទ្វារ ។

**[៣៧] តថា សោតាទយោ សោតទ្វារាទីនិ ។**

ប្រែថាៈ ដូចគ្នានេះ សោតបសាទជាដើម ក៏ឈ្មោះថាសោតទ្វារជាដើម។

**[៣៨] មនោទ្វារំ បន ភវង្គន្តិ បវុច្ចតិ ។**

ប្រែថាៈ ចំណែកភវង្គចិត្ត ឈ្មោះថាមនោទ្វារ ។

**[៣៩] តត្ថ បញ្ចទ្វារាវជ្ជនចក្ខុវិញ្ញាណសម្បដិច្ឆនសន្តីរណវោដ្ឋព្វនកាមាវចរជវនតទារម្មណវសេន ឆចត្តាលីស ចិត្តានិ ចក្ខុទ្វារេ យថារហំ ឧប្បជ្ជន្តិ; តថា បញ្ចទ្វារាវជ្ជនសោតវិញ្ញាណាទិវសេន សោតទ្វារាទីសុបិ ឆចត្តាលីសេវ ភវន្តីតិ សព្វថាបិ បញ្ចទ្វារេ ចតុបញ្ញាស ចិត្តានិ កាមាវចរានេវ។**

ប្រែថា: ក្នុងទ្វារទាំង ៦ នោះ ចិត្ត ៤៦ ដួង គឺៈ បញ្ចទ្វារាវជ្ជនចិត្ត (១) ចក្ខុវិញ្ញាណចិត្ត (២) សម្បដិច្ឆនចិត្ត (២) សន្តីរណចិត្ត (៣) វោដ្ឋព្វនចិត្ត (១) កាមជវនចិត្ត (២៩) និង តទារម្មណចិត្ត (១១) រមែងកើតឡើងក្នុង ចក្ខុទ្វារតាមសមគួរ ។

ដូចគ្នានេះ ចិត្ត ៤៦ ដួង គឺៈ បញ្ចទ្វារាវជ្ជនចិត្ត និងសោតវិញ្ញាណចិត្ត ជាដើម រមែងកើតក្នុងសោតទ្វារជាដើម ( គឺឃានទ្វារ ជិវ្ហាទ្វារ កាយទ្វារ ) ។

ដោយប្រការដូច្នេះ ចិត្ត ៥៤ ដួង ដែលកើតក្នុងទ្វារទាំង ៥ ដោយប្រការទាំងពួង ឈ្មោះថា កាមាវចរចិត្តនុ៎ះឯង ។

**[៤០] មនោទ្វារេ បន មនោទ្វារាវជ្ជនបញ្ចបញ្ញាសជវនតទារម្មណវសេន សត្តសដ្ឋិ ចិត្តានិ ភវន្តិ ។**

ប្រែថា: ចិត្ត ៦៧ ដួង គឺៈ មនោទ្វារាវជ្ជនចិត្ត (១) ជវនចិត្ត (៥៥) តទារម្មណចិត្ត (១១) រមែងកើតក្នុងមនោទ្វារ ។

**[៤១] ឯកូនវីសតិ បដិសន្ធិភវង្គចុតិវសេន ទ្វារវិមុត្តានិ ។**

ប្រែថា: ចិត្ត ១៩ ដួង គឺៈ បដិសន្ធិចិត្ត ភវង្គចិត្ត និងចុតិចិត្ត ជាចិត្តមិនទាក់ទងជាមួយទ្វារ ។

**[៤២] តេសុ បន បញ្ចវិញ្ញាណានិ ចេវ មហគ្គតលោកុត្តរជវនានិ ចេតិ ឆត្តឹសយថារហមេកទ្វារិកចិត្តានិ នាម ។**

ប្រែថា: ម្យ៉ាងទៀត បណ្តាចិត្តដែលកើតក្នុងទ្វារទាំងនោះ ចិត្ត ៣៦ ដួង គឺៈ បញ្ចវិញ្ញាណចិត្ត (១០) មហគ្គត និងលោកុត្តរជវនចិត្ត (២៦) ឈ្មោះថាជាចិត្តដែលកើតក្នុងទ្វារមួយ តាមសមគួរ ។

**[៤៣] មនោធាតុត្តិកំ បន បញ្ចទ្វារិកំ ។**

ប្រែថា: រីឯមនោធាតុចិត្តទាំង ៣ ជាចិត្តដែលកើតក្នុងទ្វារ ៥ ។

**[៤៤] សុខសន្តីរណវោដ្ឋព្វនកាមាវចរជវនានិ ឆទ្វារិកចិត្តានិ ។**

ប្រែថាៈ សន្តីរណចិត្ត ដែលប្រកបដោយសោមនស្សវេទនា (១) វោដ្ឋព្វន-ចិត្ត (១) កាមាវចរជវន (២៩) ជាចិត្តដែលកើតក្នុងទ្វារ ៦ ( គឺកើតបានគ្រប់ទ្វារ ) ។

**[៤៥] ឧបេក្ខាសហគតសន្តីរណមហាវិបាកានិ ឆទ្វារិកានិ ចេវ ទ្វារវិមុត្តានិ ច ។**

ប្រែថាៈ សន្តីរណចិត្ត ដែលប្រកបដោយឧបេក្ខាវេទនា (២) និងមហា-វិបាកចិត្ត (៨) ជាចិត្តដែលកើតក្នុងទ្វារ ៦ និង ផុតពីទ្វារ ( មិនកើតក្នុងទ្វារ ) ក៏បាន ( គឺស្រេចហើយតែនាទីរបស់ខ្លួន បើធ្វើនាទីបដិសន្ធិ ភវង្គ ចុតិ ក៏មិនកើតក្នុងទ្វារ តែបើធ្វើនាទីសន្តីរណ ឬតទារម្មណនោះ ក៏កើតក្នុងទ្វារតាមសមគួរនៃកិច្ច ) ។

**[៤៦] មហគ្គតវិបាកានិ ទ្វារវិមុត្តានេវាតិ ។**

ប្រែថាៈ មហគ្គតវិបាក (៩) ផុតពីទ្វារតែម្យ៉ាង ( គឺមិនកើតក្នុងទ្វារ ) ។

## គាថាសង្គហ

**[៤៧] ឯកទ្វារិកចិត្តានិ បញ្ច ឆទ្វារិកានិ ច**
**ឆទ្វារិកវិមុត្តានិ វិមុត្តានិ ច សព្វថា ។**
**ឆត្តឹសតិ តថា តីណិ ឯកតឹស យថាក្កមំ**
**ទសធា នវធា ចេតិ បញ្ចធា បរិទីបយេ ។**

ប្រែថាៈ បណ្ឌិតគប្បីសម្តែងចិត្តជា ៥ ន័យ គឺ ចិត្តដែលកើតក្នុងទ្វារមួយ ចិត្តដែលកើតក្នុងទ្វារប្រាំ ចិត្តដែលកើតក្នុងទ្វារប្រាំមួយ ចិត្តដែល [ គ្រាខ្លះ ] មិនកើតក្នុងទ្វារប្រាំមួយ ចិត្តដែលកើតផុតពីទ្វារប្រាំមួយ ដោយប្រការទាំងពួងជា ៣៦ ដួង ៣ ដួង ៣១ ដួង ១០ ដួង និង ៩ ដួង តាមលំដាប់ ។

# អធិប្បាយទ្វារសង្គហ

**៣៥- ទ្វារសង្គហ** គឺការរួបរួមចិត្ត និងចេតសិក ដោយចែកតាមទ្វារ មានចក្ខុទ្វារជាដើម ។

**ទ្វារ** គឺច្រកចេញចូលរបស់ជនទាំងពីពួក ។

ពាក្យថាៈ **ទ្វារ** នេះ ជាឈ្មោះរបស់ច្រកផ្លូវ ដែលពួកជននៅខាងក្នុង និងខាងក្រៅនគរចេញចូល ។

ន័យម្យ៉ាងទៀត **ទ្វារ** គឺច្រកជាទីចេញចូលរបស់ជនទាំងពីរពួក ។

[ ពាក្យថា **ទ្វារ** មានសេចក្តីពីរប្រការគឺៈ

**១**- ច្រកសម្រាប់ចេញចូលរបស់ជនទាំងពីរពួក = **ទ្វេ ជនា អរន្តិ គច្ឆន្តិ ឯតេនាតិ** > **ទ្វារំ** ( **ទុ** បុព្វបទ + **អរ** ធាតុ + **ណ** បច្ច័យ ក្នុងករណសាធន ) ។

**២**- ច្រកជាទីចេញចូលរបស់ជនពីរពួក = **ទ្វេ ជនា អរន្តិ គច្ឆន្តិ ឯត្ថាតិ** > **ទ្វារំ** ( **ទុ** បុព្វបទ + **អរ** ធាតុ + **ណ** បច្ច័យ ក្នុងអធិករណសាធន ) ។

ទ្វារមានពីរយ៉ាងគឺ ទ្វារមានចន្លោះ និងទ្វារថ្លា ។

**ទ្វារមានចន្លោះ** គឺចន្លោះផ្លូវដូចដែលបានពោលហើយ ។

**ទ្វារថ្លា** គឺច្រកផ្លូវភ្លឺ ដែលធ្វើអំពីកញ្ចក់ ។

**ទ្វារថ្លា** មានប្រើក្នុងផ្ទះអ្នកមានបុណ្យ ផ្ទះដូចដែលបានពោលមកនេះ មានទ្វារពីរបែប យ៉ាងណាមិញ សរីរៈរបស់ពួកសត្វទាំងនោះ ក៏មានទ្វារពីរបែបដូចគ្នាដែរ ។ **ទ្វារចន្លោះ** ព្រះអង្គទ្រង់បានត្រាស់ថាៈ

**នវទ្វារោ មហាវណ្ណោ** ទ្វារទាំង ៩ ជាដំបៅខ្នាតធំ

រន្ធរោមទាំង ៩ ម៉ឺន ៩ ពាន់ ក៏រាប់ជាទ្វារមានចន្លោះ តែក្នុងទ្វារសង្គហនេះ លោកបំណងយកទ្វារថ្លា ដែលដូចផែនកញ្ចក់ ព្រោះថា សូម្បីទ្វារថ្លាក៏បានឈ្មោះថាទ្វារ ដោយសារប្រហែលនឹងទ្វារ ដោយភាវៈជាផ្លូវចេញចូល

របស់ធម៌ មានអារម្មណ៍ (ចិត្ត និងចេតសិក) និងធម៌ជាអារម្មណ៍ (អារម្មណ៍ ៦) ។

**៣៦-** ទ្វារថ្លាមានពីរប្រភេទគឺ ទ្វារថ្លាដែលជារូប និងទ្វារថ្លាដែលជានាម ព្រះអនុរុទ្ធាចារ្យពោលថា **ចក្ខុទ្វារំ** ( ចក្ខុទ្វារ ) ជាដើម ដើម្បីសម្តែងថា ទ្វារថ្លាដែលជារូបក៏មាន ៥ យ៉ាង (គឺចក្ខុទ្វារ សោតទ្វារ ឃានទ្វារ ជិវ្ហាទ្វារ និង កាយទ្វារ ) ព្រោះភាវៈថ្លាពិសេស ដែលកើតពីកម្មពិសេស និងមហា-ភូតរូបពិសេស ។

ក្នុងប្រយោគនោះ ពាក្យថា **ចក្ខុមេវ ចក្ខុទ្វារំ** (ចក្ខុបសាទនុ៎ះឯង ឈ្មោះថាចក្ខុទ្វារ) មានសេចក្តីថា រូបនិមិត្ត មានរង្វង់មូលនៃព្រះចន្ទជាដើម រមែងប្រាកដត្រង់ចក្ខុបសាទណា ទាំងវិថីចិត្តមានអាវជ្ជនចិត្តជាដើម ក៏ទទួលយកអារម្មណ៍ដែលប្រាកដតាមផ្លូវចក្ខុបសាទណា ចក្ខុបសាទនោះ បាន ឈ្មោះថា ចក្ខុទ្វារ ព្រោះជាផ្លូវសំខាន់នៃការចូលដល់ភាពជាអារម្មណ៍របស់រូបនិមិត្ត និងការទទួលអារម្មណ៍របស់វិថីចិត្តទាំងពីរ ។

ន័យម្យ៉ាងទៀត រូបខាងក្រៅ មានរង្វង់មូលនៃព្រះចន្ទជាដើម រមែងចូលដល់ភាពជាអារម្មណ៍របស់វិថីចិត្តខាងក្នុង មានអាវជ្ជនចិត្តជាដើមដោយធាតុថ្លា គឺ ចក្ខុបសាទណា ទាំងវិថីចិត្តខាងក្នុង មានអាវជ្ជនចិត្តជាដើម ក៏ចូលដល់ការទទួលដឹងរូបខាងក្រៅទាំងនោះជាអារម្មណ៍ ដោយរូបថ្លា គឺចក្ខុបសាទណា រូបថ្លា គឺចក្ខុបសាទនោះនុ៎ះឯង និងឈ្មោះថា ចក្ខុទ្វារ ដោយហេតុដូចដែលបានពោលទុកហើយ ។

**ទ្វារដទៃ មានសោតទ្វារជាដើម ក៏មានន័យដូចគ្នា ១ ។**

ចំណែកក្នុងគម្ពីរដីកាទាំងឡាយ លោកពោលទុកថា “ ឈ្មោះថា **ទ្វារ** ព្រោះដូចនឹងទ្វារ ដោយសារជាផ្លូវកើតរបស់នាមធម៌ មានអាវជ្ជនជាដើម ” សេចក្តីនេះមិនស្អាត ព្រោះទ្វារជាហេតុកើតរបស់អារម្មណ៍ មានរូបារម្មណ៍

ជាដើមផង ដោយពិតហើយ ព្រះអនុរុទ្ធាចារ្យ នឹងពោលថា **ឆព្វិធា វិសយប្បវត្តិយោ** ( ការដែលអារម្មណ៍ ប្រព្រឹត្តទៅ [ ក្នុងទ្វារ ] ៦ ប្រការ ) ។

ក្នុងប្រយោគនេះ ពាក្យថា **វិសយប្បវត្តិ** គឺការប្រព្រឹត្តិទៅដែលហៅថា អារម្មណ៍ មានរូបជាដើម ប្រាកដក្នុងទ្វារទាំងឡាយ ។

ពាក្យថា **ចក្ខុមេវ ចក្ខុទ្វារំ** ( ចក្ខុបសាទនុ៎ះឯង ឈ្មោះថា ចក្ខុទ្វារ ) បដិសេធសេចក្តីថា ទ្វារនៃភ្នែក ឈ្មោះថាចក្ខុទ្វារ ។

[ ពាក្យថា **ចក្ខុមេវ ចក្ខុទ្វារំ** សម្តែងរូបវិគ្គហ អវធារណបុព្វបទកម្មធារយសមាសថា **ចក្ខុមេវ ទ្វារំ** > **ចក្ខុទ្វារំ** ប្រែថាៈ ទ្វារ គឺចក្ខុបសាទនុ៎ះឯង ឈ្មោះថាចក្ខុទ្វារ

ក្រៅពីនេះ នៅបដិសេធរូបវិគ្គហ ឆដ្ឋីតប្បុរិសសមាសថា **ចក្ខុស្ស ទ្វារំ** > **ចក្ខុទ្វារំ** ទ្វារនៃចក្ខុបសាទ ឈ្មោះថាចក្ខុទ្វារ ] ។

**៣៧,៣៨-** ពាក្យថា **តថា សោតាទយោ សោតទ្វារាទីនិ** ប្រែថាៈ ដូចគ្នានេះ សោតបសាទជាដើម ក៏ឈ្មោះថាសោតទ្វារជាដើម ។ សម្តែងសេចក្តីនេះថា សោតបសាទនុ៎ះឯង ឈ្មោះថាសោតទ្វារ ... ចិត្តនុ៎ះឯង ឈ្មោះថាមនោទ្វារ ចំណែកទ្វារនៃចិត្តមិនឈ្មោះថាមនោទ្វារ ។

ព្រះអនុរុទ្ធាចារ្យ កាលនឹងសម្តែងចិត្ត ដែលលោកប្រាថ្នាយកក្នុងទីនេះ ដោយសារចិត្តមានច្រើនប្រភេទ ទើបពោលថា **មនោទ្វារំ បន ភវង្គន្តិ បវុច្ចតិ** ប្រែថាៈ ចំណែកភវង្គចិត្ត បានឈ្មោះថាមនោទ្វារ ។

សូម្បីចិត្ត ៨៩ ដួង ទាំងអស់ ឈ្មោះថាមនោទ្វារ តែក្នុងបរិច្ឆេទនេះ សំដៅយកទ្វារដែលជាប់ទាក់ទងនឹងឧបបត្តិភពប៉ុណ្ណោះ ដូច្នោះ លោកទើបពោលថាៈ **ភវង្គន្តិ បវុច្ចតិ** ( ចំណែកភវង្គចិត្ត ឈ្មោះថា មនោទ្វារ ) មាន

សេចក្តីថា  ភវង្គចិត្ត ១៩ ដួងប៉ុណ្ណោះ  ដែលប្រព្រឹត្តទៅជាប់តគ្នារហូតអស់ជីវិត  ដូចក្រសែទឹក  តាំងពីបដិសន្ធិកាល  ឈ្មោះថា **មនោទ្វារ** ក្នុងទីនេះ។

**៣៩**- ពាក្យថា **តត្ថ** ( បណ្តាទ្វារទាំងនោះ )  ចុះសត្តមីវិភត្តិ  ក្នុងអត្ថនិទ្ធារណៈ ( សេចក្តីដែលត្រូវដកចេញ ) ។

ពាក្យថា **យថារហំ** ( តាមសមគួរ )  មានសេចក្តីថា សមគួរដល់អារម្មណ៍ ភូមិ  បុគ្គល  និងមនសិការៈជាដើម ។

ពាក្យថា **សព្វថាបិ** មានសេចក្តីថា ដោយប្រការទាំងពួង  ពោលគឺ  ចិត្ត ៨៦ដួង  ផ្សេងៗគ្នា ។

គប្បីសម្ព័ន្ធបទនេះជាមួយពាក្យថា **ចតុបញ្ញាស** ( ៥៤ ដួង )  ដោយការរាប់ចិត្តដែលនៅមិនទាន់បានរាប់ ។

ន័យម្យ៉ាងទៀត  ពាក្យថា  **សព្វថាបិ** មានសេចក្តីថា  ដោយប្រការទាំងពួង ដែលប្រកបដោយកិច្ចផ្សេងៗ  ចំនួនច្រើន  មានអាវជ្ជនកិច្ចជាខាងដើម  និងតទារម្មណកិច្ចជាខាងចុងបំផុត ។

គប្បីសម្ព័ន្ធបទនេះ  ជាមួយនឹងពាក្យថា  **កាមាវចរានេវ** ( ជាកាមាវចរចិត្ត ) ។

**៤១- ទ្វារិកចិត្ត**  គឺចិត្តដែលមានកិច្ចមានអាវជ្ជនកិច្ចជាដើម  ប្រព្រឹត្តទៅដោយអាស្រ័យការប្រែប្រួលរបស់ទ្វារ  ព្រោះជាសភាវៈប្រកបក្នុងទ្វារ  ។ ចំណែកបដិសន្ធិកិច្ច  ភវង្គកិច្ច  និងចុតិកិច្ច  រមែងសម្រេចដោយអំណាចនៃកម្មតែម្យ៉ាង  ប្រាសចាកការប្រែប្រួលរបស់ទ្វារ  ចិត្តដែលមានកិច្ចទាំងនោះ ទើបមិនឈ្មោះថា  ទ្វារិកចិត្ត  ដូច្នោះ  លោកទើបពោលថា  **ឯកូន ។ បេ ។ ទ្វារវិមុត្តានិ** ( ចិត្ត ១៩ ដួង  ដោយប្រភេទនៃបដិសន្ធិចិត្ត  ភវង្គចិត្ត  និងចុតិចិត្ត ) ជាចិត្តមិនទាក់ទងជាមួយទ្វារ ។

ការប្រែប្រួលរបស់ទ្វារក្នុងទីនេះ គឺការញ័ររបស់ភវង្គចិត្ត ដោយសារអារម្មណ៍មកប្រាកដក្នុងខ្លួន និងការប្រកបដោយសេចក្តីអាចពិសេស គឺការដែលចក្ខុបសាទជាដើម ញ៉ាំងចិត្តឲ្យកើតក្នុងខ្លួន ។

**៤៥-** សេចក្តីក៏គឺ [ សន្តីរណចិត្តដែលប្រកបដោយឧបេក្ខាវេទនា និងមហាវិបាកចិត្ត ] ជាចិត្តដែលកើតក្នុងទ្វារ ៦ ដោយប្រភេទនៃសន្តីរណកិច្ច និងតទារម្មណកិច្ច និងជាចិត្តដែលមិនទាក់ទងដោយទ្វារ ដោយប្រភេទនៃបដិសន្ធិកិច្ចជាដើម ។

**៤៧- បញ្ចឆទ្វារិក** គឺចិត្តដែលកើតឡើងក្នុងទ្វារ ៥ និងទ្វារ ៦ ។

**ឆទ្វារិកវិមុត្ត** គឺចិត្តដែលទាក់ទងជាមួយទ្វារ ៦ ក្នុងពេលខ្លះ និងផុតពីទ្វារ ៦ ក្នុងពេលខ្លះ ។ ពាក្យថា **ទ្វារ** ក្នុងបទនេះ ប្រកបទុកដោយការជាប់តាមមក ។

[ ពាក្យថា **ឆទ្វារិកវិមុត្ត** មានសេចក្តីពីរប្រការគឺះ **ឆទ្វារិក** ( ចិត្តដែលទាក់ទងដោយទ្វារ ៦ ) និង **វិមុត្ត** ( ផុតពីទ្វារ ៦ ) ពាក្យថា **ទ្វារ** ជាប់តាមមកប្រកបជាមួយពាក្យថា **វិមុត្ត** ទើបបានដល់ ផុតពីទ្វារ ៦ ] ។

គប្បីជ្រាបថា គប្បីសម្តែងចិត្ត ៥ ន័យ គឺចិត្តដែលកើតក្នុងទ្វារមួយ... និងចិត្តមិនទាក់ទងដោយទ្វារ ៦ ដោយប្រការទាំងពួង ត្រូវជា ៣៦ ដួង... និង ៩ ដួង តាមលំដាប់ ។

## អារម្មណសង្គហ

## ( ការរួបរួមចិត្ត និងចេតសិកដោយអារម្មណ៍ )

**[៤៨] អាលម្ពណសង្គហេ អារម្មណានិ នាម រូបារម្មណំ សទ្ទារម្មណំ គន្ធារម្មណំ រសារម្មណំ ផោដ្ឋព្វារម្មណំ ធម្មារម្មណញ្ចេតិ ឆព្វិធានិ ភវន្តិ ។**

ប្រែថា: ឈ្មោះថាអារម្មណ៍ទាំងឡាយ ក្នុងអារម្មណសង្គហមាន ៦ យ៉ាង គឺះ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ ។

**[៤៩] តត្ថ រូបមេវ រូបារម្មណំ តថា សទ្ទាទយោ សទ្ទារម្មណាទីនិ ។**

ប្រែថា: បណ្តាអារម្មណ៍ទាំងនោះ រូបនុ៎ះឯងជារូបារម្មណ៍ ដូចគ្នានេះ សម្លេងជាដើម ជាសទ្ទារម្មណ៍ជាដើម ។

**[៥០] ធម្មារម្មណំ បន បសាទសុខុមរូបចិត្តចេតសិកនិព្វានបញ្ញត្តិវសេន ឆធា សង្គយ្ហតិ។**

ប្រែថា: ចំណែកធម្មារម្មណ៍ មានការរួបរួមទុក ៦យ៉ាង ដោយប្រភេទនៃបសាទរូប (៥) សុខុមរូប (១៦) ចិត្ត (៨៩) ចេតសិក (៥២) និព្វាន និង បញ្ញត្តិ។

**[៥១] តត្ថ ចក្ខុទ្វារិកចិត្តានិ សព្វេសម្បិ រូបមេវ អារម្មណំ តញ្ច បច្ចុប្បន្នំ តថា សោតទ្វារិកចិត្តាទីនម្បិ សទ្ទាទីនិ តានិ ច បច្ចុប្បន្នានិយេវ ។**

ប្រែថា: បណ្តាអារម្មណ៍ទាំងនោះ រូបប៉ុណ្ណោះជាអារម្មណ៍របស់ចិត្ត ដែលប្រព្រឹត្តទៅក្នុងចក្ខុទ្វារទាំងអស់ ទាំងរូបនោះឯងជាបច្ចុប្បន្ន ដូចគ្នានេះ សម្លេងជាដើម ជាអារម្មណ៍របស់ចិត្ត ដែលប្រព្រឹត្តទៅក្នុងសោតទ្វារជាដើម ថែមទាំងសម្លេងជាដើមនោះ ជាបច្ចុប្បន្ន ។

[ ចិត្តដែលអាស្រ័យចក្ខុទ្វារ ទទួលដឹងរូបារម្មណ៍បានតែម្យ៉ាង និង ទទួលដឹងរូបដែលជាបច្ចុប្បន្នបានប៉ុណ្ណោះ មិនអាចទទួលដឹងរូបដែលជាអតីត ឬអនាគតបានឡើយ ព្រោះមើលមិនឃើញ ] ។

**[៥២] មនោទ្វារិកចិត្តានំ បន ឆព្វិធម្បិ បច្ចុប្បន្នមតីតំ អនាគតំ កាលវិមុត្តញ្ច យថារហមារម្មណំ ហោតិ ។**

ប្រែថា: ចំណែកអារម្មណ៍របស់ចិត្ត ដែលប្រព្រឹត្តទៅក្នុងមនោទ្វារ មាន ៦ យ៉ាង ជាបច្ចុប្បន្ន អតីត អនាគត និងផុតចាកកាល ( គឺនិព្វាន និងបញ្ញត្តិ ) បានតាមសមគួរ ។

**[៥៣] ទ្វារវិមុត្តានញ្ច បដិសន្ធិភវង្គចុតិសង្ខាតានំ ឆព្ពិធម្បិ យថាសម្ភវំ យេភុយ្យេន ភវន្តរេ ឆទ្វារគ្គហិតំ បច្ចុប្បន្នមតីតំ, បញ្ញត្តិភូតំ វា កម្មកម្មនិមិត្ត-គតិនិមិត្តសម្មតំ អារម្មណំ ហោតិ ។**

ប្រែថាៈ ម្យ៉ាងទៀត អារម្មណ៍របស់ចិត្ត ដែលផុតពីទ្វារ ដែលហៅថា បដិសន្ធិចិត្ត ភវង្គចិត្ត និងចុតិចិត្ត មាន ៦ យ៉ាង ត្រូវទទួលដឹងបានតាមទ្វារទាំង ៦ ក្នុងភពដទៃដោយច្រើន ជាបច្ចុប្បន្ន អតីត ឬជាអារម្មណ៍បញ្ញត្តិ ដែលហៅថា កម្ម កម្មនិមិត្ត និងគតិនិមិត្ត តាមសមគួរដល់អារម្មណ៍ដែលកើតឡើង ។

[ អារម្មណ៍របស់ចិត្ត ដូចពោលមកនេះ មាន ៦យ៉ាងគឺៈ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ តែជាអារម្មណ៍ដែលនឹងកើតឡើងដល់ចិត្តក្នុងភពដទៃ ] ។

**[៥៤] តេសុ ចក្ខុវិញ្ញាណាទីនិ យថាក្កមំ រូបាទិឯកេការម្មណានេវ ។**

បណ្ដាចិត្តទាំងនោះ ចក្ខុវិញ្ញាណចិត្តជាដើម មានអារម្មណ៍បានតែម្យ៉ាង១ ប៉ុណ្ណោះ ដូចជារូបារម្មណ៍ជាដើម តាមលំដាប់ ។

[ បានសេចក្ដីថា ចក្ខុវិញ្ញាណចិត្ត ទទួលដឹងរូបារម្មណ៍តែម្យ៉ាង សោត-វិញ្ញាណចិត្តទទួលដឹងសទ្ទារម្មណ៍តែម្យ៉ាង ដូចនេះជាដើម ] ។

**[៥៥] មនោធាតុត្តិកំ បន រូបាទិបញ្ចារម្មណំ ។**

ប្រែថាៈ ចំណែកមនោធាតុចិត្តទាំង ៣ មានអារម្មណ៍ ៥ យ៉ាង មានរូបារម្មណ៍ជាដើម ។

**[៥៦] សេសានិ កាមាវចរវិបាកានិ ហសនចិត្តញ្ចេតិ សព្វថាបិ កាមាវចរារម្ម-ណានេវ ។**

ប្រែថាៈ ចិត្តពួកនេះគឺៈ កាមាវចរវិបាកចិត្តដែលនៅសល់ និងហសនចិត្ត មានអារម្មណ៍ជាកាមាវចរប៉ុណ្ណោះ សូម្បីដោយប្រការទាំងពួង ( គឺមហាវិបាកចិត្ត ៨ សន្តីរណចិត្ត ៣ ហសិតុប្បាទចិត្ត ១ ) ។

**[៥៧] អកុសលានិ ចេវ ញាណវិប្បយុត្តកាមាវចរជវនានិ ចេតិ លោកុត្តរ-វជ្ជិតសព្វារម្មណានិ ។**

ប្រែថា: អកុសលចិត្តទាំងឡាយ និងកាមាវចរជវនទាំងឡាយ ដែលប្រាសចាកបញ្ញា មានអារម្មណ៍បានទាំងអស់ វៀរលោកុត្តរ ។

**[៥៨] ញាណសម្បយុត្តកាមាវចរកុសលានិ ចេវ បញ្ចមជ្ឈានសង្ខាតំ អភិញ្ញាកុសលញ្ចេតិ អរហត្តមគ្គផលវជ្ជិតសព្វារម្មណានិ ។**

ប្រែថា: កាមាវចរកុសលចិត្តទាំងឡាយ ដែលប្រកបដោយបញ្ញា ( ៤ ដួង ) និងអភិញ្ញាកុសលចិត្ត ដែលហៅថា បញ្ចមជ្ឈានចិត្ត (១) មានអារម្មណ៍បានទាំងអស់ វៀរអរហត្តមគ្គ និងអរហត្តផល ។

**[៥៩] ញាណសម្បយុត្តកាមាវចរកិរិយានិ ចេវ កិរិយាភិញ្ញាវោដ្ឋព្វនញ្ចេតិ សព្វថាបិ សព្វារម្មណានិ ។**

ប្រែថា:កាមាវចរកិរិយាចិត្ត ដែលប្រកបដោយបញ្ញា (៤) អភិញ្ញាកិរិយា-ចិត្ត (១) និងវោដ្ឋព្វនចិត្ត (១) មានអារម្មណ៍បានទាំងអស់ ដោយប្រការទាំងពួង ។

**[៦០] អារុប្បេសុ ទុតិយចតុត្ថានិ មហគ្គតារម្មណានិ ។**

ប្រែថា: បណ្តាអរូបាវចរចិត្តទាំងឡាយ អរូបាវចរចិត្តទីពីរ និងទីបួន មានអារម្មណ៍ជាមហគ្គត [ គឺអរូបាវចរចិត្តទីពីរ មានអរូបាវចរចិត្តទីមួយ ជាអារម្មណ៍, អរូបាវចរចិត្តទីបួន មានអរូបាវចរចិត្តទីបី ជាអារម្មណ៍ ] ។

**[៦១] សេសានិ បន មហគ្គតចិត្តានិ សព្វានិបិ បញ្ញត្តារម្មណានិ ។**

ប្រែថា: ចំណែកមហគ្គតចិត្តដែលនៅសល់ សូម្បីទាំងអស់មានបញ្ញត្តិជាអារម្មណ៍ ( ដូចកសិណជាដើម ) ។

**[៦២] លោកុត្តរចិត្តានិ និព្វានារម្មណានីតិ ។**

ប្រែថា: លោកុត្តរចិត្តទាំងឡាយ មាននិព្វានជាអារម្មណ៍ ។

## គាថាសរុប

[៦៣] បញ្ចវីស បរិត្តម្ហិ ឆ ចិត្តានិ មហគ្គតេ
ឯកវីសតិ វោហារេ អដ្ឋ និព្វានគោចរេ ។
វីសានុត្តរមុត្តម្ហិ អគ្គមគ្គផលុជ្ឈិតេ
បញ្ច សព្វត្ថ ឆច្ចេតិ សត្តធា តត្ថ សង្គហោ ។

ប្រែថាៈ ការរួបរួមក្នុងអារម្មណសង្គហនោះ មាន ៧ ប្រការគឺៈ ចិត្ត ២៥ ដួង រមែងមានក្នុងបរិត្តារម្មណ៍ ( គឺអារម្មណ៍ដែលជាកាមាវចរ ) ចិត្ត ៦ ដួង រមែងមានក្នុងមហគ្គតារម្មណ៍ ចិត្ត ២១ ដួង រមែងមានក្នុងបញ្ញត្តារម្មណ៍ ចិត្ត ៨ ដួង មានអារម្មណ៍ជានិព្វាន ។

ចិត្ត ២០ ដួង រមែងមានក្នុងអារម្មណ៍ដែលផុតពីលោកុត្តរអារម្មណ៍ ចិត្ត ៥ ដួង រមែងមានក្នុងអារម្មណ៍ដែលវៀរពីអរហត្តមគ្គ អរហត្តផល ចិត្ត ៦ ដួង រមែងមានក្នុងអារម្មណ៍ទាំងអស់ ។

## អធិប្បាយអារម្មណសង្គហ

**[៤៨] អារម្មណសង្គហ** គឺការរួបរួមចិត្ត និងចេតសិក ដោយចែកតាមអារម្មណ៍ មានរូបារម្មណ៍ជាដើម ។

**អារម្មណ** ( អារម្មណ៍ ) បានដល់ ទីគោងរបស់ចិត្ត និងចេតសិក គឺទាញទុកមិនប្រលែងចោល ដូចឈើច្រត់ជាដើម ដែលបុរសទុព្វល ( ខ្សោយ ) កម្លាំងចាប់ទប់ ។

ក្នុងអដ្ឋកថា បញ្ចបករណ៍ សម្តែងសេចក្តីរបស់ពាក្យ **អារម្មណ** ទុកថាៈ **យថា ហិ ទុព្វលោ បុរិសោ ទណ្ឌំ វា រជ្ជុំ វា អាលម្ពិត្វាវ ឧដ្ឋហតិ ចេវ តិដ្ឋតិ ច, ឯវំ ចិត្តចេតសិកា ធម្មា រូបាទិអារម្មណំ អារព្ភេវ ឧប្បជ្ជន្តិ ចេវ តិដ្ឋន្តិ ច ។**

ប្រែថា៖ ប្រៀបដូចបុរសទុព្វលភាព ចាំបាច់ត្រូវអាស្រ័យឈើច្រត់ ទប់ខ្លួន ឬតោងខ្សែ ទើបក្រោកឈរឡើងបាន យ៉ាងណាមិញ ចិត្ត និងចេតសិក ក៏ប្រារព្ធអារម្មណ៍មានរូបជាដើមហើយ ទើបកើតឡើង និង តាំងនៅបាន ក៏យ៉ាងនោះដែរ ។

**[៤៩]** ពាក្យថា **រូបមេវ** ( រូបនុ៎ះឯង ) គឺពណ៌នុ៎ះឯង ។

**[៥០]** សភាវឯណានីមួយ ដែលផុតពីអារម្មណ៍ ៥ ប្រាកដមានក្តី មិន ប្រាកដមានក្តី មានពិតក្តី មិនមានពិតក្តី ចាត់ជាធម្មារម្មណ៍ មាន ៦ ប្រភេទ កាលបើរួបរួមតាមសភាវៈដែលដូចគ្នា ដូច្នោះ ទើបលោកពោលថា **ធម្មារម្មណំ បន ។បេ។ ឆធា សង្គយ្ហតិ** ( ចំណែកធម្មារម្មណ៍ មានការរួបរួមទុក ៦ យ៉ាង ដោយប្រភេទនៃបសាទរូប (៥) សុខុមរូប (១៦) ចិត្ត (៨៩) ចេតសិក (៥២) និព្វាន និង បញ្ញត្តិ ។

**[៥១]** ពាក្យថា **តត្ថ** គឺអារម្មណ៍ ៦ យ៉ាង មានរូបារម្មណ៍ជាដើមនោះ ។

ចិត្តដែលប្រព្រឹត្តទៅក្នុងចក្ខុទ្វារ កើតឡើងបង្អោនទៅតាមរូប ដែលមក ប៉ះខ្ទប់នឹងចក្ខុទ្វារ ( ចក្ខុបសាទ ) រមែងតោងអារម្មណ៍ដទៃមិនបាន ទាំងតោង រូបារម្មណ៍ដែលជាអតីត ឬអនាគត ដែលប្រាសចាកការប៉ះខ្ទប់ ( រវាងអារម្មណ៍ ជាមួយទ្វារ ) ក៏មិនបាន ដូច្នោះ លោកទើបពោលថា **ចក្ខុទ្វារិកចិត្តានំ សព្វេសំបិ រូបមេវ អារម្មណំ, តញ្ច បច្ចុប្បន្នំ** ( រូបប៉ុណ្ណោះ ជាអារម្មណ៍របស់ចិត្ត ដែលប្រព្រឹត្តទៅក្នុងចក្ខុទ្វារទាំងអស់ ទាំងរូបនោះជាបច្ចុប្បន្ន ) សូម្បីចិត្ត ដែលប្រព្រឹត្តទៅក្នុងសោតទ្វារជាដើម ក៏មានន័យដូចគ្នា ។

ក្នុងប្រយោគនោះ **បច្ចុប្បន្ន** គឺអារម្មណ៍ដែលកើតឡើងព្រោះអាស្រ័យ ហេតុនោះៗ មានសេចក្តីថា កំពុងប្រព្រឹត្តទៅ ។

ពាក្យថា **ឆព្វិធំបិ** ( សូម្បីមាន ៦ យ៉ាង ) ដោយចែកតាមរូបារម្មណ៍ ជាដើម ។

**អតីត** គឺអារម្មណ៍ដែលកន្លងទៅហើយ ។

**អាគត** គឺអារម្មណ៍ដែលមកប្រាកដ បានដល់ បច្ចុប្បន្នអារម្មណ៍ ។

ន័យម្យ៉ាងទៀត **អាគត** គឺអារម្មណ៍ដែលមកប្រាកដហើយ បានដល់ អតីតអារម្មណ៍ ។

[ ពាក្យថា **អាគត** មានសេចក្តីពីរយ៉ាងគឺៈ

១- អារម្មណ៍ដែលមកប្រាកដ = **អាគច្ឆតីតិ** > **អាគតំ** ( ចុះ **ត** បច្ច័យ ក្នុងបច្ចុប្បន្នកាល ) ។

២- អារម្មណ៍ដែលមកប្រាកដហើយ = **អាគច្ឆីយិត្ថាតិ** > **អាគតំ** ( ចុះ **ត** បច្ច័យ ក្នុងអតីតកាល ) ] ។

**អនាគត** គឺអារម្មណ៍ដែលមិនទាន់មកប្រាកដ ឬមកប្រាកដហើយ ។

សង្ខតធម៌ ដែលមានសភាវលក្ខណៈ គឺការកើតឡើង រមែងប្រព្រឹត្ត ទៅក្នុងកាលទាំង ៣ ដូច្នោះ និព្វាន និងបញ្ញត្តិ ដែលជាអសង្ខតធម៌ ដែលប្រាសចាកការកើតឡើង ទើបឈ្មោះថា **ផុតចាកកាល ។**

ចំណែកការចែក ( ចិត្ត និងអារម្មណ៍របស់ចិត្ត ) តាមសមគួរ នឹងប្រាកដ តទៅក្នុងអារម្មណសង្គហនេះ ដោយពាក្យជាដើមថា **តេសុ** ( បណ្តាចិត្ត ទាំងនោះ ចក្ខុវិញ្ញាណចិត្តជាដើម មានអារម្មណ៍ម្យ៉ាងៗ ប៉ុណ្ណោះ ដូច រូបារម្មណ៍ជាដើម តាមលំដាប់ ) ។

**[៥៣]** គប្បីភ្ជាប់ពាក្យដែលឆ្ងាយពីគ្នាថា ម្យ៉ាងទៀត អារម្មណ៍របស់ចិត្ត ដែលផុតពីទ្វារ មាន ៦ យ៉ាង ។

អារម្មណ៍របស់ចិត្ត ដែលផុតពីទ្វារទាំងនេះ រមែងមិនដូចនឹងអារម្មណ៍ របស់អាវជ្ជនចិត្តជាដើម ដែលកើតតាមទ្វារ ៦ ដែលត្រូវទទួលដឹងខ្លះ មិន ត្រូវទទួលដឹងខ្លះ តាមទ្វារណាមួយមុន ( វិថីចិត្តកើត ) ក្នុងភពដទៃ ឬភពនេះ ដូច្នោះ លោកទើបពោលថា **ភវន្តរេ ឆទ្វារគ្គហិតំ** ( ត្រូវទទួលដឹង តាមទ្វារទាំង៦ ក្នុងភពដទៃ ) ។

លោកពោលថា **បច្ចុប្បន្នមតីតំ បញ្ញត្តិភូតំ វា** ( ជាបច្ចុប្បន្ន អតីត ឬជាអារម្មណ៍បញ្ញត្តិ ) ដើម្បីសម្ដែងថា អារម្មណ៍របស់ចិត្ត ដែលផុតពីទ្វារទាំងនេះ ផ្សេងពីអារម្មណ៍របស់ចិត្តដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ ដែលទៀងតែជាបច្ចុប្បន្ន និងមិនដូចអារម្មណ៍របស់ចិត្តដែលប្រព្រឹត្តទៅក្នុងមនោទ្វារ ដែលមានកាល ៣ ឬផុតពីកាលទូទៅ ( បានសេចក្ដីថា មិនមែនអារម្មណ៍បញ្ញត្តិ ដែលផុតពីកាល គឺមិនមែនបច្ចុប្បន្ន អតីត និងអនាគត ) ។

លោកពោលថា **កម្មកម្មនិមិត្តគតិនិមិត្តសម្មតំ** ( ដែលហៅថាកម្ម កម្មនិមិត្ត និងគតិនិមិត្ត ) ដើម្បីសម្ដែងថា អារម្មណ៍របស់ចិត្ត ដែលផុតហើយពីទ្វារទាំងនេះ មិនដូចអារម្មណ៍របស់ចិត្ត ដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ ប្រកបដោយឈ្មោះហៅដែលសម្រេចពីកម្ម ( កម្ម កម្មនិមិត្ត និង គតិនិមិត្ត ) ខ្លះ ផុតពីឈ្មោះហៅនោះខ្លះ ។

នៅពេលសត្វទាំងឡាយជិតនឹងអស់ជីវិត សត្វទាំងនោះក៏ទទួលអារម្មណ៍ គឺកម្មដែលខ្លួនបានធ្វើមកពីមុន ឬឧបករណ៍ក្នុងការប្រកបកម្ម ដូចជាព្រះចេតិយ៍ជាដើមបាន ក្នុងខណៈនោះ កម្មក៏នៅតែជាកម្ម និងឧបករណ៍ក្នុងការប្រកបកម្ម ក៏ជាកម្មនិមិត្ត ព្រោះមានសភាពជាហេតុឲ្យកម្មសម្រេច ទើបឈ្មោះថាកម្មនិមិត្ត ។

ពពួកសត្វ អាចទទួលគតិនិមិត្តជាអារម្មណ៍បានទៀតផង ដោយការយល់សប្តិ៍ឃើញជាដើម ដូចជាព្រះបាទអជាតសត្រូវ ជាព្រះរាជាបានសម្លាប់ព្រះបិតា ក្រោយពីសម្លាប់ហើយ គតិនិមិត្តបានប្រាកដឡើងក្នុងពេលដែលព្រះអង្គផ្ទំ ។

ពាក្យថា **យថាសម្ភវំ** មានសេចក្ដីថា តាមសមគួរដល់អារម្មណ៍ដែលកើតឡើង ដោយចែកតាមអារម្មណ៍ដែលត្រូវបដិសន្ធិជាដើមនោះៗ ទទួលដឹងតាមទ្វារ ៦ ជាដើម ចំណែកការចែកតាមសមគួរដល់អារម្មណ៍ដែលកើត

ឡើង នឹងប្រាកដច្បាស់ក្នុងការកើតមរណចិត្តតទៅ [ ក្នុងបរិច្ឆេទទី ៥ ឈ្មោះថា **វិថីមុត្តសង្គហវិភាគ** ] ។

ពាក្យថា **យេភុយ្យេន** ប្រែថា ដោយច្រើន

ពាក្យថា **ភវន្តរេ** ( ក្នុងភពដទៃ ) គឺក្នុងភពមុន និងក្នុងពេលជិតស្លាប់ក្នុងពេលនោះ ។

ពាក្យថា **ឆទ្វារគ្គហិតំ** ( ត្រូវទទួលដឹងតាមទ្វារទាំង ៦ ) មានសេចក្តីថា ត្រូវមរណាសន្នជវនចិត្ត ( ជវនចិត្តដែលកើតក្នុងខណៈជិតអស់ជីវិត ) ទទួលដឹងតាមទ្វារទាំង ៦ ។

ពាក្យថា **យេភុយ្យេន** ( ដោយច្រើន ) ក្នុងទីនេះសម្តែងដល់ភាពមិនទៀងរបស់ន័យថា **ភវន្តរេ ឆទ្វារគ្គហិតំ** ( ទទួលដឹងតាមទ្វារទាំង ៦ ក្នុងភពដទៃ ) នេះ ។

-សួរថាៈ ហេតុដូចម្តេច ?

-ឆ្លើយថាៈ ព្រោះមានអារម្មណ៍ដែលមិនត្រូវទទួលដឹងខ្លះ សេចក្តីថា អារម្មណ៍របស់បដិសន្ធិចិត្ត ភវង្គចិត្ត និងចុតិចិត្ត ក្នុងកាមភូមិ ដែលហៅថា កម្ម កម្មនិមិត្ត និងគតិនិមិត្ត របស់អ្នកចុតិពីអសញ្ញីភព និងដែលហៅថា គតិនិមិត្ត របស់អ្នកចុតិពីអរូបភព រមែងមិនត្រូវទទួលដឹងតាមទ្វារណាមួយក្នុងភពដទៃ ។

**ក្នុងគម្ពីរអដ្ឋកថាក៏បានពោលថា** បដិសន្ធិចិត្តក្នុងកាមភូមិ របស់អ្នកដែលចុតិពីអរូបភូមិ មានអារម្មណ៍គឺ គតិនិមិត្ត ដែលជាបច្ចុប្បន្ន និងសម្តែងថា គតិនិមិត្តជារូបារម្មណ៍តែម្យ៉ាង ដូច្នោះ អារម្មណ៍ដែលហៅថាគតិនិមិត្តរបស់បដិសន្ធិចិត្តក្នុងកាមភូមិ របស់អរូបព្រហ្ម ទើបមិនត្រូវបានទទួលដឹងតាមទ្វារណាមួយក្នុងភពដទៃ ។

ការប្រាកដនៃកម្មអារម្មណ៍ជាដើម ដោយកម្លាំងកម្មក្នុងពេលជិតអស់ជីវិត ច្រើនតែកើតដល់អ្នករង្វេងជិតស្លាប់ តែកើតដល់ពួកជនដទៃ ដោយអានុភាពនៃសេចក្តីព្យាយាមរបស់អ្នកដទៃខ្លះ ដោយអានុភាពនៃការរលឹកដល់វត្ថុដែលខ្លួនបានសេពល្អហើយខ្លះ ដោយអានុភាពនៃទេវតាដែលមកពីទេវ-លោកហើយនាំយកទៅខ្លះ ដូចអារម្មណ៍ដែលកើតដល់**ធម្មិកឧបាសក** ជាដើម ។

សូម្បីនាយនិរយបាល ( យមបាល ) ក៏មកពីនរកហើយនាំយកទៅបានខ្លះ ក្នុងសេចក្តីនេះគប្បីពោលរេវតីវិមានវត្ថុ មានសេចក្តីដំណាលថា នាយនិរយបាលពីរនាក់ បាននាំនាងរេវតីទៅកាន់ភពតាវតឹង្សមុន ទើបនាំទៅកាន់នរកជាខាងក្រោយ ការពិត នាយនិរយបាល អាចទៅកាន់ភពតាវតឹង្សបាន ដូចបរិវាររបស់ស្តេចវេស្សវណ្ណ ព្រោះជាជាតិយក្ខ **ដូចព្រះពុទ្ធវចនក្នុងព្រះបាលីថា យមស្ស ទូតា ទ្វេ យក្ខា** ប្រែថា យក្ខពីរនាក់ ជាទូតរបស់យមរាជ ។

**ក្នុងគម្ពីរវិភាវនីពោលថា** “ អារម្មណ៍ មានកម្មនិមិត្តជាដើម រមែងប្រាកដដល់បដិសន្ធិចិត្តរបស់អ្នកចុតិពីអសញ្ញីភព ដោយកម្លាំងកម្មតែម្យ៉ាង ” ក្នុងពាក្យនោះ **អាទិ** ( ជាដើម ) សព្ទ័ក្នុងពាក្យថា “ មានកម្មនិមិត្តជាដើម ” គប្បីរួមយកកម្មទៀតផង ព្រោះមិនមានហេតុដែលនឹងវៀរកម្មទុក ដោយសារអារម្មណ៍ទាំងអស់ រមែងប្រាកដក្នុងបដិសន្ធិកាល ដោយកម្លាំងកម្មដែលញុំាងបដិសន្ធិចិត្តឲ្យកើត ។

ចំណែកអារម្មណ៍ជាអនាគតកាលនឹងប្រាកដឡើង ក៏គួរជាគតិនិមិត្តអារម្មណ៍ប៉ុណ្ណោះឯង និងនាទីដែលគួរប្រាកដដោយចំពោះរបស់អារម្មណ៍ដែលជាអនាគតនោះរមែងមិនមាន បើគតិនិមិត្តដែលជាបច្ចុប្បន្នសម្រេច គតិនិមិត្តដែលជាអនាគតក៏សម្រេចដូចគ្នា ដូច្នោះ លោកទើបពោលថា **បច្ចុប្បន្នមតីតំ បញ្ញត្តិភូតំ វា** ( ជាបច្ចុប្បន្ន អតីត ឬជាអារម្មណ៍បញ្ញត្តិ ) ។

**[៥៥]** ពាក្យថា **តេសុ** ( បណ្តាចិត្តទាំងនោះ ) គឺចិត្តដែលមានអារម្មណ៍ដូចដែលបានពោលមកហើយ ។

ពាក្យថា **រូបាទិឯកេការម្មណ** គឺមានអារម្មណ៍ម្យ៉ាងៗ ដូចរូបារម្មណ៍ជាដើម ។

ពាក្យថា **រូបាទិបញ្ចារម្មណ** គឺមានអារម្មណ៍ ៥ យ៉ាង មានរូបារម្មណ៍ជាដើម ។

**[៥៦]** ពាក្យថា **សេសានិ** ( ចិត្តដែលនៅសល់ ) គឺសន្តីរណចិត្ត និងមហាវិបាកចិត្ត ដែលក្រៅពីបញ្ចវិញ្ញាណចិត្ត និងសម្បដិច្ឆនចិត្ត ។

ពាក្យថា **សព្វថាបិ កាមាវចរាលម្ពណានេវ** ប្រែថា: មានអារម្មណ៍ជាកាមាវចរប៉ុណ្ណោះ ដោយប្រការទាំងពួង គឺប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងៗមានរូបជាដើម ដោយនាទីផ្សេងៗ មានបដិសន្ធិកិច្ចជាដើម ។ ដោយពិតហើយ ចិត្តទាំងនោះ សូម្បីកើតឡើងដល់ព្រះសព្វញ្ញូ ក៏មិនអាចដឹងអារម្មណ៍បញ្ញត្តិដែលមិនមានពិត មហគ្គតធម៌ដ៏សុខុម និងលោកុត្តរធម៌ដ៏ជ្រាលជ្រៅ ព្រោះប្រាសចាកសមត្ថភាពក្នុងការទទួលដឹង ។

បណ្តាចិត្តទាំងនោះ លំដាប់ដំបូង សន្តីរណចិត្ត ៣ ដួង រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៥ យ៉ាង មានរូបជាដើម ដោយប្រភេទនៃសន្តីរណកិច្ចចំណែកវិបាកចិត្ត ១១ ដួងទាំងអស់ រមែងប្រព្រឹត្តទៅក្នុងបរិត្តារម្មណ៍ ៦ យ៉ាង ដោយប្រភេទនៃតទារម្មណកិច្ចជាដើម ។

ការចែកការប្រព្រឹត្តិទៅរបស់ចិត្ត ក្នុងអារម្មណ៍ដែលគប្បីពោលក្នុងទីនេះ គប្បីកាន់យកតាមអដ្ឋកថាកណ្ឌ ។

[ **គម្ពីរអដ្ឋសាលិនី** សម្តែងដល់ជាមួយការប្រព្រឹត្តិទៅរបស់ចិត្ត ២៥ ដួង ក្នុងអារម្មណ៍ដែលជាកាមាវចរដូចនេះគឺះ

-ទ្វិបញ្ចវិញ្ញាណចិត្តកើតឡើង និងប្រព្រឹត្តទៅ ដោយអាស្រ័យចក្ខុបសាទជាដើម ហើយរមែងប្រារព្ធអារម្មណ៍គឺ រូប សម្លេង ក្លិន រស និងផោដ្ឋព្វ ដែលចែកជាឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើម ដូច្នោះ ទើបមានអារម្មណ៍ជាកាមាវចរ ( បរិត្តារម្មណ៍ ) ។

ចំណែកមនោធាតុពីរដួង ដែលជាកុសលវិបាក និងអកុសលវិបាក ( សម្បដិច្ឆនចិត្ត ) កើតឡើង និងប្រព្រឹត្តទៅ ដោយអាស្រ័យហទយវត្ថុ ហើយរមែងប្រារព្ធរូបារម្មណ៍ជាដើមទៀង តពីចក្ខុវិញ្ញាណចិត្តជាដើម ដូច្នោះ ទើបមានអារម្មណ៍ជាកាមាវចរ ។

-មនោវិញ្ញាណធាតុ ដែលជាផលរបស់កុសលមិនមានហេតុ ប្រកបដោយសោមនស្ស ( សោមនស្សសន្តីរណចិត្ត ) រមែងប្រព្រឹត្តទៅ ទៀងតែប្រារព្ធបរិត្តារម្មណ៍ ៦ យ៉ាង មានរូបារម្មណ៍ជាដើម ដោយប្រភេទនៃសន្តីរណកិច្ច តាមទ្វារ ៥ និងប្រភេទនៃតទារម្មណកិច្ច តាមទ្វារ ៦ ដូច្នោះ ទើបមានអារម្មណ៍ជាកាមាវចរ ។

-មនោវិញ្ញាណធាតុ ២ ដួង ដែលជាផលរបស់កុសល និងអកុសល មិនមានហេតុ ( ឧបេក្ខាសន្តីរណចិត្ត ) រមែងប្រព្រឹត្តទៅដោយប្រារព្ធបរិត្តារម្ម-ណ៍ ៦ យ៉ាង មានរូបារម្មណ៍ជាដើមទៀង ដោយប្រភេទនៃសន្តីរណកិច្ចតាមទ្វារ ៥ និងដោយប្រភេទនៃតទារម្មណកិច្ច តាមទ្វារ ៦ សូម្បីបើប្រព្រឹត្តទៅដោយប្រភេទនៃបដិសន្ធិកិច្ច រមែងទទួលអារម្មណ៍ដែលជាកម្មអារម្មណ៍ កម្ម-និមិត្តអារម្មណ៍ គតិនិមិត្តអារម្មណ៍ ជាកាមាវចរ សូម្បីប្រព្រឹត្តទៅដោយប្រភេទនៃភវង្គកិច្ចក្នុងបវត្តិកាល និងដោយប្រភេទនៃចុតិកិច្ច ក្នុងទីបំផុតរមែងទទួលអារម្មណ៍ មានកម្មអារម្មណ៍ជាដើមនុ៎ះឯង ដូច្នោះ ទើបមានអារម្មណ៍ជាកាមាវចរ ។

-ចំណែកវិបាកចិត្តដែលមានហេតុ ៨ ដួង ( មហាវិបាកចិត្ត ) រមែងប្រព្រឹត្តទៅដោយប្រារព្ធអារម្មណ៍ ជាកាមាវចរប៉ុណ្ណោះ ដោយប្រភេទនៃតទារម្មណកិច្ច និងដោយប្រភេទនៃបដិសន្ធិកិច្ច ភវង្គកិច្ច និងចុតិកិច្ច ។

-មនោធាតុដែលជាកិរិយា ( បញ្ចទ្វារាវជ្ជនចិត្ត ) រមែងប្រព្រឹត្តទៅ ដោយប្រារព្ធរូបារម្មណ៍ជាដើម តាមទ្វារ ៥ ។

-មនោវិញ្ញាណធាតុ ដែលជាកិរិយាមិនមានហេតុ ប្រកបដោយសោមនស្ស ( ហសិតុប្បាទចិត្ត ) រមែងប្រព្រឹត្តទៅ ក្នុងខណៈញ៉ាំងអាការៈរីករាយ ដល់ព្រះខីណាស្រព ដោយប្រារព្ធរូបារម្មណ៍ជាដើម ដែលជាកាមាវចរ ជាបច្ចុប្បន្នកាល តាមទ្វារទាំង ៦ និងជាអតីត និងអនាគតតាមមនោទ្វារ ដូច្នោះ ទើបមានអារម្មណ៍ជាកាមាវចរ ។

ដោយប្រការដូច្នេះ ចិត្តុប្បាទទាំង ២៥ ដួងនេះ គប្បីជ្រាបថា ទៀងតែមានអារម្មណ៍ជាកាមាវចរ ] ។

**[៥៧]** លោកុត្តរធម៌ ជាអារម្មណ៍របស់ញាណប៉ុណ្ណោះ ព្រោះជ្រាលជ្រៅល្អិតក្រៃលែង ដូច្នោះ លោកទើបពោលថា **អកុសល ។ បេ ។ លោកុត្តរវជ្ជិតសព្វារម្មណានិ** ( ចិត្តទាំងនេះគឺៈ អកុសលចិត្ត និងកាមាវចរជវនចិត្ត ដែលមិនប្រកបដោយញាណ មានអារម្មណ៍បានគ្រប់យ៉ាង វៀរតែលោកុត្តរ ) ។

ក្នុងប្រយោគនោះ ចិត្តទាំងនោះមានអារម្មណ៍ជាមហគ្គត កើតដល់បុគ្គលដែលធ្លាប់បានសមាបត្តិប៉ុណ្ណោះ ។

បណ្តាចិត្តទាំងនោះ ទោសមូលចិត្ត ២ ដួង មានអារម្មណ៍ជាមហគ្គត ពេលកើតឡើងដោយប្រារព្ធឈានដែលសាបសូន្យហើយ ។

**[៥៨]** សូម្បីបញ្ញាក៏មិនអាចតោងទាញលោកុត្តរធម៌ ដែលមិនធ្លាប់បានសម្រេចមកជាអារម្មណ៍ ដូច្នោះ លោកទើបពោលថា **ញាណសម្បយុត្ត ។ បេ ។**

**វជ្ជិតសព្វារម្មណានិ** ( ចិត្តទាំងនេះគឺ កាមាវចរកុសលចិត្ត ដែលប្រកបដោយញាណ និងអភិញ្ញាកុសលចិត្តដែលហៅថាបញ្ចមជ្ឈានចិត្ត មានអារម្មណ៍បានគ្រប់យ៉ាង វៀរតែអរហត្តមគ្គ និងអរហត្តផល ) ។

ក្នុងប្រយោគនោះ កាមាវចរកុសលចិត្តដែលប្រកបដោយញាណ មានអារម្មណ៍ជាកាមាវចរ ព្រមទាំងបញ្ញត្តិ ពេលកើតដល់បុថុជ្ជន អ្នកមិនបានសម្រេចឈាន ។

ចិត្តទាំងនោះមានអារម្មណ៍ជានិព្វាន ពេលកើតដល់បុថុជ្ជន ក្នុងខណៈគោត្រភូញាណកើត មុនសោតាបត្តិមគ្គកើត ។

ចិត្តទាំនោះ និងអភិញ្ញាកុសលចិត្ត មានអារម្មណ៍ជាមហគ្គតខ្លះ ពេលកើតដល់ឈានលាភីបុគ្គល ទាំងមានអារម្មណ៍ជាមគ្គ ផល និងនិព្វាន ដែលខ្លួនធ្លាប់បានសម្រេចហើយខ្លះ ពេលកើតដល់បុគ្គលអ្នកតាំងនៅក្នុងអរិយផលថ្នាក់ក្រោម ។

ព្រះអរិយបុគ្គលទាំងឡាយ រមែងតោងទាញមគ្គ ផល ដែលខ្លួនសម្រេចហើយជាអារម្មណ៍បាន យ៉ាងណាមិញ ឈានលាភីបុគ្គល ក៏តោងទាញឈានដែលខ្លួនសម្រេចហើយជាអារម្មណ៍បាន ក៏យ៉ាងនោះដែរ បណ្ឌិតគប្បីជ្រាបយ៉ាងនេះ ។

**[៥៩]** កាមាវចរកិរិយាជវនចិត្ត ដែលប្រកបដោយញាណ និងអភិញ្ញាកិរិយាជវនចិត្ត ដែលកើតដល់បុគ្គលអ្នកដឹងច្បាស់នូវអរហត្តមគ្គ អរហត្តផល រមែងដឹងអារម្មណ៍យ៉ាងណាមួយក៏បាន ក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ មួយអន្លើដោយបញ្ញត្តិតាមសមគួរដល់បុគ្គល ទាំងមនោទ្វារាវជ្ជនចិត្ត ដែលប្រព្រឹត្តទៅមុនចិត្តទាំងនោះ ក៏ដឹងបានដូចគ្នា ( គឺមានអារម្មណ៍បានទាំងអស់ ) ដូច្នោះ លោកទើបពោលថា **ញាណសម្បយុត្ត ។បេ។ សព្វថាបិ សព្វារម្មណានិ** ( ចិត្តទាំងនេះគឺៈ កាមាវចរកិរិយាចិត្ត ដែលប្រកបដោយញាណ អភិញ្ញាកិរិយាចិត្ត និងវោដ្ឋព្វនចិត្ត មានអារម្មណ៍ទាំងពួង ដោយប្រការទាំងពួង ) ។

ក្នុងប្រយោគនោះ ពាក្យថា **សព្វថាបិ** មានសេចក្ដីថា ដោយប្រការទាំងពួង ដែលមានអារម្មណ៍ជាកាមាវចរទាំងអស់ មហគ្គតអារម្មណ៍ទាំងអស់ លោកុត្តរអារម្មណ៍ទាំងអស់ បញ្ញត្តិអារម្មណ៍ទាំងអស់ និងបច្ចុប្បន្នអារម្មណ៍ទាំងអស់ ជាដើម ។

ពាក្យនេះសំដៅដល់អារម្មណ៍ដែលកើតដល់ព្រះសព្វញ្ញូ ចំណែកអារម្មណ៍ក្រៅនេះ សូម្បីកើតដល់ព្រះបច្ចេកពុទ្ធ ក៏ជាអារម្មណ៍ទាំងអស់ត្រឹមតែជាចំណែកខ្លះប៉ុណ្ណោះ ការពិត ព្រះបច្ចេកពុទ្ធ មិនអាចដឹងអារម្មណ៍ទាំងនោះបានទាំងអស់ សូម្បីត្រឹមតែបឋវីធាតុមួយ ។

**[៦០]** បណ្ដាអរូបាវចរចិត្តទាំងឡាយ អរូបាវចរចិត្តដួងទីពីរ និងដួងទីបួន មានអារម្មណ៍ជាមហគ្គត ព្រោះមានអារម្មណ៍គឺ បឋមារុប្បវិញ្ញាណ និងតតិយារុប្បវិញ្ញាណ ។

**[៦១]** ពាក្យថា **សេសានិ** ( មហគ្គតចិត្តដ៏សេស) គឺមហគ្គតចិត្ត ២១ ដួងទាំងអស់ ដែលនៅសល់ពីអភិញ្ញាចិត្ត ២ ដួង និងអរូបាវចរចិត្តទីពីរ និងទីបួន មានអារម្មណ៍ជាបញ្ញត្តិ មានកសិណជាដើម ។

## អធិប្បាយគាថាសរុប

**[៦៣]** ពាក្យថា **បញ្ចវីស** ( ចិត្ត ២៥ ដួង ) លោកពោលទុក សំដៅដល់បញ្ចទ្វារាវជ្ជនចិត្ត កាមាវចរវិបាកចិត្ត ២៣ និងហសនចិត្ត ។

ពាក្យថា **បរិត្តម្ហិ** ( ក្នុងបរិត្តារម្មណ៍ ) បានដល់ ក្នុងអារម្មណ៍ដែលជាកាមាវចរ អារម្មណ៍នោះ បានឈ្មោះថា **បរិត្ត** ( មានប្រមាណតូច ឬតិច ) ព្រោះមានសភាវត្រូវធម៌បៀតបៀន កាត់បង់ដោយជុំវិញ គឺធ្វើមិនឲ្យមានកម្លាំង ព្រោះមានអានុភាពតិច ។

[ ពាក្យថា **បរិត្ត** សម្រេចរូបមកពី **បរិ** បុព្វបទ + **ទា** ធាតុ = កាត់បង់ + **ត** បច្ច័យ មានវិគ្គហថា **បដិពន្ធកធម្មេហិ បរិ សមន្តតោ ទីយតិ អវខណ្ឌីយតីតិ**

> **បរិត្តំ** ប្រែថា អារម្មណ៍ដែលត្រូវធម៌បៀតបៀន ផ្ដាច់បង់ដោយជុំវិញ ឈ្មោះថា បរិត្តារម្មណ៍ ] ។

# វត្ថុសង្គហ

## ( ការរួបរួមចិត្ត និងចេតសិកដោយវត្ថុ )

**[៦៤] វត្ថុសង្គហេ វត្ថូនិ នាម ចក្ខុ សោត ឃាន ជិវ្ហា កាយ ហទយវត្ថុ ចេតិ ឆព្វិធានិ ភវន្តិ។**

ប្រែថា: ឈ្មោះថាវត្ថុទាំងឡាយ ក្នុងវត្ថុសង្គហ ( នេះ ) មាន ៦ យ៉ាង គឺៈ ចក្ខុវត្ថុ សោតវត្ថុ ឃានវត្ថុ ជិវ្ហាវត្ថុ កាយវត្ថុ និងហាទយវត្ថុ ។

**៦៥- តានិ កាមលោកេ សព្វានិបិ លព្ភន្តិ ។**

ប្រែថា: វត្ថុពួកនោះទាំងអស់ រមែងកើតក្នុងកាមភូមិ ។

**៦៦- រូបលោកេ បន ឃានាទិត្តយំ នត្ថិ ។**

ប្រែថា: តែវត្ថុ ៣ មានឃានវត្ថុជាដើម មិនមានក្នុងរូបភូមិឡើយ ។

**៦៧- អរូបលោកេ បន សព្វានិបិ ន សំវិជ្ជន្តិ ។**

ប្រែថា: ចំណែកក្នុងអរូបភូមិ វត្ថុទាំងពួងមិនមាន ។

**៦៨- តត្ថ បញ្ចវិញ្ញាណធាតុយោ យថាក្កមំ ឯកន្តេន បញ្ច បសាទវត្ថូនិ និស្សាយេវ បវត្តន្តិ ។**

ប្រែថា: បណ្ដាវត្ថុទាំងនេះ វិញ្ញាធាតុ ៥ រមែងប្រព្រឹត្តទៅដោយអាស្រ័យបសាទវត្ថុទាំង ៥ ទៀង តាមលំដាប់ ។

[ ចក្ខុវិញ្ញាណចិត្ត គឺចិត្តដែលអាស្រ័យចក្ខុបសាទ

សោតវិញ្ញាណចិត្ត គឺចិត្តដែលអាស្រ័យសោតបសាទ

ឃានវិញ្ញាណចិត្ត គឺចិត្តដែលអាស្រ័យឃានបសាទ

ជិវ្ហាវិញ្ញាណចិត្ត គឺចិត្តដែលអាស្រ័យជិវ្ហាបសាទ

កាយវិញ្ញាណចិត្ត គឺចិត្តដែលអាស្រ័យកាយបសាទ ] ។

**[៦៩] បញ្ចទ្វារាវជ្ជនសម្បដិច្ឆនសង្ខាតា បន មនោធាតុ ច ហទយំ និស្សិតាយេវ បវត្តន្តិ។**

ប្រែថា: ចំណែកមនោធាតុ ដែលហៅថាបញ្ចទ្វារាវជ្ជនចិត្ត និង សម្បដិច្ឆនចិត្ត រមែងប្រព្រឹត្តទៅដោយអាស្រ័យហទយវត្ថុប៉ុណ្ណោះ ។

**[៧០] អវសេសា បន មនោវិញ្ញាណធាតុសង្ខាតា ច សន្តីរណមហាវិបាកបដិឃ-ទ្វយបឋមមគ្គហសនរូបាវចរវសេន ហទយំ និស្សាយេវ បវត្តន្តិ ។**

ប្រែថា: ម្យ៉ាងទៀត ចិត្ត [ ៣០ដួង ] ដែលនៅសល់ ហៅថាមនោ-វិញ្ញាណធាតុ ដោយប្រភេទនៃសន្តីរណចិត្ត មហាវិបាកចិត្ត បដិឃចិត្តពីរ បឋមគ្គចិត្ត ហសនចិត្ត និងរូបាវចរចិត្ត រមែងប្រព្រឹត្តទៅ ដោយអាស្រ័យ ហទយវត្ថុប៉ុណ្ណោះ ។

**៧១- អវសេសា កុសលាកុសលកិរិយានុត្តរវសេន បន និស្សាយ វា អនិស្សាយ វា ។**

ប្រែថា: តែមនោវិញ្ញាណធាតុដែលនៅសល់ ដោយប្រភេទនៃកុសលចិត្ត អកុសលចិត្ត កិរិយាចិត្ត និងលោកុត្តរចិត្ត រមែងប្រព្រឹត្តទៅ ដោយអាស្រ័យ ហទយវត្ថុ ក៏បាន មិនអាស្រ័យហទយវត្ថុក៏បាន ។

**៧២- អារុប្បវិបាកវសេន ហទយំ អនិស្សាយេវាតិ ។**

ប្រែថា: ចំណែកអរូបាវចរវិបាកចិត្ត រមែងប្រព្រឹត្តទៅដោយមិនអាស្រ័យ ហទយវត្ថុឡើយ ។

## គាថាសរុប

**៧៣- ឆវត្ថុំ និស្សិតា កាមេ　　សត្ត រូបេ ចតុព្វិធា**
**តិវត្ថុំ និស្សិតារុប្បេ　　ធាត្វេកានិស្សិតា មតា ។**

ប្រែថាៈ វិញ្ញាណធាតុ៧ ក្នុងកាមភូមិ អាស្រ័យវត្ថុ ៦ , វិញ្ញាណធាតុ ៤ ក្នុងរូបភូមិ អាស្រ័យវត្ថុ ៣ ចំណែកវិញ្ញាណធាតុ ១ ក្នុងអរូបភូមិ មិនអាស្រ័យ [ វត្ថុរូបណា ] ឡើយ ។

**៧៤- តេចត្តាលីស និស្សាយ ទ្វេចត្តាលីស ជាយរេ**

**និស្សាយ ច អនិស្សាយ បាការុប្បា អនិស្សិតា ។**

ប្រែថាៈ ចិត្ត ៤៣ ដួង កើតឡើងដោយអាស្រ័យវត្ថុ ចិត្ត ៤២ ដួង កើតឡើងដោយអាស្រ័យវត្ថុ និងមិនអាស្រ័យវត្ថុ អរូបាវចរវិបាកកើតឡើងដោយមិនអាស្រ័យវត្ថុ ។

## អធិប្បាយវត្ថុសង្គហ

**៦៤- វត្ថុសង្គហ** គឺការរួបរួមចិត្ត និងចេតសិកដែលមានវត្ថុពួកនោះ ដោយចែកតាមវត្ថុមានចក្ខុវត្ថុជាដើម ។

**វត្ថុ** គឺបសាទរូបដែលជាទីតាំងរបស់ចិត្ត និងចេតសិក ។

គប្បីជ្រាបពាក្យថា ចក្ខុវត្ថុ សោតវត្ថុ ឃានវត្ថុ ជិវ្ហាវត្ថុ កាយវត្ថុ និងហទយវត្ថុ

**ចក្ខុវត្ថុ** គឺចក្ខុបសាទ

**សោតវត្ថុ** គឺសោតបសាទ

**ឃានវត្ថុ** គឺឃានបសាទ

**ជិវ្ហាវត្ថុ** គឺជិវ្ហាបសាទ

**កាយវត្ថុ** គឺកាយបសាទ

**ហទយវត្ថុ** គឺហទយរូប ។

**៦៥-** ពាក្យថា **តានិ កាមលោកេ សព្វានិបិ លព្ភន្តិ** ( វត្ថុពួកនោះទាំងអស់ រមែងមានបានក្នុងកាមភូមិ ) មានសេចក្ដីថា សូម្បីវត្ថុទាំង ៦ យ៉ាង រមែងមានបានក្នុងកាមភូមិប៉ុណ្ណោះ ព្រោះអត្តភាពដែលកើតពីកម្ម ទាក់ទិនដោយ

កាមតណ្ហា ឥន្ទ្រីយ៍គប្បីមានបរិបូណ៌ សេចក្ដីថា កាលបើមានចក្ខុវត្ថុជាដើម ការបរិភោគប្រើប្រាស់រូបជាដើមរមែងមាន ដូច្នោះ កាមតណ្ហាសេចក្ដីរីករាយក្នុងវត្ថុកាមមានរូបជាដើម ទើបប្រាថ្នាភាពបរិបូណ៌នៃវត្ថុ ៥ មានចក្ខុវត្ថុជាដើមជានិច្ចជាកាល ។

អាមាត្យជាអ្នកមើលការខុសត្រូវក្នុងព្រះរាជកិច្ចគ្រប់យ៉ាង រមែងញុំាងព្រះរាជបំណងឲ្យបរិបូណ៌ជានិច្ចជាកាល រមែងញុំាងព្រះរាជកិច្ចទាំងពួងឲ្យសម្រេច យ៉ាងណាមិញ កាមាវចរកម្មក៏ញុំាងសេចក្ដីប្រាថ្នារបស់កាមតណ្ហាឲ្យបរិបូណ៌ជានិច្ចជាកាល រមែងញុំាងអត្តភាពដែលមានឥន្ទ្រិយបរិបូណ៌ឲ្យកើតឡើងដូច្នោះដែរ ដោយហេតុនេះ ពពួកសត្វក្នុងកាមភូមិ ដែលកើតពីកម្មដែលទាក់ទិនដោយកាមតណ្ហា ទើបមានឥន្ទ្រីយ៍បរិបូណ៌។

**៦៦-** វត្ថុ៣ មានឃានវត្ថុជាដើម រមែងមិនកើតឡើងដើម្បីភាពបរិសុទ្ធ ( ពីកិលេស ) ដូចចក្ខុបសាទ និងសោតបសាទ ដែលជាធម៌ញុំាងការឃើញឲ្យកើត និងការឮដ៏ប្រសើរ នាំទៅកាន់ភាពបរិសុទ្ធ របស់ពួកសត្វដោយការឃើញព្រះពុទ្ធ និងការស្ដាប់ព្រះធម៌ជាដើម ចំណែកវត្ថុ ៣ ពួកនោះ រមែងកើតឡើងដើម្បីបរិភោគកាមតែម្យ៉ាង ព្រោះហេតុនោះ ទើបវត្ថុពួកនោះមិនកើតឡើងក្នុងអត្តភាពរបស់ព្រហ្ម ដែលកើតអំពីការចម្រើនភាវនា ដើម្បីប្រាសចាកតម្រេកក្នុងកាម ដូច្នោះ លោកទើបពោលថា **រូបលោកេ បន ឃានាទិត្តយំ នត្ថិ** ( តែវត្ថុ ៣ មានឃានវត្ថុជាដើម មិនមានក្នុងរូបភូមិ ) ។

ពាក្យនេះសំដៅយកបសាទរូប ៣ ចំណែកសណ្ឋានច្រមុះ អណ្ដាត និងកាយ ដែលប្រព្រឹត្តទៅព្រមជាមួយទីតាំង ( មហាភូតរូប ) រមែងគ្រប់បរិបូណ៌សមសួនដោយពិត

**៦៧-** ពាក្យថា **អរូបលោកេ បន សព្វានិបិ ន សំវិជ្ជន្តិ** ប្រែថាៈ ចំណែកក្នុងអរូបភូមិ មិនមានវត្ថុទាំងពួង ព្រោះមិនមានការប្រព្រឹត្តិទៅនៃរូបទាំងអស់ក្នុងពួកនាមធម៌ ទាំងខាងក្នុង និងទាំងខាងក្រៅ ក្នុងអរូបភូមិដែលកើតពីការចម្រើនភាវនា ដើម្បីប្រាសចាកសេចក្ដីត្រេកអរក្នុងរូប ការពិត ពពួកសត្វអ្នក

កើតក្នុងអរូបភូមិ មានត្រឹមតែតំណាចិត្តតាំងនៅក្នុងផ្ទៃនៃអាកាសសុទ្ធៗ តែប៉ុណ្ណោះ ។

**៦៨-** ក្រៅពីនេះ លោកពោលថា **តត្ថ បញ្ចវិញ្ញាណធាតុយោ** ( បណ្ដាវត្ថុទាំងនោះ វិញ្ញាណធាតុ ៥ រមែងប្រព្រឹត្តទៅដោយអាស្រ័យបសាទវត្ថុទាំង ៥ ទៀងតាមលំដាប់ ) ជាដើម ដើម្បីរួបរួមចិត្តក្នុងសង្គហនេះ ដោយចែកតាមវិញ្ញាណធាតុ៧ ។

ពាក្យថា **តត្ថ** គឺបណ្ដាវត្ថុ ៦ ទាំងនោះ ។

ពាក្យថា **បញ្ចវិញ្ញាណធាតុ** បានដល់ ធាតុគឺបញ្ចវិញ្ញាណ ព្រោះមានសភាពមិនមែនសត្វ មិនមែនជីវិត ។

## សូម្បីបទដទៃក៏ដូចគ្នា

**[៦៩] មនោធាតុ** គឺធាតុត្រឹមតែដឹង ព្រោះមិនមាននាទីដឹងពិសេស ដោយពិតហើយ នាទីត្រឹមតែគិតរំពឹងនិងទទួលដឹង ( អារម្មណ៍ ) តាមបញ្ចទ្វារប៉ុណ្ណោះ មិនមែននាទីដឹងពិសេស តែបញ្ចវិញ្ញាណមាននាទីដឹងពិសេសជាងមនោធាតុបន្តិច ដោយការឃើញយ៉ាងប្រត្យក្សជាដើម ចំណែកចិត្តដែលនៅសល់ពីបញ្ចវិញ្ញាណ និងមនោធាតុ ៣ មានសន្តីរណចិត្តជាដើម មិនមែនត្រឹមតែទទួលដឹងអារម្មណ៍ដូចមនោធាតុ និងមិនមែនត្រឹមតែដឹងពិសេសដូចបញ្ចវិញ្ញាណធាតុទេ នៅឈ្មោះថា **មនោវិញ្ញាណធាតុ**ទៀត ព្រោះជាធាតុដឹងដ៏ពិសេសក្រៃលែង មានរូបវិគ្គហថា ចិត្តឈ្មោះថា **មន** ព្រោះមានសភាពដឹង និងចិត្តនោះ ឈ្មោះថា **វិញ្ញាណ** ព្រោះមានសភាពដឹងដ៏ពិសេសដោយសារប្រកបដោយនឹងនាទីដឹងពិសេសក្រៃលែង ដោយការពិចារណាសភាវៈរបស់អារម្មណ៍ជាដើម ។

ការពិត អត្ថដ៏ក្រៃលែង ( ជាងប្រក្រតី ) របស់បទដែលជាពាក្យវេវចន នឹងគ្នា រមែងដឹងបានក្នុងវិសេសនសមាស ដូចពាក្យថា **បទដ្ឋាន** ( មូល, ហេតុជិត ) ។

[ ពាក្យថា **មន** និង **វិញ្ញាណ** ជាពាក្យវេវចននឹងគ្នា ដែលប្រែថា " ចិត្ត " កាលបើនាំមកភ្ជាប់ជាមួយសមាស ជា**កម្មធារយសមាស** ( វិសេសនសមាស ) ថា **មនោ ច តំ វិញ្ញាណញ្ចាតិ មនោវិញ្ញាណំ** ក៏ធ្វើឲ្យមានអត្ថក្រៃលែងជាងប្រក្រតី ដែលក្នុងទីនេះក៏គឺ " ដឹងពិសេសក្រៃលែង " ដូចពាក្យថា **បទ និងឋាន** ដែលជាពាក្យវេវចននឹងគ្នា ប្រែថា " **ហេតុ** " តែបើភ្ជាប់សមាសនឹងគ្នា ជារូបថា **បទដ្ឋាន** ក៏មានអត្ថថា " **ហេតុក្រៃលែង មូល ហេតុជិត** " **គម្ពីរអនុទីបនីសម្តែង ឧទាហរណ៍ដទៃៗ ទៀតថា:**

**ទុក្ខទុក្ខ** = ទុក្ខដ៏ក្រៃលែង

**រូបរូប** = រូបប្រែប្រួលក្រៃលែង, រូបប្រែប្រួលយ៉ាងច្បាស់

**រាជរាជ** = ព្រះរាជាធំក្រៃលែង, ស្តេចចក្រពត្តិ ,
ព្រះរាជាក្រៃលែងជាងព្រះរាជា

ទេវទេវ = ទេពក្រៃលែងជាងទេព, អតិទេព ] ។

**[៧០]** គប្បីប្រកបបទថា ចិត្ត ៣០ ដួង ដែលនៅសល់ ហៅថា **មនោ-វិញ្ញាណធាតុ** ដោយប្រភេទនៃសន្តីរណចិត្ត (៣) មហាវិបាកចិត្ត (៨) បដិឃ-ចិត្ត (២) បឋមមគ្គចិត្ត (១) ហសនចិត្ត (១) និងរូបាវចរចិត្ត (១៥) រមែងប្រព្រឹត្តទៅដោយអាស្រ័យហទយវត្ថុប៉ុណ្ណោះ ។

**ច** ស័ព្ទ [ ក្នុងពាក្យថា **មនោវិញ្ញាណធាតុសង្ខាតា ច** ] រមែងលើកឡើងសម្តែងថា ចិត្ត ៧៦ ដួង ដែលនៅសល់ ជា**មនោវិញ្ញាណធាតុ** ក្នុងទីនេះ ។

-សួរថា: ហេតុដូចម្តេច បានជាចិត្តទាំងនោះប្រព្រឹត្តទៅដោយអាស្រ័យហទយវត្ថុតែម្យ៉ាង ?

-ឆ្លើយថា: ព្រោះមិនកើតក្នុងអរូបភូមិ ។

-សួរថា: ហេតុដូចម្តេច បានជាមិនកើតក្នុងអរូបភូមិ ?

-ឆ្លើយថា: លំដាប់ដំបូង សន្តីរណចិត្ត និងមហាវិបាកចិត្ត រមែង មិនកើតក្នុងអរូបភូមិ ព្រោះមិនមានទ្វារ ៥ និងកិច្ចរបស់ខ្លួនក្នុងអរូបភូមិ សូម្បី បដិឃចិត្ត ២ ដួង ក៏មិនកើត ព្រោះមិនមានបដិឃដែលមិនមែនរយ:កាលនៃ នីវរណ: និងនីវរណ:ក៏មិនកើតក្នុងឈានភូមិ។

សូម្បីហសនចិត្ត រមែងមិនកើត [ ក្នុងអរូបភូមិ ] ព្រោះអរូបព្រហ្ម មិនមាន កិច្ចក្នុងការញញឹម ឬហេតុផលថា “ ព្រោះមិនមានកាយ ” រមែងសមគួរ ។

សូម្បីសោតាបត្តិមគ្គចិត្ត រមែងមិនកើត [ ក្នុងអរូបភូមិ ] ព្រោះបុថុជ្ជន អ្នកកើតក្នុងអរូបភូមិ មិនអាចដឹងច្បាស់នូវសច្ចធម៌បាន ដោយសារមិនមាន ការណែនាំពីអ្នកដទៃ ទាំងព្រះសម្ពុទ្ធ និង ព្រះបច្ចេកពុទ្ធ ក៏មិនកើតក្នុងអរូប-ភូមិ ដូច្នោះ បុថុជ្ជនអ្នកកើតក្នុងអរូបភូមិ ទើបចាត់នៅក្នុងប្រភេទបុគ្គលអ្នក ប្រកបក្នុងខណ:មិនសមគួរ ( ដើម្បីការបដិបត្តិធម៌ក្នុងការសម្រេចព្រះនិព្វាន ) ៨ យ៉ាង ។

[ ខណ:ដែលមិនសមគួរ ( **អក្ខណ:** ) មាន ៨ យ៉ាងគឺ៖

១) ខណ:កើតក្នុងនរក

២) ជាសត្វតិរច្ឆាន

៣) ជាប្រេត

៤) កើតក្នុងអសញ្ញសត្តភូមិ ឬអរូបភូមិ

៥) កើតក្នុងបច្ចន្តជនបទ ដែលមិនមានព្រះពុទ្ធសាសនា

៦) ជឿកាន់យកនូវមិច្ឆាទិដ្ឋិ

៧) ជាអ្នកល្ងង់ខ្លៅ

៨) កើតក្នុងពេលដែលមិនមានព្រះពុទ្ធត្រាស់ដឹង ។

សូម្បីរូបាវចរចិត្ត រមែងមិនកើតក្នុងអរូបភូមិ ព្រោះរូបាវចរចិត្តដែលមានអារម្មណ៍គឺ រូបនិមិត្ត [ មានកសិណជាដើម ] ត្រូវកន្លងផុតហើយ ដោយការចម្រើនភាវនា ដើម្បីប្រាសចាកសេចក្ដីត្រេកអរក្នុងរូប ។

**[៧១]** គប្បីប្រកបពាក្យថា ចិត្តដែលនៅសល់ ៤២ ដួង ហៅថាមនោ-វិញ្ញាណធាតុ ដោយប្រភេទនៃកុសលចិត្ត ( ១២ វៀររូបាវចរកុសលចិត្ត៥ ) អកុសលចិត្ត ( ១០ វៀរបដិឃចិត្ត២ ) កិរិយាចិត្ត ( ១៣ វៀរបញ្ចទ្វារាវជ្ជនចិត្ត ១ ហសនចិត្ត ១ និងរូបាវចរកិរិយាចិត្ត៥ ) និងលោកុត្តរចិត្ត ( ៧ វៀរសោតាបត្តិ-មគ្គចិត្ត ១ ) រមែងប្រព្រឹត្តទៅដោយអាស្រ័យហទយវត្ថុក៏បាន មិនអាស្រ័យហទយវត្ថុក៏បាន បានសេចក្ដីថា គឺអាស្រ័យហទយវត្ថុក្នុងបញ្ចវោការភូមិ ( ភូមិដែលមានខន្ធ ៥ ) ឬមិនអាស្រ័យហទយវត្ថុ ក្នុងចតុវោការភូមិ ( ភូមិដែលមានខន្ធ ៤ ) ។

គប្បីធ្វើរូបវិគ្គហថា **កុសលាកុសលកិរិយានុត្តរ** គឺកុសលចិត្ត អកុសល-ចិត្ត កិរិយាចិត្ត និងលោកុត្តរចិត្ត ។

ក្នុងប្រយោគនោះ ពាក្យថា **កុសលានិ** ( កុសលចិត្តទាំងឡាយ ) គឺលោកិយកុសលចិត្ត ១២ ដួង ដែលនៅសល់ពីរូបាវចរកុសលចិត្ត ៥ ដួង ។

ពាក្យថា **អកុសលានិ** ( អកុសលចិត្តទាំងឡាយ ) គឺអកុសលចិត្ត ១០ ដួង ដែលនៅសល់ពីបដិឃចិត្ត ២ ដួង ។

ពាក្យថា **កិរិយានិ** ( កិរិយាចិត្តទាំងឡាយ ) គឺកិរិយាចិត្ត ១៣ ដួង ដែលនៅសល់ពីបញ្ចទ្វារាវជ្ជនចិត្ត ហសនចិត្ត និងរូបាវចរកិរិយាចិត្ត ៥ ដួង ។

ពាក្យថា **អនុត្តរានិ** ( លោកុត្តរចិត្តទាំងឡាយ ) គឺលោកុត្តរចិត្ត ៧ ដួង ដែលនៅសល់ពីបឋមមគ្គចិត្ត ។

# អធិប្បាយគាថាសរុប

**[៧៣]** គប្បីប្រកបពាក្យថា វិញ្ញាណធាតុក្នុងកាមភូមិ ៧ អាស្រ័យវត្ថុ ៦ , វិញ្ញាណធាតុ៤ ក្នុងរូបភូមិ អាស្រ័យវត្ថុ ៣ , ចំណែកវិញ្ញាណធាតុ ១ ក្នុងអរូបភូមិ មិនអាស្រ័យវត្ថុណាមួយឡើយ ។

**[៧៤]** ពាក្យថា **តេចត្តាលីស** ( ចិត្ត ៤៣ ដួង ) បានដល់ ចិត្ត ៣០ ដួង មានសន្តីរណចិត្តជាដើម ព្រមដោយបញ្ចវិញ្ញាណចិត្ត ១០ និងមនោធាតុ ៣ ។

**ឥតិ អភិធម្មត្ថសង្គហេ បកិណ្ណកសង្គហវិភាគោ នាម តតិយោ បរិច្ឆេទោ**

**ប្រែថា: ចប់បរិច្ឆេទទី ៣ ឈ្មោះថាបកិណ្ណកសង្គហវិភាគ**

**ក្នុងអភិធម្មសង្គហនេះ ។**

**កាយស្ស ភោ វីរចិត្តស្ស យថានុក្កូលំ**
**ឆាយា វិភាតិ រុចិរាមលទប្បណោ តុ**
**កត្វា តថេវ បរមំ កុសលំ បរមត្ថ**
**សម្ពសិតសា ឥវ ភវន្តិ ផលេន តេន។**

លោកដ៏ចម្រើន ស្រមោលរបស់រាងកាយ ដែលប្រដាប់តាក់តែងហើយ រមែងល្អស្អាតក្នុងកញ្ចក់ ស្រមោលដែលថ្លាស្អាតប្រាសចាកមន្ទិលយ៉ាងណាមិញ បុគ្គលកាលបើបំពេញបរមត្ថប្រយោជន៍ហើយ រមែងបានទទួលការប្រដាប់តាក់តែងក្នុងលោកខាងមុខដោយបុណ្យនោះ ក៏យ៉ាងនោះដែរ។

តំ ពលានំ ពលំ សេដ្ឋំ អគ្គំ បញ្ញាពលំ ពលំ
បញ្ញាពលេនុបត្ថម្ភោ អត្ថំ វិន្ទតិ បណ្ឌិតោ ។

« កម្លាំងបញ្ញានេះជាកម្លាំងប្រសើរ
ជាកម្លាំងខ្ពង់ខ្ពស់ជាងកម្លាំងទាំងឡាយ
បណ្ឌិតដែលមានកម្លាំងបញ្ញាជ្រោមជ្រែងហើយ
រមែងបាននូវសេចក្តីចម្រើន » ។

( បិដកលេខ ៦០,ទំព័រ ២២៨ )